# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

# លទ្ធផល

# អង្កេតកម្លាំងពលកម្ម កម្ពុជាឆ្នាំ២០២៥


វិទ្យាស្ថានជាតិស្ថិតិ

ក្រសួងផែនការ

# លទ្ធផល

# អង្កេតកម្លាំងពលកម្ម កម្ពុជាឆ្នាំ២០២៥


**វិទ្យាស្ថានជាតិស្ថិតិ**
**ក្រសួងផែនការ**

រាជធានីភ្នំពេញ សីហា ឆ្នាំ២០២៥

# ព័ត៌មានបន្ថែម

អ៊ីនធឺណិត

http://www.nis.gov.kh គឺជាគេហទំព័ររបស់វិទ្យាស្ថានជាតិស្ថិតិ សម្រាប់ស្ថិតិផ្លូវការ ដែល ផលិតដោយវិទ្យាស្ថានជាតិស្ថិតិ និងក្រសួង ស្ថាប័ន/អង្គភាពផ្សេងៗទៀតនៅក្នុង រាជរដ្ឋាភិបាលកម្ពុជា។ គេហទំព័រនេះ គឺជាកន្លែងចាប់ផ្តើមដ៏ល្អបំផុតសម្រាប់ការទទួល បាន នូវទិន្នន័យបឋមពីការបោះពុម្ពថ្មីៗបំផុត និងព័ត៌មានអំពីវិទ្យាស្ថានជាតិស្ថិតិនិងស្ថាប័ន/ អង្គភាពស្ថិតិផ្សេងៗទៀតរបស់រាជរដ្ឋាភិបាល។

បណ្ណាល័យពិគ្រោះ

ឯកសារពិគ្រោះផ្សេងៗជាច្រើនអាចរកបាននៅមជ្ឈមណ្ឌល សេវាព័ត៌មានស្ថិតិនៃវិទ្យាស្ថាន ជាតិស្ថិតិសម្រាប់អ្នកប្រើប្រាស់ ទិន្នន័យ។

សេវាផ្តល់ព័ត៌មាន

បុគ្គលិករបស់វិទ្យាស្ថានជាតិស្ថិតិបម្រើការនៅមជ្ឈមណ្ឌលសេវា ព័ត៌មានស្ថិតិ អាចជួយដល់អ្នក ប្រើប្រាស់ទិន្នន័យទាំងឡាយ ក្នុងការដោះស្រាយនូវតម្រូវការទិន្នន័យ។ វិទ្យាស្ថានជាតិ ស្ថិតិ មានឯកសារបោះពុម្ពផ្សាយសម្រាប់លក់ ហើយសេវាកម្មជាវអាច ត្រូវបានរៀបចំជូន។ ចំពោះសេវាទិន្នន័យពិសេសក៏អាចរកបាន ផងដែរ ប៉ុន្តែអ្នកប្រើប្រាស់ទិន្នន័យត្រូវបង់ ប្រាក់។

ព័ត៌មានសម្រាប់ទាក់ទង

មជ្ឈមណ្ឌលសេវាព័ត៌មានស្ថិតិ វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ
អគារលេខ៣៨៦ ផ្លូវលេខ៣៦០ សង្កាត់បឹងកេងកង១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ទូរស័ព្ទ (៨៥៥) ២៣ ៧២៦ ៩៣៤
(៨៥៥) ២៣ ៧២៦ ៦២៤

# បុព្វកថា

របាយការណ៍លទ្ធផល**អង្កេតកម្លាំងពលកម្មកម្ពុជាឆ្នាំ២០២៥**បានផ្តល់ទិន្នន័យស្ថិតិសំខាន់ៗ រួមមាន៖ ចរិតលក្ខណៈប្រជាសាស្ត្រ មនុស្សស្ថិតក្នុងអាយុការងារ អត្រាចូលរួមក្នុងកម្លាំងពលកម្ម ទីផ្សារពលកម្ម អត្រាមានការងារ អត្រាអត់ការងារធ្វើ ស្ថានភាពការងារ អ្នកធ្វើការតាមវិស័យ ការងារក្នុងប្រព័ន្ធ ការងារក្រៅប្រព័ន្ធ ចំនួនម៉ោងធ្វើការ ប្រាក់កម្រៃពីការងារ និងចំណាយជ្រើសរើសរបស់ពលករចំណាកស្រុកនិវត្តន៍ និងសូចនាករសំខាន់ៗមួយចំនួននៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងការងារសមរម្យ។ របាយការណ៍លទ្ធផលអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥ បានមកពីការប្រមូលទិន្នន័យអង្កេតគ្រួសារមានវិសាលភាពគ្របដណ្តប់ទូទាំង ព្រះរាជាណាចក្រកម្ពុជា ដែលបានអនុវត្តចាប់ពីថ្ងៃទី២៥ ខែតុលា ដល់ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៥ ដោយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ។

អង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥ ត្រូវបានប្រមូលទិន្នន័យនៅក្នុងបរិបទដែលប្រទេសកម្ពុជា បាននិងកំពុងជួបប្រទះបញ្ហាជម្លោះព្រំដែន កម្ពុជា-ថៃ ដែលបានកើតឡើងក្នុងឆ្នាំ២០២៥ ហើយជម្លោះ ព្រំដែននេះបានជះឥទ្ធិពលទៅលើលំហូរចំណាកស្រុក នៃពលករខ្មែរដែលបានវិលត្រឡប់ពីប្រទេសថៃមកកាន់ប្រទេសកម្ពុជាវិញ។ បញ្ហាជម្លោះព្រំដែន បានបង្កផលប៉ះពាល់ដោយផ្ទាល់ដល់ជីវភាពរស់នៅរបស់កម្មករចំណាកស្រុក និងក្រុមគ្រួសាររបស់ពួកគេ ទាំងក្នុងអំឡុងពេល និងក្រោយពេលនៃជម្លោះព្រំដែននេះ។

អង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥ មានគោលបំណងដើម្បីផ្តល់ទិន្នន័យស្ថិតិ និងសូចនាករគន្លឹះសម្រាប់គាំទ្រដល់ការធ្វើសេចក្តីសម្រេចចិត្តដោយផ្អែកលើភស្តុតាង ការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការយុទ្ធសាស្ត្រ និងគោលនយោបាយជាតិសំខាន់ៗ រួមមាន៖ យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលដៅអភិវឌ្ឍប្រកបដោយចីរភាព ឆ្នាំ២០១៦-២០៣០ គោលនយោបាយជាតិស្តីពីមុខរបរនិងការងារ និងគោលនយោបាយ អភិវឌ្ឍន៍វិស័យឧស្សាហកម្ម។ លើសពីនេះ ទិន្នន័យទាំងនេះ ក៏ជាប្រភពព័ត៌មានដ៏សំខាន់សម្រាប់អ្នករៀបចំ គោលនយោបាយ ក្រុមអ្នកស្រាវជ្រាវ ដៃគូអភិវឌ្ឍ និងសាធារណជន ក្នុងការឈ្វេងយល់អំពីកម្លាំងពលកម្ម ស្ថានភាពការងារ អត្រាគ្មានការងារធ្វើ ម៉ោងធ្វើការ និងលក្ខណៈសង្គម-សេដ្ឋកិច្ចផ្សេងៗទៀតរបស់ប្រជាជនកម្ពុជា។ លទ្ធផលនៃការអង្កេតនេះ ដើរតួនាទីយ៉ាងសំខាន់ក្នុងការវិភាគស្ថានភាព

ទីផ្សារការងារ សូចនាករ ការងារសមរម្យ និងការជំរុញកំណើនសេដ្ឋកិច្ច។

ជាទីបញ្ចប់ ខ្ញុំសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ ប្រមុខរាជរដ្ឋាភិបាលកម្ពុជា និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលបានផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់ការអនុវត្តការងារអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥។ ខ្ញុំក៏សូមថ្លែងអំណរគុណដល់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អង្គការអន្តរជាតិខាងការងារ កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ ធនាគារពិភពលោក និងក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានជាតិស្ថិតិ ថ្នាក់ដឹកនាំនៃវិទ្យាស្ថានជាតិស្ថិតិ គណៈកម្មការបច្ចេកទេសអន្តរក្រសួង ក្រុមការងារបច្ចេកទេស មន្ត្រីអង្កេតទាំងអស់ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ព្រមទាំងប្រជាពលរដ្ឋក្នុងការផ្តល់បទសម្ភាសន៍ សម្រាប់ការគាំទ្រ និងការចូលរួមយ៉ាងសកម្មក្នុងដំណើរការអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥ នេះ ឈានសម្រេចបានជោគជ័យ។

**រដ្ឋមន្ត្រីក្រសួងផែនការ**

**ប៊ិន ត្រាឈៃ**

**ក្រសួងផែនការ**
**រាជធានីភ្នំពេញ**
**ខែសីហា ឆ្នាំ២០២៦**

# អារម្ភកថា

វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ សូមបង្ហាញជូននូវរបាយការណ៍លទ្ធផលអង្កេតកម្លាំងពលកម្មកម្ពុជាឆ្នាំ២០២៥ ដែលបានពីការប្រមូលទិន្នន័យចាប់ពីថ្ងៃទី២៥ ខែតុលា ដល់ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៥ គ្របដណ្តប់មានសំណាកគំរូប្រមាណ ៩៩១២ គ្រួសារ ស្ថិតនៅ ២៥រាជធានី ខេត្ត ទូទាំងប្រទេសកម្ពុជា។ អង្កេតកម្លាំងពលកម្មកម្ពុជាគឺជាសកម្មភាពស្ថិតិផ្លូវការដ៏សំខាន់ ដែលបានធ្វើឡើងដោយវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ។ អង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥ គឺជាអង្កេតលើកទី៥ បន្ទាប់ពីបានអនុវត្ត នៅក្នុងឆ្នាំ២០០០ ២០០១ ២០១២ និង២០១៩ ដែលបានសហប្រតិបត្តិការបច្ចេកទេសជាមួយភាគីពាក់ព័ន្ធ សំខាន់ៗ ដូចជា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អង្គការអន្តរជាតិខាងការងារ អង្គការកម្មវិធី អភិវឌ្ឍន៍សហប្រជាជាតិ និងធនាគារពិភពលោក។

លទ្ធផលនៃការអង្កេតនេះ បានផ្តល់នូវព័ត៌មានដ៏សំខាន់ស្តីពីស្ថានភាពនិងលក្ខណៈនៃកម្លាំងពលកម្មនៅព្រះរាជាណាចក្រកម្ពុជា ដោយផ្តោតលើសូចនាករសំខាន់ៗអំពីទីផ្សារការងាររួមមាន ភាពមាន ការងារធ្វើ និងគ្មានការងារធ្វើ អត្រាការចូលរួមក្នុងកម្លាំងពលកម្ម លក្ខខណ្ឌការងារ ព្រមទាំងសូចនាករពាក់ព័ន្ធផ្សេងៗទៀត ដែលមាននៅក្នុងរបាយការណ៍លទ្ធផលអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥។ របាយការណ៍លទ្ធផលនេះបង្ហាញនូវព័ត៌មានច្បាស់លាស់ អំពីស្ថានភាពកម្លាំងពលកម្ម និងទីផ្សារការងារ ជូនដល់ស្ថាប័នរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ អ្នកស្រាវជ្រាវ និងអ្នកប្រើប្រាស់ទិន្នន័យស្ថិតិផ្លូវការ។ លើសពីនេះ របាយការណ៍លទ្ធផលអង្កេតនេះក៏ផ្តល់នូវទិដ្ឋភាពទូទៅអំពីទំហំ និងចរិតលក្ខណៈនៃកម្លាំងពលកម្ម សម្រាប់ធ្វើជាភស្តុតាងមូលដ្ឋានគ្រឹះដ៏សំខាន់ក្នុងការរៀបចំគោលនយោបាយ ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម និងការតាមដានត្រួតពិនិត្យ និងវាយតម្លៃការវិវត្តនៃកម្លាំងពលកម្ម និងទីផ្សារការងារ សំដៅលើកកម្ពស់ឱកាសការងារ និងការកែលម្អលក្ខខណ្ឌការងារនៅកម្ពុជា ព្រមទាំងគោលនយោបាយទីផ្សារការងាររបស់រដ្ឋាភិបាល។

អង្កេតកម្លាំងពលកម្មកម្ពុជាឆ្នាំ២០២៥ ត្រូវបានអនុវត្តឡើង ដើម្បីប្រមូលព័ត៌មានសំខាន់ៗពាក់ព័ន្ធនឹងលក្ខណៈប្រជាសាស្ត្រ សកម្មភាពសេដ្ឋកិច្ច មុខរបរ វិស័យសេដ្ឋកិច្ច ម៉ោងធ្វើការ និងស្ថានភាពការងាររបស់ប្រជាពលរដ្ឋ។ នៅក្នុងដំណើរការការប្រមូលទិន្នន័យអង្កេតនេះត្រូវបានធ្វើទំនើបកម្មតាមរយៈការផ្លាស់ប្តូរពីវិធីសាស្ត្រប្រពៃណីប្រើប្រាស់ក្រដាសទៅជាវិធីសាស្ត្រប្រើប្រាស់បច្ចេកវិទ្យាតាមរយៈម៉ាស៊ីនថាប្លេតសម្រាប់ការសម្ភាស កត់ត្រា ប្រមូល ការបញ្ជូន និងការគ្រប់គ្រងទិន្នន័យអង្កេតប្រកបដោយប្រសិទ្ធភាព និងភាពទាន់ពេលវេលា។

ជាទីបញ្ចប់ ខ្ញុំសូមគោរពថ្លែងអំណរគុណចំពោះរាជរដ្ឋាភិបាលកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានគាំទ្រផ្នែកហិរញ្ញវត្ថុ និងសូមថ្លែងអំណរគុណជាពិសេសជូនចំពោះ**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងផែនការ ឯកឧត្តមប្រធាន សមាជិក សមាជិកានៃក្រុមប្រឹក្សាភិបាលស្ថិតិនៃវិទ្យាស្ថានជាតិស្ថិតិ** ដែលបានខិតខំប្រឹងប្រែងក្នុងការដឹកនាំ តម្រង់ទិស និងផ្តល់អនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់សម្រាប់ដំណើរការ និងការប្រព្រឹត្តទៅនៃអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥។ ខ្ញុំក៏សូមអរគុណចំពោះ

ឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំវិទ្យាស្ថានជាតិស្ថិតិ តំណាងក្រសួង ស្ថាប័ន ក្រុមការងារបច្ចេកទេសអន្តរក្រសួងនៃអង្កេតកម្លាំងពលកម្ម ក្រុមការងារស្នូលនៃវិទ្យាស្ថានជាតិស្ថិតិ អ្នកជំនាញការនៃអង្គការអន្តរជាតិខាងការងារ កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ និងធនាគារពិភពលោក ដែលបានសហការគាំទ្របច្ចេកទេស ទិន្នន័យអង្កេតនេះ និងមន្ត្រីអង្កេតទាំងអស់ ព្រមទាំងប្រជាពលរដ្ឋដែលបានចូលរួមសម្ភាសន៍ផ្តល់ចម្លើយនៃការអនុវត្តអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ ២០២៥ ដោយទទួលបានទិន្នន័យប្រកបដោយគុណភាព និងប្រសិទ្ធភាព ឈានឱ្យសម្រេចបានជោគជ័យជាស្ថាពរ៕

**នាយកវិទ្យាស្ថានជាតិស្ថិតិ**



**ណោ វ៉ាន់ឌី**

វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ
រាជធានីភ្នំពេញ
ខែសីហា ឆ្នាំ២០២៦

# មាតិកា


**បុព្វកថា** ...... i
**អារម្ភកថា** ...... iii
**មាតិកា** ...... ១
**អក្សរកាត់** ...... ១១
**សេចក្តីសង្ខេបរួម** ...... ១៣
**ផែនទីព្រះរាជាណាចក្រកម្ពុជា** ...... ២០

## ជំពូក ១ ...... ២១
## សេចក្តីផ្តើម ...... ២១
១.១ សាវតារ ...... ២១
១.២ គោលដៅនៃការអង្កេត ...... ២២
១.៣ ការសម្ងាត់ ...... ២៣
១.៤ ទស្សនាទាន និងនិយមន័យ ...... ២៣

## ជំពូក ២ ...... ៣០
## វិធីសាស្ត្រអង្កេត ...... ៣០
២.១. ទំហំ និងវិសាលភាព ...... ៣០
២.២. ការរៀបចំបញ្ជីសំណួរ ...... ៣០
២.៣. វិធីសាស្ត្រជ្រើសរើសសំណាកគំរូ ...... ៣១
២.៤. ក្របខ័ណ្ឌជ្រើសសំណាកគំរូ ...... ៣១
២.៥. សមាមាត្រទម្ងន់សំណាកគំរូ ...... ៣១
២.៦. វិធីសាស្ត្រប៉ាន់ស្មាន ...... ៣៣
២.៧ គុណភាពនៃការប៉ាន់ស្មានការអង្កេតកម្លាំងពលកម្មនៅកម្ពុជា ឆ្នាំ២០២៥ ...... ៣៤
២.៨ កំហុសសំណាកគំរូ ...... ៣៤
២.៩ កំហុសមិនមែនសំណាកគំរូ ...... ៣៥
២.១០. ការចុះសម្ភាសន៍សាកល្បងតារាងសំណួរ ...... ៣៥
២.១១. ការបណ្តុះបណ្តាល និងការប្រមូលទិន្នន័យ ...... ៣៧
២.១២ ការងារអង្កេតមូលដ្ឋាន ...... ៣៨
២.១៣ ការដាក់បញ្ចូលលេខកូដ ...... ៣៨
២.១៤ ការឆ្លើយតប ...... ៣៩

## ជំពូក ៣ ............ ៤០

## ចរិតលក្ខណៈប្រជាសាស្រ្ត ............ ៤០

៣.១. សេចក្តីផ្តើម ............ ៤០
៣.២. ទំហំប្រជាជន ............ ៤០
៣.៣. ទំហំគ្រួសារ ............ ៤២
៣.៤. មេគ្រួសារគ្រួសារ ............ ៤៣
៣.៥ ជនមានពិការភាព ............ ៤៣
៣.៦ ផលធៀបអ្នកនៅក្នុងបន្ទុក ............ ៤៤
៣.៧ ប្រភពសម្រាប់ចិញ្ចឹមជីវិតរបស់គ្រួសារ ............ ៤៥
៣.៨ ការចូលរួមរបស់គ្រួសារក្នុងវិស័យកសិកម្ម និងនេសាទ ............ ៤៦

## ជំពូក ៤ ............ ៤៧

៤.១. សេចក្តីផ្តើម ............ ៤៧
៤.២. ប្រជាជនក្នុងអាយុធ្វើការ ............ ៤៧
៤.៣. អត្រាចូលរួមក្នុងកម្លាំងពលកម្ម ............ ៤៨
៤.៤ ការចូលរួមក្នុងកម្លាំងពលកម្ម ............ ៤៩
៤.៥. ការងារផលិតកម្មសម្រាប់ចិញ្ចឹមជិវិត ............ ៥៣

## ជំពូក ៥ ............ ៥៦

## ភាពមានការងារធ្វើ ............ ៥៦

៥.១. សេចក្តីផ្តើម ............ ៥៦
៥.២. ប្រជាជនមានការងារធ្វើ ............ ៥៦
៥.៣ ភាពមានការងារធ្វើតាមមុខរបរ ............ ៥៧
៥.៤. ភាពមានការងារធ្វើតាមវិស័យឧស្សាហកម្ម ............ ៦០
៥.៥. ភាពមានការងារធ្វើតាមកម្រិតអប់រំ ............ ៦១
៥.៦. អត្រាអ្នកមានការងារធ្វើធៀបនឹងចំនួនប្រជាជនក្នុងវ័យធ្វើការ ............ ៦២
៥.៧ ស្ថានភាពអ្នកមានការងារធ្វើ ............ ៦៣

## ជំពូក ៦ ............ ៦៥

## ការងារក្នុងវិស័យក្រៅប្រព័ន្ធ និងក្នុងប្រព័ន្ធ ............ ៦៥

៦.១ សេចក្តីផ្តើម ............ ៦៥

៦.២ វិស័យក្រៅប្រព័ន្ធ និងក្នុងប្រព័ន្ធ ........ ៦៥
៦.៣ ការងារក្រៅប្រព័ន្ធ និងការងារក្នុងប្រព័ន្ធ ........ ៦៦

**ជំពូក ៧ ........ ៧២**

**ចំណូលពីការងារ ........ ៧២**

៧.១ សេចក្តីផ្តើម ........ ៧២
៧.២ មូលដ្ឋានទូទាត់ប្រាក់ឈ្នួល ........ ៧២
៧.៣ ប្រាក់ចំណូលប្រចាំខែជាមធ្យម ........ ៧៣

**ជំពូក ៨ ........ ៧៨**

**ម៉ោងធ្វើការ ........ ៧៨**

៨.១ សេចក្តីផ្តើម ........ ៧៨
៨.២ ម៉ោងធ្វើការ ........ ៧៨
៨.៣ ចំនួនម៉ោងធ្វើការជាមធ្យម តាមសកម្មភាពសេដ្ឋកិច្ច ........ ៨១
៨.៤ ចំនួនម៉ោងធ្វើការធម្មតាជាមធ្យម តាមវិស័យ ........ ៨២
៨.៥ ចំនួនម៉ោងធ្វើការធម្មតាជាមធ្យម តាមក្រុមអាយុ ........ ៨៤
៨.៦ ធ្វើការលើសម៉ោង ........ ៨៥
៨.៧ ភាពមានការងារធ្វើមិនគ្រាប់គ្រាន់ទាក់ទងនឹងពេលវេលា ........ ៨៦

**ជំពូក ៩ ........ ៨៨**

**ការងារយុវជន ........ ៨៨**

៩.១ សេចក្តីផ្តើម ........ ៨៨
៩.២ យុវជនចូលរួមក្នុងកម្លាំងពលកម្ម ........ ៨៨
៩.៣ យុវជនមានការងារធ្វើ និងគ្មានការងារ ........ ៨៩
៩.៤ យុវជនមិនធ្វើការងារ មិនសិក្សា ឬបណ្តុះបណ្តាល ........ ៩២

**ជំពូក ១០ ........ ៩៤**

**ភាពគ្មានការងារធ្វើ ........ ៩៤**

១០. ១ សេចក្តីផ្តើម ........ ៩៤
១០.២ ភាពគ្មានការងារធ្វើ ........ ៩៤
១០.៣ រយៈពេលគ្មានការងារធ្វើ ........ ៩៥
១០.៤ វិធីសាស្ត្រស្វែងរកការងារ ........ ៩៦

១០.៥ អត្រាគ្មានការងារធ្វើ ........ ៩៧
១០.៦ ការប្រើមិនគ្រប់គ្រាន់នូវកម្លាំងពលកម្ម ........ ៩៩

**ជំពូក ១១** ........ ១០៤
១១.១ សេចក្តីផ្តើម ........ ១០៤
១១.២ ស្ថានភាពចំណាកស្រុក ........ ១០៥
១១.៣ បទពិសោធន៍ការងារនៅបរទេសរបស់ប្រជាជនដែលកើតនៅកម្ពុជា ........ ១០៧
១១.៤ ពលករចំណាកស្រុកនិវត្តន៍ ........ ១០៨
១១,៥ បទពិសោធន៍ការងារក្រៅប្រទេស ........ ១១២
១១.៦ ចំណាយជ្រើសរើស ........ ១១៦
១១.៧ ចំណូល ........ ១១៧
១១.៨ សូចនាករចំណាយជ្រើសរើស ........ ១១៨
១១.៩ ចំនួនខែត្រូវសងចំណាយជ្រើសរើស ........ ១១៩

**ជំពូក ១២** ........ ១២០
១២.១ សេចក្តីផ្តើម ........ ១២០
១២.២ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងការងារសមរម្យ ........ ១២១

**ឧបសម្ព័ន្ធ** ........ ១២៧
**ឧបសម្ព័ន្ធ ១** ........ ១២៨
**ឧបសម្ព័ន្ធ ២** ........ ១៩៣

# តារាង និង រូបភាព


## ជំពូក ២ ........................................................................ ២៩

តារាង ២.១ ការបែងចែកសំណាកគំរូតាមតំបន់ទីប្រជុំជន និងជនបទ ក្នុងរាជធានីខេត្ត សម្រាប់ ..........៣៣

តារាង ២.២ រង្វាស់កំហុសប្រហាក់ប្រហែលនៃភាគរយ នៅកម្រិតទំនុកចិត្ត ៩៥% សម្រាប់ការស្ទង់មតិកម្លាំងពលកម្មនៅកម្ពុជា ឆ្នាំ២០២៥។ .......................................................... ៣៥

តារាង ៣.២ អត្រាឆ្លើយតបរបស់គ្រួសារគំរូ ........................................................ ៣៩

## ជំពូក ៣ ........................................................................ ៤០

តារាង ៣.១. ភាគរយប្រជាជន តាម ភេទ ក្រុមអាយុ និងតំបន់ភូមិសាស្ត្រ ................................ ៤១

តារាង ៣.២ ទំហំគ្រួសារ តាម តំបន់ និងភេទ ឆ្នាំ២០២៥ ................................................ ៤២

តារាង ៣.៣ ការបែងចែកគ្រួសារតាម ទំហំ និងតំបន់ ..................................................... ៤២

តារាង ៣.៤ ការបែងចែកគ្រួសារតាម ក្រុមអាយុ ភេទនៃមេគ្រួសារ និងតំបន់ ............................ ៤៣

តារាង ៣.៥  សមាមាត្រអ្នកនៅក្នុងបន្ទុកតាមតំបន់ ឆ្នាំ២០២៥ .............................................. ៤៥

តារាង ៣.៦ ប្រភពសម្រាប់ចិញ្ចឹមជីវិតរបស់គ្រួសារតាម តំបន់ ........................................... ៤៥

តារាង ៣.៧ ការចូលរួមរបស់គ្រួសារក្នុងការងារកសិកម្ម តាមសកម្មភាពចម្បង និងតំបន់ ................. ៤៦

## ជំពូក ៤ ........................................................................ ៤៧

តារាង ៤.១ ការបែងចែកប្រជាជនក្នុងអាយុធ្វើការ តាមក្រុមអាយុ ភេទ និងតំបន់ ឆ្នាំ ២០២៥............ ៤៧

រូបភាព ៤.២ ការបែងចែកប្រជាជនក្នុងអាយុធ្វើការតាមស្ថានភាពទីផ្សារការងារ និងក្រុមអាយុ ........... ៤៨

តារាង ៤.៣ ការបែងចែកប្រជាជនក្នុងអាយុធ្វើការតាមស្ថានភាពទីផ្សារការងារ កម្រិតសិក្សា និងភេទ... ៥០

តារាង ៤.៤ អត្រាចូលរួមក្នុងកម្លាំងពលកម្ម តាមក្រុមអាយុ ភេទ និងតំបន់ ឆ្នាំ២០២៥ .................... ៥១

តារាង ៤.៥ ប្រជាជនដែលស្ថិតនៅក្រៅកម្លាំងពលកម្មមានអាយុ ១៥ ឆ្នាំឡើងទៅ តាមកម្រិតអប់រំ ភេទ និងតំបន់ ឆ្នាំ ២០២៥ ............................................................................ ៥២

តារាង ៤.៦ ការចូលរួមក្នុងផលិតកម្មសម្រាប់ការប្រើប្រាស់ដោយខ្លួនឯង តាមក្រុមអាយុ ស្ថានភាពក្នុងទីផ្សារការងារ ភេទ និងតំបន់................................................................... ៥៥

## ជំពូក ៥ ........................................................................ ៥៦

តារាង ៥.១ ការបែងចែកភាគរយប្រជាជនមានការងារធ្វើ តាមក្រុមអាយុ តំបន់ និងភេទ ឆ្នាំ ២០២៥ ... ៥៦

តារាង ៥.២ ប្រជាជនមានការងារធ្វើ តាមកម្រិតសិក្សា និងប្រភេទមុខរបរ ................................ ៥៩

តារាង ៥.៣ ប្រជាជនមានការងារធ្វើ តាមវិស័យសេដ្ឋកិច្ចនិងភេទ............................................ ៦០

តារាង ៥.៤ ប្រជាជនមានការងារធ្វើ តាមកម្រិតសិក្សា តំបន់ និងភេទ ..................................... ៦២

តារាង ៥.៥ ប្រជាជនមានការងារធ្វើ តាមស្ថានភាពអ្នកមានការងារធ្វើ........................................៦៣

## ជំពូក ៦ ........................................................................ ៦៥

តារាង ៦.១ ប្រជាជនមានការងារធ្វើ នៅក្នុងវិស័យក្រៅប្រព័ន្ធ និងក្នុងប្រព័ន្ធតាមវិស័យសេដ្ឋកិច្ច ......... ៦៦

តារាង ៦.២ ប្រជាជនមានការងារធ្វើ តាមការងារក្រៅប្រព័ន្ធ និងការងារក្នុងប្រព័ន្ធ និងក្រុមអាយុ ......... ៦៧

រូបភាព ៦.១ អ្នកមានការងារក្រៅប្រព័ន្ធ តាមក្រុមអាយុ ........................................ ៦៧

រូបភាព ៦.២ អ្នកមានការងារក្រៅប្រព័ន្ធ និងអ្នកមានការងារក្នុងប្រព័ន្ធ តាមតំបន់ .................. ៦៨

តារាង ៦.៣ អ្នកមានការងារក្រៅប្រព័ន្ធ និងអ្នកមានការងារក្នុងប្រព័ន្ធ តាមមុខរបរ .................. ៦៨

តារាង ៦.៤ អ្នកមានការងារក្រៅប្រព័ន្ធ និងអ្នកមានការងារក្នុងប្រព័ន្ធ តាមវិស័យឧស្សាហកម្ម............ ៦៩

តារាង ៦.៥ អ្នកធ្វើការងារក្រៅប្រព័ន្ធ និងក្នុងប្រព័ន្ធ តាមវិស័យ.................................. ៧០

តារាង ៦.៦ ប្រជាជនមានការងារធ្វើអាយុ ១៥ ឆ្នាំ ឡើង តាមកម្រិតការអប់រំ និងការងារក្នុងប្រព័ន្ធ/ការងារក្រៅប្រព័ន្ធ ........................................................................ ៧១

## ជំពូក ៧........................................................................ ៧២

តារាង ៧.១ និយោជិត តាមមូលដ្ឋានទូទាត់ប្រាក់ឈ្នួល........................................ ៧៣

តារាង ៧.២ ប្រាក់ឈ្នួលប្រចាំខែជាមធ្យម និងជាមេដ្យាន តាមមុខរបរ និងភេទ.......................... ៧៥

តារាង ៧.៣ ប្រាក់ឈ្នួលប្រចាំខែជាមធ្យម និងជាមេដ្យាន តាមសកម្មភាពសេដ្ឋកិច្ច និងភេទ.............. ៧៥

តារាង ៧.៤ ប្រាក់ឈ្នួលប្រចាំខែជាមធ្យម និងជាមេដ្យាន តាមក្រុមអាយុ និងភេទ ........................ ៧៧

តារាង ៧.៥ ប្រាក់ឈ្នួលប្រចាំខែជាមធ្យម និងជាមេដ្យាន តាមតំបន់ និងភេទ ............................ ៧៧

## ជំពូក ៨ ........................................................................ ៧៨

តារាង ៨.១ ម៉ោងធ្វើការជាមធ្យមក្នុងមួយសប្តាហ៍ ក្នុងការងារចម្បង តាមសកម្មភាពសេដ្ឋកិច្ច និងភេទ........ ៨១

តារាង ៨.២ អ្នកធ្វើការលើសម៉ោងធ្វើការធម្មតាក្នុងមួយសប្តាហ៍ ក្នុងការងារចម្បង តាមក្រុមអាយុ និងភេទ ........................................................................ ៨៦

តារាង ៨.៣ ភាពមានការងារធ្វើមិនគ្រប់គ្រាន់ទាក់ទងនឹងពេលវេលា តាមក្រុមអាយុ និងភេទ ............ ៨៧

តារាង ៨.៤ អត្រាការមានការងារធ្វើមិនគ្រប់ម៉ោងតាមក្រុមអាយុ និងភេទ .............................. ៨៧

## ជំពូក ៩ ........................................................................ ៨៨

តារាង ៩.១ យុវជននៅក្នុងកម្លាំងពលកម្ម តាមតំបន់ និងភេទ.......................................... ៨៨

តារាង ៩.២ យុវជនមានការងារធ្វើ និងគ្មានការងារ តាមតំបន់ និងភេទ.................................. ៨៩

តារាង ៩.៣ យុវជនមានការងារធ្វើ តាមមុខរបរ និងភេទ................................................ ៩០

តារាង ៩.៤ យុវជនមានការងារធ្វើ តាមសេដ្ឋកិច្ច និងភេទ............................................... ៩០

តារាង ៩.៥ យុវជនមានការងារធ្វើ តាមកម្រិតអប់រំ និងភេទ ............................................ ៩១

តារាង ៩.៦ យុវជនគ្មានការងារធ្វើ តាមកម្រិតអប់រំ និងភេទ ............................................ ៩២

តារាង ៩.៧ យុវជនមិនធ្វើការងារ មិនសិក្សា ឬបណ្តុះបណ្តា តាមក្រុមអាយុ តំបន់ និងភេទ ............... ៩៣

## ជំពូក ១០ ........................................................................ ៩៤

តារាង ១០.១ អ្នកគ្មានការងារធ្វើ តាមក្រុមអាយុ និងភេទ.................................................... ៩៤
តារាង ១០.២ ប្រជាជនគ្មានការងារធ្វើ តាមកម្រិតសិក្សា តំបន់ និងភេទ ......................................... ៩៥
តារាង ១០.៣ រយៈពេលគ្មានការងារធ្វើ តាមភេទ.......................................................... ៩៦
តារាង ១០.៤ អត្រាគ្មានការងារធ្វើ តាមកម្រិតអប់រំ តំបន់ និងភេទ............................................ ៩៧
តារាង ១០.៥ អត្រាគ្មានការងារធ្វើ តាមក្រុមអាយុ តំបន់ និងភេទ ............................................ ៩៨
តារាង ១០.៦ សូចនាករទីផ្សារការងារ.............................................................. ១០២
តារាង ១០.៧ ការបែងចែកប្រជាជនក្នុងអាយុធ្វើការដែលស្ថិតនៅក្រៅកម្លាំងពលកម្មបន្ថែម តាមសកម្មភាពចម្បងបច្ចុប្បន្ន .................................................................................. ១០៣

## ជំពូក ១១ ........................................................................ ១០៤

តារាង ១១.១ ការបែងចែកប្រជាជនតាមប្រទេសកំណើត និងភេទ.............................................. ១០៥
តារាង ១១.២ ការបែងចែកប្រជាជនតាមរយៈពេលរស់ក្នុងប្រទេសកម្ពុជា ....................................... ១០៦
តារាង ១១.៣ ការបែងចែកប្រជាជន តាមមូលហេតុចម្បងនៃការវិលត្រលប់មកកម្ពុជា......................... ១០៦
តារាង ១១.៤ ការបែងចែកប្រជាជន តាមសញ្ជាតិ និងភេទ ............................................... ១០៧
តារាង ១១.៥ ការបែងចែកប្រជាជនដែលបានផ្លាស់ទៅរស់នៅ ឬធ្វើការនៅបរទេសដើម្បីទទួលបានប្រាក់ឈ្នួល តាមក្រុមអាយុ និងភេទ .................................................................. ១០៨
តារាង ១១.៦ ការបែងចែកប្រជាជនក្នុងអាយុធ្វើការដែលបានទៅរស់នៅ និងធ្វើការនៅបរទេសដើម្បីទទួលបានប្រាក់ឈ្នួល តាមក្រុមអាយុ និងភេទ............................................................ ១០៩
តារាង ១១.៧ ការបែងចែកប្រជាជនក្នុងអាយុយធ្វើការដែលបានទៅធ្វើការនៅបរទេស តាមប្រទេសចុងក្រោយដើម្បីធ្វើការ និងភេទ .......................................................................... ១១០
តារាង ១១.៨ ការបែងចែកប្រជាជនក្នុងអាយុយធ្វើការតាមមូលហេតុចម្បងនៃការវិលត្រលប់មកវិញ និងភេទ.................................................................................................. ១១១
តារាង ១១.៩ ការបែងចែកប្រជាជន តាមមូលហេតុចម្បងនៃពលករចំណាកស្រុកនិវត្តន៍ និងភេទ...... ១១១
តារាង ១១.១០ ការបែងចែកប្រជាជនតាមរយៈពេលចាប់ផ្ដើមការងារនៅក្រៅប្រទេស..................... ១១២
តារាង ១១.១១ ប្រភេទការងារដំបូងនៅក្រៅប្រទេស តាមមុខរបរ និងភេទ.................................. ១១៣
តារាង ១១.១២ ប្រភេទការងារដំបូងនៅក្រៅប្រទេស តាមវិស័យសេដ្ឋកិច្ច និងភេទ......................... ១១៤
តារាង ១១.១៣ ប្រភពព័ត៌មានអំពីការងារដំបូងនៅក្រៅប្រទេសសម្រាប់ពលករចំណាកស្រុកនិវត្តន៍ តាមភេទ.................................................................................................. ១១៤
តារាង ១១.១៤ វិធីជ្រើសរើសពលករចំណាកស្រុកនិវត្តន៍បានប្រើប្រាស់ ដើម្បីទទួលបានការងារដំបូងនៅក្រៅប្រទេស តាមភេទ.................................................................................. ១១៥
តារាង ១១.១៥ វិធីប្រើដោយពលករចំណាកស្រុកនិវត្តន៍ចូលទៅប្រទេសក្រៅចុងក្រោយដើម្បីធ្វើការ តាមភេទ.................................................................................................. ១១៦
តារាង ១១.១៦ ចំណាយទទួលបានការងារដំបូងនៅបរទេសរបស់ពលករចំណាកស្រុកនិវត្តន៍ តាមភេទ .................................................................................................. ១១៧

តារាង ១១.១៧ ចំណូលប្រចាំខែរបស់ពលករចំណាកស្រុកនិវត្តន៍ពីការងារដំបូងនៅបរទេស តាមភេទ ........ ១១៧
តារាង ១១.១៨ សូចនាករចំណាយជ្រើសរើស តាមភេទ តំបន់ ក្រុមអាយុ វិស័យសេដ្ឋកិច្ច និងប្រទេសចុងក្រោយរបស់ការងារ ........ ១១៨
តារាង ១១.១៩ ចំនួនខែរបស់ពលករចំណាកស្រុកនិវត្តន៍ត្រូវទូទាត់សងចំណាយជ្រើសរើស តាមភេទ ១១៩
**ជំពូក ១២ ........ ១២០**
តារាង ១២.១ សូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងការងារសមរម្យជ្រើសរើសនៅកម្ពុជា ឆ្នាំ ២០២៥ ........ ១២២
តារាង ១២.២ ចំណូលប្រចាំខែជាមេដ្យានរបស់និយោជិតស្រី និងប្រុស តាមមុខរបរ ........ ១២៤
តារាង ១២.៣ ភាគរយនៃយុវជនមិនធ្វើការងារ មិនសិក្សា ឬបណ្តុះបណ្តាល ........ ១២៤
តារាង ១២.៤ យុវជនមិនធ្វើការងារ មិនសិក្សា ឬបណ្តុះបណ្តាល តាមក្រុមអាយុ តំបន់ និងភេទ ........ ១២៥

# រូបភាព


## ជំពូក ៣ .................................................................................. ៤០

រូបភាព ៣.១៖ ពីរ៉ាមីតប្រជាជនតាមភេទ និងក្រុមអាយុ ឆ្នាំ២០២៥ ............................................ ៤១

រូបភាព ៣.២ សមាមាត្រប្រជាជន(អាយុ ៥ឆ្នាំឡើង) ជាជនមានពិការភាពតាម ភេទ និងតំបន់ ............ ៤៤

## ជំពូក ៤ .................................................................................. ៤៧

រូប ៤.១ ការបែងចែកប្រជាជនក្នុងអាយុធ្វើការតាម ក្រុមអាយុ ភេទ និងតំបន់................................. ៤៨

រូបភាព ៤.២ ការបែងចែកប្រជាជនក្នុងអាយុធ្វើការតាមស្ថានភាពទីផ្សារការងារ និងក្រុមអាយុ ............ ៤៩

រូបភាព ៤.៣ អត្រាចូលរួមក្នុងកម្លាំងពលកម្ម តាមក្រុមអាយុ និងភេទ ............................................៥៣

## ជំពូក ៥ .................................................................................. ៥៦

រូបភាព ៥.១ ការបែងចែកប្រជាជនមានការងារធ្វើ តាមប្រភេទមុខរបរ ...........................................៥៧

រូបភាព ៥.2 ការបែងចែកប្រជាជនមានការងារធ្វើ តាមប្រភេទមុខរបរ និងភេទ ................................ ៥៨

រូបភាព ៥.៣ អត្រាការងារធ្វើធៀបនឹងប្រជាជនតាមក្រុមអាយុ និងភេទ .........................................៦៣

## ជំពូក ៦ .................................................................................. ៦៥

រូបភាព ៦.១ អ្នកមានការងារក្រៅប្រព័ន្ធ តាមក្រុមអាយុ .............................................................៦៧

រូបភាព ៦.២ អ្នកមានការងារក្រៅប្រព័ន្ធ និងអ្នកមានការងារក្នុងប្រព័ន្ធ តាមតំបន់ ............................ ៦៨

## ជំពូក ៧ .................................................................................. ៧២

រូបភាព ៧.១ ការបែងចែកប្រាក់ឈ្នួលប្រចាំខែ តាមភេទ........................................................... ៧៣

រូបភាព ៧.២ ចំណែកប្រាក់ឈ្នួលប្រចាំខែ តាមភេទ.................................................................. ៧៤

## ជំពូក ៨ .................................................................................. ៧៨

រូបភាព ៨.១ ម៉ោងធ្វើការជាមធ្យមក្នុងមួយសប្តាហ៍ ក្នុងការងារចម្បង តាមតំបន់ និងភេទ ..................៧៩

រូបភាព ៨.២ ម៉ោងធ្វើការធម្មតាជាមធ្យមក្នុងមួយសប្តាហ៍ ក្នុងការងារចម្បង តាមមុខរបរ និងភេទ ........ ៨០

រូបភាព ៨.៣ ម៉ោងធ្វើការជាកស្តែងជាមធ្យមក្នុងមួយសប្តាហ៍ ក្នុងការងារចម្បង តាមមុខរបរ និងភេទ... ៨០

រូបភាព ៨.៤ ម៉ោងធ្វើការធម្មតាជាមធ្យមក្នុងមួយសប្តាហ៍ ក្នុងការងារចម្បង តាមវិស័យសកម្មភាពសេដ្ឋកិច្ច និងភេទ...................................................................................................... ៨០

រូបភាព ៨.៥ ម៉ោងធ្វើការជាក់ស្តែងជាមធ្យមក្នុងមួយសប្តាហ៍ ក្នុងការងារចម្បង តាមវិស័យសកម្មភាពសេដ្ឋកិច្ច និងភេទ......................................................................................................៨៣

រូបភាព ៨.៦ ម៉ោងធ្វើការធម្មតាជាមធ្យមក្នុងមួយសប្តាហ៍ ក្នុងការងារចម្បង តាមក្រុមអាយុ និងភេទ..... ៨៤

រូបភាព ៨.៧ ម៉ោងធ្វើការជាក់ស្តែងជាមធ្យមក្នុងមួយសប្តាហ៍ ក្នុងការងារចម្បង តាមក្រុមអាយុ និងភេទ ៨៥

**ជំពូក ១០ ........................................................................ ៩៤**

រូបភាព ១០.១ វិធីសាស្ត្រស្វែងរកការងារ ........................................................................៩៧

រូបភាព ១០.២ សមាសធាតុនៃការប្រើមិនគ្រប់គ្រាន់នូវកម្លាំងពលកម្ម ........................................១០០

# អក្សរកាត់

| | |
|---|---|
| CAPI | ការសម្ភាសផ្ទាល់ដោយប្រើកុំព្យូទ័រជាជំនួយ |
| CLFS | ការអង្កេតកម្លាំងពលកម្មកម្ពុជា |
| GPC | ជំរឿនប្រជាជនទូទៅកម្ពុជា |
| ILO | អង្គការអន្តរជាតិខាងការងារ |
| KIR | របាយការណ៍សូចនាករសំខាន់ៗ |
| LFPR | អត្រាចូលរួមក្នុងកម្លាំងពលកម្ម |
| MLVT | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| NEET | មិនមានការងារ មិនបានសិក្សា និងមិនបានបណ្តុះបណ្តាល |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NIS | វិទ្យាស្ថានជាតិស្ថិតិ |
| PSU | ឯកតាគំរូដំបូង |
| RCI | សូចនាករចំណាយក្នុងការជ្រើសរើសបុគ្គលិក |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| SD | គម្លាតស្តង់ដារ |
| SDG | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
| SDM | វិធីសាស្ត្រថ្ងៃតាមស្តង់ដារ |
| SNA | ប្រព័ន្ធគណនេយ្យជាតិ |
| UNDP | កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ |
| WB | ធនាគារពិភពលោក |

# សេចក្តីសង្ខេបរួម

អង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥ គឺជាការអង្កេតលើកទី៥ បន្ទាប់ពីអង្កេតដែលបានអនុវត្តក្នុងឆ្នាំ២០០០ ឆ្នាំ២០០១ ឆ្នាំ២០១២ និងឆ្នាំ២០១៩។ អង្កេតនេះត្រូវបានអនុវត្តដោយ វិទ្យាស្ថានជាតិស្ថិតិ សហការជាមួយ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងដោយមានការគាំទ្រពី អង្គការអន្តរជាតិខាងការងារ (ILO) កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ(UNDP) និងធនាគារពិភពលោក(WB) ។ ការប្រមូលទិន្នន័យនៅមូលដ្ឋានបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី ២៥ ខែតុលា ដល់ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៥។ អង្កេតកម្លាំងពលកម្មទទួលបានការគាំទ្រទាំងផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសពីរាជរដ្ឋាភិបាលកម្ពុជា អង្គការអន្តរជាតិខាងការងារ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ និងធនាគារពិភពលោក។ ក្នុងចំណោមអង្គការដៃគូទាំងនេះ អង្គការអន្តរជាតិខាងការងារ គឺជាអង្គការអន្តរជាតិតែមួយគត់ដែលផ្តល់ជំនួយបច្ចេកទេសលើអង្កេតកម្លាំងពលកម្ម នៅទូទាំងពិភពលោក ដោយគាំទ្រប្រទេសនានាក្នុងការប្រមូល វិភាគ និងផ្សព្វផ្សាយទិន្នន័យ សម្រាប់តាមដាន និងវាយតម្លៃស្ថានភាពប្រជាជនកម្លាំងពលកម្ម ការងារ ភាពគ្មានការងារធ្វើ និងការងារសមរម្យ ។

អង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥ គឺជាអង្កេតតាមគ្រួសារ ដែលអនុវត្តដោយ វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ ដោយមានការគាំទ្រផ្នែកបច្ចេកទេសពី អង្គការអន្តរជាតិខាងការងារ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ និងធនាគារពិភពលោក។ អង្កេតនេះមានគោលបំណងធ្វើបច្ចុប្បន្នភាពទិន្នន័យស្តីពីកម្លាំងពលកម្ម ការងារ និងស្ថានភាពការងាររបស់ប្រជាជនកម្ពុជា។ អង្កេតលើកមុនៗក៏ត្រូវបានអនុវត្តដោយមានកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍នានាផងដែរ។

## ចរិតលក្ខណៈប្រជាសាស្ត្រ

នៅពេលដែលអង្កេតត្រូវបានអនុវត្តក្នុងឆ្នាំ២០២៥ ប្រទេសកម្ពុជាមានប្រជាជនសរុបប្រមាណ១៧.៦ លាននាក់ ដែលក្នុងនោះ ៤៨,៧% ជាប្រុស និង ៥១,៣% ជាស្រី។ ក្នុងចំណោមប្រជាជនសរុប មានប្រមាណ ៦០,៤% ឬ ១០.៦ លាននាក់ រស់នៅតំបន់ជនបទ ខណៈដែល ៣៩,៦% ឬ ៦.៩ លាននាក់ រស់នៅតំបន់ទីប្រជុំជន។ គេប៉ាន់ប្រមាណថា មានប្រមាណ ២.៦ លានគ្រួសារ រស់នៅតំបន់ជនបទ និង ១.៧ លានគ្រួសារ រស់នៅតំបន់ទីប្រជុំជន ដែលសរុបមានប្រមាណ ៤.៣ លានគ្រួសារ នៅទូទាំងប្រទេស។ ទំហំគ្រួសារជាមធ្យមនៅថ្នាក់ជាតិមាន ៤.១ នាក់ក្នុងមួយគ្រួសារ។ ទំហំគ្រួសារជាមធ្យមមានចំនួន ៤.១ នាក់ក្នុងមួយគ្រួសារ ដូចគ្នាទាំងនៅតំបន់ជនបទ និងតំបន់ទីប្រជុំជន។

## ប្រជាជនក្នុងអាយុធ្វើការ

នៅពេលអនុវត្តអង្កេតក្នុងឆ្នាំ២០២៥ កម្ពុជាមានប្រជាជនសរុបប៉ាន់ស្មានប្រមាណ ១៧.៦ លាននាក់ ក្នុងនោះ ប្រុសមានចំនួន ៤៨,៧% និង ស្រី មានចំនួន ៥១,៣%។ ក្នុងចំណោមប្រជាជនសរុប ប្រមាណ ៦០,៤% ឬ ១០.៦ លាននាក់ រស់នៅតំបន់ជនបទ ខណៈដែល ៣៩,៦% ឬប្រមាណ ៦.៩ លាននាក់ រស់នៅតំបន់ទីប្រជុំជន។

តាមការប៉ាន់ស្មាន កម្ពុជាមានគ្រួសារសរុបជាង ៤.៣ លានគ្រួសារ ក្នុងនោះមានគ្រួសារជាង ២.៦ លានគ្រួសារ ស្ថិតនៅតំបន់ជនបទ និងប្រមាណ ១.៧ លានគ្រួសារ ស្ថិតនៅតំបន់ទីប្រជុំជន។ ទំហំគ្រួសារជា

មធ្យមនៅទូទាំងប្រទេសមាន ៤,១ នាក់ក្នុងមួយគ្រួសារ ដែលដូចគ្នាទាំងតំបន់ជនបទ (៤,១ នាក់ក្នុងមួយគ្រួសារ) និងតំបន់ទីប្រជុំជន (៤,១ នាក់ក្នុងមួយគ្រួសារ)។ ក្នុងចំណោមគ្រួសារទាំងអស់នេះ ៧៣,១% ឬប្រមាណ ៣.១ លានគ្រួសារ មានមេគ្រួសារជាប្រុស ខណៈដែល ២៦,៩% ឬប្រមាណ ១.២ លានគ្រួសារ មានមេគ្រួសារជាស្រី។ ការបែងចែកតាមភេទរបស់មេគ្រួសារមានលក្ខណៈប្រហាក់ប្រហែលគ្នារវាងតំបន់ទីប្រជុំជន និងតំបន់ជនបទ។ នៅតំបន់ទីប្រជុំជន ប្រមាណ ៧០,៦% (ជិត ១.២ លានគ្រួសារ) មានមេគ្រួសារជាប្រុស ខណៈដែល ២៩,៤% (ជាង ០.៥ លានគ្រួសារ) មានមេគ្រួសារជាស្រី។ ចំណែកនៅតំបន់ជនបទ ប្រមាណ ៧៤,៧% (ប្រមាណ ១.៩ លានគ្រួសារ) មានមេគ្រួសារជាប្រុស ខណៈដែល ២៥,៣% (ជាង ០.៦ លានគ្រួសារ) មានមេគ្រួសារជាស្រី។

យោងតាមលទ្ធផលនៃការអង្កេត ប្រជាជនកម្ពុជាដែលមានអាយុ ៥ ឆ្នាំឡើងទៅ និងមានពិការភាព ត្រូវបានប៉ាន់ស្មានថាមានប្រមាណ ៣,១% នៃប្រជាជនសរុបរបស់កម្ពុជាក្នុងឆ្នាំ២០២៥។ កម្រិតនៃពិការភាព មានភាពខុសគ្នា ដោយរាប់ចាប់ពី មានការលំបាកខ្លះៗ ក្នុងការបំពេញមុខងាររាងកាយ រហូតដល់ មិនអាចអនុវត្តមុខងាររាងកាយបានទាំងស្រុង។ នៅឆ្នាំ២០២៥ អត្រាបន្ទុកក្នុងបន្ទុកសរុបមាន ៤៩,៥% ដោយក្នុងនោះ ៤៥,៩% ស្ថិតនៅតំបន់ទីប្រជុំជន និង ៥២,០% ស្ថិតនៅតំបន់ជនបទ។ បន្ទុកភាគច្រើននៃអត្រានេះបណ្តាលមកពីប្រជាជនវ័យក្មេងដែលមានអាយុក្រោម ១៥ ឆ្នាំ ដែលមានសមាមាត្ររហូតដល់ ៣៧,៩%។ ចំពោះប្រភពចម្បងនៃជីវភាពរស់នៅរបស់គ្រួសារ ប្រមាណ ៤០,២% នៃគ្រួសារបានរាយការណ៍ថា ចំណូលពីការងារទទួលបានប្រាក់ឈ្នួល គឺជាប្រភពចម្បងនៃជីវភាពរស់នៅរបស់ខ្លួន។ ប្រមាណ ២៥,៨% ពឹងផ្អែកលើ កសិកម្ម ឬនេសាទក្នុងគ្រួសារ ខណៈដែល ២៥,៩% ពឹងផ្អែកលើ អាជីវកម្មដែលគ្រួសារប្រតិបត្តិដោយខ្លួនឯង ក្រៅពីកសិកម្ម ឬនេសាទ។

## អត្រាចូលរួមក្នុងកម្លាំងពលកម្ម

អត្រាចូលរួមក្នុងកម្លាំងពលកម្ម (LFPR) នៅកម្ពុជាមាន ៧១,៦% ដោយប្រុសមានអត្រាចូលរួមខ្ពស់ជាងស្រី គឺ ៧៧,៧% ធៀបនឹង ៦៥,៩%, អត្រាចូលរួមក្នុងកម្លាំងពលកម្មបានកើនឡើងយ៉ាងឆាប់រហ័សពី ៤៦,៦% ក្នុងចំណោមប្រជាជនអាយុ ១៥–១៩ ឆ្នាំ រហូតដល់កម្រិតខ្ពស់បំផុតប្រមាណ ៨៧,% សម្រាប់ក្រុមអាយុ ២៥–៣៤ ឆ្នាំ, បន្ទាប់មកបានថយចុះជាបន្តបន្ទាប់តាមអាយុ មកនៅត្រឹម ៣៣,៥% សម្រាប់ប្រជាជនអាយុ ៦៥ ឆ្នាំ និងលើសពីនេះ, ជារួម តំបន់ទីប្រជុំជន (៧៣,៦%) មានអត្រាចូលរួមក្នុងកម្លាំងពលកម្មខ្ពស់ជាងបន្តិចបើប្រៀបធៀបនឹងតំបន់ជនបទ (៧០,២%), ហើយប្រុសមានអត្រាចូលរួមក្នុងកម្លាំងពលកម្មខ្ពស់ជាងស្រីជាប់លាប់នៅគ្រប់ក្រុមអាយុ និងគ្រប់តំបន់។

## អ្នកមានការងារធ្វើ

ក្នុងចំណោមប្រជាជនដែលមានការងារធ្វើប្រមាណ ៩.១ លាននាក់ ក្នុងឆ្នាំ២០២៥ ដែលមាន ៥២,៤% ជាប្រុស និង ៤៧,៦% ជាស្រី។ ប្រជាជនដែលមានការងារធ្វើភាគច្រើន (៥៩,០%) រស់នៅតំបន់ជនបទ ខណៈដែល ៤១,០% រស់នៅតំបន់ទីប្រជុំជន។ តាមមុខរបរ ប្រុសមានសមាមាត្រខ្ពស់ជាងស្រីក្នុងមុខរបរមួយចំនួន ដូចជា សិប្បកម្ម និងពាណិជ្ជកម្មពាក់ព័ន្ធដែលមាន ១៧,៦% ប្រៀបធៀបនឹង ៤,៨% សម្រាប់ស្រី។ ប្រុសក៏មាន

សមាមាត្រខ្ពស់ជាងក្នុងក្រុមកម្មករជំនាញកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមាន២២,៨% ប្រៀបធៀបនឹង ២១,៤% សម្រាប់ស្រី។

តាមវិស័យសេដ្ឋកិច្ច វិស័យសេវាកម្មមានសមាមាត្រខ្ពស់ជាងគេនៃប្រជាជនមានការងារធ្វើ ស្មើនឹង ៤៣,០% ខណៈដែលវិស័យឧស្សាហកម្មមានសមាមាត្រ ២៩,៤% និងវិស័យកសិកម្មមានសមាមាត្រ ២៧,៦%។ ប្រមាណ ៤,៨% នៃប្រជាជនដែលមានការងារធ្វើ មិនធ្លាប់បានចូលរៀននៅសាលាឡើយ។ ប្រមាណ ៤២,៩% នៃអ្នកមានការងារធ្វើសរុប បានបញ្ចប់ការអប់រំកម្រិតបឋមសិក្សា ខណៈដែល ៣៩,២% បានបញ្ចប់ការអប់រំកម្រិតមធ្យមសិក្សា (រួមមាន មធ្យមសិក្សាបឋមភូមិ និង មធ្យមសិក្សាទុតិយភូមិ)។

ចំណែកឯអ្នកដែលបានបញ្ចប់ការសិក្សាថ្នាក់ឧត្តមសិក្សា មានត្រឹមតែ៧,៨% ប៉ុណ្ណោះ ខណៈដែល ៥,២% បានទទួល វិញ្ញាបនបត្របណ្តុះបណ្តាលវិជ្ជាជីវៈ។ ក្នុងចំណោមប្រុសដែលមានការងារធ្វើ ប្រមាណ ៤១,២% បានបញ្ចប់ការសិក្សាត្រឹម បឋមសិក្សា ប៉ុណ្ណោះ។ ប្រមាណ២៦,៦% បានបញ្ចប់មធ្យមសិក្សាបឋមភូមិ ខណៈដែល១៤,៤% បានបញ្ចប់មធ្យមសិក្សាទុតិយភូមិ។ ចំណែកឯអ្នកដែលបានបញ្ចប់ការសិក្សាថ្នាក់ឧត្តមសិក្សា មាន៨,៤% និង ៥,៦% បានទទួល វិញ្ញាបនបត្រ បណ្តុះបណ្តាលវិជ្ជាជីវៈ។

នៅឆ្នាំ ២០២៥ សមាមាត្រធំបំផុតនៃប្រជាជនមានការងារធ្វើ គឺជានិយោជិត ដែលមាន ៥០,១% បន្ទាប់មកគឺកម្មករធ្វើការដោយខ្លួនឯង ដែលមាន ២២,២% កម្មករជួយការងារគ្រួសារដោយមិនទទួលបានប្រាក់ឈ្នួល មាន ២,៧% និងនិយោជក មាន ៥,០%។

## ការងារក្រៅប្រព័ន្ធ

លទ្ធផលនៃការអង្កេតបង្ហាញថា ប្រមាណ ៧៥,១% នៃប្រជាជនដែលមានការងារធ្វើ និងមានអាយុ ១៥ ឆ្នាំឡើងទៅស្ថិតក្នុង ការងារក្រៅប្រព័ន្ធខណៈដែល ២៤,៩% ស្ថិតក្នុង ការងារក្នុងប្រព័ន្ធ ។ ការងារក្រៅប្រព័ន្ធមានសមាមាត្រខ្ពស់ជាងនៅតំបន់ជនបទ(៦៣,៥%) បើប្រៀបធៀបនឹងតំបន់ទីប្រជុំជន(៣៦,៥%)។ យោងតាមលទ្ធផលនៃការអង្កេត ការងារក្រៅប្រព័ន្ធ មានសមាមាត្រខ្ពស់បំផុតក្នុងចំណោមអ្នកជំនាញកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមាន ៩៩,៦%។ បន្ទាប់មកគឺ អ្នកធ្វើសិប្បកម្ម និងអាជីកម្មពាក់ព័ន្ធ មាន ៩០,៣%, មុខរបរងាយៗមាន ៨៨,៩%, និង អ្នកផ្តល់សេវាកម្ម និងអ្នកលក់ មាន ៨៨,០% ដែលភាគច្រើនស្ថិតក្នុងការងារក្រៅប្រព័ន្ធ។

## ប្រាក់ចំណូលពីការងារ

លទ្ធផលនៃការអង្កេតបង្ហាញថា នៅឆ្នាំ២០២៥ ប្រាក់ឈ្នួល ឬប្រាក់បៀវត្ស គឺជាទម្រង់នៃការទូទាត់ដែលនិយោជិតទទួលបានច្រើនជាងគេ ដោយមានសមាមាត្រ ៩៦,៨% នៃនិយោជិតសរុប។ សមាមាត្រនេះមានកម្រិតខ្ពស់ជាងបន្តិចសម្រាប់ ស្រី (៩៧,១%) បើប្រៀបធៀបនឹង ប្រុស (៩៦,៦%)។ ចំណែកឯទម្រង់នៃការទូទាត់ផ្សេងទៀត មានសមាមាត្រតិចតួចប៉ុណ្ណោះ។ ប្រមាណ ១,៩% នៃនិយោជិតទទួលបានការទូទាត់ជា

ទម្រង់ផ្សេងៗ ដូចជា អាហារឬកន្លែងស្នាក់នៅ ឬអត្ថប្រយោជន៍ជាប្រភេទផ្សេងទៀត ដោយមិនមានភាពខុសគ្នាគួរឱ្យកត់សម្គាល់រវាងប្រុស និងស្រីឡើយ។

យោងតាមលទ្ធផលនៃការអង្កេត ប្រាក់ឈ្នួលប្រចាំខែជាមធ្យម នៅការងារចម្បងរបស់និយោជិត ត្រូវបានប៉ាន់ស្មានថាមានចំនួន ១.២០១.៤៣៦ រៀល (៣០០,៣៦ ដុល្លារអាមេរិក) ខណៈដែល ប្រាក់ឈ្នួលប្រចាំខែពាក់កណ្ដាលមានចំនួន ១.១៥០.០០០ រៀល (២៨៧,៥០ ដុល្លារអាមេរិក)។ លទ្ធផលនៃការអង្កេតក៏បានបង្ហាញពី គម្លាតប្រាក់ឈ្នួលរវាងប្រុស និងស្រី ផងដែរ។ ជាមធ្យម និយោជិតជាប្រុសទទួលបានប្រាក់ឈ្នួលប្រចាំខែខ្ពស់ជាងនិយោជិតជាស្រីចំនួន ១៤២.១៧៦ រៀល (៣៥,៥៤ ដុល្លារអាមេរិក)។ ដូចគ្នានេះដែរ ប្រាក់ឈ្នួលប្រចាំខែពាក់កណ្ដាល របស់ប្រុសក៏ខ្ពស់ជាងស្រីចំនួន ១៦០,០០០ រៀល (៤០,០០ ដុល្លារអាមេរិក)។

## ម៉ោងធ្វើការ

សរុបជារួម ប្រុសធ្វើការជាមធ្យម ៤១,០ ម៉ោងក្នុងមួយសប្ដាហ៍ ខណៈស្រីធ្វើការជាមធ្យម ៣៩,០ ម៉ោងក្នុងមួយសប្ដាហ៍។ តាមក្រុមមុខរបរ ការីម៉ាស៊ីន និងរោងចក្រ និងអ្នកប្រមូលផ្ដុំ មានម៉ោងធ្វើការជាមធ្យមក្នុងមួយសប្ដាហ៍ខ្ពស់ជាងគេសម្រាប់ភេទទាំងពីរ ដោយប្រុសធ្វើការ ៤៨,២ ម៉ោង និងស្រី ៤៩,៨ ម៉ោងក្នុងមួយសប្ដាហ៍។ ក្រុមស្មៀន ក៏មានចំនួនម៉ោងធ្វើការខ្ពស់ផងដែរ ដោយជាមធ្យមប្រុសធ្វើការ ៤៨,៨ ម៉ោង និងស្រី ៤៨,៦ ម៉ោងក្នុងមួយសប្ដាហ៍។

លទ្ធផលក៏បានបង្ហាញផងដែរថា មានភាពខុសគ្នានៃចំនួនម៉ោងធ្វើការជាធម្មតាក្នុងមួយសប្ដាហ៍ទៅតាមសកម្មភាពសេដ្ឋកិច្ច។ វិស័យដែលមានចំនួនម៉ោងធ្វើការជាធម្មតាក្នុងមួយសប្ដាហ៍ខ្ពស់ជាងគេ គឺ សិល្បៈ ការកម្សាន្ត និងការកំសាន្ត (៥៧,២ ម៉ោង) បន្ទាប់មកគឺ សំណង់ (៤៨,៨ ម៉ោង) កម្មន្តសាល និងឧស្សាហកម្ម (៤៨,៥ ម៉ោង) ការផ្គត់ផ្គង់អគ្គិសនី ឧស្ម័ន ចំហាយទឹក និងម៉ាស៊ីនត្រជាក់ (៤៧,៩ ម៉ោង) សកម្មភាពសេវាកម្មរដ្ឋបាល និងសេវាគាំទ្រ(៤៧,៨ ម៉ោង) និងសកម្មភាពរបស់អង្គការ និងស្ថាប័នក្រៅរដ្ឋាភិបាល(៤៧,២ម៉ោង)។

## ភាពគ្មានការងារធ្វើ

នៅឆ្នាំ២០២៥ មានប្រជាជនអាយុ ១៥ ឆ្នាំឡើង ដែលស្ថិតក្នុងភាពគ្មានការងារធ្វើចំនួន ៣៤២.០៦៧ នាក់ ក្នុងនោះមាន ប្រុស ១៤៦.៥០៤ នាក់ និង ស្រី ១៩៥.៥៦៤ នាក់។ អត្រាអត់ការងារធ្វើសរុប ដែលកំណត់ថាជា សមាមាត្រនៃចំនួនអ្នកអត់ការងារធ្វើធៀបនឹងកម្លាំងពលកម្មសរុប ត្រូវបានប៉ាន់ស្មានថាមាន ៣,៦% ដោយ អត្រានេះមានកម្រិតដូចគ្នាសម្រាប់ទាំងប្រុស និងស្រី។ ទោះជាយ៉ាងណា អត្រាអត់ការងារធ្វើមានភាពខុសគ្នាទៅតាមក្រុមអាយុ តំបន់ភូមិសាស្ត្រ និងលក្ខណៈប្រជាសាស្ត្រផ្សេងៗទៀត។ អត្រាអត់ការងារធ្វើមាននិន្នាការថយចុះនៅពេលអាយុរបស់ក្រុមអាយុកើនឡើង ដោយអត្រាខ្ពស់បំផុតត្រូវបានកត់ត្រាក្នុងចំណោមយុវជនអាយុ ១៥–២៤ ឆ្នាំ ដែលមាន ៩,៩ %។ អត្រាអត់ការងារធ្វើរបស់យុវជនប្រុស (អាយុ ១៥–២៤ ឆ្នាំ) មានកម្រិតខ្ពស់ជាងយុវជនស្រី ទាំងនៅតំបន់ទីប្រជុំជន និងតំបន់ជនបទ។ ប្រមាណ ៩៤,០ % នៃអ្នកអត់ការងារធ្វើបានរាយការណ៍ថា ស្ថិតក្នុងស្ថានភាពគ្មានការងារធ្វើរយៈពេលខ្លី (តិចជាង ១២ ខែ) ខណៈដែល ៥,៩ % បានស្វែងរកការងារធ្វើអស់រយៈពេលលើសពី ១ ឆ្នាំ។ ស្រីមានសមាមាត្រស្ថិតក្នុងស្ថានភាពគ្មានការងារធ្វើ

រយៈពេលខ្លីខ្ពស់ជាងប្រុស។ ដូច្នេះ សមាមាត្រនៃអ្នកអត់ការងារធ្វើរយៈពេលវែង មានកម្រិតខ្ពស់ជាងក្នុងចំណោមប្រុស បើធៀបនឹងស្រី។

ក្នុងចំណោមអ្នកអត់ការងារធ្វើដែលកំពុងស្វែងរកការងារយ៉ាងសកម្ម ប្រមាណ ៥០,២% បានស្វែងរកជំនួយពីសាច់ញាតិ ឬមិត្តភក្តិ។ បន្ទាប់មក គឺអ្នកដែលបាន ដាក់ពាក្យស្នើសុំការងារទៅនិយោជកដោយផ្ទាល់ (២០,៩%) អ្នកដែលបាន ទៅសាកសួរនៅរោងចក្រ ឬកន្លែងធ្វើការ (១១,៤%) និងអ្នកដែលបាន សិក្សា ឬអានការផ្សាយប្រកាសជ្រើសរើសបុគ្គលិក (៧,៨ %)។

## យុវជនមានការងារធ្វើ

នៅឆ្នាំ២០២៥ យុវជនអាយុ ១៥–២៤ ឆ្នាំ ប្រមាណ ១.៨ លាននាក់ បានចូលរួមក្នុងកម្លាំងពលកម្មដែលស្មើនឹង ៦១,១% នៃយុវជនសរុបក្នុងប្រទេស។ ក្នុងចំណោមនោះ ៦៤,២ % ជាប្រុស និង ៥៧,៩% ជាស្រី។ ក្នុងឆ្នាំ២០២៥ មានប្រមាណ ៩០,១% នៃយុវជនដែលស្ថិតក្នុងកម្លាំងពលកម្មមានការងារធ្វើ (មានន័យថា អត្រាគ្មានការងារធ្វើមាន ៩,៩%)។ អត្រានេះមានភាពខុសគ្នាតិចតួចប៉ុណ្ណោះរវាងយុវជនប្រុស និងយុវជនស្រី ព្រមទាំងរវាងតំបន់ទីប្រជុំជន និងតំបន់ជនបទ។ តាមមុខរបរយុវជនទាំងប្រុស និងស្រីភាគច្រើនបានបម្រើការងារជា កម្មករប្រតិបត្តិការម៉ាស៊ីន និងអ្នកប្រមូលផ្គុំ ដោយស្រីមានសមាមាត្រ ៣០,៤% និងប្រុសមាន ២៣,៩%។ ចំណែកតាមវិស័យសេដ្ឋកិច្ច យុវជនប្រុសភាគច្រើន(៤៣,៨%)ធ្វើការក្នុងវិស័យសេវាកម្ម ខណៈដែលយុវជនស្រីស្ទើរតែពាក់កណ្ដាល (៤៨,៣ %) ក៏ធ្វើការក្នុងវិស័យសេវាកម្មផងដែរ។

សរុបមានយុវជនចំនួន ១៩៨.៥៨៦ នាក់ ដែលស្មើនឹង ១៤,៦% នៃយុវជនសរុប មិនស្ថិតក្នុងការងារ ការអប់រំ ឬការបណ្តុះបណ្តាល (NEET)។ ក្នុងចំណោមនោះ ចំនួនយុវជនស្រីដែលស្ថិតក្នុងស្ថានភាព NEET មានច្រើនជាងយុវជនប្រុស ដោយមាន ១១៨.៥២២ នាក់ ឬស្មើនឹង ១៨,០% នៃយុវជនស្រីសរុប ខណៈដែលយុវជនប្រុសមាន ៨០.០៦៤ នាក់ ឬស្មើនឹង ១១,៧% នៃយុវជនប្រុសសរុប។ លើសពីនេះទៅទៀត សមាមាត្រយុវជនដែលមិនស្ថិតក្នុងការងារ ការអប់រំ ឬការបណ្តុះបណ្តាល មានកម្រិតខ្ពស់ជាងនៅតំបន់ជនបទ (១៦,២%) បើធៀបនឹងតំបន់ទីប្រជុំជន (១២,៦%)។

## ចំណាយជ្រើសរើសរបស់ពលករចំណាកស្រុកនិវត្តន៍

ការជ្រើសរើសសំណាកនៃការអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥ មិនត្រូវបានកែប្រែជាពិសេសដើម្បីបង្កើនសមត្ថភាពក្នុងការចាប់យកព័ត៌មានអំពីពលករចំណាកស្រុកអន្តរជាតិដែលបានវិលត្រលប់មកប្រទេសវិញ។ ដូច្នេះលទ្ធផលដែលទទួលបានពីការអង្កេតនេះ អាចប៉ាន់ស្មានទាបជាងចំនួនជាក់ស្តែងនៃពលករចំណាកស្រុកដែលបានវិលត្រឡប់មកប្រទេសវិញ។ លើសពីនេះ ការអង្កេតគ្របដណ្តប់តែអ្នករស់នៅក្នុងគ្រួសារធម្មតាដែលត្រូវបានរកឃើញនៅលំនៅឋានប្រក្រតីរបស់ពួកគេក្នុងអំឡុងពេលប្រមូលទិន្នន័យប៉ុណ្ណោះ។ ដោយសារចំនួនសំណាកនៃពលករចំណាកស្រុកដែលបានវិលត្រឡប់មកប្រទេសវិញមានទំហំតូច (សរុបមានត្រឹមតែ ៦៣១ ករណី) ដូច្នេះ ការសន្និដ្ឋានមួយចំនួននៅក្នុងរបាយការណ៍នេះ ជាពិសេសលទ្ធផលដែលបែងចែកតាមលក្ខណៈផ្សេងៗ គួរតែត្រូវបានបកស្រាយ និងប្រើប្រាស់ដោយប្រុងប្រយ័ត្ន។

ក្នុងចំណោមប្រជាជនដែលធ្លាប់បានធ្វើការនៅក្រៅប្រទេស លទ្ធផលនៃការអង្កេតបង្ហាញថា មានប្រមាណ ២៦៨.៥៧៧ នាក់ ដែលបានវិលត្រឡប់មកប្រទេសកម្ពុជាវិញក្នុងរយៈពេល ៣ ឆ្នាំមុនពេលធ្វើការអង្កេត ដែលក្នុងនោះមានប្រុស ១៥៨.៥៣៨ នាក់ និងស្រី ១១០.០៣៩ នាក់។ ភាគច្រើននៃពលករចំណាកស្រុកដែលបានវិលត្រលប់មកប្រទេសវិញ មានលំនៅឋាននៅតំបន់ជនបទ និងស្ថិតក្នុងក្រុមអាយុវ័យក្មេងជាពិសេសក្រុមអាយុ ២៥–៣៤ ឆ្នាំ។

ភាគច្រើនលើសលប់នៃពលករចំណាកស្រុកដែលបានវិលត្រឡប់មកប្រទេសវិញ បានវិលត្រលប់មកពីប្រទេសថៃ (៩០,១%) ខណៈដែលអ្នកផ្សេងទៀតបានវិលត្រលប់មកពីសាធារណរដ្ឋកូរ៉េ (២,៨%) ម៉ាឡេស៊ី (១,៧%) និងប្រទេសចិន (០,៧%)។

សម្រាប់ការអង្កេតនេះ ថ្លៃចំណាយលើការជ្រើសរើសត្រូវបានកំណត់ន័យថា ជាការចំណាយដែលបានបង់ដើម្បីទទួលបានការងារនៅប្រទេសផ្សេង រួមមានថ្លៃសេវាសម្រាប់៖ (១) ឯកសារផ្លូវការ ដូចជា លិខិតឆ្លងដែន និងទិដ្ឋាការ (២) ការពិនិត្យសុខភាព និងការធ្វើតេស្តសុខភាព (៣) ការបណ្តុះបណ្តាលមុនចេញដំណើរ និងការវាយតម្លៃជំនាញ (៤) ការធានារ៉ាប់រង ការអនុម័តកិច្ចសន្យា និងការបញ្ជាក់សន្តិសុខសម្រាប់ការធ្វើដំណើរ និង (៥) អ្នកជ្រើសរើស ឈ្មួញកណ្តាល ឬភ្នាក់ងារជ្រើសរើសពលករ/ភ្នាក់ងារផ្គត់ផ្គង់កម្លាំងពលកម្ម។ ថ្លៃចំណាយទាំងនេះក៏រួមបញ្ចូលថ្លៃធ្វើដំណើរ ដូចជា ថ្លៃដឹកជញ្ជូន និងកន្លែងស្នាក់នៅ ការបង់ប្រាក់ផ្លូវការ ឬមិនផ្លូវការផ្សេងៗ ឧទាហរណ៍ (ដូចជា ការបង់ប្រាក់ឱ្យមិត្តភក្តិ ឬសាច់ញាតិដែលបានជួយរកការងារ និងការប្រាក់លើប្រាក់ដែលបានខ្ចីផងដែរ)។

យោងតាមលទ្ធផលនៃការអង្កេត ប្រមាណ ៨,៥% នៃពលករចំណាកស្រុកដែលបានវិលត្រលប់មកប្រទេសវិញ បានចំណាយថ្លៃជ្រើសរើសតិចជាង ៤០០.០០០ រៀល (១០០ ដុល្លារអាមេរិក) ខណៈដែល ៥២,៦% បានចំណាយថ្លៃជ្រើសរើសចន្លោះពី ៤០០.០០០ រៀល ដល់ប្រមាណ ១.៦០០.០០០ រៀល (៤០០ ដុល្លារអាមេរិក)។ ជាមធ្យមថ្លៃចំណាយសរុបលើការជ្រើសរើសសម្រាប់ការទទួលបានការងារនៅក្រៅប្រទេស មានចំនួន ៣.៥៦២.៨២៩ រៀល (៨៩០ដុល្លារអាមេរិក)។

ជារួម ប្រាក់ចំណូលប្រចាំខែរបស់ពលករចំណាកស្រុកដែលបានវិលត្រឡប់មកប្រទេសវិញនៅ កម្ពុជាជាមធ្យម ៤.៣លានរៀល (១.០៧០ដុល្លារអាមេរិក)។ ក្នុងចំណោមពលករទាំងនេះ ៦៤,៩% ទទួលបានប្រាក់ចំណូលប្រចាំខែចន្លោះពី ៤០០.០០០រៀល (១០០ដុល្លារអាមេរិក) ដល់ប្រមាណ ១.៦ លានរៀល (៤០០ ដុល្លារអាមេរិក)។ ចំណែកពលករដែលមានប្រាក់ចំណូលខ្ពស់បំផុត ដោយទទួលបានប្រាក់ចំណូលប្រចាំខែចាប់ពី ៤.០លានរៀល (១.០០០ដុល្លារអាមេរិក) ឡើងទៅ មានត្រឹមតែ ១៤,៤% នៃពលករចំណាកស្រុកដែលបានវិលត្រលប់មកប្រទេសវិញប៉ុណ្ណោះ។

សូចនាករថ្លៃចំណាយលើការជ្រើសរើស (១០.៧.១) នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពត្រូវបានកំណត់ជាសមាមាត្ររវាងថ្លៃចំណាយលើការជ្រើសរើសជាមធ្យម និងប្រាក់ឈ្នួលប្រចាំខែជាមធ្យម (សម្រាប់ខែដំបូងនៃការងារនៅក្រៅប្រទេស)។ សម្រាប់ពលករចំណាកស្រុកកម្ពុជា សូចនាករនេះមានតម្លៃប្រមាណ ០,៧ ខែនៃប្រាក់ចំណូល។ នេះមានន័យថា ប្រាក់ឈ្នួលតិចជាងមួយខែ គឺគ្រប់គ្រាន់សម្រាប់សងត្រលប់ថ្លៃ

ចំណាយលើការជ្រើសរើស។ ទោះជាយ៉ាងណា លទ្ធផលដែលបានរាយការណ៍ដោយពលករផ្ទាល់បានបង្ហាញថា រយៈពេលជាមធ្យមដែលត្រូវការដើម្បីសងត្រលប់ថ្លៃចំណាយលើការជ្រើសរើសពិតប្រាកដ មានប្រមាណ ១,៤ ខែ ដែលស្មើនឹងប្រហែលពីរដងនៃតម្លៃសូចនាករដែលបានគណនា ។

# ផែនទីព្រះរាជាណាចក្រកម្ពុជា



# ជំពូក ១
# សេចក្ដីផ្ដើម

អង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥ គឺជាការអនុវត្តលើកទី៥ បន្ទាប់ពីការអង្កេតនៅឆ្នាំ ២០០០ ២០០១ ២០១២ និង ២០១៩។ វិទ្យាស្ថានជាតិស្ថិតិ (វ.ជ.ស.) បានសហការជាមួយ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ អង្គការអន្តរជាតិខាងការងារ អង្គការសហប្រជាជាតិដើម្បីអភិវឌ្ឍន៍ និងធនាគារពិភពលោក ក្នុងការអនុវត្តការអង្កេតនេះ។ ការប្រមូលទិន្នន័យនៅមូលដ្ឋានបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី ២៥ ខែតុលា ដល់ថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ ២០២៥។ ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសសម្រាប់ការអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥ ត្រូវបានផ្ដល់ដោយ រាជរដ្ឋាភិបាលកម្ពុជា អង្គការអន្តរជាតិខាងការងារ អង្គការសហប្រជាជាតិដើម្បីការអភិវឌ្ឍ និងធនាគាពិភពលោក។

អង្គការអន្តរជាតិខាងការងារ បានផ្ដល់ជំនួយបច្ចេកទេសសម្រាប់ការអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥ ហើយបានគាំទ្រក្នុងការប្រមូលទិន្នន័យដើម្បីត្រួតពិនិត្យ និងវាយតម្លៃ ចំនួនប្រជាជន ភាពមានការងារធ្វើ ភាពគ្មានការងារធ្វើ និងការងារសមរម្យ។

អង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥ គឺជាអង្កេតគ្រួសារ ដែលត្រូវបានអនុវត្តន៍ដោយវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ និងមានការគាំទ្របច្ចេកទេសពីអង្គការអន្តរជាតិខាងការងារ អង្គការសហប្រជាជាតិដើម្បីអភិវឌ្ឍន៍ និងធនាគារពិភពលោក ។ នេះជាអង្កេតទូទាំងប្រទេសលើកទីប្រាំ ដែលកម្ពុជាបានប្រមូលទិន្នន័យអំពីការងារ និងភាពមានការងារធ្វើ តាមរយៈអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥។ អង្កេតកម្លាំងពលកម្មកម្ពុជាដែលបានដំណើរការកន្លងមក ក៏បានសហការជាមួយដៃគូអភិវឌ្ឍន៍មួយចំនួនផងដែរ។

របាយការណ៍សូចនាករសំខាន់ៗនេះផ្ដល់នូវទិដ្ឋភាពទូទៅដំបូងនៃការរកឃើញដែលបានជ្រើសរើសពីអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥ ។ ការវិភាគដ៏ទូលំទូលាយនៃទិន្នន័យនឹងត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ចុងក្រោយ ដែលគ្រោងនឹងចេញផ្សាយនៅក្នុងខែមិថុនា ឆ្នាំ២០២៦។

## ១.១ សាវតារ

អាទិភាពគោលនយោបាយ និងគោលដៅយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា រួមមាន ការពង្រីក ទីផ្សារការងារ ការទទួលបានប្រាក់ចំណូលខ្ពស់ លក្ខខណ្ឌការងារល្អ និងការយកចិត្តទុកដាក់កាន់តែខ្លាំងលើសុខុមាលភាពរបស់កម្មករ និងនិយោជិត ទាំងក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធសេដ្ឋកិច្ច។ ទិន្នន័យ និងលទ្ធផល ដែលទទួលបានពីការអង្កេតនេះ នឹងបម្រើដល់ការតាមដានវឌ្ឍនភាព ក្នុងការសម្រេចឱ្យបាននូវអាទិភាព និងគោលដៅយុទ្ធសាស្ត្រទាំងនេះ។

ការអង្កេតនេះត្រូវបានធ្វើឡើងក្នុងអំឡុងពេល ២៥ថ្ងៃ ចាប់ពីថ្ងៃទី២៥ ខែតុលា ដល់ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ ២០២៥។ ការអង្កេតនេះបានគ្របដណ្ដប់លើគ្រួសារចំនួន ៩.៩១២គ្រួសារ ក្នុងភូមិចំនួន ៧០៨ភូមិ ដែលបានគ្របដណ្ដប់ទូទាំងរាជធានីភ្នំពេញខេត្តចំនួន ២៥ ទូទាំងប្រទេស។ បញ្ជីសំណាកដែលបានប្រើប្រាស់ គឺផ្អែកលើជំរឿនទូទៅប្រជាជនកម្ពុជា ឆ្នាំ២០១៩។ ការរៀបចំផែនការសំណាក ការបណ្ដុះបណ្ដាលយ៉ាងហ្មត់ចត់ ការ

ធ្វើតេស្តសាកល្បង និងការគ្រប់គ្រងការចុះប្រមូលទិន្នន័យផ្ទាល់ បានគាំទ្រដល់ការប៉ាន់ប្រមាណប្រកបដោយភាពជឿជាក់ទាំងក្នុងកម្រិតថ្នាក់ជាតិ និងកម្រិតតំបន់ទីប្រជុំជន ជនបទ។

លទ្ធផលបានបង្ហាញពីកម្រិតខ្ពស់នៃអត្រាចូលរួមក្នុងកម្លាំងពលកម្ម និងការមានការងារធ្វើ ព្រមជាមួយគ្នា នឹងបញ្ហាប្រឈមជារចនាសម្ព័ន្ធដែលកំពុងកើតមាន ជាពិសេសពាក់ព័ន្ធនឹងការងារយុវជន គម្លាតយេនឌ័រ និងគុណភាពនៃការងារ។

យោងតាមច្បាប់ស្តីពីស្ថិតិ និងអនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង រាជរដ្ឋាភិបាលកម្ពុជាបានតម្រូវអោយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ប្រកាសផ្សព្វផ្សាយជាសាធារណៈនូវទិន្នន័យស្ថិតិអង្កេតកម្លាំងពលកម្មប្រចាំឆ្នាំ។ គោលបំណងសំខាន់គឺឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកប្រើប្រាស់ទិន្នន័យមាន ដូចជា រាជរដ្ឋាភិបាលកម្ពុជា អង្គការជាតិ និងអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល អ្នកស្រាវជ្រាវ អ្នកធ្វើផែនការ និងអ្នកគោលនយោបាយ និងដើម្បីបង្កើនប្រសិទ្ធភាពក្នុងការអភិវឌ្ឍគោលនយោបាយ អភិវឌ្ឍន៍ជាតិ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ ជាតិ និងការខិតខំដើម្បីសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព កម្ពុជា។

អ្វីដែលពិសេសនោះ គឺការចង់បានទិន្នន័យឆ្លុះបញ្ចាំងដល់ការគាំទ្រនៃយុទ្ធសាស្រ្តបញ្ចកោណ ដំណាក់កាលទី ១ របស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី ៧ នៃរដ្ឋសភា និងបម្រើតម្រូវការសម្រាប់គោលនយោបាយទីផ្សារការងារ។ ក្រសួងផែនការ ជាពិសេសវិទ្យាស្ថានជាតិស្ថិតិជាអ្នកគ្រប់គ្រងការផ្តល់ទិន្នន័យស្ថិតិផ្លូវការ ហើយក៏នឹងផ្តល់អាទិភាពដល់កិច្ចខិតខំប្រឹងប្រែងដើម្បីធ្វើឱ្យប្រសើរឡើងនូវការសម្របសម្រួលរវាងអ្នកផលិត និងអ្នកប្រើប្រាស់ទិន្នន័យសូចនាករ ដើម្បីធានាថាតម្រូវការត្រូវបានឆ្លើយតប។

ការអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥ គឺផ្អែកលើគំរូអង្កេតកម្លាំងពលកម្មរបស់អង្គការខាងការងារអន្តរជាតិ ដែលរួមមានសំណួរលម្អិតអំពីចរិតលក្ខណៈនៃម៉ូឌុលប្រជាសាស្រ្ត និងកម្លាំងពលកម្ម ស្ថានភាពចំណាកស្រុកអន្តរជាតិ ការងារថៃទាំដែលមិនបានទទួលប្រាក់ឈ្នួល ភាពមិនត្រូវគ្នានៃជំនាញ និងគុណវុឌ្ឍិ។ អង្កេតបានប្រមូលព័ត៌មានជាច្រើនដែលអាចប្រើសម្រាប់ការរៀបចំ ការអនុវត្ត ការតាមដាន និង ការវាយតម្លៃគោលនយោបាយ និងកម្មវិធីការងារ និងកម្លាំងពលកម្មនានានៅទូទាំងប្រទេស។

## ១.២ គោលដៅនៃការអង្កេត

គោលដៅចម្បងនៃការអង្កេតគឺដើម្បីប្រមូលទិន្នន័យដ៏ទូលំទូលាយលើសកម្មភាពសេដ្ឋកិច្ចសម្រាប់ប្រជាជនដែលមានអាយុ១៥ឆ្នាំឡើង។ នេះរួមបញ្ចូលទាំងការតាមដាននិន្នាការកម្លាំងពលកម្មដូចជា ភាពមានការងារធ្វើ ភាពគ្មានការងារធ្វើ និងភាពអសកម្មនៃកម្លាំងពលកម្ម។ ការរកឃើញនេះផ្តល់នូវមូលដ្ឋានគ្រឹះដែលមានមូលដ្ឋានលើភស្តុតាងសម្រាប់ភ្នាក់ងាររដ្ឋាភិបាល អង្គការអន្តរជាតិ និងអ្នកស្រាវជ្រាវដើម្បីរៀបចំការអន្តរាគមន៍សម្រាប់គោលដៅ។ លើសពីនេះ ការអង្កេតនេះតម្រឹមទិន្នន័យជាតិជាមួយនឹងស្តង់ដារអន្តរជាតិសម្រាប់ស្ថិតិការងារ និងការប្រើប្រាស់កម្លាំងពលកម្មមិនគ្រប់គ្រាន់។

ព័ត៌មានដែលប្រមូលបានតាមរយៈការអង្កេតកម្លាំងពលកម្ម ឆ្នាំ២០២៥ ជាជំនួយដល់អ្នកធ្វើគោលនយោបាយនិងសម្រាប់កម្មវិធីរបស់ថ្នាក់ដឹកនាំ នៅក្នុងការវាយតម្លៃកម្មវិធី និងយុទ្ធសាស្រ្តពង្រឹងសុខភាព

ប្រជាជនទូទាំងប្រទេសផងដែរ។ លើសពីនេះ ការអង្កេតកម្លាំងពលកម្ម ឆ្នាំ២០២៥ ក៏បានបំពេញនូវសូចនាករនៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពសកល(SDGs) ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជា។

## ១.៣ ការសម្ងាត់

មាត្រា ៣០ នៃច្បាប់ស្តីពីស្ថិតិបានបង្ហាញការរក្សាការសម្ងាត់។ មាត្រានេះបានចែងយ៉ាងច្បាស់ថាមន្ត្រីរាជការបុគ្គលិកធ្វើការនៅវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ និងអង្គភាពស្ថិតិក្នុងក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ក៏ដូចជាមន្ត្រីស្ថិតិដែលបានចាត់តាំងដោយអង្គការទាំងនោះ ត្រូវធានារក្សាការសម្ងាត់នូវរាល់ព័ត៌មាន ផ្ទាល់ខ្លួនទាំងឡាយដែល បានមកពីអ្នកឆ្លើយ។ ព័ត៌មានដែលប្រមូលបានក្រោមច្បាប់នេះ ត្រូវយកមកប្រើប្រាស់តែក្នុងគោលដៅស្ថិតិប៉ុណ្ណោះ។

មាត្រានេះត្រូវបានដាក់បញ្ចូលក្នុងច្បាប់ ជាពិសេសដើម្បីធានារក្សាការសម្ងាត់ទិន្នន័យផ្ទាល់ខ្លួនដែលងាយរំភើប ឬឈឺចាប់ ហើយក៏ចាំបាច់ណាស់ក្នុងការទទួលបានការទុកចិត្តពីអ្នកផ្តល់ទិន្នន័យ។ បើអ្នកឆ្លើយមិនជឿថាព័ត៌មាន ផ្ទាល់ខ្លួនរបស់ពួកគេនឹងត្រូវបានរក្សាទុកជាការសម្ងាត់ និងមិនត្រូវបានចែករំលែកដល់ស្ថាប័នរាជរដ្ឋាភិបាលដទៃទៀត (ឧទាហរណ៍ នាយកដ្ឋានពន្ធដារ) ពួកគេនឹងមិនផ្តល់នូវព័ត៌មានពិតឬពួកគេនឹងបដិសេធផ្តល់ព័ត៌មានណាមួយទាល់តែសោះ ហើយជាលទ្ធផលមានអត្រាឆ្លើយតបការអង្កេតដោយមានការជឿទុកចិត្តរបស់អ្នកឆ្លើយពិតជាមានសារៈសំខាន់ ដើម្បីធានាបាននូវអត្រាឆ្លើយខ្ពស់ និងប្រមូលបានទិន្នន័យមានគុណភាពល្អ។ មិនដាក់បញ្ចូលមាត្រានេះនឹងមានន័យថាបន្តអត្រាឆ្លើយទាបនិងស្ថិតិមានគុណភាពទាប។

ម៉្យាងទៀត មាត្រា ៣៤ នៃច្បាប់ស្តីពីស្ថិតិចែងថា មន្ត្រីរាជការ និងមន្ត្រីស្ថិតិដែលបានចាត់តាំងដោយក្រសួងផែនការ និងដោយក្រសួង ស្ថាប័នរាជរដ្ឋាភិបាលដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ៣០ នៃច្បាប់នេះនឹងត្រូវទទួលទណ្ឌកម្មរដ្ឋបាល។

មាត្រានេះមានសារៈសំខាន់ណាស់ដែលអាចធានាដល់អ្នកផ្តល់ទិន្នន័យថា ការដាក់ពិន័យជាក់លាក់នឹងអនុវត្តចំពោះមន្ត្រីរាជការ និងមន្ត្រីស្ថិតិដែលបានចាត់តាំងដែលបានរំលោភលើការសម្ងាត់ ឬប្រើព័ត៌មានផ្ទាល់ខ្លួនរបស់ពួកគេ មិនត្រឹមត្រូវ។

ក្នុងអំឡុងពេលបណ្តុះបណ្តាលអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥ ច្បាប់ស្តីពីស្ថិតិ ជាពិសេសជំពូកសិទ្ធិ និងកាតព្វកិច្ច និងជំពូកទោសប្បញ្ញត្តិត្រូវបានបង្ហាញដល់មន្ត្រីទាំងអស់ដែលបានចូលរួមក្នុងដំណើរការអង្កេតនេះ។

## ១.៤ ទស្សនាទាន និងនិយមន័យ

អង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥ បានអនុវត្តតាមស្តង់ដារអន្តរជាតិថ្មី ដែលបានអនុម័តដោយសន្និសិទ្ធ អន្តរជាតិនៃអ្នកស្ថិតិកម្លាំងពលកម្មលើកទី១៩ នៅឆ្នាំ២០១៣។ សន្និសីទអន្តរជាតិនៃអ្នកស្ថិតិ កម្លាំងពលកម្មលើកទី១៩ បានដាក់ចេញនូវក្របខ័ណ្ឌថ្មីមួយសម្រាប់ស្ថិតិទីផ្សារការងារ រួមមានស្ថិតិទាក់ទងនឹងការងារ

ភាពមានការងារធ្វើ និងការប្រើមិនគ្រប់គ្រាន់នូវកម្លាំងពលកម្ម។

និយមន័យនៃពាក្យ "ភាពមានការងារធ្វើ" ដែលប្រើក្នុងកម្លាំងពលកម្មកម្ពុជា គ្របដណ្តប់លើសកម្មភាពស្ទើរតែទាំងអស់នៅក្នុងព្រំដែនផលិតកម្មប្រព័ន្ធគណនេយ្យជាតិ(SNA) រួមទាំងការផលិតសម្រាប់ប្រាក់បៀវត្សរ៍ ប្រាក់ចំណេញ ឬផលប្រយោជន៍គ្រួសារ និងការផលិតសម្រាប់ការប្រើប្រាស់ចុងក្រោយ ផ្ទាល់ខ្លួន។ ទោះជាយ៉ាងណាក៏ដោយ និយមន័យនៃភាពមានការងាររួមបញ្ចូលតែការងារដែលធ្វើឡើងសម្រាប់អ្នកដទៃទទួលបានប្រាក់បៀវត្សរ៍ ឬប្រាក់ចំណេញប៉ុណ្ណោះ។ ការផលិតសម្រាប់ការប្រើប្រាស់ចុងក្រោយផ្ទាល់ខ្លួនមិនត្រូវបានចាត់ទុកថាជាភាពមានការងារធ្វើឡើយ។

## និយមន័យ

### អ្នកដែលមានការងារធ្វើ

អ្នកដែលមានការងារធ្វើគឺជាមនុស្សទាំងអស់ដែលមានអាយុធ្វើការ ក្នុងអំឡុងពេលយោងខ្លី (ប្រាំពីរថ្ងៃ ឬមួយសប្តាហ៍) បានចូលរួមក្នុងសកម្មភាពណាមួយដើម្បីផលិតទំនិញ ឬផ្តល់សេវាកម្មជាថ្នូរនឹងប្រាក់ឈ្នួល ឬដើម្បីបង្កើតប្រាក់ចំណេញ។

### ពួកគេរួមមាន៖

អ្នកដែលមានការងារធ្វើ "នៅកន្លែងធ្វើការ" ពោលគឺអ្នកដែលមានការងារធ្វើយ៉ាងហោចណាស់មួយម៉ោងឡើងទៅ។ អ្នកដែលមានការងារធ្វើ "មិននៅកន្លែងធ្វើការ" ដោយសារតែអវត្តមានបណ្តោះអាសន្នពីការងារ ឬការរៀបចំពេលវេលាធ្វើការ (ដូចជាការងារតាមវេន ម៉ោងធ្វើការបត់បែនតាមជាក់ស្តែង និងការឈប់សម្រាកសំណងដោយធ្វើការបន្ថែមម៉ោង)។

"សម្រាប់ប្រាក់ឈ្នួល ឬប្រាក់ចំណេញ" សំដៅទៅលើការងារដែលធ្វើឡើងដោយរំពឹងថានឹងទទួលបានប្រាក់បំណាច់ក្នុងទម្រង់ជាប្រាក់ឈ្នួល ឬប្រាក់ខែសម្រាប់ពេលវេលាធ្វើការ ឬការងារដែលបានធ្វើ ឬក្នុងទម្រង់ជាប្រាក់ចំណេញពីការលក់ ឬការដោះដូរទំនិញ និងសេវាកម្ម។ នេះរួមបញ្ចូលទាំងប្រាក់បំណាច់ជាសាច់ប្រាក់ ឬជាវត្ថុ មិនថាបង់ដោយផ្ទាល់ទៅអ្នកដែលកំពុងធ្វើការ ឬដោយប្រយោលទៅគ្រួសារ ឬសមាជិកគ្រួសារ (ដូចដែលអាចកើតឡើងនៅក្នុងអាជីវកម្មគ្រួសារ)។ ភាពខុសគ្នារវាងការងារ និងការផលិតទំនិញប្រើប្រាស់ដោយខ្លួនឯងគឺផ្អែកលើគោលដៅសំខាន់នៃការផលិត។ ការផលិតទំនិញដែលភាគច្រើនមានបំណងលក់ ឬដោះដូរត្រូវបានរួមបញ្ចូលនៅក្នុងការងារ។

ប្រភព៖ សេចក្តីសម្រេចទី I ទាក់ទងនឹងស្ថិតិការងារ ភាពមានការងារធ្វើ និងការប្រើប្រាស់កម្លាំងពលកម្មមិនគ្រប់គ្រាន់ ICLS លើកទី ១៩ (២០១៣)។

ខាងក្រោមនេះជានិយមន័យនៃទស្សនាទានដែលបានផ្តល់ដោយសន្និសីទអន្តរជាតិនៃអ្នកស្ថិតិកម្លាំងពលកម្ម (ICLS) លើកទី ១៩ ។

"**ប្រជាជនក្នុងអាយុធ្វើការ**" សំដៅលើមនុស្សទាំងអស់មានអាយុ១៥ ឆ្នាំឡើង។ ប្រជាជនក្នុងអាយុធ្វើការរួមមានអ្នក នៅក្នុងកម្លាំងពលកម្ម (អ្នកមានការងារធ្វើ ឬអ្នកគ្មានការងារធ្វើ) ក៏ដូចជាអ្នកនៅក្រៅកម្លាំងពលកម្ម។

បានចូលរួមក្នុងសកម្មភាពណាមួយ ដើម្បីផលិតទំនិញ ឬផ្តល់សេវាកម្មប្តូរយកប្រាក់ឈ្នួល ឬដើម្បីរក

ចំណោញ។ពួកគេ រួមមានអ្នកមានការងារធ្វើ "នៅកន្លែងការងារ" (ពោលគឺអ្នកដែលបានធ្វើការយ៉ាងហោចណាស់មួយម៉ោង) និងអ្នកមានការងារធ្វើ "មិននៅកន្លែងការងារ" ដោយសារតែអវត្តមានជាបណ្ដោះអាសន្នពីការងារ ឬដោយសារការរៀបចំពេលវេលាធ្វើការ (ដូចជា ការងារប្ដូរវេន ការបញ្ចប់ការងារតាមពេលវេលាខុសៗគ្នា និងការឈប់សម្រាកសំណងដោយធ្វើការបន្ថែមម៉ោង)។

អ្នកមានការងារធ្វើ រួមមាន៖

- ❖ អ្នកធ្វើការដើម្បីប្រាក់ឈ្នួល ឬប្រាក់ចំណោញ ដែលកំពុងចូលរួមក្នុងសកម្មភាពបណ្ដុះបណ្ដាល ឬបង្កើនជំនាញដែលតម្រូវដោយការងារ ឬសម្រាប់ការងារផ្សេងទៀតនៅក្នុងអង្គភាពសេដ្ឋកិច្ចតែមួយ (អ្នកទាំងនេះត្រូវបានចាត់ទុកថាជាអ្នកមានការងារធ្វើ និង "នៅកន្លែងការងារ" ស្របតាមស្តង់ដារស្ថិតិអន្តរជាតិស្តីពីម៉ោងធ្វើការ)។
- ❖ អ្នករៀនធ្វើការ អ្នកហាត់ការ ឬអ្នកហាត់រៀន ដែលធ្វើការដើម្បីប្រាក់ឈ្នួលជាសាច់ប្រាក់ ឬជារបស់។
- ❖ អ្នកធ្វើការដើម្បីប្រាក់ឈ្នួល ឬចំណោញ តាមរយៈកម្មវិធីលើកកម្ពស់ការងារ។
- ❖ អ្នកធ្វើការនៅក្នុងអង្គភាពសេដ្ឋកិច្ចខ្លួនឯង ដើម្បីផលិតទំនិញក្នុងគោលបំណងចម្បងសម្រាប់លក់ ឬដោះដូរ ទោះបីផ្នែកខ្លះនៃផលិតផលត្រូវបានប្រើប្រាស់ដោយក្រុមគ្រួសារ ឬគ្រួសារក៏ដោយ។
- ❖ អ្នកមានការងារតាមរដូវក្នុងពេលបិទរដូវ បើពួកគេនៅបន្តបំពេញភារកិច្ច និងកិច្ចការមួយចំនួននៃការងារ ដោយ មិនរាប់បញ្ចូលការបំពេញកាតព្វកិច្ចផ្លូវច្បាប់ ឬរដ្ឋបាល (ឧទាហរណ៍ បង់ពន្ធ) និងមិនគិតការទទួលបានអត្ថប្រយោជន៍
- ❖ អ្នកធ្វើការដើម្បីប្រាក់ឈ្នួល ឬចំណោញ ដែលត្រូវបង់ឱ្យក្រុមគ្រួសារ ឬគ្រួសារ
    - a) នៅក្នុងទីផ្សារប្រតិបត្តិការដោយសមាជិកគ្រួសាររស់នៅក្នុងគ្រួសារតែមួយ ឬក្នុងគ្រួសារផ្សេងទៀត។
    - b) បំពេញភារកិច្ច ឬកិច្ចការជានិយោជិតរបស់សមាជិកគ្រួសារនៅក្នុងគ្រួសារតែមួយ ឬក្នុងគ្រួសារផ្សេងទៀត។
- ❖ ជាសមាជិកទៀងទាត់នៃកងកម្លាំងប្រដាប់អាវុធ និងអ្នកមានមុខងារជាយោធាឬជាស៊ីវិលជំនួស ដែលបំពេញ ការងារនេះដើម្បីប្រាក់ឈ្នួលជាសាច់ប្រាក់ ឬជារបស់។

អង្កេតកម្លាំងពលកម្ម បានចាត់ថ្នាក់ អ្នកនៅកន្លែងការងារ ជាអ្នកមានការងារធ្វើ កាលណាគាត់ ឬនាងបានធ្វើការ យ៉ាងហោចណាស់មួយម៉ោងក្នុងសប្តាហ៍យោង។

"**អ្នកគ្មានការងារធ្វើ**" សំដៅលើមនុស្សក្នុងអាយុធ្វើការងារទាំងអស់ ដែលមិនបានធ្វើការងារក្នុងរយៈពេលសប្តាហ៍យោង ប៉ុន្តែបានអនុវត្តសកម្មភាពស្វែងរកការងារធ្វើក្នុងរយៈពេលថ្មីៗជាក់លាក់ណាមួយ និងបច្ចុប្បន្ន អាចទទួលយកការងារធ្វើបាន នៅពេលផ្តល់ឱកាសការងារឱ្យគាត់។

**អ្នកគ្មានការងារធ្វើ រួមមាន៖**

១. "មិនធ្វើការងារ" ត្រូវបានវាយតម្លៃដោយយោងទៅលើរយៈពេលយោងខ្លី សម្រាប់ការវាស់វែងការងារ

២. "បានស្វែងរកការងារធ្វើ" សំដៅលើសកម្មភាពណាមួយដែលបានអនុវត្ត ក្នុងរយៈពេលថ្មីៗ ជាក់លាក់

ណាមួយ រួមមាន ៤ សប្តាហ៍ ឬមួយខែមុន សម្រាប់គោលបំណងរកការងារធ្វើ ឬបង្កើតអាជីវកម្ម ឬធ្វើកសិកម្ម។ ផ្នែកនេះក៏រាប់បញ្ចូលផងដែរនូវការងារក្រៅម៉ោង ការងារក្រៅប្រព័ន្ធ ការងារបណ្តោះអាសន្ន និងការងារតាមរដូវ ឬម្តងម្កាល ក្នុងប្រទេស ឬក្រៅប្រទេស។ ឧទាហរណ៍នៃសកម្មភាពទាំងនេះគឺ៖

២.១ ការរៀបចំធនធានហិរញ្ញវត្ថុ ដាក់ពាក្យសុំការអនុញ្ញាត អាជ្ញាប័ណ្ណ

២.២ ស្វែងរកដី ទីក្នុងបរិវេណ ម៉ាស៊ីន សម្ភារៈផ្គត់ផ្គង់ ឧបករណ៍កសិកម្ម

២.៣ ស្វែងរកជំនួយពីមិត្តភក្តិ សាច់ញាតិ ឬប្រភេទអន្តរការីផ្សេងទៀត

២.៤ ចុះឈ្មោះជាមួយ ឬទាក់ទងសេវាកម្មការងារសាធារណៈ ឬឯកជន

២.៥ ដាក់ពាក្យសុំដោយផ្ទាល់ដល់និយោជក ពិនិត្យកន្លែងធ្វើការ កសិដ្ឋាន ច្រកទ្វាររោងចក្រ ទីផ្សារ ឬ កន្លែងជួបប្រជុំផ្សេងទៀត

២.៦ ដាក់ពាក្យ ឬព័ត៌មានតាមកាសែត ឬការផ្សព្វផ្សាយការងារតាមអនឡាញ

២.៧ ដាក់ពាក្យ ឬធ្វើបច្ចុប្បន្នកម្មប្រវត្តិ អំពីវិជ្ជាជីវៈ ឬគេហទំព័របណ្តាញសង្គមតាមអនឡាន

៣. ចំណុចដែលសហគ្រាសចាប់ផ្តើមគួរតែត្រូវបានប្រើ ដើម្បីដឹងនូវភាពផ្សេងគ្នារវាងសកម្មភាពស្វែងរកក្នុងគោលដៅបង្កើតអាជីវកម្ម និងសកម្មភាពការងាររបស់ខ្លួនឯងផ្ទាល់ ។ ដែលបង្ហាញភស្តុតាងតាមការចុះឈ្មោះសហគ្រាសដើម្បីប្រតិបត្តិការ ឬនៅពេលមានធនធានហិរញ្ញវត្ថុមាន ហេដ្ឋារចនាសម្ព័ន្ធ ឬសម្ភារៈចាំបាច់នៅនឹងកន្លែង ឬបានទទួលអតិថិជន ឬការបញ្ជាទិញដំបូង អាស្រ័យលើស្ថានភាពជាក់ស្តែង។

៤."បច្ចុប្បន្នអាចធ្វើការបាន" ចង់ដឹងពីការត្រៀមខ្លួនជាស្រេច ដើម្បីចាប់ផ្តើមការងារក្នុងពេលបច្ចុប្បន្ន ដែលវាយតម្លៃដោយរយៈពេលយោងខ្លីមួយប្រើសម្រាប់វាស់វែងការងារ៖ អាស្រ័យលើកាលៈទេសៈជាតិ យោងតាមពេលវេលាអាចត្រូវបានពង្រីកដើម្បីរួមបញ្ចូលរយៈពេលខ្លីជាបន្តបន្ទាប់ ដែលមិនលើសពី ពីរសប្តាហ៍ ដើម្បីធានាបាននូវការគ្របដណ្តប់គ្រប់គ្រាន់នៃស្ថានភាពអត់ការងារធ្វើក្នុងចំណោមក្រុមប្រជាជនផ្សេងៗគ្នា។

**ភាពគ្មានការងារធ្វើរួមមាន ៖**

៤.១. អ្នកចាប់ផ្តើមនាពេលអនាគតបានកំណត់ជាមនុស្ស "មិនមានការងារធ្វើ" និង "បច្ចុប្បន្នអាចធ្វើការបាន" ដែលមិនបាន "ស្វែងរកការងារធ្វើ" ពីព្រោះពួកគេបានរៀបចំរួចហើយ ដើម្បីចាប់ផ្តើមការងារក្នុងរយៈពេលយោងខ្លីមួយ ដោយកំណត់លើរយៈពេលរង់ចាំជាទូទៅសម្រាប់ការចាប់ផ្តើមការងារថ្មីនៅក្នុងបរិបទប្រទេស ប៉ុន្តែជាទូទៅមិនច្រើនជាងបីខែ។

៤.២ អ្នកចូលរួមក្នុងការបណ្តុះបណ្តាលជំនាញ ឬគម្រោងបណ្តុះបណ្តាលឡើងវិញក្នុងកម្មវិធីលើកកម្ពស់ការងារ ដោយផ្អែកលើមូលដ្ឋាន "មិនមានការងារធ្វើ" និងមិន "បច្ចុប្បន្នអាចធ្វើការបាន" និងមិនបាន "ស្វែងរកការងារធ្វើ" ពីព្រោះពួក គេមានការងារដែលផ្តល់ឱ្យដែលត្រូវចាប់ផ្តើមក្នុងរយៈពេលបន្តបន្ទាប់ខ្លីមួយ ជាទូទៅមិនច្រើនជាងបីខែ។

៤.៣ អ្នក "មិនធ្វើការងារ" ដែលបានអនុវត្តសកម្មភាពចំណាកស្រុកទៅបរទេស ដើម្បីធ្វើការយក ប្រាក់ឈ្នួល ឬចំណេញ ប៉ុន្តែពួកគេនៅរង់ចាំឱកាសចាកចេញ។

**"កម្លាំងពលកម្ម"** សំដៅលើមនុស្សក្នុងអាយុធ្វើការទាំងអស់ ដែលចូលរួមចំណែក ឬអាចចូលរួមចំណែកក្នុងការ ផលិត ទំនិញ និងសេវាកម្មនៅក្នុងប្រទេស ដើម្បីយកប្រាក់ឈ្នួល ឬទទួលបានប្រាក់ចំណេញ។ ពួកគេអាចជា អ្នកមានការងារធ្វើ ឬគ្មានការងារធ្វើ ក្នុងរយៈពេលមួយសប្តាហ៍យោងមុនអង្កេត។ អ្នកនៅក្រៅកម្លាំងពលកម្ម សំដៅលើមនុស្សក្នុងអាយុធ្វើការទាំងអស់ ដែលអត់ធ្វើការ ឬមិនធ្វើការងារក្នុង រយៈពេលយោងជាក់លាក់ ដោយសារៈ

១. ជាប់រៀននៅគ្រឹះស្ថានសិក្សាជាសិស្ស

២. ជាប់ភារកិច្ចគ្រួសារ ថែទាំសមាជិកគ្រួសារ ឬក្នុងសកម្មភាពផ្សេងៗជាមេផ្ទះ

៣. ចូលនិវត្តន៍ ឬចាស់ជរា

៤. មូលហេតុផ្សេងទៀត ដូចជាភាពទន់ខ្សោយ ឬពិការភាព ដែលអាចបញ្ជាក់បាន ឬ

៥. ជឿថាគ្មានការងារធ្វើ មិនចង់ធ្វើការ ឬមិនមានការចាប់ផ្តើមការងារក្នុងរយៈពេលខ្លី។

**"ស្ថានភាពភាពមានការងារធ្វើ"** សំដៅលើប្រភេទកិច្ចសន្យាការងារជាក់ស្តែង ឬមិនជាក់លាក់នៃការងាររវាង មនុស្ស និងមនុស្ស ឬអង្គការផ្សេងទៀត។ ស្ថានភាពរបស់បុគ្គលសកម្មសេដ្ឋកិច្ចត្រូវគោរពតាមការងាររបស់ ខ្លួន (ពោលទោះបីគាត់ជានិយោជក អ្នកធ្វើការដោយទុនផ្ទាល់ខ្លួន និយោជិត ឬអ្នកធ្វើការឱ្យគ្រួសារមិនយក ប្រាក់ឈ្នួល) ត្រូវបានកំណត់ដូចខាងក្រោមៈ

**និយោជិត** គឺជាមនុស្សម្នាក់ ដែលធ្វើការឱ្យនិយោជកសាធារណៈ ឬឯកជន ហើយទទួលសំណងជា ប្រាក់ឈ្នួល បៀវត្សរ៍ កម្រៃជើងសារ ប្រាក់ទឹកតែ ប្រាក់តាមអត្រាការងារ ឬឱ្យជារបស់។ និយោជិតត្រូវបាន បែងចែកជាៈ

១. និយោជិតមានប្រាក់ឈ្នួលទៀងទាត់ ជាមួយប្រាក់ឈ្នួលថេរ

២. និយោជិតមានប្រាក់ឈ្នួលមិនទៀងទាត់/បណ្តោះអាសន្ន

៣. អ្នកធ្វើការមានប្រាក់ឈ្នួលតាមអត្រាការងារ ឬតាមការងារដែលបានបំពេញ និង

៤. អ្នករៀនធ្វើការមានប្រាក់ឈ្នួលមិនមែនគ្រួសារ។

**និយោជក** គឺជាមនុស្សម្នាក់ដែលក្នុងរយៈពេលយោងបានធ្វើការដោយទុនផ្ទាល់ខ្លួនរបស់គាត់ ឬ ជាមួយដៃគូម្នាក់ ឬច្រើននាក់នៅក្នុង "ការងារធ្វើដោយខ្លួនឯង" ជាមួយនិយោជិតម្នាក់ ឬច្រើននាក់ចូលរួម ការងារជាប្រចាំជាមូលដ្ឋាន។

**អ្នកធ្វើការដោយទុនផ្ទាល់ខ្លួន** គឺជាមនុស្សម្នាក់ ដែលក្នុងរយៈពេលយោង បានធ្វើការដោយទុនផ្ទាល់ ខ្លួនរបស់ពួកគេជាមួយដៃគូម្នាក់ ឬច្រើននាក់នៅក្នុង "ការងារធ្វើដោយខ្លួនឯង" ដោយគ្មាននិយោជិតណាមួយ ចូលរួមការងារជាប្រចាំ ប៉ុន្តែក៏អាចជាមួយអ្នកធ្វើការឱ្យគ្រួសារមិនយកប្រាក់ឈ្នួលម្នាក់ ឬច្រើននាក់ចូលរួម ការងារម្តងម្កាលជាមូលដ្ឋានផងដែរ។ អ្នកធ្វើការប្រភេទនេះ រួមមានម្ចាស់អ្នកដាំដុះ អ្នកដាំដំណាំចែកគ្នា និង

អ្នកដាំដុះ កិច្ចសន្យាធ្វើការដើម្បីចំណេញ។

**អ្នកធ្វើការឱ្យគ្រួសារមិនយកប្រាក់ឈ្នួល** គឺជាមនុស្សម្នាក់ដែលធ្វើការដោយគ្មានប្រាក់ឈ្នួលជាសាច់ប្រាក់ ឬជារបស់ ក្នុងសហគ្រាសមួយដែលប្រតិបត្តិការដោយសមាជិកក្រុមគ្រួសាររបស់គាត់ ឬដោយសមាជិកគ្រួសារមួយ។

**"ផ្សេងទៀត"** រួមមានសមាជិកនៃសហករណ៍អ្នកផលិត ។ល។

**វិស័យក្នុងប្រព័ន្ធ** រួមមានអ្នកធ្វើការទាំងអស់នៅក្នុងរដ្ឋាភិបាល ឬសហគ្រាសរដ្ឋ ឬអង្គការអន្តរជាតិ និងក្នុងស្ថានទូតបរទេស ក៏ដូចជាក្រុមហ៊ុនមានដែនកំណត់ភាពជាដៃគូពាណិជ្ជកម្ម ភាពជាដៃគូមានកំណត់ និងសហគ្រាសបានចុះបញ្ជីជាមួយអាជ្ញាធរពាក់ព័ន្ធ និង/ឬ មានបញ្ជីគណនេយ្យពេញលេញសម្រាប់រាយការណ៍ទៅរដ្ឋាភិបាល រួមមាន តារាងតុល្យភាពត្រឹមត្រូវមួយនៃទ្រព្យសម្បត្តិ ចំណូល និងចំណាយ។

**វិស័យក្រៅប្រព័ន្ធ** រួមមានអ្នកធ្វើការទាំងអស់នៅក្នុងសហគ្រាសដែលមិនបានចុះបញ្ជីជាមួយអាជ្ញាធរពាក់ព័ន្ធ និងគ្មានបញ្ជីគណនេយ្យពេញលេញ។ វិស័យក្រៅប្រព័ន្ធមិនរាប់បញ្ចូលគ្រួសារដែលផលិតសម្រាប់តែការប្រើប្រាស់ចុងក្រោយ ខ្លួនឯង កសិកម្មសម្រាប់ចិញ្ចឹមជីវិត ការសាងសង់លំនៅដ្ឋានខ្លួនឯង។ល។

**គ្រួសារ** រួមមានអ្នកធ្វើការទាំងអស់នៅក្នុងសហគ្រាសគ្រួសារដែលផលិតទំនិញ និងសេវាកម្មសម្រាប់តែការប្រើប្រាស់ ចុងក្រោយខ្លួនឯង។ គ្រួសារ រួមមានអ្នកធ្វើកិច្ចការផ្ទះមានប្រាក់ឈ្នួលជួលដោយគ្រួសារ។ បុគ្គលដែលបានចាត់ចូលក្នុង ផ្នែក៩៧ នៃចំណាត់ថ្នាក់សកម្មភាពសេដ្ឋកិច្ចតាមស្តង់ដារអន្តរជាតិ ជំនាន់៤ (ISIC) និងផ្នែក៦៣ នៃចំណាត់ថ្នាក់មុខរបរតាមស្តង់ដារអន្តរជាតិ ឆ្នាំ២០០៨ (ISCO-08) ត្រូវបានរាប់បញ្ចូលក្នុងវិស័យនេះ។

**ការងារក្នុងប្រព័ន្ធ** រួមមានអ្នកដែលធ្វើការនៅក្នុងអាជីវកម្មផ្ទាល់ខ្លួនរបស់ពួកគេក្នុងវិស័យក្នុងប្រព័ន្ធ ឬអ្នកធ្វើការជានិយោជិត អ្នករៀនធ្វើការ អ្នកហាត់ការរបស់និយោជកដែលចូលរួមវិភាគទានដល់របបសោធននិវត្តន៍ សុខភាព និង/ឬ មូលនិធិធានារ៉ាប់រងភាពគ្មានការងារធ្វើ ឬផ្តល់ប្រាក់ឈ្នួលឈប់សម្រាកប្រចាំឆ្នាំ និងឈប់សម្រាកឈឺក្នុងករណីមាន ជំងឺ ឬរបួស។

**ការងារក្រៅប្រព័ន្ធ** រួមមាននិយោជក និងអ្នកធ្វើការដោយទុនផ្ទាល់ខ្លួនដែលធ្វើការក្នុងសហគ្រាសវិស័យក្រៅប្រព័ន្ធផ្ទាល់ខ្លួនរបស់ពួកគេ អ្នកធ្វើការឱ្យគ្រួសារមិនយកប្រាក់ឈ្នួល និងនិយោជិតនិងអ្នករៀនធ្វើការនិងអ្នកហាត់ការដែលគ្មានប្រាក់ឈ្នួលពេលឈប់សម្រាកប្រចាំឆ្នាំ ឬអត្ថប្រយោជន៍ឈប់សម្រាកឈឺ និងដែលនិយោជករបស់ពួកគេមិនបានចូលរួមវិភាគទានដល់របបសន្តិសុខសង្គមរបស់ពួកគេ។ ចំនួនមនុស្សក្នុងផ្នែកនេះ ជាផលសងរវាងចំនួនមនុស្សទាំងអស់ដែលបានធ្វើការ និងចំនួនមនុស្សក្នុងការងារក្នុងប្រព័ន្ធ។

**ភាពមានការងារធ្វើមិនគ្រប់គ្រាន់ទាក់ទងនឹងពេលវេលា** សំដៅលើមនុស្សទាំងអស់ក្នុងការងារ ដែលក្នុងរយៈលយោងខ្លី ចង់ធ្វើការម៉ោងបន្ថែមដោយសារចំនួនម៉ោងធ្វើការក្នុងការងារទាំងអស់របស់គាត់តិចជាងកម្រិតម៉ោងដែលបានកំណត់ (៤០ ម៉ោងសម្រាប់កម្ពុជា)ហើយគាត់អាចធ្វើការម៉ោងបន្ថែមបានបើផ្តល់ឱកាស

ការងារមានប្រាក់ ឈ្នួលបន្ថែមទៀត ដែល៖

១. "ម៉ោងធ្វើការ" សំដៅលើចំនួនម៉ោងជាក់ស្តែងបានធ្វើការ ឬចំនួនម៉ោងធម្មតាបានធ្វើការអាស្រ័យ លើគោលដៅនៃការវាស់វែង(ស្ថានភាពរយៈពេលខ្លី ឬវែង)និងអនុលោមតាមស្តង់ដារស្ថិតិអន្តរជាតិ ស្តីពីប្រធានបទ

២."ម៉ោងបន្ថែម" អាចជាម៉ោងលើសនៅក្នុងការងារតែមួយ នៅក្នុងមួយឬច្រើនការងារបន្ថែម ឬនៅក្នុង មួយឬច្រើនការងារជំនួស

៣."កម្រិតកំណត់ចំនួនម៉ោង" គឺផ្អែកលើព្រំដែនរវាងការងារម៉ោងពេញ និងម៉ោងក្រៅ លើតម្លៃមេដ្យាន ឬម៉ូតនៃ ចំនួនម៉ោងធ្វើការធម្មតារបស់អ្នកធ្វើការងារទាំងអស់ ឬលើបទដ្ឋានចំនួនម៉ោងធ្វើការដូចចែង ក្នុងច្បាប់ពាក់ព័ន្ធ ឬការអនុវត្តថ្នាក់ជាតិ និងការកំណត់សម្រាប់ក្រុមអ្នកធ្វើការជាក់លាក់ និង

៤."អាចធ្វើការងារម៉ោងបន្ថែម" ត្រូវបានកំណត់ក្នុងរយៈពេលយោងខ្លីមួយដែលឆ្លុះបញ្ចាំងពីរយៈពេល តាមតម្រូវការនៅក្នុងបរិបទប្រទេសរវាងការចាកចេញពីការងារមួយនិងការចាប់ផ្តើមការងារផ្សេងទៀត

**កម្លាំងពលកម្មសក្តានុពល** (អ្នកចូលរួម) សំដៅលើមនុស្សក្នុងអាយុធ្វើការទាំងអស់ ដែលក្នុងរយៈពេលយោង ខ្លី មិនបានធ្វើការងារ ឬគ្មានការងារធ្វើហើយ៖

១. ធ្វើសកម្មភាព "ស្វែងរកការងារធ្វើ" ហើយមិន "បច្ចុប្បន្នអាចធ្វើការបាន" ប៉ុន្តែនឹងអាចធ្វើបានក្នុង រយៈពេលបន្តបន្ទាប់ខ្លីមួយទៅតាមកាលៈទេសៈប្រទេស(ពោលគឺអ្នកស្វែងរកការងារតែមិនអាចធ្វើបាន) ឬ

២. មិនធ្វើសកម្មភាព "ស្វែងរកការងារធ្វើ ប៉ុន្តែចង់ធ្វើការ និង "បច្ចុប្បន្នអាចធ្វើការបាន" (ពោលគឺ អ្នក ស្វែងរក ការងារមានសក្តានុពលដែលអាចធ្វើបាន)។

# ជំពូក ២
# វិធីសាស្ត្រអង្កេត

ជំពូកនេះពិពណ៌នាអំពីវិធីសាស្ត្រដែលប្រើក្នុងការអង្កេតកម្លាំងពលកម្ម ឆ្នាំ២០២៥។ វាត្រូវបានពន្យល់អំពីវិសាលភាព និងការគ្របដណ្តប់នៃការអង្កេត ការរៀបចំជ្រើសរើសសំណាកគំរូ ប្រតិបត្តិការនៅមូលដ្ឋាន និងប្រព្រឹត្តកម្មទិន្នន័យ។ ការអង្កេតនេះត្រូវបានអនុវត្តន៍ក្នុងរយៈពេល ២៥ថ្ងៃ ត្រូវចាប់ផ្តើមពីថ្ងៃទី២៥ខែតុលា ដល់ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៥។

## ២.១. ទំហំ និងវិសាលភាព

ការអង្កេតកម្លាំងពលកម្ម ឆ្នាំ២០២៥ ត្រូវបានដំណើរការ ដើម្បីផ្តល់នូវការប៉ាន់ស្មានដែលអាចមានភាពជឿជាក់បាននូវចំនួនកម្លាំងពលកម្មកម្រិតថ្នាក់ជាតិនៅកម្ពុជា ទីប្រជុំជន និងជនបទ។ ការអង្កេតបានផ្តោតលើចំនួនប្រជាជនដែលមានអាយុធ្វើការ ដែលត្រូវបានកំណត់ថាជាអ្នកដែលមានអាយុ ១៥ ឆ្នាំឡើងទៅ ដែលកំពុងរស់នៅក្នុងគ្រួសារគំរូ។ អង្កេតបានរៀបចំឡើងដើម្បីទទួលបានការប៉ាន់ស្មានថ្នាក់ជាតិនៃអថេរជាច្រើន ជាពិសេសទាក់ទងនឹងសកម្មភាពសេដ្ឋកិច្ច និងមិនមែនសេដ្ឋកិច្ចរបស់ប្រជាជនកម្ពុជានៅក្នុងកម្លាំងពលកម្ម។

ការអង្កេតនេះពាក់ព័ន្ធនឹងគំរូចំនួន ៩.៩១២ គ្រួសារ ពី ៧០៨ ភូមិសំណាកគំរូ ដោយបែងចែកនៅ២៥ រាជធានីភ្នំពេញ ខេត្ត។ ការអង្កេតនេះគ្របដណ្តប់ទាំងតំបន់ទីប្រជុំជន និងទីជនបទ និងគ្រប់ប្រភេទទាំងអស់នៃគ្រួសារធម្មតា រួមទាំងគ្រួសារដែលមានមនុស្សម្នាក់ផងដែរ។

## ២.២. ការរៀបចំបញ្ជីសំណួរ

បញ្ជីសំណួរអង្កេតកម្លាំងពលកម្ម ឆ្នាំ២០២៥ ត្រូវបានបង្កើតឡើងដោយផ្អែកលើ "សេចក្តីសម្រេចស្តីពីស្ថិតិការងារ ភាពមានការងារធ្វើ និងការប្រើប្រាស់កម្លាំងពលកម្មមិនគ្រប់គ្រាន់" ដែលត្រូវបានអនុម័តដោយសន្និសីទអន្តរជាតិលើកទី១៩ ទី២០ និងទី២១ នៃអ្នកស្ថិតិការងារ (ICLS)។ នៅឆ្នាំ២០២៤ កម្រងសំណួរបានបញ្ចូលម៉ូឌុលចំនួនបីពីការអង្កេតកម្លាំងពលកម្មគំរូរបស់ ILO ដែលត្រូវបានរៀបចំឡើងសម្រាប់ការប្រមូលទិន្នន័យការសម្ភាសន៍ផ្ទាល់ខ្លួនដោយមានជំនួយពីកុំព្យូទ័រ (CAPI) ដែលមាន ១៧ ផ្នែកដូចខាងក្រោម៖

១. ផ្នែក A. បញ្ជីសមាជិកគ្រួសារ និងលក្ខណៈប្រជាសាស្ត្រ (DEM)
២. ផ្នែក B. ស្ថានភាពចំណាកស្រុក (MIG)
៣. ផ្នែក C. ស្ថានភាពពិការភាព (DIF)
៤. ផ្នែក D. ប្រភពរបស់គ្រួសារក្នុងការចិញ្ចឹមជីវិត (HLL)
៥. ផ្នែក E. ស្ថានភាពអ្នកផ្តល់ចម្លើយ (RSP)
៦. ផ្នែក F. ភាពមានការងារធ្វើ (ATW)
៧. ផ្នែក G. អវត្តមានពីការងារបណ្តោះអាសន្ន (ABS)

៨. ផ្នែក H. ការងារកសិកម្ម និងការលក់ផលិតផលកសិកម្ម (AGF)
៩. ផ្នែក I. ការងារចម្បង - ចរិតលក្ខណៈនៃការងារចម្បង (MJJ)
១០. ផ្នែក J. ការងារទីពីរ - ចរិតលក្ខណៈនៃការងារ (SJJ)
១១. ផ្នែក K. ម៉ោងធ្វើការក្នុងការងារ (WKT)
១២. ផ្នែក L. ការស្វែងរកការងារ និងភាពអាចមានលទ្ធភាពធ្វើការ (SRH)
១៣. ផ្នែក M. ការដាំដំណាំសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន (OPC)
១៤. ផ្នែក N. ផលិតផលសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួននៃម្ហូបអាហារមិនមែនចេញពីផលដំណាំ (OPC)
១៥. ផ្នែក O. ផលិតផលសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន-សំណង់ (BLDG)
១៦. ផ្នែក P. ការងារផ្ទះដែលមិនមានប្រាក់កម្រៃ (UCW)
១៧. ផ្នែក Q. ភាពមិនស៊ីគ្នានៃជំនាញ និងគុណវុឌ្ឍិ (SQM)

## ២.៣. វិធីសាស្ត្រជ្រើសរើសសំណាកគំរូ

ដើម្បីសម្រេចបាននូវគោលដៅនៃការផ្តល់ការប៉ាន់ស្មានដែលអាចទុកចិត្តបាននៅកម្រិតជាតិ ទីប្រជុំជន និងជនបទ អង្កេតកម្លាំងពលកម្ម ឆ្នាំ២០២៥ បានប្រើវិធីសាស្ត្រជ្រើសរើសគំរូតាមដំណាក់កាលបីដំណាក់កាល៖ (i) ការជ្រើសរើសភូមិ (ii) ការជ្រើសរើសមណ្ឌលសម្ភាសន៍មួយ សម្រាប់ភូមិសំណាកគំរូនីមួយៗនិង (iii) ការជ្រើសរើសគ្រួសារសម្រាប់មណ្ឌលសម្ភាសន៍នីមួយៗសំណាកគំរូនីមួយៗ។ តំបន់ទីប្រជុំជន និងតំបន់ជនបទត្រូវបានបម្រើជាអថេរតាមផ្នែក។ ឯកតាសំណាកគំរូបឋម (PSU) គឺជាភូមិ។ ភូមិត្រូវបានជ្រើសជាសំណាកគំរូតាមប្រូបាប៊ីលីតេសមាមាត្រទៅនឹងចំនួនគ្រួសារដែលបានចុះបញ្ជីនៅក្នុងក្របខ័ណ្ឌ។ មណ្ឌលសម្ភាសន៍ (EA) គឺជាផ្នែកមួយនៃភូមិមួយ ហើយផ្នែកមួយនេះត្រូវបានជ្រើសរើសដោយចៃដន្យពីក្នុងភូមិនីមួយៗ ដែលជាសំណាកគំរូ។ ឯកតាជ្រើសសំណាកគំរូចុងក្រោយ គឺគ្រួសារ ជាសរុបចំនួន ១៤ គ្រួសារ ត្រូវបានជ្រើសរើសដោយចៃដន្យតាមវិធីសាស្ត្រជ្រើសសំណាកគំរូតាមប្រព័ន្ធ ពីក្នុងមណ្ឌលសម្ភាសន៍នីមួយៗ។

## ២.៤. ក្របខ័ណ្ឌជ្រើសសំណាកគំរូ

ក្របខ័ណ្ឌជ្រើសសំណាកគំរូប្រើសម្រាប់អង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥ ត្រូវបានរៀបចំដោយវិទ្យាស្ថានជាតិស្ថិតិ ដោយប្រើព័ត៌មានដែលបានប្រមូលពីជំរឿនទូទៅប្រជាជននៅកម្ពុជា ឆ្នាំ២០១៩។ ក្របខ័ណ្ឌមានចំនួន ១៤.៥១៤ ភូមិ បានបែងចែកក្នុងចំណោម ៧០៨ (PSU) ឯកតាសំណាកគំរូបឋម និង ៧០៨ មណ្ឌលសម្ភាសន៍នៅទូទាំងប្រទេស។ មុនធ្វើជំរឿនទូទៅប្រជាជននៅកម្ពុជា ឆ្នាំ២០១៩ ផែនទីព្រាងត្រូវបានរៀបចំដើម្បីកំណត់ព្រំប្រទល់នៃមណ្ឌលសម្ភាសន៍នីមួយៗ។ ផែនទីនេះក៏ត្រូវបានប្រើប្រាស់សម្រាប់អង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥ ផងដែរ។

## ២.៥. សមាមាត្រទម្ងន់សំណាកគំរូ

**ជំហានដំបូង** សមាមាត្រទម្ងន់ (weight) សម្រាប់ឯកតាសំណាកគំរូបឋមដែលបានជ្រើសរើស (i) ក្នុងតំបន់ h (ទីប្រជុំជន/ជនបទ) ត្រូវបានគណនាតាមរូបមន្តខាងក្រោម៖

$$W_{I,hi} = \frac{M_h}{n_h \cdot M_{hi}} \quad )$$

$M_h$ = ចំនួនគ្រួសារក្នុងតំបន់ (h) យោងតាមការចុះបញ្ជីភូមិ

$M_{hi}$ = ចំនួនគ្រួសារក្នុងឯកតាសំណាកគំរូបឋម (1) ក្នុងតំបន់ (h) យោងតាមការចុះបញ្ជីភូមិ

$n_h$ = ចំនួនឯកតាសំណាកគំរូបឋមដែលបានជ្រើសរើសក្នុងតំបន់ (h)

**ជំហានទីពីរ** សមាមាត្រទម្ងន់សម្រាប់គ្រួសារដែលបានជ្រើសរើស ក្នុងឯកតាសំណាកគំរូបឋមដែលបានជ្រើសរើស ត្រូវបានគណនាតាមរូបមន្តខាងក្រោម៖

$$W_{II,hi} = \frac{M^*_{hi}}{m_{hik}}$$

M = ចំនួនគ្រួសារក្នុងឯកតាសំណាកគំរូបឋម (1) នៃតំបន់ (h) នៅពេលអង្កេត

$m_{hik}$ = ចំនួន ១៤ គ្រួសារសំណាកគំរូ ក្នុងមួយឯកតាសំណាកគំរូ (1) ក្នុងតំបន់ (h)

$M^*$ ត្រូវបានកំណត់ជាពីរវិធីសាស្ត្រផ្សេងគ្នា អាស្រ័យលើស្ថានភាព។ បើឯកតាសំណាកគំរូបឋម ដែលបានជ្រើសរើសមានតែមួយមណ្ឌលសម្ភាសន៍ នោះការចុះបញ្ជីគ្រួសារនៅក្នុងមណ្ឌលសម្ភាសន៍នឹងចុះគ្រប់គ្រួសារទាំងអស់ដែលមាននៅក្នុងឯកតាសំណាកគំរូបឋម។ បើឯកតាសំណាកគំរូបឋមនៅក្នុងមណ្ឌលសម្ភាសន៍ច្រើន នោះការចុះបញ្ជីគ្រួសារត្រូវចុះបញ្ជីតែចំនួនគ្រួសារនៅក្នុងមណ្ឌលសម្ភាសន៍ដែលបានជ្រើសរើសប៉ុណ្ណោះ។ ក្នុងករណីនេះ ចំនួនគ្រួសារនៅក្នុងឯកតាសំណាកគំរូបឋម ត្រូវបានទទួលពីប្រធានភូមិ។

M ច្រើនតែខុសពី Mhi ដែលជាចំនួនគ្រួសារក្នុងឯកតាសំណាកគំរូបឋម (i) យោងតាមការចុះបញ្ជីភូមិ។ ក្នុង ករណីភាគច្រើន ភាពខុសគ្នានេះមានតិចតួចប៉ុណ្ណោះ។

**ជំហានទីបី** សមាមាត្រទម្ងន់សំណាកគំរូសម្រាប់គ្រួសារត្រូវបានគណនាដោយការរួមបញ្ចូលសមាមាត្រទម្ងន់ពីជំហានជ្រើសសំណាកគំរូទាំងពីរដំបូង។ សមាមាត្រទម្ងន់សំណាកគំរូ (គណនា weight) សម្រាប់គ្រួសារ (k) ក្នុងឯកតាសំណាកគំរូបឋម (1) ត្រូវបានគណនាតាមរូបមន្តខាងក្រោម៖

$$d_{hik} = W_{I.hi} \times W_{II.hi}$$

ដែល drak = គណនាសមាមាត្រទម្ងន់ ក្នុងតំបន់ (h) ឯកតាសំណាកគំរូបឋម (1) និងគ្រួសារ (k) ។ ជាទូទៅការកែតម្រូវសម្រាប់ការមិនឆ្លើយត្រូវបានបញ្ចូលក្នុងការគណនាសមាមាត្រទម្ងន់អង្កេត។ ជាពិសេស បើឯកតាសំណាកគំរូបឋមមានតិចជាង ១៤ គ្រួសារបានឆ្លើយ នោះសមាមាត្រទម្ងន់គួរត្រូវបានកែតម្រូវតាមកត្តា ១៤/r ដែលជាចំនួនគ្រួសារបានឆ្លើយនៅក្នុងឯកតាសំណាកគំរូបឋមដែលត្រូវពិចារណា។ ទោះជាយ៉ាងណាក៏ដោយ ដោយសារមានតែមួយករណី ដែលចំនួនគ្រួសារបានឆ្លើយមានតិចជាង ១៤ គ្រួសារ ដូច្នេះដំណើរការគណនាសមាមាត្រទម្ងន់ ត្រូវបានរំលង។

ទីបញ្ចប់ សមាមាត្រទម្ងន់គ្រួសារចុងក្រោយគឺ៖ $W_{hik} = d_{hik} \times f$

ដែល $W_{hik}$ = សមាមាត្រទម្ងន់គ្រួសារចុងក្រោយ

f = កត្តាគ្រួសារក្រិតតាមខ្នាត

**តារាង ២.១ ការបែងចែកសំណាកគំរូតាមតំបន់ទីប្រជុំជន និងជនបទ ក្នុងរាជធានីខេត្ត សម្រាប់អង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥**

| រាជធានី/ខេត្ត | ចំនួនភូមិសំណាកគំរូ | | | ចំនួនគ្រួសារសំណាកគំរូ | | |
|---|---|---|---|---|---|---|
| | ទីប្រជុំជន | ជនបទ | សរុប | ទីប្រជុំជន | ជនបទ | សរុប |
| បន្ទាយមានជ័យ | ១៤ | ២៤ | ៣៨ | ១៩៦ | ៣៣៦ | ៥៣២ |
| បាត់ដំបង | ៩ | ៣៦ | ៤៥ | ១២៦ | ៥០៤ | ៦៣០ |
| កំពង់ចាម | ៦ | ៣៦ | ៤២ | ៨៤ | ៥០៤ | ៥៨៨ |
| កំពង់ឆ្នាំង | ៦ | ២០ | ២៦ | ៨៤ | ២៨០ | ៣៦៤ |
| កំពង់ស្ពឺ | ២៤ | ១៦ | ៤០ | ៣៣៦ | ២២៤ | ៥៦០ |
| កំពង់ធំ | ៣ | ២៨ | ៣១ | ៤២ | ៣៩២ | ៤៣៤ |
| កំពត | ៣ | ២៦ | ២៩ | ៤២ | ៣៦៤ | ៤០៦ |
| កណ្ដាល | ៣៤ | ១៩ | ៥៣ | ៤៧៦ | ២៦៦ | ៧៤២ |
| កោះកុង | ៣ | ៣ | ៦ | ៤២ | ៤២ | ៨៤ |
| ក្រចេះ | ២ | ១៥ | ១៧ | ២៨ | ២១០ | ២៣៨ |
| មណ្ឌលគិរី | ១ | ២ | ៣ | ១៤ | ២៨ | ៤២ |
| ភ្នំពេញ | ១០១ | ០ | ១០១ | ១.៤១៤ | ០ | ១.៤១៤ |
| ព្រះវិហារ | ១ | ១០ | ១១ | ១៤ | ១៤០ | ១៥៤ |
| ព្រៃវែង | ៣ | ៥១ | ៥៤ | ៤២ | ៧១៤ | ៧៥៦ |
| ពោធិ៍សាត់ | ៣ | ១៦ | ១៩ | ៤២ | ២២៤ | ២៦៦ |
| រតនៈគិរី | ២ | ៩ | ១១ | ២៨ | ១២៦ | ១៥៤ |
| សៀមរាប | ១៤ | ៣១ | ៤៥ | ១៩៦ | ៤៣៤ | ៦៣០ |
| ព្រះសីហនុ | ៧ | ២ | ៩ | ៩៨ | ២៨ | ១២៦ |
| ស្ទឹងត្រែង | ២ | ៥ | ៧ | ២៨ | ៧០ | ៩៨ |
| ស្វាយរៀង | ៧ | ១៩ | ២៦ | ៩៨ | ២៦៦ | ៣៦៤ |
| តាកែវ | ១៣ | ២៩ | ៤២ | ១៨២ | ៤០៦ | ៥៨៨ |
| ឧត្តរមានជ័យ | ៤ | ៨ | ១២ | ៥៦ | ១១២ | ១៦៨ |
| កែប | ២ | ០ | ២ | ២៨ | ០ | ២៨ |
| ប៉ៃលិន | ៣ | ១ | ៤ | ៤២ | ១៤ | ៥៦ |
| ត្បូងឃ្មុំ | ៣ | ៣២ | ៣៥ | ៤២ | ៤៤៨ | ៤៩០ |
| **កម្ពុជា** | **២៧០** | **៤៣៨** | **៧០៨** | **៣.៧៨** | **៦.១៣២** | **៩.៩១២** |

## ២.៦. វិធីសាស្ត្រប៉ាន់ស្មាន

ការប៉ាន់ស្មានថ្នាក់ជាតិគ្របដណ្ដប់លើប្រទេសកម្ពុជាទាំងមូល [ទីប្រជុំជន (h=1) ឬជនបទ (h=2)]។ ដើម្បីប៉ាន់ស្មានសរុបថ្នាក់ជាតិនៃចរិតលក្ខណៈប្រជាជនជាក់លាក់X គឺជាអថេរដែលរាប់បញ្ចូលគ្រួសារ (k)ឯកតា

សំណាកគំរូបឋម (1) និងតំបន់ (h)។

ក្នុងទូទាំងប្រទេស ($\hat{X}$):

$$\hat{X} = \sum_{h=1}^{2} \sum_{i=1}^{n_{hi}} \sum_{k=1}^{m_{hik}} (X_{hik} \cdot W_{hik})$$

ក្នុងតំបន់ (h) (ទីប្រជុំជន ជនបទ) ($\hat{X}_h$):

$$\hat{X}_h = \sum_{i=1}^{n_{hi}} \sum_{k=1}^{m_{hik}} (X_{hik} \cdot W_{hik})$$

## ២.៧ គុណភាពនៃការប៉ាន់ស្មានការអង្កេតកម្លាំងពលកម្មនៅកម្ពុជា ឆ្នាំ២០២៥

ទិន្នន័យទាំងអស់ដែលប្រមូលបានពីការអង្កេត អាចប្រឈមនឹងកំហុសដែលកើតឡើងពីប្រភពផ្សេងៗ កំហុសទាំងនេះអាចកើតមាននៅគ្រប់ដំណាក់កាលនៃការអនុវត្តការអង្កេត ជាទូទៅកំហុសត្រូវបានបែងចែកជាពីរប្រភេទធំៗ គឺកំហុសសំណាកគំរូ និងកំហុសមិនមែនសំណាកគំរូ គុណភាពនៃការប៉ាន់ស្មាន ឬលទ្ធផលដែលទទួលបានពីការអង្កេតអាស្រ័យលើទាំងកំហុសសំណាកគំរូ និងកំហុសមិនមែនសំណាកគំរូ។

## ២.៨ កំហុសសំណាកគំរូ

តែងតែមានភាពមិនប្រាកដប្រជានៅក្នុងលទ្ធផល (ការប៉ាន់ស្មាន) ដែលទទួលបានពីការអង្កេតដោយសារតែមិនមែនគ្រប់គ្រួសារទាំងអស់នៅកម្ពុជាត្រូវបានជ្រើសរើសចូលក្នុងការអង្កេតនោះទេ ភាពមិនប្រាកដប្រជានេះ ត្រូវបានបង្ហាញតាមរយៈកំហុសស្តង់ដារនៃការប៉ាន់ស្មានកំហុសស្តង់ដារកាន់តែធំមានន័យថាភាពមិនប្រាកដប្រជានៃការប៉ាន់ស្មានកាន់តែខ្ពស់ ភាពមិនប្រាកដប្រជានេះក៏អាចបង្ហាញជាចន្លោះទំនុកចិត្ត ឬ «រង្វាស់កំហុស» ជុំវិញតម្លៃប៉ាន់ស្មានផងដែរ។ ចន្លោះទំនុកចិត្តកម្រិត ៩៥% នៃការប៉ាន់ស្មាន ត្រូវបានគណនាដោយដក ១,៩៦ ដងនៃកំហុសស្តង់ដារ ចេញពីតម្លៃប៉ាន់ស្មាន ដើម្បីកំណត់ជាព្រំដែនក្រោមនៃចន្លោះទំនុកចិត្ត និងបូក ១,៩៦ ដងនៃកំហុសស្តង់ដារ ទៅនឹងតម្លៃប៉ាន់ស្មាន ដើម្បីកំណត់ជាព្រំដែនលើនៃចន្លោះទំនុកចិត្ត គឺជាចន្លោះតម្លៃដែលអាចសន្មតដោយសមហេតុផលថា តម្លៃពិតប្រាកដរបស់ប្រជាជនស្ថិតនៅក្នុងចន្លោះនោះ ឧទាហរណ៍៖

**តារាង ២.២ រង្វាស់កំហុសប្រហាក់ប្រហែលនៃភាគរយ នៅកម្រិតទំនុកចិត្ត ៩៥% សម្រាប់ការស្ទង់មតិកម្លាំងពលកម្មនៅកម្ពុជា ឆ្នាំ២០២៥។**

| (p)<br>មូលដ្ឋានសកល | ១%ឬ៩៩%<br>(+/-) | ១០%ឬ ៩០%<br>(+/-) | ២០%ឬ ៨០%<br>(+/-) | ៣០%ឬ ៧០%<br>(+/-) | ៤០%ឬ ៦០%<br>(+/-) | ៥០%<br>(+/-) |
|---|---|---|---|---|---|---|
| គ្រួសារកម្ពុជា | ០,២៥ | ០,៧៦ | ១,០១ | ១,១៦ | ១,២៤ | ១,២៦ |
| ទីប្រជុំជន | ០,៤១ | ១,២៣ | ១,៦៤ | ១,៨៧ | ២,០០ | ២,០៤ |
| ជនបទ | ០,៣២ | ០,៩៦ | ១,២៨ | ១,៤៧ | ១,៥៧ | ១,៦១ |
| កម្រិតកំហុសនៃការប៉ាន់ស្មានប្រជាជន | | | | | | |
| សរុបថ្នាក់ជាតិ | ០,១២ | ០,៣៧ | ០,៥០ | ០,៥៧ | ០,៦១ | ០,៦២ |
| ប្រុស | ០,១៨ | ០,៥៣ | ០,៧១ | ០,៨២ | ០,៨៧ | ០,៨៩ |
| ស្រី | ០,១៧ | ០,៥២ | ០,៦៩ | ០,៧៩ | ០,៨៥ | ០,៨៧ |
| សរុបទីប្រជុំជន | ០,២០ | ០,៦០ | ០,៨០ | ០,៩២ | ០,៩៩ | ១,០១ |
| ប្រុស | ០,២៨ | ០,៨៤ | ១,១២ | ១,២៨ | ១,៣៧ | ១,៤០ |
| ស្រី | ០,២៩ | ០,៨៧ | ១,១៦ | ១,៣៣ | ១,៤២ | ១,៤៥ |
| សរុបជនបទ | ០,១៦ | ០,៤៧ | ០,៦៣ | ០,៧២ | ០,៧៧ | ០,៧៩ |
| ប្រុស | ០,២២ | ០,៦៨ | ០,៩០ | ១,០៣ | ១,១០ | ១,១៣ |
| ស្រី | ០,២២ | ០,៦៦ | ០,៨៨ | ១,០១ | ១,០៨ | ១,១០ |

តម្លៃ P (P-value) គឺជាប្រូបាប៊ីលីតេនៃការបដិសេធ ឬមិនបដិសេធសម្មតិកម្មសូន្យ (Null Hypothesis $H_0$)។

ឧទាហរណ៍៖ លទ្ធផលនៃការស្ទង់មតិ = ៦៥%

- រង្វាស់កំហុសប្រហាក់ប្រហែល (Margin of Error) ≈ ១,២៦%
- ដូច្នេះ ចន្លោះទំនុកចិត្តនៃការប៉ាន់ស្មាន គឺ ៦៥% ± ១,២៦% → (៦៣,៧៤% ដល់ ៦៦,២៦%)

## ២.៩ កំហុសមិនមែនសំណាកគំរូ

ភាពលម្អៀងដែលមិនមែនជាភាពលម្អៀងដោយសារសំណាកគំរូគឺភាគច្រើនពាក់ព័ន្ធនឹងការងារប្រមូលទិន្នន័យនៅទីតាំងអង្កេត និងដំណើរការកែច្នៃទិន្នន័យ ភាពលម្អៀងដែលមិនមែនជាកំហុសសំណាកគំរូ ក្នុងការអង្កេតកម្លាំងពលកម្ម កម្ពុជា ឆ្នាំ២០២៥ រួមមាន ភាពលម្អៀងដោយសារមិនមានការឆ្លើយតប ភាពលម្អៀងដោយសារការឆ្លើយតប និងភាពលម្អៀងក្នុងដំណើរការកែច្នៃទិន្នន័យ ដូចជា ការចាត់ថ្នាក់មុខរបរ ការចាត់ថ្នាក់សកម្មភាពសេដ្ឋកិច្ច និងដំណើរការពាក់ព័ន្ធផ្សេងៗ។

## ២.១០. ការចុះសម្ភាសន៍សាកល្បងតារាងសំណួរ

ការបណ្តុះបណ្តាលសម្រាប់ការចុះសាកល្បងកម្រងសំណួរមុន ត្រូវបានធ្វើឡើងរយៈពេលសរុបប្រាំមួយថ្ងៃ ហើយត្រូវបានរៀបចំឡើង ដើម្បីត្រៀមលក្ខណៈឱ្យបានគ្រប់គ្រាន់ដល់ក្រុមការងារចុះសម្ភាសន៍នៅមូលដ្ឋាន សម្រាប់ការប្រមូលទិន្នន័យឱ្យមានប្រសិទ្ធភាព។ក្នុងដំណាក់កាលដំបូងនៃការបណ្តុះបណ្តាល រយៈពេលបីថ្ងៃត្រូវបានបែងចែកសម្រាប់ការបណ្តុះបណ្តាលលើកម្រងសំណួរដែលប្រើប្រាស់ក្រដាស។ សមាសភាគនេះ

បានផ្តោតលើការធ្វើឱ្យអ្នកចូលរួមបានដឹងអំពីរចនាសម្ព័ន្ធ និងខ្លឹមសារនៃកម្រងសំណួរ ការបញ្ជាក់ឱ្យច្បាស់ពីគោលបំណងនៃផ្នែកនីមួយៗ និងការធានាឱ្យមានការយល់ដឹងច្បាស់លាស់នូវរាល់សំណួរ និងជម្រើសនៃចម្លើយទាំងអស់។ ការបណ្តុះបណ្តាលនេះក៏បានគ្របដណ្តប់ផងដែរនូវបច្ចេកទេសសម្ភាសន៍ ការពិចារណាលើផ្នែកសីលធម៌ នីតិវិធីនៃការយល់ព្រមបន្ទាប់ពីទទួលបានព័ត៌មាន និងការអនុវត្តជាក់ស្តែងដូចជា ការដើរតួសម្តែង និងការធ្វើសម្ភាសន៍សាកល្បង ដើម្បីពង្រឹងជំនាញ និងសង្គតភាព (ភាពស៊ីសង្វាក់គ្នា) របស់អ្នកសម្ភាសន៍។

បន្ទាប់ពីការបណ្តុះបណ្តាលលើកម្រងសំណួរក្រដាស រយៈពេលបីថ្ងៃបន្ថែមទៀតត្រូវបានផ្តល់ជូនសម្រាប់ការបណ្តុះបណ្តាលលើការសម្ភាសដោយប្រើប្រាស់ប្រព័ន្ធកុំព្យូទ័រ ។ ដំណាក់កាលនេះបានសង្កត់ធ្ងន់លើការអនុវត្តផ្ទាល់ជាមួយឧបករណ៍ប្រមូលទិន្នន័យឌីជីថល រួមមានរបៀបប្រើប្រាស់កម្មវិធី CAPI នីតិវិធីបញ្ចូលទិន្នន័យ ប្រព័ន្ធលោតរំលងសំណួរ ការត្រួតពិនិត្យភាពត្រឹមត្រូវនៃទិន្នន័យ និងការដោះស្រាយបញ្ហាបច្ចេកទេសទូទៅ។ អ្នកចូលរួមត្រូវបានណែនាំតាមរយៈការធ្វើសម្ភាសន៍បែបគ្រាប់តាមដោយប្រើប្រាស់ប្រព័ន្ធ CAPI ដើម្បីបង្កើនទំនុកចិត្ត និងភាពត្រឹមត្រូវក្នុងស្ថានភាពនៅមូលដ្ឋានជាក់ស្តែង។ ជាទូទៅ ការបណ្តុះបណ្តាលនេះបានធានាថាសមាជិកក្រុមទាំងអស់ត្រូវបានរៀបចំខ្លួនយ៉ាងល្អ ដើម្បីអនុវត្តការសាកល្បងមុននេះឱ្យមានប្រសិទ្ធភាព ភាពត្រឹមត្រូវ និងស្របតាមស្តង់ដារគុណភាពទិន្នន័យដែលបានកំណត់។

ការសាកល្បងកម្រងសំណួរនៃអង្កេតកម្លាំងពលកម្មកម្ពុជាឆ្នាំ២០២៥ ។ត្រូវបានអនុវត្តចំនួនបីដងដាច់ដោយឡែកពីគ្នា ដើម្បីធ្វើតេស្ត និងកែលម្អឧបករណ៍អង្កេត នីតិវិធី និងវិធីសាស្ត្រប្រមូលទិន្នន័យមុនពេលឈានដល់ការអនុវត្តការអង្កេតថ្នាក់ជាតិជាផ្លូវការ។

ការសាកល្បងកម្រងសំណួរមុនលើកទី១ ត្រូវបានធ្វើឡើងចាប់ពីថ្ងៃទី១១ ដល់ថ្ងៃទី១៦ ខែសីហា ឆ្នាំ ២០២៥ នៅក្នុងខេត្តតាកែវ។ ការសាកល្បងជុំដំបូងនេះ បានផ្តោតសំខាន់លើការវាយតម្លៃទៅលើរចនាសម្ព័ន្ធរួមនៃកម្រងសំណួរ ភាពច្បាស់លាស់នៃសំណួរ និងប្រសិទ្ធភាពនៃនីតិវិធីចុះអនុវត្តការងារនៅមូលដ្ឋាន ក្រោមលក្ខខណ្ឌអង្កេតជាក់ស្តែង។ មតិកែលម្អពីមន្ត្រីសម្ភាសន៍ និងអ្នកត្រួតពិនិត្យត្រូវបានប្រមូលដើម្បីកំណត់រកបញ្ហានានាដែលពាក់ព័ន្ធនឹងការប្រើប្រាស់ឃ្លាឃ្លោងក្នុងសំណួរ លំដាប់លំដោយនៃសំណួរ ឬការយល់ដឹងរបស់អ្នកឆ្លើយតប។

ការសាកល្បងកម្រងសំណួរលើកទី២ បានប្រព្រឹត្តទៅចាប់ពីថ្ងៃទី០៨ ដល់ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ ២០២៥ នៅក្នុងខេត្តកំពង់ឆ្នាំង។ ការសាកល្បងជុំនេះ បានបញ្ចូលនូវរាល់ការកែសម្រួលនានាដែលបានធ្វើឡើងបន្ទាប់ពីការសាកល្បងកម្រងសំណួរលើកទី១ ដោយក្នុងគោលបំណងបន្តពិនិត្យផ្ទៀងផ្ទាត់កម្រងសំណួរ និងប្រព័ន្ធសម្ភាសន៍ដោយប្រើកុំព្យូទ័រជំនួយ(CAPI)។ ការយកចិត្តទុកដាក់ខ្ពស់ត្រូវបានផ្តោតទៅលើ លក្ខខណ្ឌរំលងសំណួរ វិធាននៃការផ្ទៀងផ្ទាត់ទិន្នន័យ រយៈពេលនៃការសម្ភាស និងភាពមិនច្បាស់លាស់នៃចម្លើយនៅតាមស្ថានភាពគ្រួសារ និងស្ថានភាពមុខរបរខុសៗគ្នា។

ការសាកល្បងកម្រងសំណួរលើកទី៣ ត្រូវបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី១៥ ដល់ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ ២០២៥ នៅក្នុងខេត្តសៀមរាប។ ការសាកល្បងជុំចុងក្រោយនេះ មានគោលបំណងបញ្ជាក់ពីប្រសិទ្ធភាពនៃ

ការកែសម្រួលទាំងអស់ និងដើម្បីធានាថា មន្ត្រីសម្ភាសន៍អាចអនុវត្តការអង្កេតបានយ៉ាងរលូន និងត្រឹមត្រូវ។ លើសពីនេះ វាក៏បានសាកល្បងលើការរៀបចំយន្តការត្រួតពិនិត្យ និងដំណើរការបញ្ជូនទិន្នន័យផងដែរ។ ជារួម ការសាកល្បងកម្រងសំណួរមុនទាំងបីលើកនេះ បានផ្តល់នូវធាតុចូលដ៏មានតម្លៃ ដែលរួមចំណែកដល់ការលើកកម្ពស់គុណភាពទិន្នន័យ និងការត្រៀមលក្ខណៈរួចរាល់សម្រាប់ការអនុវត្តពេញលេញនៃការអង្កេតកម្លាំងពលកម្ម ឆ្នាំ២០២៥។

បេក្ខជនសរុបចំនួន ១៣ រូប បានចូលរួមក្នុងការបណ្តុះបណ្តាលកម្រងសំណួរនេះ ដែលក្នុងនោះមានស្ត្រី ៥ រូប និងប្រុស ៨ រូប។ ក្រុមនេះរួមមាន៖ មន្ត្រីសម្ភាសន៍ចំនួន ៩ រូប និងអ្នកត្រួតពិនិត្យចំនួន ២ រូប មកពីវិទ្យាស្ថានជាតិស្ថិតិ ព្រមទាំងមន្ត្រីមូលដ្ឋានពាក់ព័ន្ធផ្សេងទៀត ដែលចូលរួមក្នុងការអនុវត្តការអង្កេត។

វគ្គបណ្តុះបណ្តាលបានផ្តោតសំខាន់លើការកសាងការយល់ដឹងឱ្យបានច្បាស់លាស់អំពីខ្លឹមសារនៃកម្រងសំណួរ គោលបំណងនៃការអង្កេត និងនីតិវិធីនៃការប្រមូលទិន្នន័យ។ អ្នកចូលរួមយ៉ាងសកម្មតាមរយៈការពិភាក្សា ការអនុវត្តលំហាត់ជាក់ស្តែង និងវគ្គសំណួរ-ចម្លើយ ដើម្បីធានាបាននូវសង្គតភាព និងភាពត្រឹមត្រូវក្នុងការប្រមូលទិន្នន័យ។ សិក្ខាកាមទាំង ១៣រូប ដែលបានបញ្ចប់ការបណ្តុះបណ្តាល ត្រូវបានរំពឹងថានឹងត្រលប់មកចូលរួមក្នុងការអង្កេតចម្បងវិញ ដើម្បីធានាបាននូវនិរន្តរភាព ការរក្សាបាននូវជំនាញ និងការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវចំណេះដឹងដែលទទួលបានពីការបណ្តុះបណ្តាល។

## ២.១១. ការបណ្តុះបណ្តាល និងការប្រមូលទិន្នន័យ

ដើម្បីអនុវត្តការអង្កេតទូទាំងប្រទេសឱ្យបានត្រឹមត្រូវ កម្មវិធីបណ្តុះបណ្តាលយ៉ាងស៊ីជម្រៅសម្រាប់អ្នកត្រួតពិនិត្យ និងមន្ត្រីសម្ភាសន៍ត្រូវបានរៀបចំឡើង។ ជាសរុប មានសិក្ខាកាមចំនួន ១១០ នាក់ ត្រូវបានជ្រើសរើស ដែលក្នុងនោះមានប្រុស ៨០ នាក់ និងស្ត្រី ៣០ នាក់ (រួមមានអ្នកត្រួតពិនិត្យ ២២ រូប និងមន្ត្រីសម្ភាសន៍ ៨៨ រូប) ហើយពួកគេទទួលបានការបណ្តុះបណ្តាលរយៈពេល ៦ ថ្ងៃ លើការប្រមូលទិន្នន័យ ចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី២១ ខែតុលា ឆ្នាំ២០២៥ នៅវិទ្យាស្ថានជាតិស្ថិតិ (NIS)។ ក្នុងចំណោមពួកគេ មន្ត្រី ចំនួន ២៥ រូប ត្រូវបានជ្រើសរើសមកពីមន្ទីរផែនការរាជធានី-ខេត្តទាំង ២៥ និង ៨៥ រូបទៀត ត្រូវបានជ្រើសរើសមកពីវិទ្យាស្ថានជាតិស្ថិតិ និងនាយកដ្ឋានផ្សេងៗទៀតនៃក្រសួងផែនការ។

ការបណ្តុះបណ្តាលសម្រាប់ការងារចម្បងនេះ ត្រូវបានធ្វើឡើងក្នុងរយៈពេលសរុប ៦ ថ្ងៃ និងត្រូវបានរៀបចំឡើងដើម្បីត្រៀមលក្ខណៈឱ្យបានគ្រប់គ្រាន់សម្រាប់ក្រុមការងារនៅមូលដ្ឋាន ក្នុងការប្រមូលទិន្នន័យប្រកបដោយប្រសិទ្ធភាព។ ក្នុងដំណាក់កាលដំបូងនៃវគ្គបណ្តុះបណ្តាល រយៈពេល ៣ថ្ងៃ ត្រូវបានបម្រុងទុកសម្រាប់ការបណ្តុះបណ្តាលលើកម្រងសំណួរជាក្រដាស។ ផ្នែកនេះបានផ្តោតលើការធ្វើឱ្យសិក្ខាកាមដឹងពីរចនាសម្ព័ន្ធ និងខ្លឹមសារនៃកម្រងសំណួរ ការបញ្ជាក់ឱ្យច្បាស់ពីគោលបំណងនៃផ្នែកនីមួយៗ និងការធានាឱ្យមានការយល់ដឹងច្បាស់លាស់លើរាល់សំណួរ និងជម្រើសនៃចម្លើយ។ ការបណ្តុះបណ្តាលក៏បានគ្របដណ្តប់លើបច្ចេកទេសសម្ភាសន៍ ការពិចារណាលើក្រមសីលធម៌ នីតិវិធីនៃការសុំការយល់ព្រម និងការអនុវត្តជាក់ស្តែង ដូចជាការសម្តែងតួសាកល្បង និងការសម្ភាសសាកល្បង ដើម្បីពង្រឹងជំនាញ និងសុគតភាពរបស់មន្ត្រីសម្ភាសន៍។

បន្ទាប់ពីការបណ្តុះបណ្តាលលើកម្រងសំណួរជាក្រដាស រយៈពេលបីថ្ងៃបន្ថែមទៀតត្រូវបានបម្រុងទុកសម្រាប់ការបណ្តុះបណ្តាលលើការសម្ភាសន៍ដោយប្រើកុំព្យូទ័រជំនួយ (CAPI )។ ដំណាក់កាលនេះបានសង្កត់ធ្ងន់លើការអនុវត្តផ្ទាល់ជាមួយឧបករណ៍ប្រមូលទិន្នន័យឌីជីថល រួមមានការប្រើប្រាស់កម្មវិធី CAPI នីតិវិធីបញ្ចូលទិន្នន័យ លក្ខខណ្ឌរំលងសំណួរ ការពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យ និងការដោះស្រាយបញ្ហាបច្ចេកទេសទូទៅ។ សិក្ខាកាមត្រូវបានណែនាំតាមរយៈការធ្វើសម្ភាសសាកល្បងដោយប្រើប្រាស់ប្រព័ន្ធ CAPI ដើម្បីកសាងទំនុកចិត្ត និងភាពត្រឹមត្រូវក្នុងលក្ខខណ្ឌការងារមូលដ្ឋានជាក់ស្តែង។ ជារួម ការបណ្តុះបណ្តាលនេះបានធានាថា សមាជិកក្រុមទាំងអស់ត្រូវបានត្រៀមលក្ខណៈយ៉ាងល្អ ដើម្បីអនុវត្តការសាកល្បងមុនឱ្យបានប្រកបដោយប្រសិទ្ធភាព ភាពត្រឹមត្រូវ និងស្របតាមស្តង់ដារគុណភាពទិន្នន័យដែលបានកំណត់។

## ២.១២ ការងារអង្កេតមូលដ្ឋាន

ការប្រមូលទិន្នន័យត្រូវបានអនុវត្តដោយក្រុមស្រាវជ្រាវចំនួន ២២ក្រុម។ ក្រុមនីមួយៗមានមនុស្សប្រាំនាក់ មន្ត្រីត្រួតពិនិត្យម្នាក់ និងមន្ត្រីសម្ភាសន៍ចំនួនបួននាក់។ មន្ត្រីត្រួតពិនិត្យត្រូវបានចាត់តាំងឱ្យត្រួតពិនិត្យ និងសម្របសម្រួលសកម្មភាពការងារស្រាវជ្រាវនៅនឹងកន្លែង។ ក្រុមមួយទទួលខុសត្រូវក្នុងការធ្វើបទសម្ភាសន៍នៅក្នុងភូមិចំនួន ៣០ ជាមធ្យមដែលមានទីតាំងនៅក្នុងខេត្តច្រើនជាងមួយ។ ការងារស្រាវជ្រាវនៅនឹងកន្លែងបានចាប់ផ្តើមពីថ្ងៃទី២៥ ខែតុលា ដល់ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៥ ដោយមានរយៈពេល ២៥ ថ្ងៃដែលដំណើរការនៅគ្រប់ខេត្តទាំង ២៥ ទូទាំងប្រទេសកម្ពុជា។ ក្រុមទាំងនោះត្រូវបានត្រួតពិនិត្យ និងគ្រប់គ្រងយ៉ាងជិតដល់ដោយអ្នកសម្របសម្រួលការអង្កេតនៅនឹងកន្លែងទាំងបួនសម្រាប់ធានាគុណភាព។ ដំណើរការទាំងមូលនៃការប្រមូលទិន្នន័យការងារស្រាវជ្រាវនៅនឹងកន្លែងត្រូវបានបញ្ចប់នៅក្នុងខែវិច្ឆិកា ឆ្នាំ២០២៥។

ការតាមដានការងារអង្កេតមូលដ្ឋាន គឺជាផ្នែកមួយដ៏សំខាន់មិនអាចខ្វះបាននៃអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥ ហើយត្រូវបានអនុវត្តក្នុងអំឡុងពេលប្រមូលទិន្នន័យដោយវិទ្យាស្ថានជាតិស្ថិតិ (NIS) ដែលក្នុងនោះមន្ត្រីនៃវិទ្យាស្ថានជាតិស្ថិតិត្រូវបានបំពាក់នូវគោលការណ៍ណែនាំសម្រាប់ការតាមដាន។ រៀងរាល់សប្តាហ៍ វិទ្យាស្ថានជាតិស្ថិតិបានរៀបចំជាតារាងត្រួតពិនិត្យការងារអង្កេតមូលដ្ឋានចេញពីទិន្នន័យសម្ភាសន៍ដែលបានបញ្ចប់ ដើម្បីតាមដានគុណភាពទិន្នន័យ និងវឌ្ឍនភាពនៃការងារវាល។ មតិកែលម្អត្រូវបានផ្តល់ជូនជាទៀងទាត់ទៅកាន់អ្នកសម្របសម្រួល និងក្រុមការងារអង្កេតមូលដ្ឋាន។

## ២.១៣ ការដាក់បញ្ចូលលេខកូដ

បន្ទាប់ពីបញ្ចប់ការដាក់ស្នើទិន្នន័យពីការងារនៅមូលដ្ឋានទៅវិទ្យាស្ថានជាតិស្ថិតិតាមអ៊ីនធឺណិត ការបណ្តុះបណ្តាលអំពីការសរសេរកូដ និងការកែសម្រួលទិន្នន័យត្រូវបានចាប់ផ្តើម។ បុគ្គលិករបស់វិទ្យាស្ថានជាតិស្ថិតិចំនួន ១០ នាក់ ធ្វើការងារកែសម្រួល និងសរសេរកូដ។ អ្នកកែសម្រួលទិន្នន័យបានពិនិត្យដោយប្រុងប្រយ័ត្ននូវភាពស៊ីសង្វាក់គ្នានៃការឆ្លើយតប ការដាក់លេខកូដមុខរបរអោយត្រូវគ្នានឹងកាឆ្លើយតប និងដើម្បីផ្ទៀងផ្ទាត់បញ្ជីកំហុស និងលទ្ធផលកុំព្យូទ័រផ្សេងទៀត។

កូដកម្រិត ៤ខ្ទង់ នៃចំណាត់ថ្នាក់ស្តង់ដារអន្តរជាតិស្តីពីមុខរបរ ឆ្នាំ២០០៨ (ISCO-08) និងកូដកម្រិត៤ ខ្ទង់ នៃចំណាត់ថ្នាក់ស្តង់ដារឧស្សាហកម្មអន្តរជាតិ កែសម្រួលលើកទី៤ (ISIC Rev. 4) ត្រូវបានយកមកប្រើប្រាស់។ បន្ទាប់ពីការកែសម្រួល និងការសម្អាតទិន្នន័យរួចរាល់ តារាងនានាត្រូវបានរៀបចំឡើងដោយផ្អែកលើផែនការរៀបចំតារាងដែលបានព្រាងទុកជាមុន។ កម្មវិធីស្ថិតិសម្រាប់វិទ្យាសាស្ត្រសង្គម (SPSS) និងកម្មវិធី STATA ត្រូវបានប្រើប្រាស់ដើម្បីទាញចេញជាតារាង។ បន្ទាប់មក កម្មវិធី Microsoft Excel-Word ត្រូវបានប្រើប្រាស់ដើម្បីរៀបចំតារាង រូបភាព និងគណនានូវសូចនាករបន្ថែមផ្សេងៗតាមតម្រូវការ។

## ២.១៤ ការឆ្លើយតប

តារាង ២.៣ បង្ហាញពីអត្រាឆ្លើយតបសម្រាប់ការអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥។ គ្រួសារសរុបចំនួន ៩.៩១២ ត្រូវបានជ្រើសរើសជាសំណាកនៃការអង្កេត ដែលក្នុងនោះគ្រួសារទាំង ៩.៩១២ ត្រូវបានសម្ភាសន៍ដោយជោគជ័យ។

ជំហានសំខាន់ៗដែលត្រូវបានអនុវត្តដើម្បីសម្រេចបាននូវអត្រាឆ្លើយតបដ៏ខ្ពស់នេះ រួមមានដូចខាងក្រោម៖

១. លិខិតអនុញ្ញាតផ្លូវការ ដើម្បីចុះអនុវត្តការអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥ ដែលបានចុះហត្ថលេខាដោយឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវបានផ្ញើជូនរដ្ឋបាលគ្រប់លំដាប់ថ្នាក់ (អភិបាលរាជធានី ឬខេត្ត អភិបាលក្រុង/ស្រុក មេឃុំ/ចៅសង្កាត់ និងមេភូមិ) មុនពេលប្រតិបត្តិការអង្កេតចាប់ផ្តើម។

២. មេភូមិម្នាក់ៗ បានជូនដំណឹងដល់គ្រួសារទាំងអស់នៅក្នុងភូមិរបស់ខ្លួនអំពីការអង្កេតនេះ។ អ្នកត្រួតពិនិត្យការងារវាលបានធ្វើការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរមូលដ្ឋាន ជាពិសេសគឺមេភូមិ ក្នុងអំឡុងពេលប្រមូលទិន្នន័យនៅតាមមូលដ្ឋាន។ ការចូលរួមរបស់មេភូមិបានធ្វើឱ្យមានលទ្ធភាពជំរុញឱ្យមានកិច្ចសហការយ៉ាងសកម្មពីសំណាក់គ្រួសារនីមួយៗ។

**តារាង ៣.២ អត្រាឆ្លើយតបរបស់គ្រួសារគំរូ**

| តំបន់ | ភូមិសំណាកគំរូ | គ្រួសារសំណាកគំរូ | សំណាកគំរូគ្រួសារបានសម្ភាសន៍ | អត្រាឆ្លើយតប (%) |
|---|---|---|---|---|
| ទីប្រជុំជន | ១៨០ | ២.៨៨០ | ២.៨៧៩ | ៩៩,៩៧ |
| ជនបទ | ៤២០ | ៦.៧២០ | ៦.៧២០ | ១០០ |
| សរុប | **៦០០** | **៩.៦០០** | **៩.៩១២** | **៩៩,៩៩** |

# ជំពូក ៣
# ចរិតលក្ខណៈប្រជាសាស្ត្រ

## ៣.១. សេចក្តីផ្តើម

ជំពូកនេះផ្តល់នូវព័ត៌មានអំពីលក្ខណៈប្រជាសាស្ត្រនៃប្រជាជនគោលដៅនៃការអង្កេត។ អថេរដែលត្រូវបានបង្ហាញរួមមាន៖ ទំហំប្រជាជន ការបែងចែកប្រជាជន ទំហំគ្រួសារ មេគ្រួសារ ប្រជាជនមានពិការភាព អត្រាអ្នកនៅក្នុងបន្ទុក ប្រភពចំណូលសម្រាប់ជីវភាពគ្រួសារ និងចរិតលក្ខណៈនៃគ្រួសារដែលពឹងផ្អែកលើវិស័យកសិកម្ម។

ព័ត៌មានប្រជាសាស្ត្រមានសារៈសំខាន់ណាស់នៅរាល់ការអង្កេតនីមួយៗ ព្រោះវាផ្តល់នូវមូលដ្ឋានគ្រឹះសម្រាប់ការវិភាគលើចរិតលក្ខណៈប្រជាជន និងទំនាក់ទំនងរបស់ពួកគេជាមួយនឹងកត្តាកំណត់ផ្សេងៗដែលជះឥទ្ធិពលដល់ការផ្លាស់ប្តូរប្រជាជន។ ជាឧទាហរណ៍ ព័ត៌មានប្រជាសាស្ត្រកំណត់នូវកម្រិតសម្រាប់កំណត់និយមន័យនៃប្រជាជនក្នុងអាយុធ្វើការ និងកម្លាំងពលកម្ម។

## ៣.២. ទំហំប្រជាជន

ចំនួនប្រជាជន គឺជាចំនួនសរុបនៃមនុស្សទាំងអស់នៃភេទទាំងពីរដែលមានអាយុចាប់ពី ០ ឆ្នាំឡើងទៅនៅក្នុងទឹកដីដែលបានផ្តល់ឱ្យនៅចំណុចជាក់លាក់មួយក្នុងពេលវេលា។

រូបភាព ៣.១ បង្ហាញពីសាជីប្រជាជនតាមក្រុមអាយុ និងភេទ, មូលដ្ឋានតូចចង្អៀតនៃសាជីប្រជាជន ជាពិសេសនៅក្នុងក្រុមអាយុ ០–៤ ឆ្នាំ និង ៥–៩ ឆ្នាំ បង្ហាញថា កម្ពុជាកំពុងស្ថិតនៅក្នុងដំណាក់កាលជឿនលឿននៃការផ្លាស់ប្តូរប្រជាសាស្ត្រ ដែលមានលក្ខណៈដោយសារអត្រាកំណើតមានការថយចុះ, ក្នុងរយៈពេល ១០ ឆ្នាំខាងមុខ ប្រជាជនកម្ពុជាត្រូវបានរំពឹងថានឹងមានភាពចាស់ជរាកាន់តែច្រើន ដោយសារសមាមាត្រប្រជាជនវ័យចាស់នឹងបន្តកើនឡើង។

ការផ្លាស់ប្តូរប្រជាសាស្ត្រទាំងនេះ បង្ហាញពីភាពចាំបាច់ដែលកម្ពុជាត្រូវផ្លាស់ប្តូរទៅរកសេដ្ឋកិច្ចដែលមានផលិតភាពខ្ពស់ ដោយផ្អែកលើការបង្កើនផលិតភាពការងារ កម្លាំងពលកម្មដែលមានជំនាញសមស្រប ប្រាក់ចំណូលខ្ពស់ និងការងារដែលមានគុណភាពកាន់តែល្អប្រសើរ។

នៅឆ្នាំ ២០២៥ ប្រជាជនកម្ពុជាត្រូវបានប៉ាន់ស្មានថាមានចំនួន ១៧.៦ លាននាក់ ក្នុងនោះមានប្រុស ៨.៦ លាននាក់ (៤៨,៧%) និងស្រី ៩.០ លាននាក់ (៥១,៣%), ចំនួនស្រីមានច្រើនជាងប្រុស ដែលជាលក្ខណៈទូទៅមួយដែលត្រូវបានសង្កេតឃើញនៅក្នុងប្រទេសភាគច្រើន ជាពិសេសក្នុងក្រុមអាយុចាស់ ដោយសារស្រីជាទូទៅមានអាយុសង្ឃឹមរស់វែងជាងប្រុស, ក្នុងចំណោមប្រជាជនសរុប ៣៩,៦% រស់នៅតំបន់ទីប្រជុំជន ខណៈដែល ៦០,៤% រស់នៅតំបន់ជនបទ, ការបែងចែកប្រជាជនកម្ពុជាតាមក្រុមអាយុ ត្រូវបានបង្ហាញនៅក្នុងរូបភាព ៣.១។

## រូបភាព ៣.១៖ ពីរ៉ាមីតប្រជាជនតាមភេទ និងក្រុមអាយុ ឆ្នាំ២០២៥




## តារាង ៣.១. ភាគរយប្រជាជន តាម ភេទ ក្រុមអាយុ និងតំបន់ភូមិសាស្ត្រ

| ក្រុមអាយុ | កម្ពុជា | | | ទីប្រជុំជន | | | ជនបទ | | |
|---|---|---|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| < ១៥ឆ្នាំ | ២៥,៤ | ១២,៩ | ១២,៤ | ៩,៤ | ៤,៧ | ៤,៧ | ១៥,៩ | ៨,២ | ៧,៧ |
| ១៥–២៤ ឆ្នាំ | ១៦,៦ | ៨,៤ | ៨,២ | ៦,៦ | ៣,៣ | ៣,៣ | ១០,០ | ៥,១ | ៤,៩ |
| ២៥–៣៤ ឆ្នាំ | ១៤,៧ | ៧,១ | ៧,៥ | ៦,១ | ២,៩ | ៣,២ | ៨,៦ | ៤,២ | ៤,៤ |
| ៣៥–៤៤ ឆ្នាំ | ១៦,៣ | ៨,១ | ៨,២ | ៧,០ | ៣,៥ | ៣,៦ | ៩,៣ | ៤,៧ | ៤,៦ |
| ៤៥–៥៤ ឆ្នាំ | ១០,៧ | ៥,១ | ៥,៧ | ៤,១ | ២,០ | ២,២ | ៦,៦ | ៣,១ | ៣,៥ |
| ៥៥–៦៤ ឆ្នាំ | ៨,៥ | ៣,៩ | ៤,៦ | ៣,៣ | ១,៥ | ១,៨ | ៥,២ | ២,៤ | ២,៨ |
| ៦៥+ | ៧,៨ | ៣,១ | ៤,៧ | ៣,០ | ១,២ | ១,៨ | ៤,៧ | ១,៩ | ២,៩ |
| សរុប | ១០០,០ | ៤៨,៧ | ៥១,៣ | ៣៩,៦ | ១៩,១ | ២០,៥ | ៦០,៤ | ២៩,៦ | ៣០,៨ |

## ៣.៣. ទំហំគ្រួសារ

គ្រួសារត្រូវបានកំណត់និយមន័យថាជា បុគ្គលម្នាក់ ឬក្រុមមនុស្សដែលរស់នៅជាមួយគ្នាក្នុងផ្ទះ ឬបរិវេណជាមួយគ្នា ដែលមានការចាត់ចែងការងារក្នុងផ្ទះរួមគ្នា និងត្រូវបានផ្គត់ផ្គង់ជាអង្គភាពតែមួយ។ សមាជិកនៃគ្រួសារនីមួយៗមិនចាំបាច់ទាល់តែមានទំនាក់ទំនងជាប់សាច់ឈាមឬរៀបការជាមួយគ្នាឡើយ។

ក្នុងឆ្នាំ២០២៥ ចំនួនគ្រួសារត្រូវបានប៉ាន់ស្មានថាមានប្រហែល ២.៦ លានគ្រួសារ នៅតំបន់ជនបទ និង ១.៧ លានគ្រួសារ នៅតំបន់ទីប្រជុំជន ដែលធ្វើឱ្យចំនួនគ្រួសារសរុបនៅទូទាំងប្រទេសមានប្រហែល ៤.៣ លានគ្រួសារ។ ទំហំសមាជិកគ្រួសារជាមធ្យមនៅកម្រិតជាតិគឺ ៤.១ នាក់ក្នុងមួយគ្រួសារ។ ទំហំសមាជិកគ្រួសារមធ្យមនៅតែថេរ ៤.១ នាក់ ដូចគ្នាទាំងតំបន់ជនបទ និងតំបន់ទីប្រជុំជន។

### តារាង ៣.២ ទំហំគ្រួសារ តាម តំបន់ ឆ្នាំ២០២៥

| តំបន់ | ចំនួន | ទំហំគ្រួសារ |
|---|---|---|
| កម្ពុជា | ៤,២៩៧,៨៨៥ | ៤.១ |
| តំបន់ទីប្រជុំជន | ១,៧០២,២៩៥ | ៤.១ |
| ជនបទ | ២,៥៩៥,៥៩១ | ៤.១ |

តារាង ៣.៣ បង្ហាញថា នៅឆ្នាំ២០២៥ កម្ពុជាមានប្រមាណ ៤.៣ លានគ្រួសារ ដែលក្នុងនោះប្រមាណ ៦០,៤% ស្ថិតនៅតំបន់ជនបទ និង ៣៩,៦% ស្ថិតនៅតំបន់ទីប្រជុំជន។ ទំហំគ្រួសារដែលមានច្រើនជាងគេ គឺគ្រួសារដែលមានសមាជិក ៤នាក់ (២៨,៨%) បន្ទាប់មកគឺគ្រួសារដែលមានសមាជិក ៥នាក់ (១៩,៤%) និងគ្រួសារដែលមានសមាជិក ៣នាក់ (១៩,៣%)។

### តារាង ៣.៣ ការបែងចែកគ្រួសារតាម ទំហំ និងតំបន់

| ទំហំគ្រួសារ | ចំនួនគ្រួសារ | | | ភាគរយនៃគ្រួសារ | | |
|---|---|---|---|---|---|---|
| | កម្ពុជា | ទីប្រជុំជន | ជនបទ | កម្ពុជា | ទីប្រជុំជន | ជនបទ |
| ១ | ១៣៧.១៦៥ | ៥៤.៨៦៤ | ៨២.៣០១ | ៣,២ | ៣,២ | ៣,២ |
| ២ | ៥០៧.១៧៥ | ២១០.៦០៣ | ២៩៦.៥៧១ | ១១,៨ | ១២,៤ | ១១,៤ |
| ៣ | ៨៣០.៤៣៩ | ៣៣២.១៣៦ | ៤៩៨.៣០៣ | ១៩,៣ | ១៩,៥ | ១៩,២ |
| ៤ | ១.២៣៥.៧២៣ | ៤៧៣.៧៣៣ | ៧៦១.៩៨៩ | ២៨,៨ | ២៧,៨ | ២៩,៤ |
| ៥ | ៨៣២.៦៧៩ | ៣២២.៨០៤ | ៥០៩.៨៧៥ | ១៩,៤ | ១៩,០ | ១៩,៦ |
| ៦ | ៤៣៦.៥១៧ | ១៨០.៦១៨ | ២៥៥.៨៩៩ | ១០,២ | ១០,៦ | ៩,៩ |
| ៧ | ១៨៥.០៨៤ | ៧១.៦៧០ | ១១៣.៤១៤ | ៤,៣ | ៤,២ | ៤,៤ |
| ៨ | ៧៨.៤៣១ | ២៨.៧០៣ | ៤៩.៧២៨ | ១,៨ | ១,៧ | ១,៩ |
| ៩+ | ៥៤.៦៧២ | ២៧.១៦៣ | ២៧.៥០៩ | ១,៣ | ១,៦ | ១,១ |
| Total | ៤.២៩៧.៨៨៥ | ១.៧០២.២៩៥ | ២.៥៩៥.៥៩១ | ១០០ | ១០០ | ១០០ |

## ៣.៤. មេគ្រួសារ

ជាទូទៅនៅប្រទេសកម្ពុជាត្រូវបានចាត់ទុកថាជាសង្គមដែលប្រកាន់យករបបបិតាធិបតេយ្យ ហើយទាំងនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងច្បាស់នៅក្នុងទិន្នន័យ។ ក្នុងចំណោមចំនួនគ្រួសារសរុបចំនួន ៤.៣ លានគ្រួសារ ប្រមាណជា ៣.១ លានគ្រួសារជាមេគ្រួសារដោយប្រុស បើប្រៀបធៀបទៅនឹងប្រហែល ១.២ លានគ្រួសារដែលជាមេគ្រួសារជាស្រី។ នេះបង្ហាញថា ៧៣,១% នៃគ្រួសារជាមេគ្រួសារដោយប្រុស ខណៈដែល ២៧,០% ជាមេគ្រួសារដោយស្រី។

និន្នាការស្រដៀងគ្នានេះដែរ ក៏ត្រូវបានសង្កេតឃើញនៅតាមតំបន់រស់នៅផងដែរ។ នៅក្នុងតំបន់ទីប្រជុំជន គ្រួសារដែលមានមេគ្រួសារជាប្រុសមានប្រហែល ៧០,៦% ខណៈដែលគ្រួសារមានមេគ្រួសារជាស្រីមាន ២៩,៤%។ នៅក្នុងតំបន់ជនបទ សមាមាត្រនៃគ្រួសារដែលមានមេគ្រួសារជាប្រុសគឺរឹតតែខ្ពស់ជាងនេះពោលគឺមានរហូតដល់ ៧៤,៧% បើប្រៀបធៀបទៅនឹង ២៥,៣% នៃគ្រួសារដែលមានមេគ្រួសារជាស្រី។

**តារាង ៣.៤ ការបែងចែកគ្រួសារតាម ក្រុមអាយុ ភេទនៃមេគ្រួសារ និងតំបន់**

(%)

| ក្រុមអាយុ | កម្ពុជា | | | ទីប្រជុំជន | | | ជនបទ | | |
|---|---|---|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| ១៥–១៩ | ០,១ | ០,១ | ០,២ | ០,២ | ០,២ | ០,២ | ០,១ | ០,១ | ០,១ |
| ២០–២៤ | ១,២ | ១,១ | ១,៥ | ១,០ | ០,៩ | ១,៤ | ១,៣ | ១,២ | ១,៥ |
| ២៥–២៩ | ៣,៩ | ៤,១ | ៣,២ | ៣,២ | ៣,២ | ៣,១ | ៤,៣ | ៤,៧ | ៣,២ |
| ៣០–៣៤ | ៧,៧ | ៨,៤ | ៥,៧ | ៧,៩ | ៨,៥ | ៦,៥ | ៧,៥ | ៨,៣ | ៥,០ |
| ៣៥–៣៩ | ១២,៣ | ១៤,២ | ៧,១ | ១២,១ | ១៤,១ | ៧,៥ | ១២,៤ | ១៤,៣ | ៦,៨ |
| ៤០–៤៤ | ១៤,៤ | ១៥,៥ | ១១,៦ | ១៥,៩ | ១៦,៩ | ១៣,៤ | ១៣,៥ | ១៤,៦ | ១០,២ |
| ៤៥–៤៩ | ១២,២ | ១២,៧ | ១០,៨ | ១១,៩ | ១២,៦ | ១០,១ | ១២,៥ | ១២,៨ | ១១,៤ |
| ៥០–៥៤ | ១០,៥ | ១០,៦ | ១០,២ | ១០,៦ | ១០,៩ | ១០,០ | ១០,៤ | ១០,៤ | ១០,៤ |
| ៥៥–៥៩ | ១១,១ | ១០,៧ | ១១,៩ | ១០,៦ | ១០,១ | ១២,០ | ១១,៣ | ១១,២ | ១១,៩ |
| ៦០–៦៤ | ៩,១ | ៨,២ | ១១,៤ | ៩,៤ | ៨,៤ | ១១,៧ | ៨,៨ | ៨,១ | ១១,២ |
| ៦៥ + | ១៧,៦ | ១៤,៣ | ២៦,៥ | ១៧,២ | ១៤,៣ | ២៤,០ | ១៧,៩ | ១៤,៣ | ២៨,៣ |
| សរុប(%) | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ |
| សរុប(ចំនួន) | ៤.២៩៨.៨៨៥ | ៣.១៤០.៨០៨ | ១.១៥៧.០៧៧ | ១.៧០២.២៩៥ | ១.២០១.១០៥ | ៥០១.១៩០ | ២.៥៩៥.៥៩១ | ១.៩៣៩.៧០៣ | ៦៥៥.៨៨៧ |

## ៣.៥ ជនមានពិការភាព

យោងតាមអនុសាសន៍ចុងក្រោយរបស់ក្រុមវ៉ាស៊ីនតោនស្តីពីស្ថិតិជនមានពិការភាព កម្រិតនៃការលំបាកដែលបុគ្គលមានពិការភាពអាចជួបប្រទះ ត្រូវបានវាស់វែងតាមរយៈមុខងារស្នូលចំនួនប្រាំមួយ រួមមាន៖ ការមើលឃើញ ការស្តាប់ ការដើរឬឡើងជណ្តើរ ការយល់ដឹង ឬការចងចាំ ការថែទាំខ្លួនឯង និងការប្រាស្រ័យទាក់ទង។

ការអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥ បានដាក់បញ្ចូលកម្រងសំណួរស្នូលចំនួនប្រាំមួយ ដើម្បីប្រមូលព័ត៌មានអំពីស្ថានភាពជនមានពិការភាពរបស់ប្រជាជនដែលស្ថិតក្នុងសំណាកគំរូអង្កេត ស្របតាមអនុសាសន៍របស់ក្រុមវ៉ាស៊ីនតោនស្តីពីស្ថិតិជនមានពិការភាព។

រូបភាព ៣.២ បង្ហាញពីសមាមាត្រប្រជាជនកម្ពុជាអាយុ ៥ឆ្នាំឡើង ដែលមានពិការភាព។ នៅឆ្នាំ២០២៥ ប្រមាណ ៣,១% នៃប្រជាជនរស់នៅជាមួយពិការភាពយ៉ាងហោចណាស់មួយប្រភេទ ដែលមានកម្រិតនៃការលំបាកខុសៗគ្នា ចាប់ពីការលំបាកខ្លះៗ រហូតដល់ការលំបាកធ្ងន់ធ្ងរ ឬមិនអាចអនុវត្តសកម្មភាពនោះបានទាំងស្រុង។ អត្រាប្រេវ៉ាឡង់នៃជនមានពិការភាពមានកម្រិតខ្ពស់ជាងក្នុងចំណោមស្រី (៣,៤%) បើធៀបនឹងប្រុស (២,៨%)។

**រូបភាព ៣.២ សមាមាត្រប្រជាជន(អាយុ ៥ឆ្នាំឡើង) ជាជនមានពិការភាពតាម ភេទ និងតំបន់**

**%**




## ៣.៦ ផលធៀបអ្នកនៅក្នុងបន្ទុក

ការអង្កេតកម្លាំងពលកម្មកម្ពុជា បានកំណត់និយមន័យ «អត្រានៅក្នុងបន្ទុកតាមអាយុ» ជាផលធៀបរវាងចំនួនប្រជាជនសរុបដែលមិនស្ថិតក្នុងអាយុធ្វើការ (អ្នកដែលមានអាយុពី 0 - ១៤ឆ្នាំ និងអ្នកដែលមានអាយុចាប់ពី ៦៥ឆ្នាំឡើង)ធៀបនឹងប្រជាជនក្នុងអាយុធ្វើការ(ពោលគឺ អ្នកដែលមានអាយុពី ១៥ - ៦៤ឆ្នាំ)។ អត្រានៅក្នុងបន្ទុកតាមអាយុនេះត្រូវបានចាត់ទុកជាសូចនាករសង្ខេបនៃបន្ទុកទៅលើប្រជាជនក្នុងអាយុធ្វើការ។

ដូចដែលបានបង្ហាញក្នុងតារាង ៣.៥ អំពីអត្រានៅក្នុងបន្ទុកសរុបរបស់ប្រទេសកម្ពុជាក្នុងឆ្នាំ២០២៥ គឺមានចំនួន ៤៩,៥% ដោយនៅតំបន់ទីប្រជុំជនមាន ៤៥,៩% និងនៅតំបន់ជនបទមាន ៥២,0%។ ភាគច្រើននៃអត្រានៅក្នុងបន្ទុកនេះ គឺបណ្ដាលមកពីចំនួនប្រជាជនវ័យក្មេងដែលស្ថិតនៅអាយុក្រោម ១៥ឆ្នាំ ដែលមានរហូតដល់ ៣៧,៩%។

**តារាង ៣.៥ សមាមាត្រអ្នកនៅក្នុងបន្ទុកតាមតំបន់ ឆ្នាំ២០២៥**

| ក្រុមអាយុ | កម្ពុជា | | ទីប្រជុំជន | | ជនបទ | |
|---|---|---|---|---|---|---|
| | (ចំនួន) | (%) | (ចំនួន)) | (%) | (ចំនួន) | (%) |
| 0-១៤ | ៤.៤៦៤.៨១៥ | ២៥,៤ | ១.៦៦០.៤៦៨ | ២៣,៨ | ២.៨០៤.៣៤៧ | ២៦,៤ |
| ១៥-៦៤ | ១១.៧៧៤.៥៤០ | ៦៦,៩ | ៤.៧៨០.០១៩ | ៦៨,៥ | ៦,៩៩៤.៥២១ | ៦៥,៨ |
| ៦៥+ | ១.៣៦៩.១៦១ | ៧,៨ | ៥៣៣.៧៩៩ | ៧,៧ | ៨៣៥.៣៦២ | ៧,៩ |
| សរុប | ១៧.៦០៨.៥១៦ | ១០០ | ៦.៩៧៤.២៨៦ | ១០០ | ១០.៦៣៤.២៣០ | ១០០ |
| | | | សមមាត្រ | | | |
| សមាមាត្រនៅក្នុងបន្ទុកវ័យក្មេង | | ៣៧,៩ | | ៣៤,៧ | | ៤០,១ |
| សមាមាត្រនៅក្នុងបន្ទុកវ័យចាស់ | | ១១,៦ | | ១១,២ | | ១១,៩ |
| សមាមាត្រនៅក្នុងបន្ទុកទាំងពីរភេទ | | ៤៩,៥ | | ៤៥,៩ | | ៥២,០ |

## ៣.៧ ប្រភពសម្រាប់ចិញ្ចឹមជីវិតរបស់គ្រួសារ

ការអង្កេតនេះក៏បានដាក់បញ្ចូលសំណួរអំពីប្រភពនៃជីវភាពរស់នៅរបស់គ្រួសារ ក្នុងរយៈពេល ១២ខែមុនថ្ងៃសម្ភាសន៍។ លទ្ធផលនៃការអង្កេតបានបែងចែកប្រភពចំណូលរបស់គ្រួសារជាពីរក្រុមសំខាន់ៗ គឺ ប្រភពចំណូលទាក់ទងនឹងការងារ និងប្រភពចំណូលផ្សេងទៀតរបស់គ្រួសារ រួមមានប្រាក់ផ្ញើពីសមាជិកគ្រួសារឬអ្នកដទៃការផ្ទេរប្រាក់ឬជំនួយផ្សេងៗនិងការផលិតស្បៀងអាហារសម្រាប់ប្រើប្រាស់ដោយខ្លួនឯង

តារាង ៣.៦ បង្ហាញថា មានប្រមាណ ៤០,២% នៃគ្រួសារបានរាយការណ៍ថា ប្រាក់ចំណូលបានពីការងារដែលមានប្រាក់ឈ្នួល គឺជាប្រភពចម្បងនៃជីវភាពរស់នៅរបស់គ្រួសារ។ ប្រមាណ២៥,៨% នៃគ្រួសារពឹងផ្អែកជាចម្បងលើការធ្វើកសិកម្ម ឬនេសាទរបស់គ្រួសារ ខណៈដែល២៥,៩% ពឹងផ្អែកលើអាជីវកម្មដែលគ្រួសារប្រតិបត្តិដោយខ្លួនឯង ក្រៅពីការធ្វើកសិកម្ម ឬនេសាទ។

**តារាង ៣.៦ ប្រភពសម្រាប់ចិញ្ចឹមជីវិតរបស់គ្រួសារតាម តំបន់**

| ប្រភពសម្រាប់ចិញ្ចឹមជីវិត | កម្ពុជា | ទីប្រជុំជន | ជនបទ | កម្ពុជា | ទីប្រជុំជន | ជនបទ |
|---|---|---|---|---|---|---|
| | | ចំនួនគ្រួសារ | | | ភាគរយនៃគ្រួសារ | |
| ចំណូលពីការធ្វើកសិកម្ម ឬនេសាទ | ១.០៧៣.៦៦៣ | ១៥៧.៦៩ | ៩១៥.៩៩៤ | ២៥,៨ | ៩,៦ | ៣៦,៥ |
| ចំណូលពីអាជីវកម្មគ្រួសារ(ក្រៅពីកសិកម្ម ឬនេសាទ) | ១.០៧៤.៩៧៨ | ៥៨៨.១២៨ | ៤៨៦.៨៥០ | ២៥,៩ | ៣៥,៧ | ១៩,៤ |
| ចំណូលពីការងារមានប្រាក់ឈ្នួល | ១.៦៦៩.៨០៥ | ៧៧០.០៧២ | ៨៩៩.៧៣៣ | ៤០,២ | ៤៦,៨ | ៣៥,៨ |
| ស្បៀងអាហារដែលផលិតដោយគ្រួសារពីការធ្វើកសិកម្ម ការចិញ្ចឹមសត្វ ឬការនេសាទ | ៣៨.៣៨៧ | ៦.៨៦០ | ៣១.៥២៧ | ០,៩ | ០,៤ | ១,៣ |
| ប្រាក់ផ្ញើពីក្រៅប្រទេស | ១៨.៣១២ | ២.៩៩០ | ១៥.៣២២ | ០,៤ | ០,២ | ០,៦ |
| ជំនួយពីគ្រួសារផ្សេងក្នុងស្រុក | ១២៥.៦៨៧ | ៣៨.៧២១ | ៨៦.៩៦៥ | ៣,០ | ២,៤ | ៣,៥ |
| ចំណូលពីទ្រព្យសម្បត្តិ វិនិយោគ ឬការសន្សំ | ១២.៧៦៨ | ៤.៥១១ | ៨.២៥៧ | ០,៣ | ០,៣ | ០,៣ |
| ប្រាក់សោធននិវត្តន៍ពីឯកជន ឬរដ្ឋ ឬជំនួយផ្សេងទៀតពីរាជរដ្ឋាភិបាល | ៤៥.៥៥៣ | ២៧.៦៧៦ | ១៧.៨៧៦ | ១,១ | ១,៧ | ០,៧ |
| សប្បុរសទានពីអង្គការមិនមែនរដ្ឋាភិបាល ឬអង្គការសង្គ្រោះផ្សេងទៀត | ២.១៥២ | ៨០៥ | ១.៣៤៧ | ០,១ | ០,០ | ០,១ |
| ផ្សេងៗ | ៩៥.០១៦ | ៤៩.១៧១ | ៤៥.៨៤៥ | ២,៣ | ៣,០ | ១,៨ |
| Total | ៤,១៥៦,៣២១ | ១,៦៤៦,៦០៤ | ២,៥០៩,៧១៦ | ១០០ | ១០០ | ១០០ |

## ៣.៨ ការចូលរួមរបស់គ្រួសារក្នុងវិស័យកសិកម្ម និងនេសាទ

ផ្នែកនេះបង្ហាញព័ត៌មានមូលដ្ឋានអំពីការចូលរួមរបស់គ្រួសារក្នុងសកម្មភាពកសិកម្ម និងនេសាទ ដែលអនុវត្តដោយឯករាជ្យ ដោយមិនគិតថាគ្រួសារនោះមានកម្មសិទ្ធិលើដីធ្លី ឬឧបករណ៍ដែលពាក់ព័ន្ធឬអត់នោះទេ។ ព័ត៌មានមូលដ្ឋានដែលត្រូវបានប្រមូលរួមមាន៖ ការចូលរួមរបស់គ្រួសារក្នុងសកម្មភាពកសិកម្ម (រួមទាំងការចិញ្ចឹមសត្វ) ឬនេសាទ ដែលជាមូលដ្ឋានឯករាជ្យជាចម្បងសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ ការកំណត់អត្តសញ្ញាណសមាជិកគ្រួសារដែលចូលរួមក្នុងសកម្មភាពកសិកម្ម ឬនេសាទរបស់គ្រួសារ និងកម្រិតនៃការចូលរួមរបស់សមាជិកគ្រួសារក្នុងការធ្វើសេចក្តីសម្រេចចិត្តពាក់ព័ន្ធនឹងសកម្មភាពកសិកម្ម ឬនេសាទរបស់គ្រួសារ។

នៅក្នុងផ្នែកអង្កេតនេះ មេគ្រួសារ ឬបុគ្គលយោងរបស់គ្រួសារ គឺជាអ្នកផ្តល់ព័ត៌មាន។ ការអង្កេតត្រូវបានអនុវត្តក្នុងអំឡុងពេលដែលគ្រួសារកំពុងប្រកបសកម្មភាពកសិកម្ម និង/ឬ នេសាទ។ ចំពោះគ្រួសារដែលមិនបានអនុវត្តសកម្មភាពទាំងនេះក្នុងអំឡុងពេលអង្កេត រយៈពេលយោងត្រូវបានកែសម្រួលឱ្យសំដៅលើ «រដូវផលិតកម្មចុងក្រោយ» ឬរយៈពេល ១២ខែមុនថ្ងៃសម្ភាសន៍។

នៅកម្ពុជា ប្រមាណ ២៧,៨% នៃគ្រួសារ (ប្រមាណ១.២លានគ្រួសារ) បានចូលរួមក្នុងសកម្មភាពកសិកម្ម។ ក្នុងចំណោមគ្រួសារទាំងនេះ ប្រមាណពីរភាគបីបានរាយការណ៍ថា ពួកគេប្រកបការងារកសិកម្មលើកសិដ្ឋានដើម្បីដាំដំណាំ ផ្លែឈើ ឬផលិតផលកសិកម្មផ្សេងៗ។

**តារាង ៣.៧ ការចូលរួមរបស់គ្រួសារក្នុងការងារកសិកម្ម តាមសកម្មភាពចម្បង និងតំបន់**

| សកម្មភាពកសិកម្ម | កម្ពុជា | ទីប្រជុំជន | ជនបទ | កម្ពុជា | ទីប្រជុំជន | ជនបទ |
|---|---|---|---|---|---|---|
| | | ចំនួនគ្រួសារ | | | ភាគរយនៃគ្រួសារ | |
| គ្រួសារទាំងអស់ | ៤.២៩៧.៨៨៥ | ១.៧០២.២៩៥ | ២.៥៩៥.៥៩១ | ១០០ | ១០០ | ១០០ |
| គ្រួសារបានចូលរួមកសិកម្ម | ១.១៩២.៩១៥ | ១៧៩.៣១៦ | ១.០១៣.៥៩៩ | ២៧,៨ | ១០,៥ | ៣៩,១ |
| | | ចំនួនការឆ្លើយតប | | | អត្រាការឆ្លើយតប(%) | |
| ធ្វើកសិកម្មដាំដំណាំ ផ្លែឈើ ឬផលិតផលផ្សេង | ៨៩៨.១៤៣ | ១២៥.៣៨២ | ៧៧២.៧៦០ | ៨០,៨ | ៧៥,៩ | ៨១,៦ |
| ចិញ្ចឹមសត្វ ឬរក្សាសត្វសម្រាប់យកសាច់ ឬផលិតផលផ្សេង | ១៣៥.៦០១ | ២៤.២១៥ | ១១១.៣៨៦ | ១២,២ | ១៤,៧ | ១១,៨ |
| នេសាទ នេសាទតាមបឹង ឬកខ្យង ខ្ចៅ គ្រំ លៀស | ៧៨.០៦០ | ១៥.៦៧៥ | ៦២.៣៨៥ | ៧,០ | ៩,៥ | ៦,៦ |
| សរុប | **១.១១.៨០៤** | **១៦៥.២៧២** | **៩៤៦.៥៣១** | **១០០** | **១០០** | **១០០** |

# ជំពូក ៤
# ប្រជាជនក្នុងអាយុធ្វើការ

## ៤.១. សេចក្តីផ្តើម

ជំពូកនេះគ្របដណ្តប់ទិន្នន័យអំពីប្រជាជនក្នុងអាយុធ្វើការ ស្ថានភាពសកម្មភាពសេដ្ឋកិច្ចបច្ចុប្បន្ន និងការចូលរួមក្នុងកម្លាំងពលកម្ម។

## ៤.២. ប្រជាជនក្នុងអាយុធ្វើការ

នៅឆ្នាំ២០២៥ ប្រជាជនក្នុងវ័យធ្វើការត្រូវបានប៉ាន់ប្រមាណថាមានចំនួន ១៣.១លាននាក់ ដែលក្នុងនោះមានស្រី ៦.៨លាននាក់ និងប្រុស ៦.៣លាននាក់។ ក្នុងចំណោមប្រជាជនក្នុងវ័យធ្វើការទាំងអស់ ប្រមាណ ៧.៨លាននាក់រស់នៅតំបន់ជនបទ ខណៈដែលប្រមាណ ៥.៣លាននាក់រស់នៅតំបន់ទីប្រជុំជន (តារាង៤.១)។

**តារាង ៤.១ ការបែងចែកប្រជាជនក្នុងអាយុធ្វើការ តាមក្រុមអាយុ ភេទ និងតំបន់ ឆ្នាំ ២០២៥**

| ក្រុមអាយុ | កម្ពុជា (000) | | | ទីប្រជុំជន (000) | | | ជនបទ (000) | | |
|---|---|---|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| ១៥–២៤ ឆ្នាំ | ២.៩២២ | ១.៤៨១ | ១.៤៤១ | ១.១៥៩ | ៥៨២ | ៥៧៧ | ១.៧៦២ | ៨៩៩ | ៨៦៤ |
| ២៥–៣៤ ឆ្នាំ | ២.៥៨៥ | ១.២៥៩ | ១.៣២៦ | ១.០៧ | ៥១១ | ៥៥៩ | ១.៥១៥ | ៧៤៧ | ៧៦៨ |
| ៣៥–៤៤ ឆ្នាំ | ២.៨៧៥ | ១.៤២៧ | ១.៤៤៧ | ១.២៣៧ | ៦០៨ | ៦២៨ | ១.៦៣៨ | ៨១៩ | ៨១៩ |
| ៤៥–៥៤ ឆ្នាំ | ១.៨៨៨ | ៨៩០ | ៩៩៨ | ៧៣១ | ៣៤៩ | ៣៨២ | ១.១៥៧ | ៥៤១ | ៦១៦ |
| ៥៥–៦៤ ឆ្នាំ | ១.៥០៦ | ៦៩២ | ៨១៣ | ៥៨៣ | ២៦៧ | ៣១៧ | ៩២២ | ៤២៦ | ៤៩៦ |
| ៦៥+ | ១.៣៦៩ | ៥៤៩ | ៨២០ | ៥៣៤ | ២២០ | ៣១៤ | ៨៣៥ | ៣៣០ | ៥០៦ |
| **សរុប** | **១៣.១៤៤** | **៦.២៩៩** | **៦.៨៤៥** | **៥.៣១៤** | **២.៥៣៧** | **២.៧៧៦** | **៧.៨៣** | **៣.៧៦២** | **៤.០៦៨** |

យោងតាមអង្គការសហប្រជាជាតិ «យុវជន»សំដៅលើបុគ្គលដែលមានអាយុពី ១៥-២៤ឆ្នាំ ខណៈដែល «មនុស្សពេញវ័យ» សំដៅលើបុគ្គលដែលមានអាយុ ២៥ ឆ្នាំឡើង។ នៅឆ្នាំ២០២៥ ប្រជាជនក្នុងវ័យធ្វើការជាយុវជន ត្រូវបានប៉ាន់ប្រមាណថាមានចំនួន ២.៩លាននាក់ ខណៈដែលប្រជាជនក្នុងវ័យធ្វើការជាមនុស្សពេញវ័យមានប្រមាណ ១០.២លាននាក់។

ប្រមាណ៤១,៩% នៃប្រជាជនក្នុងវ័យធ្វើការ មានអាយុពី ១៥-៣៤ឆ្នាំ ដែលឆ្លុះបញ្ចាំងថា ប្រជាជនវ័យក្មេងមានសមាមាត្រច្រើនជាងគេក្នុងរចនាសម្ព័ន្ធប្រជាជនក្នុងវ័យធ្វើការ។ ទន្ទឹមនឹងនេះ មានត្រឹមតែ ១០,៤% នៃប្រជាជនក្នុងវ័យធ្វើការប៉ុណ្ណោះ ដែលមានអាយុចាប់ពី ៦៥ ឆ្នាំឡើងទៅ (រូបភាព ៤.១)។

### រូបភាព ៤.១ ការបែងចែកប្រជាជនក្នុងអាយុធ្វើការតាម ក្រុមអាយុ ភេទ និងតំបន់




## ៤.៣. អត្រាចូលរួមក្នុងកម្លាំងពលកម្ម

តារាង ៤.២ បង្ហាញពីការបែងចែកប្រជាជនក្នុងអាយុធ្វើការតាមស្ថានភាពនៅក្នុងទីផ្សារការងារ រួមមានអ្នកមានការងារធ្វើ អ្នកគ្មានការងារធ្វើ និងអ្នកនៅក្រៅកម្លាំងពលកម្ម (ឬអ្នកអសកម្មផ្នែកសេដ្ឋកិច្ច)។ ក្នុងចំណោមប្រជាជនក្នុងអាយុធ្វើការទាំងអស់ មាន ៦៩,០% (ឬប្រមាណ ៩,១លាននាក់) ត្រូវបានចាត់ថ្នាក់ថាមានការងារធ្វើ ខណៈ ៣,៦% (ឬ ៣៤២.០៦៧ នាក់) ត្រូវបានចាត់ថ្នាក់ថា អ្នកគ្មានការងារធ្វើ និង ២៨,៤% (ឬប្រមាណ ៣,៧លាននាក់) ស្ថិតនៅក្រៅកម្លាំងពលកម្មនៅពេលធ្វើការអង្កេត។

**តារាង ៤.២ ការបែងចែកប្រជាជនក្នុងអាយុធ្វើការតាមស្ថានភាពនៅក្នុងទីផ្សារការងារ អាយុ ភេទ និងតំបន់**

(ចំនួនគិតជាពាន់)

| ស្ថានភាពទីផ្សារការងារ | កម្ពុជា | | | ទីប្រជុំជន | | | ជនបទ | | |
|---|---|---|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| ប្រជាជន | | | | | | | | | |
| សរុបអាយុ១៥+ | ១៣.១៤៤ | ៦.២៩៩ | ៦.៨៤៥ | ៥.៣១៤ | ២.៥៣៧ | ២.៧៧៦ | ៧.៨៣០ | ៣.៧៦២ | ៤.០៦៨ |
| ១៥–៦៤ | ១១.៧៧៥ | ៥.៧៥០ | ៦.០២៥ | ៤.៧៨០ | ២.៣១៨ | ២.៤៦២ | ៦.៩៩៥ | ៣.៤៣២ | ៣.៥៦២ |
| ៦៥+ | ១.៣៦៩ | ៥៤៩ | ៨២០ | ៥៣៤ | ២២០ | ៣១៤ | ៨៣៥ | ៣៣០ | ៥០៦ |
| មានការងារធ្វើ | | | | | | | | | |
| សរុបអាយុ ១៥+ | ៩.០៦៦ | ៤.៧៤៨ | ៤.៣១៨ | ៣.៧២១ | ១.៩០៦ | ១.៨១៤ | ៥.៣៤៥ | ២.៨៤១ | ២.៥០៤ |
| ១៥–៦៤ | ៨.៦០៧ | ៤.៥០៦ | ៤.១០១ | ៣.៥៤៤ | ១.៨១០ | ១.៧៣៣ | ៥.០៦៣ | ២.៦៩៥ | ២.៣៦៨ |
| ៦៥+ | ៤៥៩ | ២៤២ | ២១៧ | ១៧៧ | ៩៦ | ៨១ | ២៨២ | ១៤៦ | ១៣៦ |
| គ្មានការងារធ្វើ | | | | | | | | | |
| សរុបអាយុ **១៥+** | ៣៤២ | ១៤៧ | ១៩៦ | ១៩០ | ៨៦ | ១០៤ | ១៥២ | ៦០ | ៩១ |
| ១៥–៦៤ | ៣៤២ | ១៤៧ | ១៩៥ | ១៩០ | ៨៦ | ១០៤ | ១៥១ | ៦០ | ៩១ |
| ៦៥+ | ០ | - | ០ | - | - | - | ០ | - | ០ |
| នៅក្រៅកម្លាំងពលកម្ម | | | | | | | | | |
| **សរុបអាយុ១៥+** | ៣.៧៣៦ | ១.៤០៥ | ២.៣៣១ | ១.៤០៣ | ៥៤៥ | ៨៥៨ | ២.៣៣៣ | ៨៦០ | ១.៤៧៣ |
| ១៥–៦៤ | ២.៨២៦ | ១.០៩៧ | ១.៧២៩ | ១.០៤៦ | ៤២១ | ៦២៥ | ១.៧៨០ | ៦៧៦ | ១.១០៤ |
| ៦៥+ | ៩១០ | ៣០៧ | ៦០២ | ៣៥៧ | ១២៤ | ២៣៣ | ៥៥៣ | ១៨៤ | ៣៦៩ |

រូបភាព ៤.២ បង្ហាញថា យុវជនដែលមានអាយុពី ១៥–២៤ ឆ្នាំ មានសមាមាត្រ ២២,២% នៃប្រជាជនក្នុងវ័យធ្វើការនៅឆ្នាំ ២០២៥ ប៉ុន្តែមានត្រឹម ១៩,០% ប៉ុណ្ណោះនៃកម្លាំងពលកម្ម។ ផ្ទុយទៅវិញ ក្រុមអាយុ ២៥–៣៤ ឆ្នាំ មានសមាមាត្រ ១៩,៧% នៃប្រជាជនក្នុងវ័យធ្វើការ ប៉ុន្តែមានរហូតដល់ ២៣,៩% នៃកម្លាំងពលកម្ម។ និន្នាការដូចគ្នានេះក៏ត្រូវបានសង្កេតឃើញផងដែរក្នុងក្រុមអាយុ ៣៥–៤៤ ឆ្នាំ និង ៤៥–៥៤ ឆ្នាំ។ ចំណែកឯក្រុមអាយុចាស់ជាងគេ (៦៥ ឆ្នាំឡើងទៅ) មានសមាមាត្រទាបជាងគេទាំងក្នុងចំណោមប្រជាជនក្នុងវ័យធ្វើការ (១០,៤%) និងក្នុងកម្លាំងពលកម្ម (៤,៩%)។

ទោះបីជាក្រុមអាយុ ១៥–២៤ ឆ្នាំ មានសមាមាត្រ ១៩,០% នៃកម្លាំងពលកម្មក៏ដោយ ក៏ក្រុមនេះមានត្រឹមតែ ១៧,៨% នៃអ្នកមានការងារធ្វើ ប៉ុន្តែមានរហូតដល់ ៥១,៤% នៃអ្នកគ្មានការងារធ្វើ។ ផ្ទុយទៅវិញ ក្រុមអាយុ ៤៥ ឆ្នាំឡើង មានសមាមាត្រទាបជាងនៅក្នុងកម្លាំងពលកម្ម ប៉ុន្តែមានសមាមាត្រខ្ពស់ជាងនៅក្នុងចំណោមអ្នកមានការងារធ្វើ និងមានសមាមាត្រទាបជាងនៅក្នុងចំណោមអ្នកគ្មានការងារធ្វើ។

**រូបភាព ៤.២ ការបែងចែកប្រជាជនក្នុងអាយុធ្វើការតាមស្ថានភាពទីផ្សារការងារ និងក្រុមអាយុ**

**(%)**




តារាង ៤.៣ បង្ហាញពីការបែងចែកប្រជាជនក្នុងវ័យធ្វើការតាមស្ថានភាពនៅក្នុងទីផ្សារការងារ កម្រិតអប់រំ និងភេទ។ ក្នុងចំណោមប្រជាជនដែលមានការងារធ្វើនៅឆ្នាំ ២០២៥ មាន ៤២,៩% បានបញ្ចប់ការសិក្សាត្រឹមកម្រិតបឋមសិក្សា ២៥,៥% បានបញ្ចប់ការសិក្សាត្រឹមកម្រិតមធ្យមសិក្សាបឋមភូមិ និង ១៨,៣% បានបញ្ចប់ការសិក្សាត្រឹមកម្រិតមធ្យមសិក្សាទុតិយភូមិ។ មានតែ ៧,៨% ប៉ុណ្ណោះដែលបានបញ្ចប់ការសិក្សាថ្នាក់ឧត្តមសិក្សា ខណៈ ០,៥% ទទួលបានវិញ្ញាបនបត្របណ្តុះបណ្តាលវិជ្ជាជីវៈ។ ទន្ទឹមនឹងនេះ ប្រហែល ៤,៨% នៃប្រជាជនដែលមានការងារធ្វើ មិនធ្លាប់បានចូលរៀនសោះ។ សមាមាត្រនៃអ្នកមានការងារធ្វើដែលបានបញ្ចប់ការសិក្សាត្រឹមកម្រិតបឋមសិក្សា មានខ្ពស់ជាងក្នុងចំណោមស្រី (៤៤,៨%) បើធៀបនឹងប្រុស (៤១,៣%)។ ផ្ទុយទៅវិញ សម្រាប់កម្រិតអប់រំខ្ពស់ជាងនេះ សមាមាត្ររបស់ប្រុសមានខ្ពស់ជាងស្រី។

ក្នុងចំណោមអ្នកគ្មានការងារធ្វើ ២៩,២% បានបញ្ចប់ការសិក្សាត្រឹមកម្រិតបឋមសិក្សា ប្រមាណ ៥១,៤% បានបញ្ចប់ការសិក្សាកម្រិតមធ្យមសិក្សា និង ១៤,៦% បានបញ្ចប់ការសិក្សាថ្នាក់ឧត្តមសិក្សា។ សមាមាត្រនៃអ្នក

គ្មានការងារធ្វើដែលបានបញ្ចប់ការសិក្សាត្រឹមកម្រិតបឋមសិក្សា មានខ្ពស់ជាងក្នុងចំណោមស្រី (៣៣,៣%) បើធៀបនឹងប្រុស (២៣,៦%)។ ផ្ទុយទៅវិញ សម្រាប់កម្រិតអប់រំខ្ពស់ជាងនេះ សមាមាត្ររបស់ប្រុសមានខ្ពស់ជាងស្រី។

**តារាង ៤.៣ ការបែងចែកប្រជាជនក្នុងអាយុធ្វើការតាមស្ថានភាពទីផ្សារការងារ កម្រិតសិក្សា និងភេទ**

| កម្រិតសិក្សា | ប្រជាជនក្នុងអាយុធ្វើការ | មានការងារធ្វើ | គ្មានការងារធ្វើ | កម្លាំងពលកម្ម | នៅក្រៅកម្លាំងពលកម្ម |
|---|---|---|---|---|---|
| **ទាំងពីរភេទ** | | | | | |
| **ប្រជាជន (ចំនួនគិតជាពាន់)** | **១៣.១៤៤** | **៩.០៦៦** | **៣៤២** | **៩.៤០៨** | **៣.៧៣៦** |
| មិនដែលបានរៀន (%) | ៧,៧ | ៤,៨ | ៤,៥ | ៤,៨ | ១៤,៨ |
| បឋមសិក្សា (%) | ៤១,៥ | ៤២,៩ | ២៩,២ | ៤២,៤ | ៣៩,២ |
| មធ្យមសិក្សាបឋមភូមិ (%) | ២៣,៦ | ២៥,៥ | ២០,២ | ២៥,៣ | ១៩,៤ |
| មធ្យមសិក្សាទុតិយភូមិ(%) | ១៩,៤ | ១៨,៣ | ៣១,២ | ១៨,៨ | ២០,៩ |
| បច្ចេកទេស/វិជ្ជាជីវៈ (%) | ០,៤ | ០,៥ | ០,៣ | ០,៥ | ០,២ |
| ឧត្តមសិក្សា (%) | ៧,៣ | ៧,៨ | ១៤,៦ | ៨,១ | ៥,៥ |
| **សរុប (%)** | **១០០** | **១០០** | **១០០** | **១០០** | **១០០** |
| **ប្រុស** | | | | | |
| **ប្រជាជន (ចំនួនគិតជាពាន់)** | **៦.២៩៩** | **៤.៧៤៨** | **១៤៧** | **៤.៨៩៤** | **១.៤០៥** |
| មិនដែលបានរៀន (%) | ៤,៩ | ៣,៧ | ២,៦ | ៣,៧ | ៩,០ |
| បឋមសិក្សា (%) | ៣៩,៨ | ៤១,៣ | ២៣,៦ | ៤០,៧ | ៣៦,៦ |
| មធ្យមសិក្សាបឋមភូមិ (%) | ២៥,៧ | ២៦,៦ | ២៥,៤ | ២៦,៦ | ២២,៥ |
| មធ្យមសិក្សាទុតិយភូមិ(%) | ២១,១ | ១៩,៥ | ៣១,៦ | ១៩,៨ | ២៥,៤ |
| បច្ចេកទេស/វិជ្ជាជីវៈ (%) | ០,៥ | ០,៦ | ០,៥ | ០,៦ | ០,២ |
| ឧត្តមសិក្សា (%) | ៨,១ | ៨,៤ | ១៦,៤ | ៨,៦ | ៦,៣ |
| **សរុប (%)** | **១០០** | **១០០** | **១០០** | **១០០** | **១០០** |
| **ស្រី** | | | | | |
| **ប្រជាជន (ចំនួនគិតជាពាន់)** | **៦.៨៤៥** | **៤.៣១៨** | **១៩៦** | **៤.៥១៤** | **២.៣៣១** |
| មិនដែលបានរៀន (%) | ១០,២ | ៦,១ | ៦,០ | ៦,១ | ១៨,៣ |
| បឋមសិក្សា (%) | ៤៣,១ | ៤៤,៨ | ៣៣,៣ | ៤៤,៣ | ៤០,៨ |
| មធ្យមសិក្សាបឋមភូមិ (%) | ២១,៨ | ២៤,៣ | ១៦,៣ | ២៤,០ | ១៧,៥ |
| មធ្យមសិក្សាទុតិយភូមិ(%) | ១៧,៩ | ១៧,១ | ៣០,៩ | ១៧,៧ | ១៨,២ |
| បច្ចេកទេស/វិជ្ជាជីវៈ (%) | ០,៤ | ០,៥ | ០,២ | ០,៥ | ០,២ |
| ឧត្តមសិក្សា (%) | ៦,៦ | ៧,២ | ១៣,២ | ៧,៥ | ៥,០ |
| **សរុប (%)** | **១០០** | **១០០** | **១០០** | **១០០** | **១០០** |

## ៤.៤ ការចូលរួមក្នុងកម្លាំងពលកម្ម

អត្រាចូលរួមក្នុងកម្លាំងពលកម្ម គឺជាសូចនាករដែលវាស់វែងសមាមាត្រនៃប្រជាជនសកម្មផ្នែកសេដ្ឋកិច្ចធៀបនឹងប្រជាជនសរុបក្នុងអាយុធ្វើការ ដែលបង្ហាញជាភាគរយ។ អត្រាចូលរួមក្នុងកម្លាំងពលកម្មទាប បង្ហាញថាមានតែសមាមាត្រតិចតួចប៉ុណ្ណោះនៃប្រជាជនក្នុងអាយុធ្វើការ ដែលបានចូលរួមក្នុងទីផ្សារការងារ ។

តារាង ៤.៤ បង្ហាញថា អត្រាចូលរួមក្នុងកម្លាំងពលកម្មនៅកម្ពុជាមាន ៧១,៦% ដោយអត្រានេះមានកម្រិតខ្ពស់ជាងក្នុងចំណោមប្រុស (៧៧,៧%) បើធៀបនឹងស្រី (៦៥,៩%)។ អត្រាចូលរួមក្នុងកម្លាំងពលកម្មបានកើនឡើងយ៉ាងឆាប់រហ័សពី ៤៦,៦% ក្នុងក្រុមអាយុ ១៥–១៩ ឆ្នាំ ដល់កម្រិតខ្ពស់បំផុតប្រមាណ ៨៧% ក្នុងក្រុម

អាយុ ២៥–៣៤ ឆ្នាំ បន្ទាប់មកបានថយចុះជាបន្តបន្ទាប់តាមអាយុ រហូតដល់ ៣៣,៥% ក្នុងចំណោមអ្នកដែលមានអាយុ ៦៥ ឆ្នាំឡើងទៅ។ ជារួម តំបន់ទីប្រជុំជន (៧៣,៦%) មានអត្រាចូលរួមក្នុងកម្លាំងពលកម្មខ្ពស់ជាងបន្តិចបើធៀបនឹងតំបន់ជនបទ (៧០,២%) ហើយនៅគ្រប់ក្រុមអាយុ និងគ្រប់តំបន់ទាំងអស់ ប្រុសមានអត្រាចូលរួមក្នុងកម្លាំងពលកម្មខ្ពស់ជាងស្រីជានិច្ច។

**តារាង ៤.៤ អត្រាចូលរួមក្នុងកម្លាំងពលកម្ម តាមក្រុមអាយុ ភេទ និងតំបន់ ឆ្នាំ២០២៥**

(%)

| ក្រុមអាយុ | កម្ពុជា | | | ទីប្រជុំជន | | | ជនបទ | | |
|---|---|---|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| ១៥–១៩ ឆ្នាំ | ៤៦,៦ | ៤៨,៩ | ៤៤,២ | ៤២,៧ | ៤២,៨ | ៤២,៥ | ៤៩,១ | ៥២,៨ | ៤៥,៤ |
| ២០–២៤ ឆ្នាំ | ៧៨,២ | ៨២,០ | ៧៤,២ | ៧៩,២ | ៨២,២ | ៧៦,១ | ៧៧,៦ | ៨១,៩ | ៧៣,០ |
| ២៥–២៩ ឆ្នាំ | ៨៧,០ | ៩១,០ | ៨៣,១ | ៩០,៣ | ៩៣,០ | ៨៧,៩ | ៨៤,៧ | ៨៩,៧ | ៧៩,៦ |
| ៣០–៣៤ ឆ្នាំ | ៨៧,១ | ៩០,៧ | ៨៣,៦ | ៨៩,៣ | ៩១,៧ | ៨៦,៩ | ៨៥,៤ | ៩០,០ | ៨១,២ |
| ៣៥–៣៩ ឆ្នាំ | ៨៦,៩ | ៩១,៩ | ៨១,៦ | ៨៩,៤ | ៩២,៩ | ៨៥,៧ | ៨៥,០ | ៩១,២ | ៧៨,៤ |
| ៤០–៤៤ ឆ្នាំ | ៨៦,៨ | ៩០,៨ | ៨៣,១ | ៩០,៩ | ៩៤,៦ | ៨៧,៧ | ៨៣,៦ | ៨៨,០ | ៧៩,៥ |
| ៤៥–៤៩ ឆ្នាំ | ៧៩,៧ | ៨៥,៧ | ៧៤,៤ | ៨៤,២ | ៩០,០ | ៧៩,០ | ៧៦,៩ | ៨៣,០ | ៧១,៥ |
| ៥០–៥៤ ឆ្នាំ | ៧៧,៥ | ៨៤,១ | ៧១,៤ | ៨០,៤ | ៨៥,៥ | ៧៥,៧ | ៧៥,៥ | ៨៣,២ | ៦៨,៨ |
| ៥៥–៥៩ ឆ្នាំ | ៦៨,១ | ៧៧,៧ | ៥៩,៧ | ៧០,៨ | ៧៩,៩ | ៦៣,១ | ៦៦,៥ | ៧៦,៤ | ៥៧,៥ |
| ៦០–៦៤ ឆ្នាំ | ៥៤,០ | ៦៣,៧ | ៤៦,១ | ៥២,៥ | ៦១,៦ | ៤៥,០ | ៥៤,៩ | ៦៥,១ | ៤៦,៨ |
| ៦៥ ឆ្នាំ + | ៣៣,៥ | ៤៤,០ | ២៦,៥ | ៣៣,១ | ៤៣,៧ | ២៥,៨ | ៣៣,៨ | ៤៤,៣ | ២៧,០ |
| **សរុប** | **៧១,៦** | **៧៧,៧** | **៦៥,៩** | **៧៣,៦** | **៧៨,៥** | **៦៩,១** | **៧០,២** | **៧៧,១** | **៦៣,៨** |

តារាង ៤.៥ បង្ហាញពីកម្រិតអប់រំរបស់ប្រជាជនដែលមានអាយុ ១៥ ឆ្នាំឡើងទៅ និងស្ថិតនៅក្រៅកម្លាំងពលកម្មនៅកម្ពុជាក្នុងឆ្នាំ ២០២៥ ដោយបែងចែកតាមភេទ និងតំបន់រស់នៅ។

ទិន្នន័យបង្ហាញថា កម្រិតអប់រំមុនបឋមសិក្សា គឺជាកម្រិតអប់រំដែលមានច្រើនជាងគេក្នុងចំណោមប្រជាជនដែលស្ថិតនៅក្រៅកម្លាំងពលកម្ម ដោយមានសមាមាត្រ ៣៩,២% នៃចំនួនសរុប។ សមាមាត្រនេះមានខ្ពស់ជាងក្នុងចំណោមស្រី (៤០,៨%) បើធៀបនឹងប្រុស (៣៦,៦%) ហើយក៏មានខ្ពស់ជាងនៅតំបន់ជនបទ (៤២,៨%) បើធៀបនឹងតំបន់ទីប្រជុំជន (៣៣,៤%)។

ប្រជាជនដែលស្ថិតនៅក្រៅកម្លាំងពលកម្មមួយចំណែកគួរឱ្យកត់សម្គាល់ (១៤,៨%) មិនធ្លាប់បានចូលរៀនសោះ។ ស្រីមានសមាមាត្រមិនធ្លាប់បានទទួលការអប់រំផ្លូវការខ្ពស់ជាងប្រុសយ៉ាងច្បាស់ ដោយមាន ១៨,៣% ធៀបនឹង ៩,០%។ ដូចគ្នានេះដែរ សមាមាត្រនេះមានកម្រិតខ្ពស់ជាងនៅតំបន់ជនបទ (១៧,៣%) បើធៀបនឹងតំបន់ទីប្រជុំជន (១០,៦%)។

អ្នកដែលបានបញ្ចប់ការសិក្សាត្រឹមកម្រិតបឋមសិក្សា មានសមាមាត្រ ១៩,៤% នៃប្រជាជនដែលស្ថិតនៅក្រៅកម្លាំងពលកម្ម។ ប្រុសមានសមាមាត្រខ្ពស់ជាងស្រី (២២,៥% ធៀបនឹង ១៧,៥%)។

អ្នកដែលបានបញ្ចប់ការសិក្សាត្រឹមកម្រិតមធ្យមសិក្សាបឋមភូមិ មានសមាមាត្រ ២០,៩% នៃប្រជាជនដែលស្ថិតនៅក្រៅកម្លាំងពលកម្ម។ ប្រុសមានសមាមាត្រខ្ពស់ជាងស្រីក្នុងការសម្រេចបានកម្រិតអប់រំនេះ ដោយ

មាន ២៥,៤% និង ១៨,២% រៀងគ្នា។ ចំណែកអ្នករស់នៅតំបន់ទីប្រជុំជនមានសមាមាត្រខ្ពស់ជាង (២៥,៤%) បើធៀបនឹងអ្នករស់នៅតំបន់ជនបទ (១៨,២%)។

មានតែសមាមាត្រតិចតួចប៉ុណ្ណោះ (0,២%) ដែលបានបញ្ចប់ការសិក្សាត្រឹមកម្រិតមធ្យមសិក្សាទុតិយភូមិ ដោយមិនមានភាពខុសគ្នាគួរឱ្យកត់សម្គាល់តាមភេទ ឬតំបន់រស់នៅឡើយ។ ដូចគ្នានេះដែរ ការបញ្ចប់ការសិក្សាផ្នែកបណ្ដុះបណ្ដាលវិជ្ជាជីវៈ នៅតែមានសមាមាត្រទាប ដោយមានត្រឹម ៥,៥% នៃប្រជាជនសរុបដែលស្ថិតនៅក្រៅកម្លាំងពលកម្ម។ ទោះជាយ៉ាងណា អ្នកដែលបានបញ្ចប់ការបណ្ដុះបណ្ដាលវិជ្ជាជីវៈមានសមាមាត្រខ្ពស់ជាងនៅតំបន់ទីប្រជុំជន (៨,៥%) បើធៀបនឹងតំបន់ជនបទ (៣,៦%)។

**តារាង ៤.៥ ប្រជាជនដែលស្ថិតនៅក្រៅកម្លាំងពលកម្មមានអាយុ ១៥ ឆ្នាំឡើងទៅ តាមកម្រិតអប់រំ ភេទ និងតំបន់ ឆ្នាំ ២០២៥**

| កម្រិតអប់រំ | កម្ពុជា | | | ទីប្រជុំជន | | | ជនបទ | | |
|---|---|---|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| | | | | | ចំនួនគិតជាពាន់ | | | | |
| មិនដែលបានរៀន | ៥៥២ | ១២៦ | ៤២៦ | ១៤៨ | ៣៣ | ១១៥ | ៤០៤ | ៩៣ | ៣១០ |
| បឋមសិក្សា | ១.៤៦៦ | ៥១៤ | ៩៥២ | ៤៦៨ | ១៥៧ | ៣១១ | ៩៩៨ | ៣៥៧ | ៦៤១ |
| មធ្យមសិក្សាបឋមភូមិ | ៧២៥ | ៣១៦ | ៤០៩ | ៣០៧ | ១៣០ | ១៧៧ | ៤១៨ | ១៨៧ | ២៣១ |
| មធ្យមសិក្សាទុតិយភូមិ | ៧៨២ | ៣៥៧ | ៤២៥ | ៣៥៦ | ១៧១ | ១៨៥ | ៤២៦ | ១៨៦ | ២៤០ |
| បច្ចេកទេស/វិជ្ជាជីវៈ | ៧ | ៣ | ៤ | ៤ | ២ | ២ | ៣ | ១ | ២ |
| ឧត្តមសិក្សា | ២០៥ | ៨៩ | ១១៦ | ១២០ | ៥២ | ៦៨ | ៨៥ | ៣៦ | ៤៨ |
| **សរុប** | **៣.៧៣៦** | **១.៤០៥** | **២.៣៣១** | **១.៤០៣** | **៥៤៥** | **៨៥៨** | **២.៣៣៣** | **៨៦០** | **១.៤៧៣** |
| | | | | | **%** | | | | |
| មិនដែលបានរៀន | ១៤,៨ | ៩,០ | ១៨,៣ | ១០,៦ | ៦,០ | ១៣,៤ | ១៧,៣ | ១០,៩ | ២១,១ |
| បឋមសិក្សា | ៣៩,២ | ៣៦,៦ | ៤០,៨ | ៣៣,៤ | ២៨,៨ | ៣៦,២ | ៤២,៨ | ៤១,៥ | ៤៣,៥ |
| មធ្យមសិក្សាបឋមភូមិ | ១៩,៤ | ២២,៥ | ១៧,៥ | ២១,៩ | ២៣,៨ | ២០,៧ | ១៧,៩ | ២១,៧ | ១៥,៧ |
| មធ្យមសិក្សាទុតិយភូមិ | ២០,៩ | ២៥,៤ | ១៨,២ | ២៥,៤ | ៣១,៥ | ២១,៥ | ១៨,២ | ២១,៦ | ១៦,៣ |
| បច្ចេកទេស/វិជ្ជាជីវៈ | 0,២ | 0,២ | 0,២ | 0,៣ | 0,៣ | 0,២ | 0,១ | 0,១ | 0,១ |
| ឧត្តមសិក្សា | ៥,៥ | ៦,៣ | ៥,0 | ៨,៥ | ៩,៦ | ៧,៩ | ៣,៦ | ៤,២ | ៣,៣ |
| **សរុប (%)** | **១០០** | **១០០** | **១០០** | **១០០** | **១០០** | **១០០** | **១០០** | **១០០** | **១០០** |

នៅឆ្នាំ២០២៥ អត្រាចូលរួមក្នុងកម្លាំងពលកម្ម ថ្នាក់ជាតិ មានកម្រិតខ្ពស់បំផុតនៅក្នុងក្រុមអាយុ ៣០–៣៤ ឆ្នាំ ហើយបានចាប់ផ្តើមថយចុះជាបន្តបន្ទាប់ទៅតាមក្រុមអាយុចាស់ជាងនេះ។ និន្នាការស្រដៀងគ្នានេះក៏ត្រូវបានសង្កេតឃើញចំពោះស្រីផងដែរ ដោយអត្រាចូលរួមក្នុងកម្លាំងពលកម្មរបស់ស្រីបានកើនឡើងយ៉ាងឆាប់រហ័សដល់ ៨៣,៦% នៅក្នុងក្រុមអាយុ ៣០–៣៤ ឆ្នាំ បន្ទាប់មកបានថយចុះជាបន្តបន្ទាប់ រហូតដល់ ២៦,៥% ក្នុងក្រុមអាយុ ៦៥ ឆ្នាំ និងលើសពីនេះ។ ផ្ទុយទៅវិញ អត្រាចូលរួមក្នុងកម្លាំងពលកម្មរបស់ប្រុសបានឈានដល់កម្រិតខ្ពស់បំផុត ៩១,៩% នៅក្នុងក្រុមអាយុ ៣៥–៣៩ឆ្នាំ មុននឹងថយចុះមកនៅត្រឹម ៤៤,0% ក្នុងក្រុមអាយុ ៦៥ ឆ្នាំ និងលើសពីនេះ (រូបភាព ៤.៣)។

**រូបភាព ៤.៣ អត្រាចូលរួមក្នុងកម្លាំងពលកម្ម តាមក្រុមអាយុ និងភេទ**

(%)




## ៤.៥. ការងារផលិតកម្មសម្រាប់ចិញ្ចឹមជីវិត

សមិទ្ធផលដ៏សំខាន់មួយនៃសន្និសីទអន្តរជាតិស្តីពីអ្នកស្ថិតិការងារលើកទី១៩ ដែលបានប្រារព្ធឡើងនៅឆ្នាំ២០១៣ គឺការណែនាំឱ្យផលិតស្ថិតិស្តីពីអ្នកផលិតស្បៀងអាហារសម្រាប់ការប្រើប្រាស់ដោយ ខ្លួនឯង ។ ផ្នែកនេះបង្ហាញទិន្នន័យអំពីបុគ្គលដែលបានចូលរួមក្នុងសកម្មភាពផលិតកម្មសម្រាប់ការប្រើប្រាស់ដោយខ្លួនឯង និងអ្នកផលិតស្បៀងអាហារសម្រាប់ការប្រើប្រាស់ដោយខ្លួនឯង។

ផលិតកម្មសម្រាប់ការប្រើប្រាស់ដោយខ្លួនឯង សំដៅលើសកម្មភាពទាំងឡាយដែលធ្វើឡើងដើម្បីផលិត ទំនិញ ឬ ផ្តល់សេវាកម្មសម្រាប់ការប្រើប្រាស់ចុងក្រោយរបស់គ្រួសារ ឬសមាជិកគ្រួសារ។ សកម្មភាពទាំងនេះរួមមាន៖

(i) ការផលិត និង/ឬការកែច្នៃសម្រាប់រក្សាទុកនូវផលិតផលកសិកម្ម នេសាទ បរបាញ់ និងការប្រមូលផលពីធម្មជាតិ។

(ii) ការប្រមូលអាហារព្រៃ ដូចជា ផ្សិត ផ្លែប៊ឺរី និងរុក្ខជាតិឱសថ។

(iii) ការបរបាញ់សត្វព្រៃសម្រាប់យកសាច់ និងផលិតផលផ្សេងៗ។

(iv) ការរៀបចំ និងកែច្នៃអាហារ ឬភេសជ្ជៈសម្រាប់រក្សាទុក ដូចជា ម្សៅ ត្រីងៀត និងផលិតផលស្រដៀងគ្នា។

(v) ការសាងសង់ ការជួសជុល ឬការពង្រីកលំនៅឋានផ្ទាល់ខ្លួន អគារកសិដ្ឋាន និងសំណង់ផ្សេងៗសម្រាប់ប្រើប្រាស់ដោយគ្រួសារ។

(vi) ការផលិតសម្ភារៈប្រើប្រាស់ ដូចជា កន្ទេល កន្ត្រក គ្រឿងសង្ហារឹម និងសម្លៀកបំពាក់។

(vii) ការទៅយកទឹកពីប្រភពទឹកធម្មជាតិ ឬប្រភពទឹកសាធារណៈសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ។

(viii) ការប្រមូលអុស ឬផលិតផលធម្មជាតិផ្សេងទៀតសម្រាប់ប្រើប្រាស់ជាឥន្ធនៈ។

អ្នកផលិតស្បៀងអាហារសម្រាប់ការប្រើប្រាស់ដោយខ្លួនឯងគឺជាក្រុមសំខាន់មួយនៃបុគ្គលដែលចូលរួមក្នុងសកម្មភាពផលិតកម្មសម្រាប់ការប្រើប្រាស់ដោយខ្លួនឯង។អ្នកទាំងនេះត្រូវបានកំណត់និយមន័យថា៖

(i) បុគ្គលទាំងអស់ដែលបានអនុវត្តសកម្មភាពណាមួយក្នុងការផលិត និង/ឬកែច្នៃសម្រាប់រក្សាទុកនូវផលិតផលពីវិស័យកសិកម្ម នេសាទ បរបាញ់ និងការប្រមូលផលពីធម្មជាតិ ជាស្បៀងអាហារ ដែលរួមចំណែកដល់ការចិញ្ចឹមជីវភាពរបស់គ្រួសារ។

(ii) មិនរាប់បញ្ចូលបុគ្គលដែលចូលរួមក្នុងសកម្មភាពផលិតកម្មទាំងនេះ ដើម្បីគោលបំណងកម្សាន្ត ឬលំហែកាយនោះទេ។

សូមកត់សម្គាល់ថា ក្នុងកម្រងសំណួរអង្កេតនេះ បានរាប់បញ្ចូលតែបុគ្គលដែលចូលរួមក្នុងផលិតកម្មទំនិញសម្រាប់ការប្រើប្រាស់ដោយខ្លួនឯងតែប៉ុណ្ណោះ ដោយមិនបានរាប់បញ្ចូលបុគ្គលដែលចូលរួមក្នុង ការងារថែទាំដោយមិនទទួលបានកម្រៃនោះទេ។ នៅក្នុងការអង្កេតនាពេលអនាគត សកម្មភាពផ្តល់សេវាកម្មសម្រាប់ការប្រើប្រាស់ដោយខ្លួនឯង ដូចជា ការងារថែទាំ និងការងារផ្ទះដោយមិនទទួលបានកម្រៃ អាចនឹងត្រូវបានដាក់បញ្ចូលក្នុងការប្រមូលទិន្នន័យផងដែរ។

លទ្ធផលនៃការអង្កេតបង្ហាញថា ផលិតកម្មសម្រាប់ការប្រើប្រាស់ដោយខ្លួនឯង នៅតែជាសកម្មភាពចិញ្ចឹមជីវភាពដ៏សំខាន់មួយនៅក្នុងប្រទេសកម្ពុជា ជាពិសេសនៅតំបន់ជនបទ។ ប្រុសមានទំនោរចូលរួមក្នុងសកម្មភាពនេះច្រើនជាងស្រី ខណៈដែលការចូលរួមមានកម្រិតខ្ពស់បំផុតក្នុងចំណោមមនុស្សវ័យចាស់ និងអ្នកដែលមានការងារធ្វើ។ការផលិតស្បៀងអាហារសម្រាប់ការប្រើប្រាស់ដោយខ្លួនឯង មានចំណែកភាគច្រើននៃសកម្មភាពផលិតកម្មសម្រាប់ការប្រើប្រាស់ដោយខ្លួនឯង ដែលឆ្លុះបញ្ចាំងពីតួនាទីដ៏សំខាន់ជាបន្តបន្ទាប់របស់វិស័យកសិកម្ម និងការផលិតស្បៀងអាហារក្នុងគ្រួសារ ក្នុងការទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាជននៅតំបន់ជនបទ និងការធានាសន្តិសុខស្បៀង។

តារាង ៤.៥ បង្ហាញថា មានប្រជាជនប្រមាណ ១.៨៣០.៤៦៨ នាក់ ស្មើនឹង ១៣,៩% នៃប្រជាជនអាយុ ១៥ឆ្នាំ និងលើសពីនេះ បានចូលរួមក្នុងសកម្មភាពផលិតកម្មសម្រាប់ការប្រើប្រាស់ដោយខ្លួនឯង ក្នុងអំឡុងពេល ៧ថ្ងៃ មុនថ្ងៃសម្ភាសន៍។ ប្រុសមានអត្រាចូលរួមក្នុងសកម្មភាពនេះខ្ពស់ជាងស្រី ដោយមាន ១៧,៩% ធៀបនឹង ១០,៣%រៀងគ្នា។ តាមក្រុមអាយុ ប្រជាជនអាយុ២៥–៦៤ឆ្នាំ មានសមាមាត្រចូលរួមក្នុងសកម្មភាពផលិតកម្មសម្រាប់ការប្រើប្រាស់ដោយខ្លួនឯងខ្ពស់ជាងគេ គឺ១៧,៨%នៃប្រជាជនក្នុងវ័យធ្វើការ រីឯយុវជនអាយុ ១៥–២៤ឆ្នាំ មានសមាមាត្រ ៨,៧% ខណៈដែលប្រជាជនអាយុ ៦៥ ឆ្នាំ និងលើសពីនេះ មានសមាមាត្រ ១៦,០%។

តាមស្ថានភាពក្នុងទីផ្សារការងារ សមាមាត្រខ្ពស់ជាងគេនៃបុគ្គលដែលបានចូលរួមក្នុងផលិតកម្មសម្រាប់ការប្រើប្រាស់ដោយខ្លួនឯង គឺស្ថិតក្នុងចំណោមអ្នកមានការងារធ្វើ (១៨,៥%) បន្ទាប់មកគឺអ្នកគ្មានការងារធ្វើ (៦,០%) និងអ្នកនៅក្រៅកម្លាំងពលកម្ម (៣,៥%) ។ ក្នុងចំណោមអ្នកនៅក្រៅកម្លាំងពលកម្ម សមាមាត្រប្រុសដែលបានចូលរួមក្នុងផលិតកម្មសម្រាប់ការប្រើប្រាស់ដោយខ្លួនឯង មានខ្ពស់ជាងស្រី (៤,២% ធៀបនឹង ៣,០%)។ និន្នាការស្រដៀងគ្នានេះត្រូវបានសង្កេតឃើញផងដែរ ក្នុងចំណោមអ្នកផលិតស្បៀងអាហារសម្រាប់ការប្រើប្រាស់ដោយខ្លួនឯង

## តារាង ៤.៦ ការចូលរួមក្នុងផលិតកម្មសម្រាប់ការប្រើប្រាស់ដោយខ្លួនឯង តាមក្រុមអាយុ ស្ថានភាពក្នុងទីផ្សារការងារ ភេទ និងតំបន់

| ប្រភេទ | កម្ពុជា | | | ទីប្រជុំជន | | | ជនបទ | | |
|---|---|---|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| **ផលិតកម្មសម្រាប់ចិញ្ចឹមជីវិតសរុប ដោយប្រជាជនក្នុងអាយុធ្វើការ** | | | | | | | | | |
| អ្នកផលិតសម្រាប់ចិញ្ចឹមជីវិត ដោយប្រជាជនក្នុងអាយុធ្វើការ (ចំនួន) | ១.៨៣០.៣៦៨ | ១.១២៦.១០៦ | ៧០៤.២៦២ | ៣២៩.៧៨០ | ២០៩.៥៧៣ | ១២០.២០៦ | ១.៥០០.៥៨៨ | ៩១៦.៥៣២ | ៥៨៤.០៥៦ |
| សមាមាត្រនៃប្រជាជនក្នុងអាយុធ្វើការ (%) | ១៣,៩ | ១៧,៩ | ១០,៣ | ៦,២ | ៨,៣ | ៤,៣ | ១៩,២ | ២៤,៤ | ១៤,៤ |
| តាមក្រុមអាយុ (%) | | | | | | | | | |
| ១៥–២៤ | ៨,៧ | ១១,៣ | ៦,១ | ៣,៤ | ៥,០ | ១,៨ | ១២,២ | ១៥,៣ | ៩,០ |
| ២៥–៦៤ | ៧,៨ | ៨,៣ | ៦,៩ | ៦,៥ | ៧,៦ | ៤,៦ | ៨,១ | ៨,៥ | ៧,៤ |
| ៦៥+ | ១៦,០ | ២០,៦ | ១១,៩ | ៧,៤ | ៩,៦ | ៥,៤ | ២១,៩ | ២៨,៣ | ១៦,៣ |
| តាមស្ថានភាពទីផ្សារការងារ (%) | | | | | | | | | |
| មានការងារធ្វើ | ១៨,៥ | ២២,៣ | ១៤,៤ | ៨,១ | ១០,៣ | ៥,៩ | ២៥,៨ | ៣០,៤ | ២០,៥ |
| គ្មានការងារធ្វើ | ៦,០ | ៥,៩ | ៦,១ | ១,៧ | ១,៣ | ២,១ | ១១,៥ | ១២,៥ | ១០,៨ |
| នៅក្រៅកម្លាំងពលកម្ម | ៣,៥ | ៤,២ | ៣,០ | ១,៧ | ២,៤ | ១,៣ | ៤,៦ | ៥,៤ | ៤,១ |
| **ផលិតកម្មសម្រាប់ចិញ្ចឹមជីវិត ដោយប្រជាជនក្នុងអាយុធ្វើការ មិនធ្វើការងារ** | | | | | | | | | |
| អ្នកផលិតសម្រាប់ចិញ្ចឹមជីវិតដោយប្រជាជនក្នុងអាយុធ្វើការ មិនធ្វើការងារ (ចំនួន) | ១៥០.៧៩១ | ៦៧.៧១៥ | ៨៣.០៧៦ | ២៧.១២៦ | ១៤.០៩៣ | ១៣.០៣៣ | ១២៣.៦៦៥ | ៥៣.៦២២ | ៧០.០៤៣ |
| សមាមាត្រនៃប្រជាជនក្នុងអាយុធ្វើការ (%) | ១,១ | ១,១ | ១,២ | ០,៥ | ០,៦ | ០,៥ | ១,៦ | ១,៤ | ១,៧ |
| តាមក្រុមអាយុ (%) | | | | | | | | | |
| ១៥–២៤ | ២,៧ | ២,៥ | ២,៩ | ១,០ | ១,១ | ០,៩ | ៣,៨ | ៣,៤ | ៤,២ |
| ២៥–៦៤ | ០,៤ | ០,៤ | ០,៣ | ០,១ | ០,៣ | - | ០,៥ | ០,៥ | ០,៥ |
| ៦៥+ | ០,៨ | ០,៧ | ០,៨ | ០,៤ | ០,៤ | ០,៤ | ១,០ | ០,៩ | ១,១ |
| ផលិតកម្មសម្រាប់ចិញ្ចឹមជីវិតសរុប ដោយប្រជាជនក្នុងអាយុធ្វើការ | | | | | | | | | |
| អ្នកផលិតស្បៀងអាហារសម្រាប់ចិញ្ចឹមជីវិត (ចំនួន) | ១.៤៥១.១២៧ | ៨៨៣.៦៩៨ | ៥៦៧.៤២៩ | ២៧៦.៣៦៤ | ១៧៦.១៩១ | ១០០.១៧៤ | ១.១៧៤.៧៦៣ | ៧០៧.៥០៧ | ៤៦៧.២៥៦ |
| សមាមាត្រនៃប្រជាជនក្នុងអាយុធ្វើការ (%) | ១១,០ | ១៤,០ | ៨,៣ | ៥,២ | ៦,៩ | ៣,៦ | ១៥,០ | ១៨,៨ | ១១,៥ |
| តាមក្រុមអាយុ (%) | | | | | | | | | |
| ១៥–២៤ | ៦,៧ | ៨,៥ | ៤,៨ | ២,៨ | ៤,១ | ១,៤ | ៩,២ | ១១,៣ | ៧,១ |
| ២៥–៦៤ | ៨០,៥ | ៨០,៦ | ៨០,៤ | ៨២,០ | ៨០,៩ | ៨៣,៩ | ៨០,២ | ៨០,៥ | ៧៩,៦ |
| ៦៥+ | ១,០ | ១,១ | ០,៩ | ០,៥ | ០,៦ | ០,៤ | ១,៣ | ១,៥ | ១,២ |
| តាមស្ថានភាពទីផ្សារការងារ (%) | | | | | | | | | |
| មានការងារធ្វើ | ១៤,៧ | ១៧,៤ | ១១,៦ | ៦,៨ | ៨,៦ | ៤,៩ | ២០,១ | ២៣,៣ | ១៦,៥ |
| គ្មានការងារធ្វើ | ៥,៦ | ៥,៩ | ៥,៤ | ១,៥ | ១,៣ | ១,៧ | ១០,៨ | ១២,៥ | ៩,៧ |
| នៅក្រៅកម្លាំងពលកម្ម | ២,៨ | ៣,៤ | ២,៤ | ១,៥ | ២,១ | ១,១ | ៣,៦ | ៤,៣ | ៣,១ |

# ជំពូក ៥
# ភាពមានការងារធ្វើ

## ៥.១. សេចក្ដីផ្ដើម

ទិន្នន័យស្ដីពីការងារធ្វើ ផ្ដល់នូវសូចនាករសេដ្ឋកិច្ច និងសង្គមដ៏សំខាន់ សម្រាប់ការយល់ដឹងអំពីស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។ លើសពីនេះ ស្ថិតិស្ដីពីការងារធ្វើ បង្ហាញពីចំនួនប្រជាជនដែលមានការងារធ្វើ ប្រភេទការងារដែលពួកគេកំពុងបំពេញ កម្រិតអប់រំ និងជំនាញដែលសមស្របនឹងការងាររបស់ពួកគេ ព្រមទាំងលក្ខណៈនៃការធ្វើការងាររបស់ពួកគេ។

ជំពូកនេះ បង្ហាញព័ត៌មានអំពីលក្ខណៈរបស់ប្រជាជនមានការងារធ្វើ ដូចជា មុខរបរ និងសកម្មភាពសេដ្ឋកិច្ចដែលពួកគេកំពុងបំពេញ កម្រិតការអប់រំ ស្ថានភាពក្នុងការងារ និងអត្រាការងារធ្វើធៀបនឹងប្រជាជនក្នុងវ័យធ្វើការ

## ៥.២. ប្រជាជនមានការងារធ្វើ

តារាង ៥.១ បង្ហាញពីចំនួន និងការបែងចែកជាភាគរយនៃប្រជាជនមានការងារធ្វើក្នុងវ័យធ្វើការ តាមក្រុមអាយុ តំបន់ និងភេទ។ ប្រជាជនមានការងារធ្វើ ត្រូវបានប៉ាន់ប្រមាណមានចំនួន ៩ ០៦៥ ៦៤៩ នាក់ ក្នុងនោះប្រុសមានចំនួន ៥២,៤% និងស្រីមានចំនួន ៤៧,៦%។ ប្រជាជនមានការងារធ្វើភាគច្រើនរស់នៅតំបន់ជនបទដែលមានសមាមាត្រ ៥៩,០% ខណៈដែល ៤១,០% រស់នៅតំបន់ទីប្រជុំជន។ ជារួម ប្រុសមានសមាមាត្រច្រើនជាងស្រីក្នុងចំណោមប្រជាជនមានការងារធ្វើ ទាំងនៅតំបន់ទីប្រជុំជន (៥១,២%) និងតំបន់ជនបទ (៥៣,២%)។ ផ្ទុយទៅវិញ ក្នុងក្រុមអាយុ ១៥–២៤ ឆ្នាំ ប្រជាជនមានការងារធ្វើភាគច្រើន ទាំងនៅតំបន់ទីប្រជុំជន និងតំបន់ជនបទ គឺជាស្រី។

ប្រជាជនមានការងារធ្វើជាងពាក់កណ្ដាល ស្ថិតក្នុងក្រុមអាយុ ២០–៣៩ ឆ្នាំ។ ក្រុមអាយុក្មេងជាងគេ (១៥–១៩ ឆ្នាំ) មានសមាមាត្រ ៧,១% ខណៈដែលបុគ្គលដែលមានអាយុ ៦០ ឆ្នាំឡើងទៅ មានសមាមាត្រ ៩,១%។

**តារាង ៥.១ ការបែងចែកភាគរយប្រជាជនមានការងារធ្វើ តាមក្រុមអាយុ តំបន់ និងភេទ ឆ្នាំ ២០២៥**

(%)

| ក្រុមអាយុ | កម្ពុជា | | | ទីប្រជុំជន | | | ជនបទ | | |
|---|---|---|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| ១៥–១៩ ឆ្នាំ | ៧,១ | ៧,២ | ៦,៩ | ៥,៧ | ៥,៥ | ៥,៨ | ៨,១ | ៨,៤ | ៧,៧ |
| ២០–២៤ ឆ្នាំ | ១០,៧ | ១១, | ១០,៣ | ១០,០ | ១០,១ | ៩,៨ | ១១,១ | ១១,៦ | ១០,៧ |
| ២៥–២៩ ឆ្នាំ | ១១,៦ | ១១,៥ | ១១,៧ | ១១,៦ | ១១,០ | ១២,២ | ១១,៦ | ១១,៨ | ១១,៤ |
| ៣០–៣៤ ឆ្នាំ | ១២,៦ | ១២,១ | ១៣,១ | ១៣,៤ | ១៣,១ | ១៣,៨ | ១២,០ | ១១,៤ | ១២,៦ |
| ៣៥–៣៩ ឆ្នាំ | ១៣,៨ | ១៤,៤ | ១៣,១ | ១៤,៧ | ១៥,៤ | ១៤,០ | ១៣,១ | ១៣,៧ | ១២,៥ |
| ៤០–៤៤ ឆ្នាំ | ១៣,២ | ១២,៧ | ១៣,៧ | ១៤,៥ | ១៤,១ | ១៥,០ | ១២,២ | ១១,៧ | ១២,៨ |
| ៤៥–៤៩ ឆ្នាំ | ៩,៣ | ៩,០ | ៩,៧ | ៩,៣ | ៩,២ | ៩,៤ | ៩,៤ | ៨,៩ | ៩,៩ |
| ៥០–៥៤ ឆ្នាំ | ៦,៦ | ៦,៦ | ៦,៦ | ៦,៦ | ៦,៧ | ៦,៤ | ៦,៧ | ៦,៦ | ៦,៧ |
| ៥៥–៥៩ ឆ្នាំ | ៦,២ | ៦,៤ | ៥,៩ | ៥,៩ | ៦,១ | ៥,៦ | ៦,៤ | ៦,៥ | ៦,១ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ៦០–៦៤ ឆ្នាំ | ៤,០ | ៤,០ | ៣,៩ | ៣,៧ | ៣,៨ | ៣,៦ | ៤,២ | ៤,១ | ៤,២ |
| ៦៥ ឆ្នាំ + | ៥,១ | ៥,១ | ៥,០ | ៤,៨ | ៥,០ | ៤,៥ | ៥,៣ | ៥,១ | ៥,៤ |
| **សរុប** | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ |
| សរុប(ចំនួនគិតពាន់) | ៩.០៦៦ | ៤.៧៤៨ | ៤.៣១៨ | ៣.៧២១ | ១.៩០៦ | ១.៨១៤ | ៥.៣៤៥ | ២.៨៤១ | ២.៥០៤ |

## ៥.៣ ភាពមានការងារធ្វើតាមមុខរបរ

«មុខរបរ» សំដៅលើភារកិច្ច ឬការងារចម្បងដែលបុគ្គលម្នាក់អនុវត្តនៅកន្លែងការងាររបស់ខ្លួន។ ការអង្កេតកម្លាំងពលកម្មនៅកម្ពុជាឆ្នាំ២០២៥ បានប្រើប្រាស់ការចាត់ថ្នាក់មុខរបរស្តង់ដារអន្តរជាតិ ឆ្នាំ២០០៨ (២០០៨: ISCO-0៨)ដើម្បីចាត់ថ្នាក់កម្មករ និយោជិត និងអ្នកមានការងារធ្វើជា ១០ ក្រុមមុខរបរសំខាន់ៗ។

រូបភាព ៥.១ បង្ហាញពីការបែងចែកជាភាគរយនៃប្រជាជនមានការងារធ្វើតាមមុខរបរ ។ អ្នកផ្តល់ផ្នែកសេវាកម្ម និងការលក់ មានសមាមាត្រខ្ពស់ជាងគេ គឺ២៣,២%បន្ទាប់មកគឺអ្នកជំនាញផ្នែកកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មាន ២២,១% ប្រតិបត្តិករម៉ាស៊ីន និងការីម៉ាស៊ីន មាន ១៨,០% កងកម្លាំងប្រដាប់អាវុធមាន ០,៩% អ្នកធ្វើសិប្បកម្ម និងអាជីវកម្មពាក់ព័ន្ធ មាន ១១,៥% ខណៈដែលអ្នកធ្វើមុខរបរងាយៗ មានសមាមាត្រទាបជាងគេ គឺ ១១,៧% នៃប្រជាជនមានការងារធ្វើសរុប។

**រូបភាព ៥.១ ការបែងចែកប្រជាជនមានការងារធ្វើ តាមប្រភេទមុខរបរ**




រូបភាព ៥.២ បង្ហាញថា ប្រុសមានសមាមាត្រច្រើនជាងក្នុងចំណោមប្រជាជនមានការងារធ្វើនៅក្នុងក្រុមមុខរបរភាគច្រើន ខណៈដែលស្រីមានសមាមាត្រខ្ពស់ជាងក្នុងក្រុមមុខរបរជាក់លាក់មួយចំនួន។

ប្រុសមានសមាមាត្រខ្ពស់គួរឱ្យកត់សម្គាល់ក្នុងចំណោមអ្នកធ្វើសិប្បកម្ម និងមុខរបរពាក់ព័ន្ធ (៨០,២% ជាប្រុស ធៀបនឹង ១៩,៨% ជាស្រី) កងកម្លាំងប្រដាប់អាវុធ (៩៥,៣%ជាប្រុស ធៀបនឹង ៤,៧%ជាស្រី) និងអ្នក

ជំនាញកសិកម្ម (៥៣,៩% ធៀបនឹង ៤៦,១%)។ ផ្ទុយទៅវិញ ស្រីមានសមាមាត្រខ្ពស់ជាងក្នុងចំណោមកម្មករ និងអ្នកផ្តល់សេវាកម្ម និងការលក់ (៦៣,៧%ជាស្រី ធៀបនឹង ៣៦,៣% ជាប្រុស) ការីម៉ាស៊ីន និងអ្នកបញ្ជាម៉ាស៊ីន ព្រមទាំងអ្នកដំឡើងផលិតផល (៥២,៦% ជាស្រីធៀបនឹង ៤៧,៤% ជាប្រុស) និងអ្នកមានវិជ្ជាជីវៈ (៥២,៨%ជាស្រី ធៀបនឹង ៤៧,២% ជាប្រុស)។ គម្លាតយេនឌ័រធំបំផុត ត្រូវបានសង្កេតឃើញក្នុងចំណោមកម្មករ និងអ្នកផ្តល់សេវាកម្ម និងការលក់ ដែលស្រីមានសមាមាត្រខ្ពស់ជាងប្រុសយ៉ាងច្បាស់។

**រូបភាព ៥.២ ការបែងចែកប្រជាជនមានការងារធ្វើ តាមប្រភេទមុខរបរ និងភេទ**

(%)




តារាង ៥.២ បង្ហាញពីការបែងចែកប្រជាជនមានការងារធ្វើតាមមុខរបរ និងកម្រិតការអប់រំដែលបានបញ្ចប់ ដោយផ្អែកលើការចាត់ថ្នាក់មុខរបរស្តង់ដារអន្តរជាតិ ឆ្នាំ២០០៨ (ISCO-08)។ សរុបមក មានប្រជាជនមានការងារធ្វើប្រមាណ ៩ ០៦៦ ពាន់នាក់។ ក្នុងចំណោមនោះ ភាគច្រើនបានបញ្ចប់ការអប់រំបឋមសិក្សា (៣ ៨៩២ ពាន់នាក់) បន្ទាប់មកគឺអប់រំមធ្យមសិក្សាបឋមភូមិ (២ ៣១៣ ពាន់នាក់) ខណៈដែលមានប្រមាណ ៧១០ ពាន់នាក់ បានបញ្ចប់ការអប់រំថ្នាក់ឧត្តមសិក្សា។

កម្មករ និងនិយោជិតផ្នែកសេវាកម្ម និងការលក់ ជាក្រុមមុខរបរដែលមានសមាមាត្រខ្ពស់ជាងគេ ដោយមានចំណែក ២៣,២% នៃប្រជាជនមានការងារធ្វើសរុប។ សមាមាត្រនេះមានកម្រិតខ្ពស់ជាពិសេសក្នុងចំណោមអ្នកដែលបានបញ្ចប់មធ្យមសិក្សាទុតិយភូមិ (២៨,៨%) និងមធ្យមសិក្សាបឋមភូមិ (២៤,៦%) ដែលបង្ហាញថា មុខរបរនេះទាក់ទាញកម្មករ និងនិយោជិតដែលមានប្រវត្តិការអប់រំចម្រុះ។

អ្នកជំនាញផ្នែកកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាក្រុមមុខរបរធំលំដាប់ទីពីរ ដែលមានចំណែក ២២,១% នៃប្រជាជនមានការងារធ្វើសរុប។ មុខរបរនេះប្រមូលផ្តុំជាចម្បងក្នុងចំណោមអ្នកដែលមានកម្រិតការអប់រំទាប ដោយមានសមាមាត្រ ៤៧,៥% ក្នុងចំណោមអ្នកមិនដែលបានចូលរៀន និង ២៩,១% ក្នុងចំណោម

អ្នកដែលបានបញ្ចប់បឋមសិក្សា។ ផ្ទុយទៅវិញ មានតែ ១,៤% ប៉ុណ្ណោះនៃអ្នកដែលបានបញ្ចប់ការអប់រំថ្នាក់ឧត្តមសិក្សា ដែលធ្វើការក្នុងវិស័យកសិកម្ម។

ការីម៉ាស៊ីន និងព្រមទាំងអ្នកដំឡើងផលិតផល មានចំណែក ១៨,០% នៃប្រជាជនមានការងារធ្វើសរុប ហើយត្រូវបានសង្កេតឃើញច្រើនក្នុងចំណោមអ្នកដែលបានបញ្ចប់មធ្យមសិក្សាបឋមភូមិ (២៥,៨%) និងបឋមសិក្សា (១៨,៥%)។ សមាមាត្ររបស់ក្រុមមុខរបរនេះបានថយចុះយ៉ាងច្បាស់ ក្នុងចំណោមអ្នកដែលបានបញ្ចប់បច្ចេកទេស/វិជ្ជាជីវៈ និងថ្នាក់ឧត្តមសិក្សា។

អ្នកធ្វើមុខរបរងាយៗ មានចំណែក ១១,៧% នៃប្រជាជនមានការងារធ្វើសរុប។ មុខរបរនេះមានសមាមាត្រខ្ពស់ជាងក្នុងចំណោមអ្នកដែលមានកម្រិតការអប់រំទាប ដោយមាន ១៦,៤% ក្នុងចំណោមអ្នកមិនដែលបានចូលរៀន និង ១៤,៧% ក្នុងចំណោមអ្នកដែលបានបញ្ចប់បឋមសិក្សា ប៉ុន្តែមានត្រឹមតែ ១,៩% ប៉ុណ្ណោះ ក្នុងចំណោមអ្នកដែលបានបញ្ចប់ថ្នាក់ឧត្តមសិក្សា។

អ្នកធ្វើសិប្បកម្ម និងមុខរបរពាក់ព័ន្ធ មានចំណែក ១១,៥% នៃប្រជាជនមានការងារធ្វើសរុប ហើយមានការបែងចែកប្រហាក់ប្រហែលគ្នាក្នុងចំណោមអ្នកដែលបានបញ្ចប់បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ ដោយមានសមាមាត្រ ១២,៤% និង ១២,៨% រៀងគ្នា។

នៅកម្រិតសិក្សាខ្ពស់ ការងារធ្វើមាននិន្នាការប្រមូលផ្តុំកាន់តែច្រើនក្នុងក្រុមអ្នកជំនាញ។ ក្នុងចំណោមអ្នកដែលបានបញ្ចប់បច្ចេកទេស/វិជ្ជាជីវៈ ៦៥,២% កំពុងបំពេញការងារជាអ្នកជំនាញ បើធៀបនឹង ៣០,៤% ក្នុងចំណោមអ្នកដែលបានបញ្ចប់ថ្នាក់ឧត្តមសិក្សា។ អ្នកដែលបានបញ្ចប់ថ្នាក់ឧត្តមសិក្សា ក៏មាននិន្នាការច្រើនក្នុងការបំពេញការងារជាអ្នកជំនាញ (៣០,៤%) កម្មករ និងអ្នកផ្តល់សេវាកម្ម និងការលក់ (២២,១%) អ្នកបច្ចេកទេស (១៤,០%) និងស្មៀន (១៣,៩%)។

### តារាង ៥.២ ប្រជាជនមានការងារធ្វើ តាមកម្រិតសិក្សា និងប្រភេទមុខរបរ

| មុខរបរ (ISCO-08) | កម្រិតសិក្សា | | | | | | |
|---|---|---|---|---|---|---|---|
| | សរុប | មិនដែលបានចូលរៀន | បឋមសិក្សា | មធ្យមសិក្សាបឋមភូមិ | មធ្យមសិក្សាទុតិយភូមិ | បច្ចេកទេស/វិជ្ជាជីវៈ | ឧត្តមសិក្សា |
| | | | ចំនួនគិតជាពាន់ | | | | |
| **សរុប** | **៩.០៦៦** | **៤៣៩** | **៣.៨៩២** | **២.៣១៣** | **១.៦៦៣** | **៥០** | **៧១០** |
| អ្នកគ្រប់គ្រង | ១៥៩ | ១ | ៣៦ | ៣២ | ៣៧ | ៣ | ៥១ |
| អ្នកមានជំនាញវិជ្ជាជីវៈ | ៤០០ | ១ | ២១ | ៣០ | ១០០ | ៣២ | ២១៦ |
| អ្នកបច្ចេកទេស | ៣២០ | ៣ | ៧០ | ៦៣ | ៨០ | ៤ | ៩៩ |
| ស្មៀន | ២៥១ | ១ | ២៨ | ៤៩ | ៧៥ | ១ | ៩៨ |
| អ្នកផ្តល់សេវា និងលក់ | ២.១០៧ | ៨៥ | ៨១៥ | ៥៦៨ | ៤៧៨ | ៤ | ១៥៧ |
| អ្នកជំនាញកសិកម្ម | ២.០០៧ | ២០៩ | ១.១៣៤ | ៤០៦ | ២៤៩ | ០ | ១០ |
| អ្នកធ្វើកសិកម្ម និងអាជីវកម្ម | ១.០៤៤ | ៤០ | ៤៨៤ | ២៩៧ | ១៨៧ | ៣ | ៣៣ |
| ការីម៉ាស៊ីន | ១.៦៣១ | ២៦ | ៧២០ | ៥៩៨ | ២៦៨ | ១ | ១៩ |
| អ្នកធ្វើមុខរបរងាយៗ | ១.០៦៣ | ៧២ | ៥៧១ | ២៥៧ | ១៤៩ | - | ១៣ |
| កងកម្លាំងប្រដាប់អាវុធ | ៨៤ | ២ | ១៣ | ១៤ | ៤០ | ១ | ១៣ |
| | | | % | | | | |
| **សរុប** | **១០០** | **១០០** | **១០០** | **១០០** | **១០០** | **១០០** | **១០០** |
| អ្នកគ្រប់គ្រង | ១,៨ | ០,១ | ០,៩ | ១,៤ | ២,២ | ៥,២ | ៧,២ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| អ្នកមានជំនាញវិជ្ជាជីវៈ | ៤,៤ | ០,៣ | ០,៥ | ១,៣ | ៦,០ | ៦៥,២ | ៣០,៤ |
| អ្នកបច្ចេកទេស | ៣,៥ | ០,៨ | ១,៨ | ២,៧ | ៤,៨ | ៧,៨ | ១៤,០ |
| ស្មៀន | ២,៨ | ០,១ | ០,៧ | ២,១ | ៤,៥ | ៣,០ | ១៣,៩ |
| អ្នកផ្តល់សេវា និងលក់ | ២៣,២ | ១៩,៤ | ២០,៩ | ២៤,៦ | ២៨,៨ | ៧,៣ | ២២,១ |
| អ្នកជំនាញកសិកម្ម | ២២,១ | ៤៧,៥ | ២៩,១ | ១៧,៥ | ១៥,០ | ០,៩ | ១,៤ |
| អ្នកធ្វើកសិកម្ម និងអាជីវកម្ម | ១១,៥ | ៩,០ | ១២,៤ | ១២,៨ | ១១,៣ | ៦,៥ | ៤,៦ |
| ការីម៉ាស៊ីន | ១៨,០ | ៦,០ | ១៨,៥ | ២៥,៨ | ១៦,១ | ១,៣ | ២,៦ |
| អ្នកធ្វើមុខរបរងាយៗ | ១១,៧ | ១៦,៤ | ១៤,៧ | ១១,១ | ៩,០ | - | ១,៩ |

## ៥.៤. ភាពមានការងារធ្វើតាមវិស័យឧស្សាហកម្ម

ដូចដែលបានបង្ហាញក្នុងតារាង ៥.៣ វិស័យសេវាកម្មមានសមាមាត្រខ្ពស់ជាងគេនៃប្រជាជនមានការងារធ្វើ ដែលស្មើនឹង ៤៣,០%។ ចំណែកវិស័យឧស្សាហកម្មមាន ២៩,៤% និងវិស័យកសិកម្មមាន ២៧,៦%។

តារាងដដែលនេះក៏បង្ហាញផងដែរថា ប្រមាណម្នាក់ក្នុងចំណោមបីនាក់នៃប្រជាជនមានការងារធ្វើនៅកម្ពុជាបានបម្រើការងារនៅក្នុង វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមិនមានភាពខុសគ្នាគួរឱ្យកត់សម្គាល់តាមភេទឡើយ។ ទោះជាយ៉ាងណា ភាពខុសគ្នារវាងប្រុស និងស្រីត្រូវបានសង្កេតឃើញនៅក្នុងវិស័យមិនមែនកសិកម្មផ្សេងទៀត។ ស្រីមានសមាមាត្រការងារខ្ពស់ជាងនៅក្នុងវិស័យសេវាកម្ម (៤៥,៣%) និង វិស័យកម្មន្តសាល (២៥,៨%)។

**តារាង ៥.៣ ប្រជាជនមានការងារធ្វើ តាមវិស័យសេដ្ឋកិច្ចនិងភេទ**

| ឧស្សាហកម្ម (ISIC Rev. ៤) | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
|---|---|---|---|---|---|---|
| | | ចំនួន | | | (%) | |
| **កសិកម្ម** | **២.៥០២** | **១.៣៧៤** | **១.១២៧** | **២៧,៦** | **២៨,៩** | **២៦,១** |
| ផលិតកម្ម ដំណាំ និងចិញ្ចឹមសត្វ សកម្មភាពបរបាញ់ និង សេវាកម្មពាក់ព័ន្ធ | ២.៣១៤ | ១.២៤១ | ១.០៧៣ | ២៥,៥ | ២៦,១ | ២៤,៩ |
| រុក្ខាប្រមាញ់ និងការកាប់ព្រៃឈើ | ៣៨ | ២១ | ១៧ | ០,៤ | ០,៤ | ០,៤ |
| ការនេសាទ និងវារីវប្បកម្ម | ១៥០ | ១១៣ | ៣៧ | ១,៧ | ២,៤ | ០,៩ |
| **ឧស្សាហកម្ម** | **២.៦៧០** | **១.៤៣៤** | **១.២៣៦** | **២៩,៤** | **៣០,២** | **២៨,៦** |
| រុករករ៉ែ និងថ្ម | ១២ | ១១ | ០ | ០,១ | ០,២ | ០,០ |
| ការផលិតផ្នែកកាត់ដេរសំលៀកបំពាក់ | ១.៨២៣ | ៧១០ | ១.១១៣ | ២០,១ | ១៥,០ | ២៥,៨ |
| ផ្គត់ផ្គង់អគ្គិសនី ឧស្ម័ន ចំហាយ និងម៉ាស៊ីនត្រជាក់ | ២២ | ១៩ | ៣ | ០,២ | ០,៤ | ០,១ |
| ផ្គត់ផ្គង់ទឹក គ្រប់គ្រងសំរាម លូទឹក និងសកម្មភាពកែលម្អ | ៤៩ | ៣១ | ១៧ | ០,៥ | ០,៧ | ០,៤ |
| សំណង់ | ៧៦៥ | ៦៦៣ | ១០២ | ៨,៤ | ១៤,០ | ២,៤ |
| **សេវាកម្ម** | **៣.៨៩៤** | **១.៩៣៩** | **១.៩៥៥** | **៤៣,០** | **៤០,៨** | **៤៥,៣** |
| លក់ដុំ និងលក់រាយ ជួសជុលយានយន្ត | ១.៦៥២ | ៦០៦ | ១.០៤៦ | ១៨,២ | ១២,៨ | ២៤,២ |
| ដឹកជញ្ជូន និងស្តុកទំនិញ | ៤១៩ | ៣៩៣ | ២៥ | ៤,៦ | ៨,៣ | ០,៦ |
| សកម្មភាពសេវាកម្មស្នាក់នៅ និងអាហារ | ៣៦១ | ១៣៣ | ២២៨ | ៤,០ | ២,៨ | ៥,៣ |
| ព័ត៌មាន និងទំនាក់ទំនង | ៣១ | ២៥ | ៦ | ០,៣ | ០,៥ | ០,១ |
| សកម្មភាពហិរញ្ញវត្ថុ និងធានារ៉ាប់រង | ១២៦ | ៨១ | ៤៥ | ១,៤ | ១,៧ | ១,០ |
| សកម្មភាពអចលនទ្រព្យ | ៣០ | ១៥ | ១៥ | ០,៣ | ០,៣ | ០,៣ |
| សកម្មភាពវិជ្ជាជីវៈ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា | ៧៤ | ៣២ | ៤៣ | ០,៨ | ០,៧ | ១,០ |
| សកម្មភាពរដ្ឋបាល និងសេវាកម្មគាំទ្រ | ២៧៤ | ១៧០ | ១០៣ | ៣,០ | ៣,៦ | ២,៤ |
| រដ្ឋបាលសាធារណៈ និងការពារ សន្តិសុខសង្គមជាកាតព្វកិច្ច | ២៨០ | ២២៧ | ៥៣ | ៣,១ | ៤,៨ | ១,២ |

| | | | | | | |
|---|---|---|---|---|---|---|
| អប់រំ | ២០៨ | ៩៤ | ១១៤ | ២,៣ | ២,០ | ២,៦ |
| សកម្មភាពសុខភាពមនុស្ស និងកិច្ចការសង្គម | ៧៣ | ៣២ | ៤១ | ០,៨ | ០,៧ | ០,៩ |
| សិល្បៈ កម្សាន្ត និងសប្បាយ | ១០១ | ៤៥ | ៥៦ | ១,១ | ០,៩ | ១,៣ |
| សកម្មភាពសេវាកម្មដទៃទៀត | ២១០ | ៧៥ | ១៣៥ | ២,៣ | ១,៦ | ៣,១ |
| សកម្មភាពគ្រួសារជានិយោជក និងសកម្មភាពផលិតទំនិញ និង សេវាកម្មគ្រូវគ្នារបស់គ្រួសារសម្រាប់ប្រើប្រាស់ខ្លួនឯង | ៥១ | ៨ | ៤៣ | ០,៦ | ០,២ | ១,០ |
| សកម្មភាពអង្គការ និងអង្គភាពក្រៅប្រទេស | ៦ | ២ | ៤ | ០,១ | ០,១ | ០,១ |
| សរុប | ៩.០៦៦ | ៤.៧៤៨ | ៤.៣១៨ | ១០០ | ១០០ | ១០០ |

## ៥.៥. ភាពមានការងារធ្វើតាមកម្រិតអប់រំ

តារាង ៥.៤ បង្ហាញពីការបែងចែកជាភាគរយនៃប្រជាជនមានការងារធ្វើតាមកម្រិតអប់រំដែលបានបញ្ចប់។ ដូចដែលបានរៀបរាប់ខាងលើ ប្រមាណ ៤,៨% នៃប្រជាជនមានការងារធ្វើ មិនដែលបានចូលរៀន។ ប្រហែល ៤២,៩% នៃប្រជាជនមានការងារធ្វើសរុប បានបញ្ចប់បឋមសិក្សា ខណៈដែល ៣៩,២% បានបញ្ចប់មធ្យមសិក្សា (មធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ)។ មានតែ ៧,៨% ប៉ុណ្ណោះ ដែលបានបញ្ចប់ថ្នាក់ឧត្តមសិក្សា និង ៥,២% បានបញ្ចប់ថ្នាក់បច្ចេកទេស/វិជ្ជាជីវៈ។

ការអប់រំបឋមសិក្សា គឺជាកម្រិតសិក្សាដែលមានច្រើនជាងគេក្នុងចំណោមប្រជាជនមានការងារធ្វើ ដោយមានសមាមាត្រ ៤២,៩% នៃប្រជាជនមានការងារធ្វើសរុប។ សមាមាត្រនេះមានកម្រិតខ្ពស់ជាងបន្តិចក្នុងចំណោមស្រី (៤៤,៧%) បើធៀបនឹងប្រុស (៤១,២%)។ តំបន់ជនបទមានសមាមាត្រប្រជាជនមានការងារធ្វើដែលបានបញ្ចប់បឋមសិក្សាខ្ពស់ជាងតំបន់ទីប្រជុំជនយ៉ាងច្បាស់ ដោយមាន ៤៨,៤% ធៀបនឹង ៣៥,០%។

អ្នកដែលបានបញ្ចប់មធ្យមសិក្សាបឋមភូមិ មានចំណែកធំលំដាប់ទីពីរ ដោយមានសមាមាត្រ ២៥,៥% នៃប្រជាជនមានការងារធ្វើ។ សមាមាត្រនេះមានភាពប្រហាក់ប្រហែលគ្នារវាងប្រុស (២៦,៦%) និងស្រី (២៤,៣%) ព្រមទាំងរវាងតំបន់ទីប្រជុំជន (២៥,៦%) និងតំបន់ជនបទ (២៥,៤%)។

បញ្ចប់មធ្យមសិក្សាទុតិយភូមិ មានចំណែក ១៣,៧% នៃប្រជាជនមានការងារធ្វើនៅទូទាំងប្រទេស។ ប្រុស (១៤,៤%) មានសមាមាត្រខ្ពស់ជាងស្រី (១៣,០%) បន្តិច ក្នុងការបានបញ្ចប់មធ្យមសិក្សាទុតិយភូមិ។ ប្រជាជនមានការងារធ្វើនៅតំបន់ទីប្រជុំជន មានសមាមាត្រខ្ពស់ជាងអ្នកនៅតំបន់ជនបទ ដោយមាន ១៥,៦% ធៀបនឹង ១២,៤%

ការអប់រំបច្ចេកទេស/វិជ្ជាជីវៈ នៅតែមានសមាមាត្រទាប ដោយមានត្រឹមតែ ៥,២% នៃប្រជាជនមានការងារធ្វើប៉ុណ្ណោះ។ សមាមាត្រនេះមានកម្រិតខ្ពស់ជាងនៅតំបន់ទីប្រជុំជន (៧,០%) បើធៀបនឹងតំបន់ជនបទ (៣,៩%)។ ប្រុស (៥,៦%) ក៏មានសមាមាត្រខ្ពស់ជាងស្រី (៤,៦%) បន្តិច ក្នុងការបានបញ្ចប់ការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ។

ថ្នាក់ឧត្តមសិក្សា មានចំណែក ៧,៨% នៃប្រជាជនមានការងារធ្វើសរុប។ តំបន់ទីប្រជុំជនមានសមាមាត្រប្រជាជនមានការងារធ្វើដែលបានបញ្ចប់ថ្នាក់ឧត្តមសិក្សាខ្ពស់ជាងតំបន់ជនបទយ៉ាងច្បាស់ ដោយមាន ១៣,៥% ធៀបនឹង ៣,៩%។ ដូចគ្នានេះដែរ ប្រុស (៨,៤%) មានសមាមាត្រខ្ពស់ជាងស្រី (៧,២%) បន្តិច ក្នុងការបានបញ្ចប់ថ្នាក់ឧត្តមសិក្សា។

### តារាង ៥.៤ ប្រជាជនមានការងារធ្វើ តាមកម្រិតសិក្សា តំបន់ និងភេទ

| កម្រិតសិក្សា | កម្ពុជា | | | ទីប្រជុំជន | | | ជនបទ | | |
|---|---|---|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| | | | | | ចំនួនគិតជាពាន់ | | | | |
| **សរុប** | **៩.០៦៦** | **៤,៧៤៨** | **៤,៣១៨** | **៣,៧២១** | **១,៩០៦** | **១,៨១៤** | **៥,៣៤៥** | **២,៨៤១** | **២,៥០៤** |
| មិនដែលបានរៀន | ៤៣៩ | ១៧៧ | ២៦២ | ១១៩ | ៤២ | ៧៨ | ៣១៩ | ១៣៥ | ១៨៤ |
| បឋមសិក្សា | ៣.៨៩២ | ១.៩៥៩ | ១.៩៣៣ | ១.៣០២ | ៦១៦ | ៦៨៦ | ២.៥៩០ | ១.៣៤៣ | ១.២៤៧ |
| មធ្យមសិក្សាបឋមភូមិ | ២.៣១៣ | ១.២៦២ | ១.០៥១ | ៩៥៤ | ៤៨២ | ៤៧២ | ១.៣៥៨ | ៧៨០ | ៥៧៨ |
| មធ្យមសិក្សាទុតិយភូមិ | ១.៦៦៣ | ៩២៤ | ៧៣៩ | ៨២០ | ៤៧៥ | ៣៤៥ | ៨៤៣ | ៤៤៩ | ៣៩៤ |
| បច្ចេកទេស/វិជ្ជាជីវៈ | ៥០ | ២៩ | ២១ | ២២ | ១១ | ១១ | ២៨ | ១៨ | ១០ |
| ឧត្តមសិក្សា | ៧១០ | ៣៩៧ | ៣១៣ | ៥០៣ | ២៨១ | ២២២ | ២០៧ | ១១៧ | ៩០ |
| | | | | | % | | | | |
| **សរុប** | **១០០** | **១០០** | **១០០** | **១០០** | **១០០** | **១០០** | **១០០** | **១០០** | **១០០** |
| មិនដែលបានរៀន | ៤,៨ | ៣,៧ | ៦,១ | ៣,២ | ២,២ | ៤,៣ | ៦ | ៤,៨ | ៧,៤ |
| បឋមសិក្សា | ៤២,៩ | ៤១.២ | ៤៤.៧ | ៣៥ | ៣២.៣ | ៣៧.៧ | ៤៨.៤ | ៤៧.២ | ៤៩.៧ |
| មធ្យមសិក្សាបឋមភូមិ | ២៥,៥ | ២៦,៦ | ២៤,៣ | ២៥,៦ | ២៥,៣ | ២៦ | ២៥,៤ | ២៧,៥ | ២៣,១ |
| មធ្យមសិក្សាទុតិយភូមិ | ១៣,៧ | ១៤,៤ | ១៣ | ១៥,៦ | ១៧,៥ | ១៣,៦ | ១២,៤ | ១២,៤ | ១២,៥ |
| បច្ចេកទេស/វិជ្ជាជីវៈ | ៥,២ | ៥,៦ | ៤,៦ | ៧ | ៨ | ៦ | ៣,៩ | ៤ | ៣,៦ |
| ឧត្តមសិក្សា | ៧,៨ | ៨,៤ | ៧,២ | ១៣,៥ | ១៤,៧ | ១២,៣ | ៣,៩ | ៤,១ | ៣,៦ |

## ៥.៦. អត្រាអ្នកមានការងារធ្វើធៀបនឹងចំនួនប្រជាជនក្នុងវ័យធ្វើការ

រូបភាព ៥.៣ បង្ហាញអំពីអត្រាការងារធ្វើធៀបនឹងប្រជាជនក្នុងវ័យធ្វើការតាមក្រុមអាយុ និងភេទនៅកម្ពុជា។ លទ្ធផលបង្ហាញថា ការចូលរួមក្នុងការងារមានភាពខុសគ្នាគួរឱ្យកត់សម្គាល់តាមក្រុមអាយុ ហើយអត្រាការងារធ្វើរបស់ប្រុសមានកម្រិតខ្ពស់ជាងស្រីជាប្រចាំ។

រូបភាព ៥.៣ បង្ហាញថា អត្រាការងារធ្វើធៀបនឹងប្រជាជនក្នុងវ័យធ្វើការ បានកើនឡើងពី ៥៥,១% ក្នុងចំណោមយុវជនអាយុ ១៥–២៤ ឆ្នាំ ដល់កម្រិតខ្ពស់បំផុត ៨៤,៩% ក្នុងចំណោមប្រជាជនអាយុ ៣៥–៤៤ ឆ្នាំ បន្ទាប់មកបានថយចុះជាបន្តបន្ទាប់តាមការកើនឡើងនៃអាយុ រហូតនៅសល់ត្រឹម ៣៣,៥% ក្នុងចំណោមប្រជាជនដែលមានអាយុ ៦៥ ឆ្នាំ និងលើស។ នៅគ្រប់ក្រុមអាយុទាំងអស់ ប្រុសតែងតែមានអត្រាការងារធ្វើធៀបនឹងប្រជាជនក្នុងវ័យធ្វើការខ្ពស់ជាងស្រី។ គម្លាតយេនឌ័រមានកម្រិតតិចតួចក្នុងចំណោមមនុស្សវ័យក្មេង ប៉ុន្តែបានកើនឡើងនៅក្រុមអាយុចាស់ជាង ជាពិសេសក្នុងក្រុមអាយុ ៥៥–៦៤ ឆ្នាំ និង ៦៥ ឆ្នាំ និងលើស។ ជារួម លទ្ធផលនេះបង្ហាញថា ការចូលរួមក្នុងការងារមានកម្រិតខ្ពស់បំផុតក្នុងវ័យធ្វើការសំខាន់ (២៥–៤៤ ឆ្នាំ) ហើយមាននិន្នាការថយចុះនៅពេលដែលប្រជាជនឈានចូលវ័យចូលនិវត្តន៍។

### រូបភាព ៥.៣ អត្រាការងារធ្វើធៀបនឹងប្រជាជនតាមក្រុមអាយុ និងភេទ

(%)




## ៥.៧ ស្ថានភាពអ្នកមានការងារធ្វើ

ទាក់ទងនឹងស្ថានភាពក្នុងការងារ អ្នកមានការងារធ្វើត្រូវបានចែកចេញជាពីរប្រភេទធំៗ គឺ និយោជិតទទួលប្រាក់ឈ្នួល ឬប្រាក់បៀវត្ស និង អ្នកប្រកបការងារដោយខ្លួនឯង។ អ្នកប្រកបការងារដោយខ្លួនឯងអាចបែងចែកបន្ថែមជាបីក្រុម រួមមាន និយោជក អ្នកធ្វើការដោយទុនផ្ទាល់ខ្លួន និងអ្នកធ្វើការអោយគ្រួសារមិនយកប្រាក់ឈ្នួល។ គោលគំនិតនៃស្ថានភាពក្នុងការងារគ្របដណ្តប់លើលក្ខណៈនៃការបំពេញការងារ ប្រភេទការងារ និងលក្ខខណ្ឌការងារ។ សមាមាត្រខ្ពស់នៃអ្នកប្រកបការងារដោយខ្លួនឯង អាចបង្ហាញថាវិស័យកសិកម្មមានទំហំធំ ខណៈដែលសមាមាត្រខ្ពស់នៃនិយោជិតទទួលប្រាក់ឈ្នួល ឬប្រាក់បៀវត្ស អាចឆ្លុះបញ្ចាំងពីការធ្វើពិពិធកម្មឱកាសការងារស្របតាមការអភិវឌ្ឍសេដ្ឋកិច្ច។

តារាង ៥.៥ បង្ហាញពីការបែងចែកអ្នកមានការងារធ្វើតាមស្ថានភាពក្នុងការងារ។ នៅឆ្នាំ២០២៥ សមាមាត្រធំបំផុតនៃអ្នកមានការងារធ្វើ គឺនិយោជិតទទួលប្រាក់ឈ្នួល ឬប្រាក់បៀវត្ស ដែលមានចំណែក ៥០,១% បន្ទាប់មកគឺ អ្នកធ្វើការដោយទុនផ្ទាល់ខ្លួន(២២,២%) អ្នកធ្វើការមានកិច្ចសន្យា(១៩,៩%) និយោជក (៥,០%) និង អ្នកធ្វើការអោយគ្រួសារមិនយកប្រាក់ឈ្នួល (២,៧%)។

### តារាង ៥.៥ ប្រជាជនមានការងារធ្វើ តាមស្ថានភាពអ្នកមានការងារធ្វើ

| ស្ថានភាពអ្នកមានការងារធ្វើ | ទាំងពីរភេទ | ប្រុស | ស្រី |
|---|---|---|---|
| ចំនួនតាមប្រភេទនីមួយ (គិតជាពាន់) | | | |
| និយោជក | ៤៥០ | ២៨៧ | ១៦៣ |
| អ្នកធ្វើការដោយទុនផ្ទាល់ខ្លួន | ២.០១៧ | ៩១០ | ១.១០៧ |
| អ្នកធ្វើការមានកិច្ចសន្យា | ១.៨០៣ | ៩១៦ | ៨៨៧ |
| និយោជិត | ៤.៥៤០ | ២,៥៣២ | ២.០០៧ |
| អ្នកធ្វើការអោយគ្រួសារមិនយកប្រាក់ឈ្នួល | ២៤៩ | ១០០ | ១៤៩ |

| សរុប (ចំនួន) | **៩.០៦៦** | **៤.៧៤៨** | **៤.៣១៨** |
|---|---|---|---|
| ភាគរយតាមប្រភេទនីមួយ | | | |
| និយោជក | ៥,០ | ៦,០ | ៣,៨ |
| អ្នកធ្វើការដោយទុនផ្ទាល់ខ្លួន | ២២,២ | ១៩,២ | ២៥,៦ |
| អ្នកធ្វើការមានកិច្ចសន្យា | ១៩,៩ | ១៩,៣ | ២០,៦ |
| និយោជិត | ៥០,១ | ៥៣,៣ | ៤៦,៥ |
| អ្នកធ្វើការអោយគ្រួសារមិនយកប្រាក់ឈ្នួល | ២,៧ | ២,១ | ៣,៤ |
| **សរុប** (%) | **១០០** | **១០០** | **១០០** |

# ជំពូក ៦
# ការងារក្នុងវិស័យក្រៅប្រព័ន្ធ និងក្នុងប្រព័ន្ធ

## ៦.១ សេចក្តីផ្តើម

ជំពូកនេះបង្ហាញពីទិន្នន័យស្តីពីការងារនៅក្នុង វិស័យក្រៅប្រព័ន្ធ និង វិស័យក្នុងប្រព័ន្ធ នៅប្រទេសកម្ពុជា។ វិស័យក្រៅប្រព័ន្ធ គឺជាផ្នែកដ៏សំខាន់មួយនៃសេដ្ឋកិច្ច និងទីផ្សារការងារនៅក្នុងប្រទេសជាច្រើន ជាពិសេសប្រទេសកំពុងអភិវឌ្ឍន៍។ ដូច្នេះ ការវាស់វែងការចូលរួមចំណែករបស់វិស័យក្រៅប្រព័ន្ធចំពោះការងារ ព្រមទាំងការចូលរួមចំណែករបស់វិស័យនេះចំពោះ ផលិតផលក្នុងស្រុកសរុប (GDP) មានសារៈសំខាន់ណាស់។ លើសពីនេះ វិស័យក្រៅប្រព័ន្ធដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតការងារ ការផលិត និងការបង្កើតប្រាក់ចំណូល។ អត្រាការងារក្រៅប្រព័ន្ធ ត្រូវបានចាត់ទុកថាជាសូចនាករសំខាន់មួយសម្រាប់វាស់វែងគុណភាពការងារនៅក្នុងសេដ្ឋកិច្ច ដែលមានសារៈសំខាន់ស្មើគ្នាទាំងសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសឧស្សាហកម្ម។

## ៦.២ វិស័យក្រៅប្រព័ន្ធ និងក្នុងប្រព័ន្ធ

តារាង៦.១ បង្ហាញពីការបែងចែកអ្នកមានការងារធ្វើតាមវិស័យសេដ្ឋកិច្ច រួមមាន វិស័យកសិកម្ម ឧស្សាហកម្ម និងសេវាកម្ម ដោយបែងចែកតាម វិស័យក្រៅប្រព័ន្ធ, វិស័យក្នុងប្រព័ន្ធ និងភេទ។

នៅក្នុង វិស័យក្រៅប្រព័ន្ធ វិស័យសេវាកម្មមានសមាមាត្រអ្នកមានការងារធ្វើខ្ពស់ជាងគេ ដោយមានចំណែក៤០,៤% នៃអ្នកមានការងារធ្វើ បន្ទាប់មកគឺ វិស័យកសិកម្ម(៣៨,៩%) និង វិស័យឧស្សាហកម្ម(២០,៨%)។ ប្រុសមានសមាមាត្រប្រមូលផ្តុំច្រើននៅក្នុង វិស័យកសិកម្ម(៣៩,៧%) និង វិស័យឧស្សាហកម្ម(២៧,០%) ខណៈដែលស្រីភាគច្រើនមានការងារធ្វើនៅក្នុង វិស័យសេវាកម្ម(៤៨,៦%) ដែលបង្ហាញពីការចូលរួមខ្ពស់របស់ស្រីក្នុងសកម្មភាពសេវាកម្មនៃវិស័យក្រៅប្រព័ន្ធ។

នៅក្នុង វិស័យក្នុងប្រព័ន្ធ ការងារភាគច្រើនប្រមូលផ្តុំនៅក្នុង វិស័យឧស្សាហកម្ម ដែលមានចំណែក ៤៨,៧% នៃអ្នកមានការងារធ្វើក្នុងវិស័យក្នុងប្រព័ន្ធទាំងអស់ បន្ទាប់មកគឺ វិស័យសេវាកម្ម ខណៈដែល វិស័យកសិកម្ម មានចំណែកត្រឹមតែ ២,៦% ប៉ុណ្ណោះ។ ស្រីមានសមាមាត្រខ្ពស់ជាងក្នុងការងារវិស័យសេវាកម្មក្នុងប្រព័ន្ធ(៥៩,៦%) បើប្រៀបធៀបនឹងប្រុស(៣៨,៦%)។ ផ្ទុយទៅវិញ ប្រុសមានសមាមាត្រធ្វើការនៅក្នុងវិស័យឧស្សាហកម្មក្នុងប្រព័ន្ធខ្ពស់ជាងស្រី(៥៩,២% ធៀបនឹង៣៧,៩%)។

បើពិចារណាអ្នកមានការងារធ្វើទាំងនៅក្នុង វិស័យក្នុងប្រព័ន្ធ និង វិស័យក្រៅប្រព័ន្ធ រួមបញ្ចូលគ្នា (សរុបរង) វិស័យសេវាកម្មមានសមាមាត្រអ្នកមានការងារធ្វើខ្ពស់ជាងគេ ដោយមានចំណែក៤៣,០% បន្ទាប់មកគឺ វិស័យឧស្សាហកម្ម(២៩,៤%) និង វិស័យកសិកម្ម(២៧,៦%)។ ស្រីមានសមាមាត្រប្រមូលផ្តុំច្រើននៅក្នុងវិស័យសេវាកម្ម(៤៥,៣%) ខណៈដែលប្រុសមានការបែងចែកការងារស្មើៗគ្នាជាងរវាង វិស័យសេវាកម្ម(៤០,៨%) វិស័យឧស្សាហកម្ម(៣០,២%) និង វិស័យកសិកម្ម(២៨,៩%)។

**តារាង ៦.១ ប្រជាជនមានការងារធ្វើ នៅក្នុងវិស័យក្រៅប្រព័ន្ធ និងក្នុងប្រព័ន្ធតាមវិស័យសេដ្ឋកិច្ច**

| វិស័យសេដ្ឋកិច្ច | ទាំងពីរភេទ | ប្រុស (ចំនួន) | ស្រី | ទាំងពីរភេទ | ប្រុស (%) | ស្រី |
|---|---|---|---|---|---|---|
| | | **ផ្នែកក្រៅប្រព័ន្ធ** | | | | |
| កសិកម្ម | ២.៤២៧ | ១.៣៣៣ | ១.០៩៥ | ៣៨,៩ | ៣៩,៧ | ៣៧,៩ |
| ឧស្សាហកម្ម | ១.២៩៦ | ៩០៨ | ៣៨៨ | ២០,៨ | ២៧,០ | ១៣,៥ |
| សេវាកម្ម | ២.៥២១ | ១.១១៩ | ១.៤០២ | ៤០,៤ | ៣៣,៣ | ៤៨,៦ |
| **សរុប (ផ្នែកក្រៅប្រព័ន្ធ)** | **៦.២៤៤** | **៣.៣៥៩** | **២.៨៨៥** | **១០០** | **១០០** | **១០០** |
| | | **ផ្នែកក្នុងប្រព័ន្ធ** | | | | |
| កសិកម្ម | ៧៤ | ៤២ | ៣៣ | ២,៦ | ៣,០ | ២,៣ |
| ឧស្សាហកម្ម | ១,៣៧៤ | ៥២៦ | ៨៤៨ | ៤៨,៧ | ៣៧,៩ | ៥៩,២ |
| សេវាកម្ម | ១,៣៧៣ | ៨២០ | ៥៥៣ | ៤៨,៧ | ៥៩,១ | ៣៨,៦ |
| **សរុប (ផ្នែកក្នុងប្រព័ន្ធ)** | **២,៨២២** | **១,៣៨៨** | **១,៤៣៣** | **១០០** | **១០០** | **១០០** |
| | | **ផ្នែកសេដ្ឋកិច្ច** | | | | |
| កសិកម្ម | ២.៥០២ | ១.៣៧៤ | ១.១២៧ | ២៧,៦ | ២៨,៩ | ២៦,១ |
| ឧស្សាហកម្ម | ២.៦៧០ | ១.៤៣៤ | ១.២៣៦ | ២៩,៤ | ៣០,២ | ២៨,៦ |
| សេវាកម្ម | ៣.៨៩៤ | ១.៩៣៩ | ១.៩៥៥ | ៤៣,០ | ៤០,៨ | ៤៥,៣ |
| **សរុប (ផ្នែកសេដ្ឋកិច្ច)** | **៩.០៦៦** | **៤.៧៤៨** | **៤.៣១៨** | **១០០** | **១០០** | **១០០** |

## ៦.៣ ការងារក្រៅប្រព័ន្ធ និងការងារក្នុងប្រព័ន្ធ

តារាង ៦.២ បង្ហាញថា ចំនួនអ្នកមានការងារធ្វើត្រូវបានប៉ាន់ស្មានថាមានប្រមាណ ៩.១ លាននាក់ ក្នុងនោះរួមមាន ប្រុស ៤,៧ លាននាក់ និង ស្រី ៤,៣ លាននាក់។ ក្នុងចំណោមអ្នកមានការងារធ្វើទាំងនេះ មានប្រមាណ ៦,៨ លាននាក់ (៧៥,១%) កំពុងបំពេញការងារក្រៅប្រព័ន្ធ ខណៈដែល ២.៣ លាននាក់ (២៤,៩%) កំពុងបំពេញការងារក្នុងប្រព័ន្ធ។

ក្នុងចំណោមអ្នកបំពេញការងារក្រៅប្រព័ន្ធ ភាគច្រើន (៧៧,២%) ស្ថិតក្នុងក្រុមអាយុ ២៥–៦៤ ឆ្នាំ ដែលស្មើនឹងប្រមាណ ៥.៣ លាននាក់។ យុវជនអាយុ ១៥–២៤ ឆ្នាំ មានចំណែក ១៦,៩% (ប្រមាណ ១.១ លាននាក់) ខណៈដែលមនុស្សវ័យចាស់អាយុ ៦៥ ឆ្នាំ និងលើស មានចំណែក ៥,៩% (ប្រមាណ ៤០៣ ពាន់នាក់)។ ការបែងចែកតាមក្រុមអាយុមានលក្ខណៈប្រហាក់ប្រហែលគ្នារវាងប្រុស និងស្រី ទោះជាយ៉ាងណា ស្រីមានសមាមាត្រអ្នកមានការងារធ្វើដែលមានអាយុ ៦៥ ឆ្នាំ និងលើស ខ្ពស់ជាងប្រុសបន្តិច (៦,៥% ធៀបនឹង ៥,៤%)។

សម្រាប់ការងារក្នុងប្រព័ន្ធ ប្រជាជនដែលមានអាយុ ២៥–៦៤ ឆ្នាំ ក៏មានចំណែកច្រើនជាងគេផងដែរ ដោយតំណាងឱ្យ ៧៧,១% (ប្រមាណ ១.៧ លាននាក់)។ យុវជនអាយុ ១៥–២៤ ឆ្នាំ មានចំណែក ២០,៤% (ប្រមាណ ៤៦១ ពាន់នាក់) ដែលជាសមាមាត្រខ្ពស់ជាងការងារក្រៅប្រព័ន្ធ។ ចំណែកឯប្រជាជនដែលមានអាយុ ៦៥ ឆ្នាំ និងលើស មានត្រឹមតែ ២,៥% (ប្រមាណ ៥៦ ពាន់នាក់) ប៉ុណ្ណោះ។ ស្រីមានចំណែកខ្ពស់ជាងប្រុសក្នុងចំណោមយុវជនដែលបំពេញការងារក្នុងប្រព័ន្ធ (២២,១% ធៀបនឹង ១៨,៥%)។

បើពិចារណាអ្នកមានការងារធ្វើសរុប ក្រុមអាយុ ២៥–៦៤ ឆ្នាំ មានចំណែកខ្ពស់ជាងគេ ដោយតំណាងឱ្យ ៧៧,២% (ប្រមាណ ៧.០ លាននាក់) នៃអ្នកមានការងារធ្វើសរុប។ យុវជនអាយុ ១៥–២៤ ឆ្នាំ មានចំណែក ១៧,៨% (ប្រមាណ ១.៦ លាននាក់) ខណៈដែលអ្នកមានការងារធ្វើដែលមានអាយុ ៦៥ ឆ្នាំ និងលើស មាន

ចំណែក ៥,១% (ប្រមាណ ៤៥៩ ពាន់នាក់)។ ការបែងចែកតាមក្រុមអាយុមានលក្ខណៈប្រហាក់ប្រហែលគ្នារវាងប្រុស និងស្រី ប៉ុន្តែស្រីមានសមាមាត្រខ្ពស់ជាងបន្តិចក្នុងក្រុមអាយុធ្វើការសំខាន់ (២៥–៦៤ ឆ្នាំ) ដោយមាន ៧៧,៧% បើប្រៀបធៀបនឹងប្រុសដែលមាន ៧៦,៧%។

### តារាង ៦.២ ប្រជាជនមានការងារធ្វើ តាមការងារក្រៅប្រព័ន្ធ និងការងារក្នុងប្រព័ន្ធ និងក្រុមអាយុ

| វិស័យ | ទាំងពីរភេទ | ប្រុស (ចំនួន) | ស្រី | ទាំងពីរភេទ (%) | ប្រុស | ស្រី |
|---|---|---|---|---|---|---|
| សរុបការងារក្រៅប្រព័ន្ធ | ៦.៨០៥ | ៣.៦៩១ | ៣.១១៤ | ១០០ | ១០០ | ១០០ |
| ១៥-២៤ | ១.១៤៨ | ៦៧០ | ៤៧៩ | ១៦,៩ | ១៨,១ | ១៥,៤ |
| ២៥-៦៤ | ៥.២៥៤ | ២.៨២០ | ២.៤៣៣ | ៧៧,២ | ៧៦,៤ | ៧៨,១ |
| ៦៥+ | ៤០៣ | ២០១ | ២០២ | ៥,៩ | ៥,៤ | ៦,៥ |
| សរុបការងារក្នុងប្រព័ន្ធ | ២.២៦១ | ១.០៥៧ | ១.២០៤ | ១០០ | ១០០ | ១០០ |
| ១៥-២៤ | ៤៦១ | ១៩៥ | ២៦៦ | ២០,៤ | ១៨,៥ | ២២,១ |
| ២៥-៦៤ | ១.៧៤៤ | ៨២១ | ៩២៣ | ៧៧,១ | ៧៧,៧ | ៧៦,៧ |
| ៦៥+ | ៥៦ | ៤១ | ១៥ | ២,៥ | ៣,៩ | ១,៣ |
| សរុបប្រជាជនមានការងារធ្វើ | ៩.០៦៦ | ៤.៧៤៨ | ៤.៣១៨ | ១០០ | ១០០ | ១០០ |
| ១៥-២៤ | ១.៦០៩ | ៨៦៥ | ៧៤៤ | ១៧,៨ | ១៨,២ | ១៧,២ |
| ២៥-៦៤ | ៦.៩៩៨ | ៣.៦៤១ | ៣.៣៥៧ | ៧៧,២ | ៧៦,៧ | ៧៧,៧ |
| ៦៥+ | ៤៥៩ | ២៤២ | ២១៧ | ៥,១ | ៥,១ | ៥,០ |

ដូចដែលបានបង្ហាញក្នុងរូបភាព ៦.១ ភាគរយនៃអ្នកមានការងារធ្វើក្នុងការងារក្រៅប្រព័ន្ធ មាននិន្នាការកើនឡើងតាមអាយុ ចាប់ពីក្រុមអាយុ ៣៥–៤៤ ឆ្នាំ ឡើងទៅ។ សមាមាត្រនេះមាន ៧៣,៨% ក្នុងចំណោមអ្នកដែលមានអាយុ ៣៥–៤៤ ឆ្នាំ ហើយបានកើនឡើងដល់កម្រិតខ្ពស់បំផុត ៨៧,៧% ក្នុងចំណោមប្រជាជនដែលមានអាយុ ៦៥ឆ្នាំឡើង។ ផ្ទុយទៅវិញ សមាមាត្រទាបជាងនេះត្រូវបានសង្កេតឃើញក្នុងចំណោមយុវជនអាយុ ១៥–២៤ ឆ្នាំ(៧១,៤%) និងអ្នកដែលមានអាយុ ២៥–៣៤ ឆ្នាំ(៦៦,១%)

### រូបភាព ៦.១ អ្នកមានការងារក្រៅប្រព័ន្ធ តាមក្រុមអាយុ

(%)



ដូចដែលបានបង្ហាញក្នុងរូបភាព ៦.២ សមាមាត្រនៃការងារក្រៅប្រព័ន្ធនៅកម្ពុជាមាន ៧៥,១%។ ការងារក្រៅប្រព័ន្ធមានសមាមាត្រខ្ពស់ជាងនៅតំបន់ជនបទ (៨០,៨%) បើធៀបនឹងតំបន់ទីប្រជុំជន (៦៦,៨%) ដែលបង្ហាញថា ការងារក្រៅប្រព័ន្ធផ្តោតខ្លាំងជាងនៅតំបន់ជនបទ។ផ្ទុយទៅវិញ សមាមាត្រនៃការងារក្នុងប្រព័ន្ធនៅកម្ពុជាមាន ២៤,៩%។ ការងារក្នុងប្រព័ន្ធមានការប្រមូលផ្តុំខ្ពស់ជាងនៅតំបន់ទីប្រជុំជន (៣៣,២%) បើធៀបនឹងតំបន់ជនបទ (១៩,២%)។

**រូបភាព ៦.២ អ្នកមានការងារក្រៅប្រព័ន្ធ និងអ្នកមានការងារក្នុងប្រព័ន្ធ តាមតំបន់**

(%)




លទ្ធផលដែលបង្ហាញក្នុងតារាង ៦.៣ ស្តីពីសមាមាត្រការងារក្រៅប្រព័ន្ធតាមក្រុមមុខរបរសំខាន់ៗ បង្ហាញថា អត្រាការងារក្រៅប្រព័ន្ធមានកម្រិតខ្ពស់ជាងគេក្នុងចំណោម កម្មករជំនាញខាងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ(៩៩,៦%) អ្នកធ្វើសិប្បកម្ម និងអាជីវកម្មពាក់ព័ន្ធ(៩០,៣%)មុខរបរបឋម (៨៨,៩%) និង បុគ្គលិកផ្នែកសេវាកម្ម និងអ្នកលក់ (៨៨,០%)។

**តារាង ៦.៣ អ្នកមានការងារក្រៅប្រព័ន្ធ និងអ្នកមានការងារក្នុងប្រព័ន្ធ តាមមុខរបរ**

| មុខរបរ | ការងារក្រៅប្រព័ន្ធ (ចំនួនគិតជាពាន់) | ការងារក្នុងប្រព័ន្ធ (ចំនួនគិតជាពាន់) | សរុប (ចំនួនគិតជាពាន់) | ការងារក្រៅប្រព័ន្ធ (%) | ការងារក្នុងប្រព័ន្ធ (%) | សរុប (%) |
|---|---|---|---|---|---|---|
| អ្នកគ្រប់គ្រង | ៣៤ | ១២៦ | ១៥៩ | ២១,០ | ៧៩,០ | ១០០ |
| អ្នកមានវិជ្ជាជីវៈ | ១២៨ | ២៧២ | ៤០០ | ៣២,១ | ៦៧,៩ | ១០០ |
| អ្នកបច្ចេកទេស និងវិជ្ជាជីវៈរង | ១៦៤ | ១៥៦ | ៣២០ | ៥១,៣ | ៤៨,៧ | ១០០ |
| អ្នកជំនួយការស្មៀន | ១១៤ | ១៣៨ | ២៥១ | ៤៥,៣ | ៥៤,៧ | ១០០ |
| អ្នកផ្តល់សេវាកម្ម និងលក់ | ១.៨៥៤ | ២៥៣ | ២.១០៧ | ៨៨,០ | ១២,០ | ១០០ |
| អ្នកជំនាញខាងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១.៩៩៩ | ៧ | ២.០០៧ | ៩៩,៦ | ០,៤ | ១០០ |
| អ្នកធ្វើសិប្បកម្ម និងអាជីវកម្មពាក់ព័ន្ធ | ៩៤៣ | ១០១ | ១.០៤៤ | ៩០,៣ | ៩,៧ | ១០០ |

| | | | | | | |
|---|---|---|---|---|---|---|
| ការីម៉ាស៊ីន និងរោចក្រ និងអ្នកផ្គុំដំឡើង | ៥៦៦ | ១.០៦៤ | ១.៦៣១ | ៣៤,៧ | ៦៥,៣ | ១០០ |
| អ្នកធ្វើមុខរបរងាយៗ | ៩៤៥ | ១១៨ | ១.០៦៣ | ៨៨,៩ | ១១,១ | ១០០ |
| កងកម្លាំងប្រដាប់អាវុធ | ៥៧ | ២៧ | ៨៤ | ៦៧,៦ | ៣២,៤ | ១០០ |
| **សរុប** | **៦.៨០៥** | **២.២៦១** | **៩.០៦៦** | **៧៥,១** | **២៤,៩** | **១០០** |

តារាង ៦.៤ បង្ហាញពីការបែងចែកអ្នកមានការងារធ្វើរវាង ការងារក្រៅប្រព័ន្ធ និង ការងារក្នុងប្រព័ន្ធ តាមវិស័យសកម្មភាពសេដ្ឋកិច្ច។ សម្រាប់គ្រប់វិស័យសកម្មភាពសេដ្ឋកិច្ចដែលបានបង្ហាញក្នុងតារាង ៦.៤ អ្នកមានការងារធ្វើភាគច្រើនស្ថិតក្នុងការងារក្រៅប្រព័ន្ធ។ អត្រាខ្ពស់ជាងគេត្រូវបានសង្កេតឃើញនៅក្នុង វិស័យការនេសាទ និងវារីវប្បកម្ម (៩៩,១%) ផលិតកម្ម ដំណាំ និងការចិញ្ចឹមសត្វ ការបរបាញ់ និងសកម្មភាពសេវាកម្មពាក់ព័ន្ធ (៩៧,៦%) រុក្ខាប្រមាញ់ និងការកាប់ព្រៃឈើ (៩៧,០%) សកម្មភាពរបស់គ្រួសារជានិយោជក និងសកម្មភាពផលិតទំនិញ និងសេវាកម្មដែលមិនអាចបែងចែកបានសម្រាប់ប្រើប្រាស់ដោយគ្រួសារផ្ទាល់(៩៣,៧%) និងវិស័យសំណង់ (៩៣,០%)។

**តារាង ៦.៤ អ្នកមានការងារក្រៅប្រព័ន្ធ និងអ្នកមានការងារក្នុងប្រព័ន្ធ តាមវិស័យឧស្សាហកម្ម**

| សកម្មភាពសេដ្ឋកិច្ច | ការងារក្រៅប្រព័ន្ធ (ចំនួនគិតជាពាន់) | ការងារក្នុងប្រព័ន្ធ | សរុប | ការងារក្រៅប្រព័ន្ធ (%) | ការងារក្នុងប្រព័ន្ធ | សរុប |
|---|---|---|---|---|---|---|
| **កសិកម្ម** | **២.៤៤៤** | **៥៧** | **២.៥០២** | **៩៧.៧** | **២.៣** | **១០០** |
| ផលិតកម្ម ដំណាំ និងចិញ្ចឹមសត្វ សកម្មភាពបរបាញ់ និងសេវាកម្មពាក់ព័ន្ធ | ២.២៥៩ | ៥៥ | ២.៣១៤ | ៩៧,៦ | ២,៤ | **១០០** |
| រុក្ខាប្រមាញ់ និងការកាប់ព្រៃឈើ | ៣៧ | ១ | ៣៨ | ៩៧,០ | ៣,០ | **១០០** |
| ការនេសាទ និងវារីវប្បកម្ម | ១៤៨ | ១ | ១៥០ | ៩៩,១ | ០,៩ | **១០០** |
| **ឧស្សាហកម្ម** | **១.៤២១** | **១.២៤៨** | **២.៦៧១** | **៥៣,២** | **៤៦,៧** | **១០០** |
| រុករករ៉ែ និងថ្ម | ៩ | ២ | ១២ | ៨០,៤ | ១៩,៦ | **១០០** |
| ការផលិតផ្នែកកាត់ដេរសំលៀកបំពាក់ | ៦៤៣ | ១.១៨០ | ១.៨២៣ | ៣៥,៣ | ៦៤,៧ | ១០០ |
| ផ្គត់ផ្គង់អគ្គិសនី ឧស្ម័ន ចំហាយ និងម៉ាស៊ីនត្រជាក់ | ១៥ | ៧ | ២២ | ៦៨,១ | ៣១,៩ | ១០០ |
| ផ្គត់ផ្គង់ទឹក គ្រប់គ្រងសំរាម លូទឹក និងសកម្មភាពកែលម្អ | ៤៣ | ៦ | ៤៩ | ៨៨,៣ | ១១,៧ | ១០០ |
| សំណង់ | ៧១១ | ៥៣ | ៧៦៥ | ៩៣,០ | ៧,០ | ១០០ |
| **សេវាកម្ម** | ២.៩៤០ | ៩៥៦ | ៣.៨៩៦ | ៧៥,៥ | ២៤,៥ | ១០០ |
| លក់ដុំ និងលក់រាយ ជួសជុលយានយន្ត | ១.៥០៦ | ១៤៦ | ១.៦៥២ | ៩១,២ | ៨,៨ | ១០០ |
| ដឹកជញ្ជូន និងស្តុកទំនិញ | ៣៦៥ | ៥៤ | ៤១៩ | ៨៧,១ | ១២,៩ | ១០០ |
| សកម្មភាពសេវាកម្មស្នាក់នៅ និងអាហារ | ៣២៧ | ៣៤ | ៣៦១ | ៩០,៥ | ៩,៥ | ១០០ |
| ព័ត៌មាន និងទំនាក់ទំនង | ១៥ | ១៦ | ៣១ | ៤៨,៦ | ៥១,៤ | ១០០ |
| សកម្មភាពហិរញ្ញវត្ថុ និងធានារ៉ាប់រង | ៣៥ | ៩១ | ១២៦ | ២៧,៧ | ៧២,៣ | ១០០ |
| សកម្មភាពអចលនទ្រព្យ | ២៤ | ៦ | ៣០ | ៧៩,៥ | ២០,៥ | ១០០ |
| សកម្មភាពវិជ្ជាជីវៈ វិទ្យាសាស្រ្ត និងបច្ចេកវិទ្យា | ៣៦ | ៣៩ | ៧៤ | ៤៧,៨ | ៥២,២ | ១០០ |
| សកម្មភាពរដ្ឋបាល និងសេវាកម្មគាំទ្រ | ១៦៨ | ១០៥ | ២៧៤ | ៦១,៦ | ៣៨,៤ | ១០០ |
| រដ្ឋបាលសាធារណៈ និងការពារ សន្តិសុខសង្គមជាកាតព្វកិច្ច | ៨៣ | ១៩៧ | ២៨០ | ២៩,៥ | ៧០,៥ | ១០០ |
| អប់រំ | ៤៤ | ១៦៤ | ២០៨ | ២១,១ | ៧៨,៩ | ១០០ |

| | | | | | | |
|---|---|---|---|---|---|---|
| សកម្មភាពសុខភាពមនុស្ស និងកិច្ចការសង្គម | ២០ | ៥៣ | ៧៣ | ២៧,៣ | ៧២,៧ | ១០០ |
| សិល្បៈ កម្សាន្ត និងសប្បាយ | ៧៧ | ២៣ | ១០១ | ៧៦,៨ | ២៣,២ | ១០០ |
| សកម្មភាពសេវាកម្មដទៃទៀត | ១៩១ | ១៩ | ២១០ | ៩១,០ | ៩,០ | ១០០ |
| សកម្មភាពគ្រួសារជានិយោជក និងសកម្មភាពផលិតទំនិញ និង សេវាកម្មត្រូវគ្នារបស់គ្រួសារសម្រាប់ប្រើប្រាស់ខ្លួនឯង | ៤៨ | ៣ | ៥១ | ៩៣,៧ | ៦,៣ | ១០០ |
| សកម្មភាពអង្គការ និងអង្គភាពក្រៅប្រទេស | ១ | ៦ | ៦ | ៩,៨ | ៩០,២ | ១០០ |
| **សរុប** | ៦.៨០៥ | ២.២៦១ | ៩.០៦៦ | ៧៥,១ | ២៤,៩ | ១០០ |

តារាង ៦.៥ បង្ហាញថា ក្នុងចំណោមអ្នកដែលបំពេញការងារនៅក្នុង វិស័យក្រៅប្រព័ន្ធ មាន ៧៩,៧% កំពុងបំពេញការងារក្រៅប្រព័ន្ធ។ ការងារក្រៅប្រព័ន្ធ សំដៅលើចំនួនសរុបនៃការងារក្រៅប្រព័ន្ធទាំងអស់ ដែលត្រូវបានអនុវត្តនៅក្នុងសហគ្រាសវិស័យក្នុងប្រព័ន្ធ សហគ្រាសវិស័យក្រៅប្រព័ន្ធ ឬគ្រួសារ ក្នុងអំឡុងពេលយោងដែលបានកំណត់។ និយមន័យនេះរួមបញ្ចូល និយោជក និង អ្នកប្រកបការងារដោយខ្លួនឯង ដែលបំពេញការងារនៅក្នុងសហគ្រាសវិស័យក្រៅប្រព័ន្ធរបស់ខ្លួន, កម្មករគ្រួសារជួយដោយមិនទទួលប្រាក់ឈ្នួល, ព្រមទាំងនិយោជិត និងសិក្ខាកាម ឬអ្នកហាត់ការដែលទទួលប្រាក់ឈ្នួល ដែលមិនទទួលបានសិទ្ធិឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួល ឬការឈប់សម្រាកឈឺដោយមានប្រាក់ឈ្នួល ហើយនិយោជករបស់ពួកគេមិនបានបង់វិភាគទានទៅក្នុងប្រព័ន្ធសន្តិសុខសង្គមសម្រាប់ពួកគេ។

**តារាង ៦.៥ អ្នកធ្វើការងារក្រៅប្រព័ន្ធ និងក្នុងប្រព័ន្ធ តាមវិស័យ**

| វិស័យ | អ្នកធ្វើការងារក្រៅប្រព័ន្ធ | អ្នកធ្វើការងារក្រៅប្រព័ន្ធ | សរុប | អ្នកធ្វើការងារក្រៅប្រព័ន្ធ | អ្នកធ្វើការងារក្រៅប្រព័ន្ធ | សរុប |
|---|---|---|---|---|---|---|
| | (ចំនួនគិតជាពាន់) | | | (%) | | |
| **វិស័យក្រៅប្រព័ន្ធ** | ៦.២៤៣ | ១.៥៨៥ | ៧.៨២៨ | ៧៩,៧ | ២០,៣ | ១០០ |
| **វិស័យក្នុងប្រព័ន្ធ** | ៥៦១ | ៦៧៦ | ១,.៣៧ | ៤៥,៣ | ៥៤,៧ | ១០០ |
| **វិស័យទាំងអស់** | ៦.៨០៤ | ២.២៦២ | ៩.០៦៦ | ៧៥,១ | ២៤,៩ | ១០០ |

តារាង ៦.៦ បង្ហាញពីការបែងចែកអ្នកធ្វើការងារក្រៅប្រព័ន្ធ និងអ្នកធ្វើការងារក្នុងប្រព័ន្ធ តាមកម្រិតការអប់រំ។ ជារួម៧៥,៣% នៃអ្នកធ្វើការងារក្រៅប្រព័ន្ធ ខណៈដែល ២៤,៧% អ្នកធ្វើការងារក្នុងប្រព័ន្ធ។

ក្នុងចំណោមអ្នកមានការងារធ្វើដែល មិនធ្លាប់បានចូលរៀនសោះ អ្នកធ្វើការងារក្រៅប្រព័ន្ធមានសមាមាត្រខ្ពស់ជាងគេ គឺ ៩៤,៥% ខណៈដែលមានតែ ៥,៥% ប៉ុណ្ណោះអ្នកធ្វើការងារក្នុងប្រព័ន្ធ។ ផ្ទុយទៅវិញ ក្នុងចំណោមអ្នកដែលបានបញ្ចប់ថ្នាក់បច្ចេកទេស/វិជ្ជាជីវៈ មាន ៧៣,៩% អ្នកធ្វើការងារក្នុងប្រព័ន្ធ ខណៈដែល ២៦,១% អ្នកធ្វើការងារក្រៅប្រព័ន្ធ។

ស្រដៀងគ្នានេះដែរ ក្នុងចំណោមអ្នកដែលបានបញ្ចប់ថ្នាក់ឧត្តមសិក្សា មាន ៥៩,៥% អ្នកធ្វើការងារក្នុងប្រព័ន្ធ ខណៈដែល ៤០,៥% អ្នកធ្វើការងារក្រៅប្រព័ន្ធ។

## តារាង ៦.៦ ប្រជាជនមានការងារធ្វើអាយុ ១៥ ឆ្នាំ ឡើង តាមកម្រិតការអប់រំ និងការងារក្នុងប្រព័ន្ធ/ការងារក្រៅប្រព័ន្ធ

| វិស័យ | អ្នកធ្វើការងារក្រៅប្រព័ន្ធ | អ្នកធ្វើការងារក្នុងប្រព័ន្ធ (ចំនួនគិតជាពាន់) | សរុប | អ្នកធ្វើការងារក្រៅប្រព័ន្ធ | អ្នកធ្វើការងារក្នុងប្រព័ន្ធ (%) | សរុប |
|---|---|---|---|---|---|---|
| មិនដែលបានរៀន | ៤១៥ | ២៤ | ៤៣៩ | ៩៤,៥ | ៥,៥ | ១០០ |
| បឋមសិក្សា | ៣.២២៦ | ៦៦៦ | ៣.៨៩២ | ៨២,៩ | ១៧,១ | ១០០ |
| មធ្យមសិក្សាបឋមភូមិ | ១.៧១៨ | ៥៩៥ | ២.៣១៣ | ៧៤,៣ | ២៥,៧ | ១០០ |
| មធ្យមសិក្សាទុតិយភូមិ | ១.១៦៦ | ៤៩៧ | ១.៦៦៣ | ៧០,១ | ២៩,៩ | ១០០ |
| បច្ចេកទេស/វិជ្ជាជីវៈ | ១៣ | ៣៧ | ៥០ | ២៦,១ | ៧៣,៩ | ១០០ |
| ឧត្តមសិក្សា | ២៨៨ | ៤២២ | ៧១០ | ៤០,៥ | ៥៩,៥ | ១០០ |
| **សរុប** | **៦.៨២៤** | **២.២៤១** | **៩.០៦៦** | **៧៥,១** | **២៤,៩** | ១០០ |

# ជំពូក ៧
# ចំណូលពីការងារ

## ៧.១ សេចក្តីផ្តើម

ជំពូកនេះផ្តោតលើ និយោជិត និងសិក្ខាកាម ឬអ្នកហាត់ការដែលទទួលប្រាក់ឈ្នួល មានអាយុ១៥ ឆ្នាំ និងលើសដែលទទួលបានប្រាក់ឈ្នួលជាសាច់ប្រាក់នៅពេលបើកប្រាក់ឈ្នួលលើកចុងក្រោយពីការងារចម្បងរបស់ពួកគេ។ ប្រាក់ចំណូលរបស់ពួកគេ សំដៅលើចំនួនប្រាក់ដែលបានទទួលពីនិយោជក រួមទាំងប្រាក់បន្ថែមដែលអាចទទួលបានពី ប្រាក់បំណាច់ (Tips) កម្រៃជើងសារ ឬប្រាក់រង្វាន់។

ការមានការងារដែលមានផលិតភាព និងផ្តល់ប្រាក់ចំណូលប្រកបដោយនិរន្តរភាព គឺជាមធ្យោបាយដ៏សំខាន់មួយក្នុងការធានាសន្តិសុខប្រាក់ចំណូលរបស់គ្រួសារ និងការកាត់បន្ថយភាពក្រីក្រ។ ការបែងចែកប្រាក់ឈ្នួល និងការងារដែលមានប្រាក់ឈ្នួល គឺជាកត្តាសំខាន់មួយសម្រាប់កំណត់កម្រិតវិសមភាពក្នុងចំណោមប្រជាជន។

## ៧.២ មូលដ្ឋានទូទាត់ប្រាក់ឈ្នួល

តារាង ៧.១ បង្ហាញថា នៅឆ្នាំ ២០២៥ ប្រាក់ឈ្នួល ឬប្រាក់បៀវត្ស គឺជាទម្រង់នៃការទូទាត់ដែលច្រើនជាងគេក្នុងចំណោមនិយោជិត ដោយមានចំណែក ៩៦,៨% នៃនិយោជិតសរុប។ សមាមាត្រនេះមានកម្រិតខ្ពស់ជាងបន្តិចក្នុងចំណោមស្រី (៩៧,១%) បើប្រៀបធៀបនឹងប្រុស (៩៦,៦%)។ ទម្រង់នៃការទូទាត់ផ្សេងៗមានសមាមាត្រតិចតួច។ ប្រមាណ ១,៩% នៃនិយោជិតទទួលបានការទូទាត់ក្នុងទម្រង់ផ្សេងៗ ដូចជា អាហារ ឬកន្លែងស្នាក់នៅ ដោយមិនមានភាពខុសគ្នារវាងប្រុស និងស្រីនោះទេ។

ការទូទាត់ដោយផ្អែកលើការបញ្ចប់ការងារ មានចំណែក ០,៥% នៃនិយោជិត ខណៈដែលកម្រៃសម្រាប់សេវាកម្មដែលបានផ្តល់មានចំណែក ០,៤%។ ចំណែកឯ កម្រៃជើងសារ និងប្រាក់បំណាច់ (Tips) គឺជាទម្រង់នៃការទូទាត់ដែលមានសមាមាត្រទាបបំផុត ដោយទម្រង់នីមួយៗមានចំណែក ០,២% នៃនិយោជិត។ ប្រុសមានសមាមាត្រទទួលបាន កម្រៃជើងសារ (០,៣% ធៀបនឹង ០,១%) និង កម្រៃសម្រាប់សេវាកម្មដែលបានផ្តល់ (០,៥% ធៀបនឹង ០,២%) ខ្ពស់ជាងស្រីបន្តិច ខណៈដែលស្រីមានសមាមាត្រទទួលបានប្រាក់បំណាច់ (Tips) ខ្ពស់ជាងប្រុសបន្តិច (០,៣% ធៀបនឹង ០,២%)។

ជារួមលទ្ធផលបង្ហាញថា ប្រាក់ឈ្នួល ឬប្រាក់បៀវត្ស គឺជាទម្រង់នៃការទូទាត់ដែលគ្របដណ្តប់ស្ទើរតែទាំងស្រុងក្នុងចំណោមនិយោជិត ខណៈដែលទម្រង់នៃការទូទាត់ផ្សេងៗមានសមាមាត្រតិចតួចប៉ុណ្ណោះ ហើយភាពខុសគ្នារវាងប្រុស និងស្រីក្នុងទម្រង់នៃការទូទាត់ទាំងនោះមានកម្រិតតិចតួច។

### តារាង ៧.១ និយោជិត តាមមូលដ្ឋានទូទាត់ប្រាក់ឈ្នួល

| Frequency of Payment | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
|---|---|---|---|---|---|---|
| | (ចំនួនគិតជាពាន់) | | | (%) | | |
| ប្រាក់ឈ្នួល ឬប្រាក់ខែ | ៤.៥១៩ | ២.៥២១ | ១.៩៩៧ | ៩៦,៨ | ៩៦,៦ | ៩៧,១ |
| ប្រាក់ផ្តល់តាមចំណែកនៃការងារដែលធ្វើហើយ | ២២ | ១៤ | ៧ | ០,៥ | ០,៥ | ០,៤ |
| កម្រៃជើងសារ | ១០ | ៧ | ៣ | ០,២ | ០,៣ | ០,១ |
| ប្រាក់បំណាច់ | ១១ | ៥ | ៦ | ០,២ | ០,២ | ០,៣ |
| កម្រៃសេវាកម្មដែលបានផ្តល់ | ១៩ | ១៤ | ៥ | ០,៤ | ០,៥ | ០,២ |
| ទម្រង់ផ្សេងៗ (អាហារ ឬ កន្លែងស្នាក់នៅ......) | ៨៨ | ៤៩ | ៣៩ | ១,៩ | ១,៩ | ១,៩ |
| **សរុប** | **៤.៦៦៧** | **២.៦១០** | **២.០៥៧** | **១០០** | **១០០** | **១០០** |

## ៧.៣ ប្រាក់ចំណូលប្រចាំខែជាមធ្យម

រូបភាព៧.១ បង្ហាញពីការបែងចែកប្រាក់ឈ្នួលប្រចាំខែពីការងារចម្បងរបស់និយោជិតជាប្រុស និងស្រី។ តារាងនេះបង្ហាញថា ប្រាក់ឈ្នួលប្រចាំខែរបស់ប្រុស និងស្រី មានចាប់ពី ៣៥០.០០០រៀល (៨៧,៥ ដុល្លារអាមេរិក) រហូតដល់ប្រមាណ ៤.០០០.០០០ រៀល (១.០០០ ដុល្លារអាមេរិក)។

លើសពីនេះ ប្រាក់ឈ្នួលប្រចាំខែមធ្យម (Median) របស់និយោជិតជាប្រុសក្នុងឆ្នាំ២០២៥ មានប្រមាណ ១.២០០.០០០ រៀល (៣០០ ដុល្លារអាមេរិក) ខណៈដែលប្រាក់ឈ្នួលប្រចាំខែមធ្យម (Median) របស់និយោជិតជាស្រី មានប្រមាណ ១.០៤០.០០០ រៀល (២៦០ ដុល្លារអាមេរិក)។

**រូបភាព ៧.១ ការបែងចែកប្រាក់ឈ្នួលប្រចាំខែ តាមភេទ**

(រៀល)



រូបភាព ៧.២ បង្ហាញថា នៅឆ្នាំ២០២៥ ស្រីមានសមាមាត្រខ្ពស់ជាងប្រុសបន្តិចក្នុងក្រុមដែលទទួលបានប្រាក់ឈ្នួលប្រចាំខែចាប់ពី ៨០០.០០០រៀល ដល់ក្រោម ១.២០០.០០០រៀល (ប្រមាណ ២០០–៣០០ដុល្លារអាមេរិក) ដោយមានចំណែក ៥០,២% និង ៤៩,៨% រៀងគ្នា។ ផ្ទុយទៅវិញ ប្រុសមានសមាមាត្រខ្ពស់ជាងស្រីនៅក្នុងក្រុមប្រាក់ចំណូលភាគច្រើនផ្សេងទៀត។

លើកលែងតែក្រុមដែលមានប្រាក់ចំណូលខ្ពស់បំផុត ទិន្នន័យបង្ហាញពីភាពខុសគ្នាគួរឱ្យកត់សម្គាល់រវាងប្រុស និងស្រីទាក់ទងនឹងប្រាក់ចំណូលពីការងារ ដែលឆ្លុះបញ្ចាំងថា ប្រុស និងស្រីមិនត្រូវបានបែងចែកស្មើៗគ្នានៅតាមកម្រិតប្រាក់ចំណូលផ្សេងៗនោះទេ។

### រូបភាព ៧.២ ចំណែកប្រាក់ឈ្នួលប្រចាំខែ តាមភេទ

(%)




តារាង ៧.២ បង្ហាញពីប្រាក់ឈ្នួលប្រចាំខែជាមធ្យម និងប្រាក់ឈ្នួលប្រចាំខែមធ្យម (Median) របស់និយោជិតដែលមានអាយុ ១៥ ឆ្នាំ និងលើស ដោយបែងចែកតាមមុខរបរ និងភេទ។ ប្រាក់ឈ្នួលប្រចាំខែជាមធ្យមពីការងារចម្បងរបស់និយោជិត ត្រូវបានប៉ាន់ស្មានថាមានចំនួន ១.២០១.៤៣៦រៀល (៣០០,៣៦ ដុល្លារអាមេរិក) ខណៈដែលប្រាក់ឈ្នួលប្រចាំខែមធ្យម (Median) មានចំនួន ១.១៥០.០០០ រៀល (២៨៧,៥០ ដុល្លារអាមេរិក)។ ទិន្នន័យបង្ហាញពីគម្លាតប្រាក់ឈ្នួលរវាងយេនឌ័រ ដោយនិយោជិតជាប្រុសទទួលបានប្រាក់ឈ្នួលប្រចាំខែជាមធ្យមខ្ពស់ជាងនិយោជិតជាស្រីចំនួន១៤២.១៧៦រៀល (៣៥,៥៤ ដុល្លារអាមេរិក)។ ស្រដៀងគ្នានេះដែរ ប្រាក់ឈ្នួលប្រចាំខែមធ្យម (Median) របស់និយោជិតជាប្រុស ខ្ពស់ជាងនិយោជិតជាស្រីចំនួន ១៦០.០០០ រៀល (៤០,០០ ដុល្លារអាមេរិក)។

តារាងនេះក៏បង្ហាញផងដែរថា ស្ទើរតែគ្រប់ក្រុមមុខរបរទាំងអស់ ប្រាក់ឈ្នួលប្រចាំខែជាមធ្យម និងប្រាក់ឈ្នួលប្រចាំខែមធ្យម (Median) របស់និយោជិតជាប្រុស មានកម្រិតខ្ពស់ជាងនិយោជិតជាស្រីបន្តិច។ ករណី

លើកលែងតែមួយគត់ ត្រូវបានសង្កេតឃើញនៅក្នុងក្រុមមុខរបរ កងកម្លាំងប្រដាប់អាវុធ ដែលនិយោជិតជាស្រី ទទួលបានប្រាក់ឈ្នួលប្រចាំខែជាមធ្យមខ្ពស់ជាងនិយោជិតជាប្រុស។

**តារាង ៧.២ ប្រាក់ឈ្នួលប្រចាំខែជាមធ្យម និងជាមេដ្យាន តាមមុខរបរ និងភេទ**

**(ជារៀល)**

| មុខរបរ | ប្រាក់ឈ្នួលប្រចាំខែជាមធ្យម | | | ប្រាក់ឈ្នួលប្រចាំខែជាមេដ្យាន | | |
|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| អ្នកគ្រប់គ្រង | ១.៤៥៩.០៩៧ | ១.៥១២.២០១ | ១.២៤៣.៤៥៤ | ១.២០០.០០០ | ១.២០០.០០០ | ១.០០០.០០០ |
| អ្នកមានវិជ្ជាជីវៈ | ១.៦៥៧.២៧១ | ១.៧៧៣.៥០៧ | ១.៥៥៨.០៩០ | ១.៦០០.០០០ | ១.៦៨២.០០០ | ១.៦០០.០០០ |
| អ្នកបច្ចេកទេស និវិជ្ជាជិវៈរង | ១.៥៤៧.៥០១ | ១.៦៨៥.៤៥៣ | ១.៣៥១.០៩១ | ១.៤០០.០០០ | ១.៥៦០.០០០ | ១.២០០.០០០ |
| ជំនួយការស្មៀន | ១.៥៣៩.៩៥១ | ១.៥៥៤.២០៧ | ១.៥២៥.៤៨៥ | ១.៥០០.០០០ | ១.៥០០.០០០ | ១.៤០០.០០០ |
| អ្នកផ្តល់សេវាកម្ម និងលក់ | ១.១០៦.៩៣៦ | ១.១៩៤.០២០ | ១.០០៨.៩១៧ | ១.០០០.០០០ | ១.០២០.០០០ | ៨៥០.០០០ |
| អ្នកជំនាញកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១.២៥៨.៩២៦ | ១.១៨២.២៧០ | ១.៣៨១.២១៤ | ១.២០០.០០០ | ១.០០០.០០០ | ១.២០០.០០០ |
| អ្នកធ្វើសិប្បកម្ម និងអាជីវកម្មពាក់ព័ន្ធ | ១.១៩៤.៥៣៤ | ១.២១៥.១៦០ | ១.០៦៣.០១៥ | ១.២០០.០០០ | ១.២០០.០០០ | ១.០០០.០០០ |
| ការីម៉ាស៊ីន និងរោងចក្រ និងអ្នកដំឡើង | ១.១៣៦.៥២៤ | ១.២០១.៦៩៥ | ១.០៩០.៦២០ | ១.១០០.០០០ | ១.១៦០.០០០ | ១.១០០.០០០ |
| អ្នកធ្វើមុខរបរងាយៗ | ៩២៤.១៩៦ | ៩៦៤.៥៥២ | ៨៧៦.១៩៤ | ៨៥០.០០០ | ៩០០.០០០ | ៨០០.០០០ |
| កងកម្លាំងប្រដាប់អាវុធ | ១.៦១៥.០៨៦ | ១.៦១១.៧៧១ | ១.៦៨២.៣៣១ | ១.៦០០.០០០ | ១.៦០០.០០០ | ១.៨០០.០០០ |
| **សរុប** | **១.២០១.៤៣៦** | **១.២៦៣.៥៣៣** | **១.១២១.៣១៦** | **១.១៥០.០០០** | **១.២០០.០០០** | **១.០៤០.០០០** |

តារាង ៧.៣ បង្ហាញថា សកម្មភាពហិរញ្ញវត្ថុ និងធានារ៉ាប់រង មានប្រាក់ឈ្នួលមធ្យមប្រចាំខែខ្ពស់ជាងគេ គឺ ១.៩០១.៨១៤ រៀល (ឬ ៤៧៥,៥០ដុល្លារអាមេរិក) បន្ទាប់មកគឺ សកម្មភាពសុខភាពមនុស្ស និងការងារសង្គម ដែលមានប្រាក់ឈ្នួលមធ្យមប្រចាំខែ ១.៨០០.៧២៥រៀល (ឬ ៤៥០,២០ដុល្លារអាមេរិក) សកម្មភាពវិជ្ជាជីវៈ វិទ្យាសាស្ត្រ និងបច្ចេកទេស មាន ១.៦៧១.៨៧៥ រៀល (ឬ ៤១៧,៩៧ដុល្លារអាមេរិក) និង សកម្មភាពព័ត៌មាន និងទំនាក់ទំនង មាន ១.៥៨៩.៦៧៨រៀល (ឬ ៣៩៧,៤២ ដុល្លារអាមេរិក)។

តារាងនេះក៏បង្ហាញផងដែរថា ស្រីទទួលបានប្រាក់ឈ្នួលមធ្យមប្រចាំខែខ្ពស់ជាងប្រុសក្នុង សកម្មភាពអចលនទ្រព្យ ដែលមានចំនួន ១.៦៩៤.១០៧រៀល (ឬ ៤២៣,៥៣ដុល្លារអាមេរិក) សកម្មភាពសិល្បៈ ការកម្សាន្ត និងការលំហែកាយ មាន ១.៥៥៥.៨៦៨រៀល (ឬ ៣៨៨,៩៧ដុល្លារអាមេរិក) និង សកម្មភាពដឹកជញ្ជូន និងការស្តុកទុក មាន ១.២៤៦.៨៩៩ រៀល (ឬ ៣១១,៧២ដុល្លារអាមេរិក)។

**តារាង ៧.៣ ប្រាក់ឈ្នួលប្រចាំខែជាមធ្យម និងជាមេដ្យាន តាមសកម្មភាពសេដ្ឋកិច្ច និងភេទ**

**(ជារៀល)**

| សកម្មភាពសេដ្ឋកិច្ច | ប្រាក់ឈ្នួលប្រចាំខែជាមធ្យម | | | ប្រាក់ឈ្នួលប្រចាំខែជាមេដ្យាន | | |
|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| **កសិកម្ម** | **៨៦២.៨៤០** | **៨៧៣.៩៥២** | **៨៤៧.៨៥៥** | **៧៥០.០០០** | **៨០០.០០០** | **៧៥០.០០០** |
| ផលិតកម្ម ដំណាំ និងចិញ្ចឹមសត្វ សកម្មភាពបរបាញ់ និងសេវាកម្មពាក់ព័ន្ធ | ៨៤៩.២៣៦ | ៨៤៩.១៦២ | ៨៤៩.៣៣២ | ៧៥០.០០០ | ៨០០.០០០ | ៧៥០.០០០ |
| **រុក្ខាប្រមាញ់ និងការកាប់ព្រៃឈើ** | **១.០៦៧.១៩៦** | **១.៣២៧.៣១៨** | **៦០១.៧៩១** | **១.០០០.០០០** | **១.២០០.០០០** | **៣៥០.០០០** |
| នេសាទ និងវារីវប្បកម្ម | ១.១០៧.០៥៨ | ១.១១៦.៥៦១ | ១.០២២.៦៩៩ | ១.២០០.០០០ | ១.២០០.០០០ | ១.២០០.០០០ |
| **ឧស្សាហកម្ម** | ១.១៦៩.២៧៧ | ១.២៣២.៤៣៤ | ១.០៩៧.៧៦៤ | ១.១២០.០០០ | **១.២០០.០០០** | ១.០៨០.០០០ |
| រុករករ៉ែ និងថ្ម | ១.២៨៧.៨៨២ | ១.២៨៧.៨៨២ | - | ១.១០០.០០០ | ១.១០០.០០០ | - |

| | | | | | | |
|---|---|---|---|---|---|---|
| ផលិតផ្នែកកាត់ដេរសំលៀកបំពាក់ | ១.១៤៤.៧៧៧ | ១.២៣១.៩០២ | ១.០៩១.៥៩៨ | ១.១០៥.០០០ | ១.២០០.០០០ | ១.០៨០.០០០ |
| ផ្គត់ផ្គង់អគ្គិសនី ឧស្ម័ន | ១.៣៧៧.៨៨៥ | ១.៣៦០.២៤៦ | ១.៤៦៦.៥៥៤ | ១.២០០.០០០ | ១.២០០.០០០ | ១.០០០.០០០ |
| ផ្គត់ផ្គង់ទឹក គ្រប់គ្រងសំរាម លូទឹក និងម៉ាស៊ីនត្រជាក់ | ១.៣១០.៤៥៥ | ១.២៩៨.៣០១ | ១.៣៨៦.៣៩៣ | ១.៤០០.០០០ | ១.២០០.០០០ | ១.៤០០.០០០ |
| សំណង់ | ១.២១៦.០៨៤ | ១.២២៧.៧២០ | ១.១៤១.៦៦៣ | ១.២០០.០០០ | ១.២០០.០០០ | ១.០០០.០០០ |
| **សេវាកម្ម** | **១.៣១៥.២៨៤** | **១.៣៧៩.៤៩៧** | **១.២១៩.០៨០** | **១.២០០.០០០** | **១.២០០.០០០** | **១.២០០.០០០** |
| លកដុំ និងលក់រាយ ជួសជុលយានយន្ត | ១.១៩៧.០៨៧ | ១.២៥៤.៧៥៤ | ១.១២៣.៤៤០ | ១.០០០.០០០ | ១.០៥០.០០០ | ១.០០០.០០០ |
| ដឹកជញ្ជូន និងស្តុកទំនិញ | ១.១៨១.៩១៨ | ១.១៧៦.៩៦៩ | ១.២៤៦.៨៩៩ | ១.០៥០.០០០ | ១.១០០.០០០ | ១.០០០.០០០ |
| សកម្មភាពសេវាកម្មស្នាក់នៅ និងអាហារ | ៩៨៣.៩១៣ | ១.០៧៨.៤៦១ | ៩១៣.៤៩៦ | ៩០០.០០០ | ១.០០០.០០០ | ៨០០.០០០ |
| ព័ត៌មាន និងទំនាក់ទំនង | ១.៥៨៩.៦៧៨ | ១.៦៧៨.៩៣៩ | ១.២០៧.៤៧០ | ១.៣០០.០០០ | ១.៤០០.០០០ | ១.២០០.០០០ |
| សកម្មភាពហិរញ្ញវត្ថុ និងធានារ៉ាប់រង | ១.៩០១.៨១៤ | ២.០១៧.០៧៨ | ១.៦៥៦.០៥៤ | ១.៦០០.០០០ | ១.៦០០.០០០ | ១.៥០០.០០០ |
| សកម្មភាពអចលនទ្រព្យ | ១.៤៧៩.៧១៤ | ១.៣៧៥.៩៩៩ | ១.៦៩៤.១០៧ | ១.២០០.០០០ | ១.២០០.០០០ | ១.២០០.០០០ |
| សកម្មភាពវិជ្ជាជីវៈ វិទ្យាសាស្រ្ត និងបច្ចេកវិទ្យា | ១.៦៧១.៨៧៥ | ១.៨០៥.៦២២ | ១.៥៨៣.៥៨២ | ១.៦០០.០០០ | ១.៦០០.០០០ | ១.៦០០.០០០ |
| សកម្មភាពរដ្ឋបាល និងសេវកម្មគាំទ្រ | ១.០៤៣.៨០១ | ១.០៦២.៩១១ | ១.០១៣.៩០១ | ៩២០.០០០ | ៩០០.០០០ | ៩២០.០០០ |
| រដ្ឋបាលសាធារណៈ និងការពារ សន្តិសុខសង្គមជាកាតព្វកិច្ច | ១.៥២៤.២៤០ | ១.៥៦៧.៥០២ | ១.៣៣៨.៧៩២ | ១.៦០០.០០០ | ១.៦០០.០០០ | ១.៥០០.០០០ |
| អប់រំ | ១.៥៣៦.២៥៤ | ១.៦០៨.២៧៦ | ១.៤៧៧.៨៩០ | ១.៦០០.០០០ | ១.៦៨០.០០០ | ១.៥០០.០០០ |
| សកម្មភាពសុខភាពមនុស្ស និងកិច្ចការសង្គម | ១.៨០០.៧២៥ | ១.៩៨៦.៩០១ | ១.៦៧៣.១២៥ | ១.៧០០.០០០ | ១.៨០០.០០០ | ១.៦៦០.០០០ |
| សិល្បៈ កម្សាន្ត និងសប្បាយ | ១.៥០០.៨៣៦ | ១.៤២៨.៦០៥ | ១.៥៥៥.៦៦៨ | ១.៤០០.០០០ | ១.២០០.០០០ | ១.៤០០.០០០ |
| សកម្មភាពសេវាកម្មដទៃទៀត | ១.០៤៣.៤០៩ | ១.២៧១.៩០១ | ៩២៣.១៩៣ | ៩៥០.០០០ | ១.២០០.០០០ | ៨០០.០០០ |
| សកម្មភាពគ្រួសារជានិយោជក និងសកម្មភាពផលិតទំនិញ និង សេវាកម្មត្រូវគ្នារបស់គ្រួសារសម្រាប់ប្រើប្រាស់ខ្លួនឯង | ៩០៥.៤៧៤ | ១.២៣៩.៥៦៨ | ៨៤៧.៧៥២ | ៨០០.០០០ | ១.២០០.០០០ | ៨០០.០០០ |
| សកម្មភាពអង្គការ និងអង្គភាពក្រៅប្រទេស | ១.៥១៣.៥៤០ | ១.៥៣៧.១៥៧ | ១.៤៩៨.៤៥៤ | ១.២០០.០០០ | ១.២០០.០០០ | ១.២០០.០០០ |
| **សរុប** | **១.២០១.៤៣៦** | **១.២៦៣.៥៣៣** | **១.១២១.៣១៦** | **១.១៥០.០០០** | **១.២០០.០០០** | **១.០៤០.០០០** |

ដូចដែលបានបង្ហាញក្នុងតារាង ៧.៤ ប្រាក់ឈ្នួលប្រចាំខែជាមធ្យម ជាទូទៅមាននិន្នាការកើនឡើងតាមអាយុ លើកលែងតែក្នុងចំណោមនិយោជិតដែលមានអាយុ ៣៥–៤៤ឆ្នាំ និងអ្នកដែលមានអាយុ ៦៥ឆ្នាំឡើង។ និយោជិតដែលមានអាយុ ៦៥ឆ្នាំឡើង គឺជាក្រុមដែលទទួលបានប្រាក់ឈ្នួលទាបជាងគេ ដោយមានប្រាក់ឈ្នួលប្រចាំខែជាមធ្យម ៩៩០.៣៩២ រៀល (២៤៧,៦០ដុល្លារអាមេរិក) និងប្រាក់ឈ្នួលប្រចាំខែជាមេដ្យាន ៨៩០.០០០រៀល (២២២,៥០ដុល្លារអាមេរិក)។ ដោយមិនគិតពីក្រុមអាយុ ទាំងប្រាក់ឈ្នួលប្រចាំខែជាមធ្យម និងប្រាក់ឈ្នួលប្រចាំខែជាមេដ្យាន របស់និយោជិតជាស្រ្តី ជាទូទៅមានកម្រិតទាបជាងនិយោជិតជាប្រុស។ ទោះជាយ៉ាងណា ក្នុងចំណោមនិយោជិតដែលមានអាយុ ៦០ឆ្នាំឡើង ស្រីទទួលបានប្រាក់ឈ្នួលប្រចាំខែជាមធ្យមខ្ពស់ជាងប្រុសបន្តិច។

តារាង ៧.៤ ក៏បង្ហាញផងដែរថា ប្រាក់ឈ្នួលប្រចាំខែជាមធ្យម និងប្រាក់ឈ្នួលប្រចាំខែជាមេដ្យាន របស់និយោជិតជាស្រ្តី បានចាប់ផ្តើមថយចុះចាប់ពីអាយុ ៣៥ ឆ្នាំឡើង។ បញ្ហានេះអាចបណ្តាលមកពីស្រ្តីនៅកម្ពុជាជាទូទៅតែងតែចាកចេញពីទីផ្សារការងារដើម្បីទទួលខុសត្រូវលើការងារក្នុងគ្រួសារ ដូចជាការមើលថែទាំកូន ឬសមាជិកគ្រួសារផ្សេងទៀត។ ស្ថានភាពនេះអាចនាំឱ្យមានការផ្លាស់ប្តូរម៉ោងធ្វើការជាធម្មតា ព្រមទាំងការឈប់ពីការងារ ឬការរំខានដល់អាជីពការងាររបស់ពួកគេ។ នៅពេលស្រ្តីទាំងនេះចូលមកក្នុងទីផ្សារការងារឡើងវិញ ពួកគេច្រើនតែទទួលបានប្រាក់ឈ្នួលទាបជាងប្រាក់ឈ្នួលដែលពួកគេធ្លាប់ទទួលបានពីមុន។

លទ្ធផលនៃការអង្កេតក៏បានបង្ហាញផងដែរថា ចំនួនម៉ោងធ្វើការជាមធ្យមក្នុងមួយសប្តាហ៍របស់ស្រី បានចាប់ផ្តើមថយចុះចាប់ពីអាយុ ៣៥ ឆ្នាំឡើង។

**តារាង ៧.៤ ប្រាក់ឈ្នួលប្រចាំខែជាមធ្យម និងជាមេដ្យាន តាមក្រុមអាយុ និងភេទ**

(ជារៀល)

| ក្រុមអាយុ | ប្រាក់ឈ្នួលប្រចាំខែជាមធ្យម | | | ប្រាក់ឈ្នួលប្រចាំខែជាមេដ្យាន | | |
|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| ១៥–២៤ | ១.០៥៧.៦៤២ | ១.០៦៦.១៤៥ | ១.០៤៧.៦៨០ | ១.០០០.០០០ | ១.០០០.០០០ | ១.០០០.០០០ |
| ២៥–៣៤ | ១.២៦៨.១៥០ | ១.៣១៤.៩០៤ | ១.២១៥.១២៨ | ១.២០០.០០០ | ១.២០០.០០០ | ១.១៦០.០០០ |
| ៣៥–៤៤ | ១.២៦៨.៤៩៩ | ១.៣៦២.១៥៩ | ១.១៤២.៤២៣ | ១.២០០.០០០ | ១.២០០.០០០ | ១.១០០.០០០ |
| ៤៥–៥៤ | ១.២២១.៥១២ | ១.៣៥៣.៥១៣ | ១.០១០.០៣៥ | ១.២០០.០០០ | ១.២០០.០០០ | ១.០០០.០០០ |
| ៥៥–៦៤ | ១.២២៥.០០៩ | ១.៣១២.១២០ | ១.០៥១.៩៨៤ | ១.២០០.០០០ | ១.២០០.០០០ | ១.០០០.០០០ |
| ៦៥+ | ៩៩០.៣៩២ | ១.០៤៣.៩៥៣ | ៨៦៦.៤៥៣ | ៨៩០.០០០ | ៩០០.០០០ | ៨០០.០០០ |
| **សរុប** | **១.២០១.៤៣៦** | **១.២៦៣.៥៣៣** | **១.១២១.៣១៦** | **១.១៥០.០០០** | **១.២០០.០០០** | **១.០៤០.០០០** |

តារាង ៧.៥ បង្ហាញថា ប្រាក់ឈ្នួលប្រចាំខែជាមធ្យម និងប្រាក់ឈ្នួលប្រចាំខែជាមេដ្យានរបស់និយោជិតនៅតំបន់ទីប្រជុំជន មានកម្រិតខ្ពស់ជាងនិយោជិតដែលរស់នៅតំបន់ជនបទ។ លើសពីនេះ និយោជិតជាស្រីនៅតំបន់ជនបទ គឺជាក្រុមដែលទទួលបានប្រាក់ឈ្នួលប្រចាំខែជាមធ្យម និងប្រាក់ឈ្នួលប្រចាំខែជាមេដ្យានទាបជាងគេ។

**តារាង ៧.៥ ប្រាក់ឈ្នួលប្រចាំខែជាមធ្យម និងជាមេដ្យាន តាមតំបន់ និងភេទ**

**(ជារៀល)**

| តំបន់ | ប្រាក់ឈ្នួលប្រចាំខែជាមធ្យម | | | ប្រាក់ឈ្នួលប្រចាំខែជាមេដ្យាន | | |
|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| **ទីប្រជុំជន** | ១.២៩៤.៨៥០ | ១.២០០.០០០ | ១.៣៧៧.១៨៤ | ១.២០០.០០០ | ១.១៩៧.៧៣១ | ១.១២០.០០០ |
| **ជនបទ** | ១.១២៣.៩៦៣ | ១.០៣៥.០០០ | ១.១៧៥.៨៤៧ | ១.១០០.០០០ | ១.០៥១.៧៩៨ | ១.០០០.០០០ |
| **សរុប** | **១.២០១.៤៣៦** | **១.១៥០.០០០** | **១.២៦៣.៥៣៣** | **១.២០០.០០០** | **១.១២១.៣១៦** | **១.០៤០.០០០** |

# ជំពូក ៨
# ម៉ោងធ្វើការ

## ៨.១ សេចក្តីផ្តើម

ជំពូកនេះបង្ហាញពីលទ្ធផលស្តីពី ម៉ោងធ្វើការរបស់អ្នកមានការងារធ្វើ រួមទាំង ការធ្វើការលើសម៉ោងតាមស្តង់ដារក្នុងមួយសប្តាហ៍ និង ភាពខ្វះការងារធ្វើដែលពាក់ព័ន្ធនឹងរយៈពេលធ្វើការ។ ការអង្កេតបានប្រមូលព័ត៌មានលម្អិតអំពីម៉ោងធ្វើការរបស់អ្នកមានការងារធ្វើដែលមានអាយុ ១៥ ឆ្នាំ និងលើស។ អ្នកឆ្លើយត្រូវបានសួរអំពីចំនួនម៉ោង និងចំនួនថ្ងៃដែលជាធម្មតាពួកគេធ្វើការក្នុងមួយសប្តាហ៍ នៅក្នុងការងារចម្បង និងការងារបន្ទាប់បន្សំ។ ស្រដៀងគ្នានេះដែរ ពួកគេក៏ត្រូវបានសួរអំពីចំនួនម៉ោងដែលពួកគេបានធ្វើការជាក់ស្តែងតាមថ្ងៃនីមួយៗ ក្នុងរយៈងពេល៧ ថ្ងៃ មុនថ្ងៃសម្ភាសន៍។

## ៨.២ ម៉ោងធ្វើការ

ពាក្យ «ម៉ោងធ្វើការជាធម្មតា» សំដៅលើចំនួនម៉ោងដែលអ្នកមានការងារធ្វើ ជាធម្មតាធ្វើការក្នុងអំឡុងពេលយោងខ្លីមួយ ដូចជាមួយសប្តាហ៍។ ចំណែកឯ «ម៉ោងធ្វើការជាក់ស្តែង» ក្នុងមួយសប្តាហ៍ សំដៅលើរយៈពេលដែលអ្នកមានការងារធ្វើបានចំណាយជាក់ស្តែងទៅលើសកម្មភាពការងារ និងសកម្មភាពពាក់ព័ន្ធនឹងការងារ រួមទាំងរយៈពេលអសកម្មក្នុងការងារ និងរយៈពេលសម្រាក ក្នុងអំឡុងពេលយោង។ផ្នែកនេះផ្តោតលើចំនួនម៉ោងធ្វើការជាមធ្យមក្នុងមួយសប្តាហ៍ (ទាំងម៉ោងធ្វើការជាធម្មតា និងម៉ោងធ្វើការជាក់ស្តែង) នៅក្នុងការងារចម្បង។ ចំនួនម៉ោងធ្វើការជាមធ្យមក្នុងមួយសប្តាហ៍ ត្រូវបានវិភាគតាម ភេទ មុខរបរ វិស័យសកម្មភាពសេដ្ឋកិច្ច និងវិស័យការងារ។

រូបភាព ៨.១ បង្ហាញពីចំនួនម៉ោងធ្វើការជាមធ្យមក្នុងមួយសប្តាហ៍ (ទាំងម៉ោងធ្វើការជាធម្មតា និងម៉ោងធ្វើការជាក់ស្តែង) របស់អ្នកមានការងារធ្វើដែលមានអាយុ ១៥ឆ្នាំ និងលើស។ យោងតាមលទ្ធផលនៃការអង្កេតចំនួនម៉ោងធ្វើការជាមធ្យមក្នុងមួយសប្តាហ៍ ទាំងម៉ោងធ្វើការជាធម្មតា និងម៉ោងធ្វើការជាក់ស្តែង របស់ប្រុស និងស្រី មានភាពខុសគ្នាគួរឱ្យកត់សម្គាល់រវាងតំបន់ទីប្រជុំជន និងតំបន់ជនបទ។

តាមភេទ គេសង្កេតឃើញថា នៅតំបន់ជនបទ ប្រុសមានចំនួនម៉ោងធ្វើការជាមធ្យម ទាំងម៉ោងធ្វើការជាធម្មតា និងម៉ោងធ្វើការជាក់ស្តែង ខ្ពស់ជាងស្រី។ ផ្ទុយទៅវិញ នៅតំបន់ទីប្រជុំជន ស្រីមានចំនួនម៉ោងធ្វើការជាមធ្យម ទាំងម៉ោងធ្វើការជាធម្មតា និងម៉ោងធ្វើការជាក់ស្តែង ខ្ពស់ជាងប្រុស។

**រូបភាព ៨.១ ម៉ោងធ្វើការជាមធ្យមក្នុងមួយសប្តាហ៍ ក្នុងការងារចម្បង តាមតំបន់ និងភេទ**




រូបភាព ៨.២ បង្ហាញពីចំនួនម៉ោងធ្វើការជាធម្មតាជាមធ្យមក្នុងមួយសប្តាហ៍នៅក្នុងការងារចម្បង តាមមុខរបរ និងភេទ។ ជារួម ប្រុសមានចំនួនម៉ោងធ្វើការជាមធ្យមខ្ពស់ជាងស្រីបន្តិច ដោយប្រុសធ្វើការជាមធ្យម ៤១,០ ម៉ោង ក្នុងមួយសប្តាហ៍ ខណៈដែលស្រីធ្វើការជាមធ្យម ៣៩,០ ម៉ោង ក្នុងមួយសប្តាហ៍។

ក្រុមមុខរបរដែលមានចំនួនម៉ោងធ្វើការជាមធ្យមខ្ពស់ជាងគេ គឺ ប្រតិបត្តិកររោងចក្រ និងម៉ាស៊ីន និងអ្នកដំឡើង ដែលស្រីធ្វើការជាមធ្យម ៤៩,៨ ម៉ោង និងប្រុស ៤៨,២ ម៉ោង ក្នុងមួយសប្តាហ៍។ ស្រដៀងគ្នានេះដែរ បុគ្គលិកការិយាល័យ ក៏មានចំនួនម៉ោងធ្វើការខ្ពស់ផងដែរ ដោយស្រីធ្វើការជាមធ្យម ៤៨,៨ ម៉ោង និងប្រុស ៤៨,៦ ម៉ោង ក្នុងមួយសប្តាហ៍។

ក្នុងចំណោមមុខរបរផ្នែកសេវាកម្ម បុគ្គលិកផ្នែកសេវាកម្ម និងអ្នកលក់នៅតាមហាង និងទីផ្សារ មានចំនួនម៉ោងធ្វើការជាធម្មតាជាមធ្យមក្នុងមួយសប្តាហ៍ ៤៣,៦ម៉ោង សម្រាប់ស្រី និង៤៥,២ម៉ោង សម្រាប់ប្រុស។ ចំណែកឯ អ្នកបច្ចេកទេស និងអ្នកជំនាញរង មានចំនួនម៉ោងធ្វើការជាមធ្យម ៤២,៧ ម៉ោង សម្រាប់ស្រី និង ៤២,១ម៉ោង សម្រាប់ប្រុស ខណៈដែល អ្នកជំនាញ ធ្វើការជាមធ្យមប្រមាណ ៤០ ម៉ោង ក្នុងមួយសប្តាហ៍ សម្រាប់ទាំងប្រុស និងស្រី។

ចំនួនម៉ោងធ្វើការជាមធ្យមទាបជាងគេ ត្រូវបានសង្កេតឃើញនៅក្នុងក្រុម កម្មករជំនាញខាងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយស្រីធ្វើការជាមធ្យមត្រឹម ១៨,៨ ម៉ោង និងប្រុស ២៤,៩ ម៉ោង ក្នុងមួយសប្តាហ៍។ ក្រុមមុខរបរនេះក៏បង្ហាញពីភាពខុសគ្នាខ្លាំងមួយនៃចំនួនម៉ោងធ្វើការរវាងប្រុស និងស្រីផងដែរ។

## រូបភាព ៨.២ ម៉ោងធ្វើការធម្មតាជាមធ្យមក្នុងមួយសប្ដាហ៍ ក្នុងការងារចម្បង តាមមុខរបរ និងភេទ




ដូចដែលបានបង្ហាញក្នុងរូបភាព ៨.៣ ចំនួនម៉ោងធ្វើការជាក់ស្ដែងជាមធ្យមក្នុងការងារចម្បង អំឡុងពេលយោង មានកម្រិតខ្ពស់ជាងបន្តិចសម្រាប់ប្រុស(៤០,៣ម៉ោង) បើប្រៀបធៀបនឹងស្រី (៣៨,៨ ម៉ោង) ក្នុងមួយសប្ដាហ៍។ និន្នាការដូចគ្នានេះត្រូវបានសង្កេតឃើញនៅគ្រប់ក្រុមមុខរបរទាំងអស់ លើកលែងតែ ការីម៉ាស៊ីន រោងចក្រ និងអ្នកដំឡើង កងកម្លាំងប្រដាប់អាវុធ និងស្មៀន ដែលស្រីមានចំនួនម៉ោងធ្វើការជាក់ស្ដែងខ្ពស់ជាងប្រុស។

## រូបភាព ៨.៣ ម៉ោងធ្វើការជាក់ស្ដែងជាមធ្យមក្នុងមួយសប្ដាហ៍ ក្នុងការងារចម្បង តាមមុខរបរ និងភេទ



## ៨.៣ ចំនួនម៉ោងធ្វើការជាមធ្យម តាមសកម្មភាពសេដ្ឋកិច្ច

តារាង ៨.១ បង្ហាញពីចំនួនម៉ោងធ្វើការជាធម្មតាជាមធ្យមក្នុងមួយសប្តាហ៍ តាមវិស័យសកម្មភាពសេដ្ឋកិច្ច និងភេទ ព្រមទាំងចំនួនម៉ោងធ្វើការជាក់ស្តែងជាមធ្យមក្នុងអំឡុងពេលយោង។ ចំនួនម៉ោងធ្វើការជាធម្មតាជាមធ្យមក្នុងមួយសប្តាហ៍ខ្ពស់ជាងគេ ត្រូវបានសង្កេតឃើញនៅក្នុង សកម្មភាពសិល្បៈ ការកម្សាន្ត និងការសម្រាកលំហែកាយ (៥២,៧ ម៉ោង) បន្ទាប់មកគឺ វិស័យសំណង់ (៤៨,៨ ម៉ោង). វិស័យឧស្សាហកម្ម (៤៨,៥ ម៉ោង) កម្មន្តសាល (៤៨,៥ ម៉ោង) ការផ្គត់ផ្គង់អគ្គិសនី ឧស្ម័ន ចំហាយទឹក និងម៉ាស៊ីនត្រជាក់(៤៧,៩ ម៉ោង) សកម្មភាពរដ្ឋបាល និងសេវាគាំទ្រ (៤៧,៨ ម៉ោង) និង សកម្មភាពរបស់អង្គការ និងស្ថាប័នក្រៅដែនអធិបតេយ្យ (៤៧,២ ម៉ោង)។

ស្រីមានចំនួនម៉ោងធ្វើការជាធម្មតាជាមធ្យមខ្ពស់ជាងប្រុសនៅក្នុង សកម្មភាពសុខភាពមនុស្ស និងការងារសង្គម (៤៥,១ ម៉ោង ធៀបនឹង ៤៣,០ ម៉ោង). ការផ្គត់ផ្គង់អគ្គិសនី ឧស្ម័ន ចំហាយទឹក និងម៉ាស៊ីនត្រជាក់(៥៥,០ ម៉ោង ធៀបនឹង ៤៦,៦ ម៉ោង) និងសកម្មភាពសិល្បៈ ការកម្សាន្តនិងការសម្រាកលំហែកាយ (៥៤,៨ ម៉ោង ធៀបនឹង ៥០,១ ម៉ោង)។ ចំណែកនៅក្នុង សកម្មភាពស្នាក់នៅ និងសេវាកម្មម្ហូបអាហារ ប្រុស និងស្រីមានចំនួនម៉ោងធ្វើការជាធម្មតាជាមធ្យមស្មើគ្នា គឺ ៤៥,៤ ម៉ោង ក្នុងមួយសប្តាហ៍។ផ្ទុយទៅវិញ ប្រុសមានចំនួនម៉ោងធ្វើការជាធម្មតាជាមធ្យមខ្ពស់ជាងស្រីនៅក្នុងវិស័យសកម្មភាពសេដ្ឋកិច្ចភាគច្រើនផ្សេងទៀត។ និន្នាការស្រដៀងគ្នានេះក៏ត្រូវបានសង្កេតឃើញចំពោះចំនួនម៉ោងធ្វើការជាក់ស្តែងជាមធ្យមក្នុងអំឡុងពេលយោងផងដែរ ទោះជាយ៉ាងណា ស្រីមានចំនួនម៉ោងធ្វើការជាក់ស្តែងជាមធ្យមខ្ពស់ជាងប្រុសនៅក្នុងសកម្មភាពស្នាក់នៅ និងសេវាកម្មម្ហូបអាហារ ព័ត៌មាននិងទំនាក់ទំនង សកម្មភាពវិជ្ជាជីវៈវិទ្យាសាស្ត្រ និងបច្ចេកទេស សកម្មភាពសុខភាពមនុស្ស និងការងារសង្គម និង សកម្មភាពសិល្បៈ ការកម្សាន្ត និងការសម្រាកលំហែកាយ។

**តារាង ៨.១ ម៉ោងធ្វើការជាមធ្យមក្នុងមួយសប្តាហ៍ ក្នុងការងារចម្បង តាមសកម្មភាពសេដ្ឋកិច្ច និងភេទ**

| សកម្មភាពសេដ្ឋកិច្ច[a] | ម៉ោងធ្វើការធម្មតាជាមធ្យម | | | ម៉ោងធ្វើការជាក់ស្តែងជាមធ្យម | | |
|---|---|---|---|---|---|---|
| | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ |
| **កសិកម្ម** | **២៧,៩** | **២១,៩** | **២៥,២** | **២៦,៨** | **២១,៥** | **២៤,៤** |
| ផលិតកម្ម ដំណាំ និងចិញ្ចឹមសត្វ សកម្មភាពបរបាញ់ និងសេវាកម្មពាក់ព័ន្ធ | ២៦,៨ | ២១,៦ | ២៤,៤ | ២៥,៧ | ២១,២ | ២៣,៦ |
| **វារីវប្បកម្មប្រមាញ់ និងការកាប់ព្រៃឈើ** | **៣២,៤** | **២៣,៨** | **២៨,៥** | **៣២,៤** | **២៤,៨** | **២៩,០** |
| ការនេសាទ និងវារីវប្បកម្ម | ៣៨,៣ | ២៨,៦ | ៣៥,៩ | ៣៨,០ | ២៨,៦ | ៣៥,៧ |
| **ឧស្សាហកម្ម** | **៤៨,៧** | **៤៨,២** | **៤៨,៥** | **៤៧,៩** | **៤៧,៩** | **៤៧,៩** |
| រុករករ៉ែ និងថ្ម | ៤៨,១ | ៥,០ | ៤៦,៣ | ៤៨,៦ | ៥,០ | ៤៦,៩ |
| ការផលិតផ្នែកកាត់ដេរសំលៀកបំពាក់ | ៤៨,៧ | ៤៨,៤ | ៤៨,៥ | ៤៨,៥ | ៤៨,២ | ៤៨,៣ |
| ផ្គត់ផ្គង់អគ្គិសនី ឧស្ម័ន ចំហាយ និងម៉ាស៊ីនត្រជាក់ | ៤៦,៦ | ៥៥,០ | ៤៧,៩ | ៤៦,២ | ៥៥,០ | ៤៧,៥ |
| ផ្គត់ផ្គង់ទឹក គ្រប់គ្រងសំរាម លូទឹក និងសកម្មភាពកែលម្អ | ៤៥,៣ | ៣៩,២ | ៤៣,០ | ៤៥,៥ | ៣៦,៩ | ៤២,៥ |
| សំណង់ | ៤៨,៩ | ៤៨,០ | ៤៨,៨ | ៤៧,៤ | ៤៥,៩ | ៤៧,២ |
| **សេវាកម្ម** | **៤៤,៦** | **៤៣,០** | **៤៣,៨** | **៤៤,៣** | **៤៣,០** | **៤៣,៧** |
| លក់ដុំ និងលក់រាយ ជួសជុលយានយន្ត | ៤៣,៩ | ៤២,៨ | ៤៣,២ | ៤៤,៤ | ៤៣,៣ | ៤៣,៧ |
| ដឹកជញ្ជូន និងស្តុកទំនិញ | ៤៥,៣ | ៤២,៥ | ៤៥,២ | ៤៥,១ | ៤៣,០ | ៤៥,០ |
| សកម្មភាពសេវាកម្មស្នាក់នៅ និងអាហារ | ៤៥,៤ | ៤៥,៤ | ៤៥,៤ | ៤៤,៩ | ៤៥,៥ | ៤៥,៣ |
| ព័ត៌មាន និងទំនាក់ទំនង | ៤៣,៦ | ៤២,៩ | ៤៣,៥ | ៤២,២ | ៤២,៩ | ៤២,៣ |

| | | | | | | |
|---|---|---|---|---|---|---|
| សកម្មភាពហិរញ្ញវត្ថុ និងធានារ៉ាប់រង | ៤៣,៣ | ៤២,៨ | ៤៣,១ | ៤២,២ | ៤១,៥ | ៤២,០ |
| សកម្មភាពអចលនទ្រព្យ | ៣០,៥ | ១៧,៤ | ២៤,២ | ២៩,៥ | ១៨,៩ | ២៤,៤ |
| សកម្មភាពវិជ្ជាជីវៈ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា | ៤៤,៣ | ៤៣,៣ | ៤៣,៧ | ៤៣,៦ | ៤៤,១ | ៤៣,៩ |
| សកម្មភាពរដ្ឋបាល និងសេវាកម្មគាំទ្រ | ៤៩,៧ | ៤៤,៧ | ៤៧,៨ | ៤៩,៩ | ៤៤,១ | ៤៧,៧ |
| រដ្ឋបាលសាធារណៈ និងការពារ សន្តិសុខសង្គមជាកាតព្វកិច្ច | ៤៤,៣ | ៤២,៥ | ៤៤,០ | ៤២,៨ | ៤០,៩ | ៤២,៤ |
| អប់រំ | ៣៨,៧ | ៣៨,២ | ៣៨,៤ | ៣៦,០ | ៣៥,១ | ៣៥,៥ |
| សកម្មភាពសុខភាពមនុស្ស និងកិច្ចការសង្គម | ៤៣,០ | ៤៥,១ | ៤៤,២ | ៤៣,២ | ៤៤,៩ | ៤៤,១ |
| សិល្បៈ កម្សាន្ត និងសប្បាយ | ៥០,១ | ៥៤,៨ | ៥២,៧ | ៤៩,៨ | ៥៦,៥ | ៥៣,៥ |
| សកម្មភាពសេវាកម្មដទៃទៀត | ៤៤,៤ | ៤២,៥ | ៤៣,២ | ៤៤,២ | ៤១,១ | ៤២,២ |
| សកម្មភាពគ្រួសារជានិយោជក និងសកម្មភាពផលិតទំនិញ និង សេវាកម្មត្រូវផ្គត់ផ្គង់របស់គ្រួសារសម្រាប់ប្រើប្រាស់ខ្លួនឯង | ៣៩,៤ | ៣៨,៩ | ៣៨,៩ | ៣៩,៤ | ៣៨,៩ | ៣៩,០ |
| សកម្មភាពអង្គការ និងអង្គភាពក្រៅប្រទេស | ៤៨,៨ | ៤៦,១ | ៤៧,២ | ៤៧,៦ | ៤៦,១ | ៤៦,៧ |
| **សរុប** | **៤១,០** | **៣៩,០** | **៤០,០** | **៤០,៣** | **៣៨,៨** | **៣៩,៦** |

## ៨.៤ ចំនួនម៉ោងធ្វើការធម្មតាជាមធ្យម តាមវិស័យ

រូបភាព ៨.៤ បង្ហាញពីការបែងចែកចំនួនម៉ោងធ្វើការជាធម្មតាជាមធ្យមក្នុងមួយសប្តាហ៍នៅក្នុងការងារចម្បង តាមវិស័យសេដ្ឋកិច្ចធំៗ និងភេទ សម្រាប់អ្នកមានការងារធ្វើសរុប ព្រមទាំងដោយឡែកសម្រាប់វិស័យក្នុងប្រព័ន្ធ និងវិស័យក្រៅប្រព័ន្ធ។

ជារួម វិស័យឧស្សាហកម្ម មានចំនួនម៉ោងធ្វើការជាធម្មតាជាមធ្យមក្នុងមួយសប្តាហ៍ខ្ពស់ជាងគេ ដោយប្រុសធ្វើការជាមធ្យម ៥០,១ម៉ោង និងស្រី ៥០,០ម៉ោង។ បន្ទាប់មកគឺ វិស័យសេវាកម្ម ដែលទាំងប្រុស និងស្រីធ្វើការជាមធ្យម ៤៤,៦ម៉ោង ក្នុងមួយសប្តាហ៍។ ចំណែកឯ វិស័យកសិកម្ម មានចំនួនម៉ោងធ្វើការជាធម្មតាជាមធ្យមទាបជាងគេ ជាពិសេសក្នុងចំណោមស្រី ដែលធ្វើការជាមធ្យម ២១,១ម៉ោង ក្នុងមួយសប្តាហ៍ បើប្រៀបធៀបនឹងប្រុសដែលធ្វើការជាមធ្យម ៣០,៦ម៉ោង ក្នុងមួយសប្តាហ៍។

ក្នុងចំណោមអ្នកធ្វើការនៅក្នុង វិស័យក្នុងប្រព័ន្ធ វិស័យឧស្សាហកម្មនៅតែជាវិស័យដែលមានចំនួនម៉ោងធ្វើការជាធម្មតាជាមធ្យមក្នុងមួយសប្តាហ៍ខ្ពស់ជាងគេ ដោយប្រុសធ្វើការជាមធ្យម ៤៨,០ ម៉ោង និងស្រី ៤៥,០ ម៉ោង ក្នុងមួយសប្តាហ៍។ បន្ទាប់មកគឺ វិស័យសេវាកម្ម ដែលប្រុសធ្វើការជាមធ្យម ៤៤,៦ ម៉ោង និងស្រី ៤២,៦ ម៉ោង ក្នុងមួយសប្តាហ៍ ខណៈដែល វិស័យកសិកម្ម មានចំនួនម៉ោងធ្វើការជាធម្មតាជាមធ្យមទាបជាងគេ ដោយប្រុសធ្វើការជាមធ្យម ២៧,៨ ម៉ោង និងស្រី ២១,៩ ម៉ោង ក្នុងមួយសប្តាហ៍។

និន្នាការស្រដៀងគ្នានេះក៏ត្រូវបានសង្កេតឃើញនៅក្នុងវិស័យក្រៅប្រព័ន្ធផងដែរ ។ វិស័យឧស្សាហកម្មមានចំនួនម៉ោងធ្វើការជាធម្មតាជាមធ្យមក្នុងមួយសប្តាហ៍ខ្ពស់ជាងគេ ដោយប្រុសធ្វើការជាមធ្យម ៤៨,៧ ម៉ោង និងស្រី ៤៨,២ ម៉ោង។ បន្ទាប់មកគឺ វិស័យសេវាកម្ម ដែលប្រុសធ្វើការជាមធ្យម ៤៤,៦ ម៉ោង និងស្រី ៤៣,០ ម៉ោង ក្នុងមួយសប្តាហ៍។ ចំណែកឯវិស័យកសិកម្ម ជាថ្មីម្តងទៀត មានចំនួនម៉ោងធ្វើការជាធម្មតាជាមធ្យមទាបជាងគេ ដោយប្រុសធ្វើការជាមធ្យម ២៧,៩ ម៉ោង និងស្រី ២១,៩ ម៉ោង ក្នុងមួយសប្តាហ៍។

**រូបភាព ៨.៤ ម៉ោងធ្វើការធម្មតាជាមធ្យមក្នុងមួយសប្តាហ៍ ក្នុងការងារចម្បង តាមវិស័យសកម្មភាពសេដ្ឋកិច្ច និងភេទ**




រូបភាព ៨.៥ បង្ហាញថា ចំនួនម៉ោងធ្វើការជាក់ស្តែងជាមធ្យមក្នុងមួយសប្តាហ៍ មានភាពខុសគ្នាយ៉ាងច្បាស់លាស់តាមសាខាសេដ្ឋកិច្ច ខណៈដែលភាពខុសគ្នារវាងប្រុស និងស្រី ជាទូទៅមានកម្រិតតិចតួច លើកលែងតែក្នុងវិស័យកសិកម្ម។

វិស័យឧស្សាហកម្ម មានចំនួនម៉ោងធ្វើការជាក់ស្តែងជាមធ្យមក្នុងមួយសប្តាហ៍ខ្ពស់ជាងគេ នៅគ្រប់វិស័យស្ថាប័ន។ ក្នុង វិស័យក្រៅប្រព័ន្ធ ប្រុសធ្វើការជាមធ្យម ៤៨,៧ ម៉ោង ក្នុងមួយសប្តាហ៍ បើធៀបនឹង ៤៨,២ ម៉ោង សម្រាប់ស្រី។ នៅក្នុង វិស័យក្នុងប្រព័ន្ធ ប្រុសធ្វើការជាមធ្យម ៤៨,០ ម៉ោង ខណៈស្រីធ្វើការជាមធ្យម ៤៥,០ ម៉ោង ក្នុងមួយសប្តាហ៍។ ជារួមវិស័យឧស្សាហកម្មបានកត់ត្រាចំនួនម៉ោងធ្វើការជាក់ស្តែងជាមធ្យមខ្ពស់ជាងគេ ដោយប្រុសធ្វើការជាមធ្យម ៥០,១ ម៉ោង និងស្រី ៥០,០ ម៉ោង ក្នុងមួយសប្តាហ៍។

វិស័យសេវាកម្ម មានចំនួនម៉ោងធ្វើការជាក់ស្តែងជាមធ្យមក្នុងមួយសប្តាហ៍ខ្ពស់ជាលំដាប់ទីពីរ។ ក្នុង វិស័យក្រៅប្រព័ន្ធ ប្រុសធ្វើការជាមធ្យម ៤៤,៦ ម៉ោង ក្នុងមួយសប្តាហ៍ បើធៀបនឹង ៤៣,០ ម៉ោង សម្រាប់ស្រី។ នៅក្នុង វិស័យក្នុងប្រព័ន្ធ ប្រុសធ្វើការជាមធ្យម ៤៤,៦ ម៉ោង ខណៈស្រីធ្វើការជាមធ្យម ៤២,៦ ម៉ោង ក្នុងមួយសប្តាហ៍។ ជារួម ទាំងប្រុស និងស្រីក្នុងវិស័យសេវាកម្ម សុទ្ធតែធ្វើការជាមធ្យម ៤៤,៦ ម៉ោង ក្នុងមួយសប្តាហ៍។

វិស័យកសិកម្ម មានចំនួនម៉ោងធ្វើការជាក់ស្តែងជាមធ្យមក្នុងមួយសប្តាហ៍ទាបជាងគេ។ ក្នុងវិស័យក្រៅប្រព័ន្ធ ប្រុសធ្វើការជាមធ្យម ២៧,៩ ម៉ោង ក្នុងមួយសប្តាហ៍ ខណៈស្រីធ្វើការជាមធ្យម ២១,៩ ម៉ោង។ នៅក្នុង វិស័យក្នុងប្រព័ន្ធ ប្រុសធ្វើការជាមធ្យម ២៧,៨ ម៉ោង ខណៈស្រីធ្វើការជាមធ្យម ២១,៩ ម៉ោង ក្នុងមួយសប្តាហ៍។ ជារួម ប្រុសធ្វើការជាមធ្យម ៣០,៦ ម៉ោង ក្នុងមួយសប្តាហ៍ បើធៀបនឹង ២១,១ ម៉ោង សម្រាប់ស្រី។

### រូបភាព ៨.៥ ម៉ោងធ្វើការជាក់ស្តែងជាមធ្យមក្នុងមួយសប្តាហ៍ ក្នុងការងារចម្បង តាមវិស័យសកម្មភាពសេដ្ឋកិច្ច និងភេទ




## ៨.៥ ចំនួនម៉ោងធ្វើការធម្មតាជាមធ្យម តាមក្រុមអាយុ

រូបភាព ៨.៦ បង្ហាញថា នៅក្នុងក្រុមអាយុភាគច្រើន ប្រុសធ្វើការក្នុងម៉ោងធ្វើការធម្មតាជាមធ្យមក្នុងមួយសប្តាហ៍ច្រើនជាងស្រី. ចំនួនម៉ោងធ្វើការធម្មតាជាមធ្យមក្នុងមួយសប្តាហ៍ បានកើនឡើងតាមអាយុ ចាប់ពីក្រុមអាយុ ១៥–១៩ ឆ្នាំ ដល់ក្រុមអាយុ ៣០–៣៤ ឆ្នាំ បន្ទាប់មកបានថយចុះជាបន្តបន្ទាប់នៅតាមក្រុមអាយុដែលមានវ័យចាស់ជាង។

### រូបភាព ៨.៦ ម៉ោងធ្វើការធម្មតាជាមធ្យមក្នុងមួយសប្តាហ៍ ក្នុងការងារចម្បង តាមក្រុមអាយុ និងភេទ



រូបភាព ៨.៧ ចំនួនម៉ោងធ្វើការជាក់ស្តែងជាមធ្យមក្នុងមួយសប្តាហ៍នៅការងារចម្បង តាមក្រុមអាយុ និងភេទ។ ចំនួនម៉ោងធ្វើការជាក់ស្តែងជាមធ្យមក្នុងមួយសប្តាហ៍ មានកម្រិតខ្ពស់បំផុតនៅក្នុងក្រុមអាយុវ័យក្មេង ១៥–៣៤ ឆ្នាំ សម្រាប់ទាំងប្រុស ស្រី និងសរុប ក្នុងចំណោមនោះ ប្រុសមានចំនួនម៉ោងធ្វើការជាក់ស្តែងជាមធ្យមខ្ពស់បំផុត គឺ ៤៤.២ ម៉ោងក្នុងមួយសប្តាហ៍ នៅក្រុមអាយុ ២៥–៣៤ ឆ្នាំ. ចាប់ពីក្រុមអាយុ ៣៥ ឆ្នាំ ឡើងទៅ ចំនួនម៉ោងធ្វើការជាក់ស្តែងជាមធ្យមបានថយចុះជាបន្តបន្ទាប់ ហើយឈានដល់កម្រិតទាបបំផុតនៅក្នុងក្រុមអាយុ ៦៥ ឆ្នាំ និងលើសពីនេះ។

នៅក្នុងក្រុមអាយុក្មេងជាងគេ ១៥–២៤ ឆ្នាំ ភាពខុសគ្នានៃចំនួនម៉ោងធ្វើការជាក់ស្តែងជាមធ្យមក្នុងមួយសប្តាហ៍រវាងប្រុស និងស្រីមានកម្រិតតិចតួចប៉ុណ្ណោះ. ដោយប្រុសធ្វើការជាមធ្យម ៤៤.០ ម៉ោង ក្នុងមួយសប្តាហ៍ ធៀបនឹង ៤៣.៦ ម៉ោង សម្រាប់ស្រី. ផ្ទុយទៅវិញ នៅក្នុងក្រុមអាយុ ៦៥ ឆ្នាំ និងលើសពីនេះ គម្លាតនេះបានកើនឡើងយ៉ាងច្បាស់ ដល់ ៥.០ ម៉ោង ដោយប្រុសធ្វើការជាមធ្យម ៣០.៤ ម៉ោង ក្នុងមួយសប្តាហ៍ ខណៈស្រីធ្វើការជាមធ្យម ២៥.៤ ម៉ោង. លទ្ធផលនេះបង្ហាញថា ភាពខុសគ្នានៃចំនួនម៉ោងធ្វើការជាក់ស្តែងរវាងប្រុស និងស្រីកាន់តែមានភាពច្បាស់លាស់នៅក្នុងក្រុមអាយុចាស់។

**រូបភាព ៨.៧ ម៉ោងធ្វើការជាក់ស្តែងជាមធ្យមក្នុងមួយសប្តាហ៍ ក្នុងការងារចម្បង តាមក្រុមអាយុ និងភេទ**




## ៨.៦ ធ្វើការលើសម៉ោង

**ផ្នែកទី ២ ម៉ោងការងារ ប្រចាំថ្ងៃ និងប្រចាំសប្តាហ៍ មាត្រា ១៣៧** នៃច្បាប់ការងារកម្ពុជា នៅគ្រប់គ្រឹះស្ថានគ្រប់ប្រភេទ មិនថាជាគ្រឹះស្ថានដែលផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈមានលក្ខណៈសប្បុរសធម៌ ឬជាវិជ្ជាជីវៈសេរីក៏ដោយ ចំនួនម៉ោងការងាររបស់កម្មករ និយោជិត ទាំងប្រុស និងស្រី មិនត្រូវលើសពី ៨ម៉ោងក្នុងមួយថ្ងៃ ឬ៤៨ម៉ោងក្នុងមួយសប្តាហ៍ឡើយ

លទ្ធផលនៃការអង្កេតបង្ហាញថា ៣០,១% នៃអ្នកមានការងារធ្វើសរុប ជាធម្មតាធ្វើការលើសពី ៤៨ ម៉ោងក្នុងមួយសប្តាហ៍. ក្នុងនោះ ប្រុសមាន ២៦,៨% និង ស្រីមាន ២៨,៥%។ ដូចដែលបានបង្ហាញក្នុង តារាង ៨.២

អ្នកមានការងារធ្វើដែលមានអាយុ ៣៥–៤៤ ឆ្នាំ មានភាគរយខ្ពស់ជាងគេ ដែលជាធម្មតាធ្វើការលើសពី ៤៨ម៉ោងក្នុងមួយសប្តាហ៍. មាន ៣០,៩% បន្ទាប់មកគឺអ្នកមានការងារធ្វើដែលមានអាយុ ២៥–៣៤ ឆ្នាំ មាន ៣៣.៣% និងអ្នកដែលមានអាយុ ៤៥–៥៤ ឆ្នាំ មាន ២៧,៩% ផ្ទុយទៅវិញ កម្មករ និយោជិតដែលមានអាយុ ៦៥ ឆ្នាំឡើងទៅ មានភាគរយទាបជាងគេ គឺត្រឹមតែ ១៧,៥% ប៉ុណ្ណោះ។

**តារាង ៨.២ អ្នកធ្វើការលើសម៉ោងធ្វើការធម្មតាក្នុងមួយសប្តាហ៍ ក្នុងការងារចម្បង តាមក្រុមអាយុ និងភេទ**

| ក្រុមអាយុ | ទាំងពីរភេទ | ប្រុស (ចំនួន) | ស្រី | ទាំងពីរភេទ | ប្រុស (% នៃអ្នកមានការងារធ្វើទាំងអស់) | ស្រី |
|---|---|---|---|---|---|---|
| ១៥–២៤ | ៥៣៣.៩៤៣ | ២៩៩.៥៣១ | ២៣៤.៤១៣ | ៣៤,៦ | ៣១,៥ | ៣៣,២ |
| ២៥–៣៤ | ៦៧៥.៩៩៥ | ៣៧៣.៨៧២ | ៣០២.១២៣ | ៣៣,៣ | ២៨,២ | ៣០,៨ |
| ៣៥–៤៤ | ៧៤០.៦៦៧ | ៣៩៧.៣៨៥ | ៣៤៣.២៨៣ | ៣០,៩ | ២៩,៧ | ៣០,៣ |
| ៤៥–៥៤ | ៣៧៩.០១៧ | ២០៧.៩៥១ | ១៧១.០៦៧ | ២៧,៩ | ២៤,៤ | ២៦,២ |
| ៥៥–៦៤ | ១៨៤.៧២៧ | ១០៩.២៨៧ | ៧៥.៤៤០ | ២២,២ | ១៧,៧ | ២០,១ |
| ៦៥+ | ៧២.៦០៥ | ៤២.៣៣៤ | ៣០.២៧២ | ១៧,៥ | ១៤,០ | ១៥,៨ |
| សរុប | ២.៥៨៦.៩៥៦ | ១.៤៣០.៣៥៨ | ១.១៥៦.៥៩៧ | ៣០,១ | ២៦,៨ | ២៨,៥ |

## ៨.៧ ភាពមានការងារធ្វើមិនគ្រាប់គ្រាន់ទាក់ទងនឹងពេលវេលា

ទិន្នន័យស្តីពីភាពមានការងារធ្វើមិនគ្រាប់គ្រាន់ទាក់ទងនឹងពេលវេលា ត្រូវបានប្រមូលពីអ្នកមានការងារធ្វើដែលមានអាយុ ១៥ ឆ្នាំឡើងទៅ ដោយផ្អែកលើសំណួរថា៖ «តើអ្នកចង់ធ្វើការបន្ថែមម៉ោងក្នុងមួយសប្តាហ៍លើសពីម៉ោងធ្វើការធម្មតារបស់អ្នកដែរឬទេ ប្រសិនបើម៉ោងបន្ថែមនោះទទួលបានប្រាក់ឈ្នួល?»។ បន្ទាប់មកអ្នកដែលមានការងារធ្វើទាំងអស់ត្រូវបានសួរបន្ថែមថា៖ «ក្នុងរយៈពេល ៤ សប្តាហ៍ចុងក្រោយ គិតចាប់ពី (កាលបរិច្ឆេទជាក់លាក់) រហូតដល់ (ថ្ងៃចុងក្រោយ ឬម្សិលមិញ) តើអ្នកបានស្វែងរកការងារបន្ថែម ឬការងារផ្សេងទៀតដែលមានប្រាក់ឈ្នួលដែរឬទេ?។ បន្ទាប់ពីនោះ មានសំណួរទីបីថា៖ តើអ្នកអាចចាប់ផ្តើមធ្វើការបន្ថែមម៉ោងក្នុងរយៈពេល ២ សប្តាហ៍ខាងមុខបានដែរឬទេ? ។ ព័ត៌មានស្តីពីអ្នកមានការងារធ្វើដែលជាធម្មតាធ្វើការតិចជាង ៤០ ម៉ោងក្នុងមួយសប្តាហ៍ មុនពេលអង្កេត ត្រូវបានប្រើប្រាស់ដើម្បីវាស់វែងការមានការងារធ្វើមិនគ្រប់ម៉ោងពាក់ព័ន្ធនឹងពេលវេលា។

លទ្ធផលអង្កេតបង្ហាញថា មានតែ ១,១ % ប៉ុណ្ណោះនៃអ្នកមានការងារធ្វើសរុប ដែលជាធម្មតាធ្វើការតិចជាង ៤០ ម៉ោងក្នុងមួយសប្តាហ៍ មុនពេលអង្កេត (ប្រុស ១,៣ % និងស្រី 0.៩ %)។

យោងតាមតារាង ៨.៣. អ្នកមានការងារធ្វើមិនគ្រប់គ្រាន់តាមពេលវេលា ចំនួន ១៦,១% ស្ថិតក្នុងក្រុមអាយុ ១៥–២៤ ឆ្នាំ។ សមាមាត្រខ្ពស់បំផុតនៃអ្នកមានការងារធ្វើមិនគ្រប់គ្រាន់តាមពេលវេលា ស្ថិតនៅក្នុងក្រុមអាយុ ៣៥–៤៤ ឆ្នាំ (២៨,១%) បន្ទាប់មកគឺក្រុមអាយុ ២៥–៣៤ ឆ្នាំ (២៥,២%) ក្រុមអាយុ ៤៥–៥៤ ឆ្នាំ (១៩,៤%) និងក្រុមអាយុ ៥៥–៦៤ ឆ្នាំ (៨.៦%)។ ចំពោះប្រុស សមាមាត្រខ្ពស់បំផុតនៃអ្នកមានការងារធ្វើមិនគ្រប់គ្រាន់តាមពេលវេលា ស្ថិតនៅក្នុងក្រុមអាយុ ៣៥–៤៤ឆ្នាំ (៣០,៦%) ខណៈដែលសម្រាប់ស្រី សមាមាត្រខ្ពស់បំផុតក៏ស្ថិតនៅក្នុងក្រុមអាយុ ៣៥–៤៤ ឆ្នាំដូចគ្នា (២៦,៦%)។ ដោយឡែក សមាមាត្រទាបបំផុតនៃអ្នកមានការងារធ្វើមិនគ្រប់គ្រាន់តាមពេលវេលា ត្រូវបានកត់សម្គាល់ឃើញនៅក្នុងក្រុមអាយុ ៦៥ ឆ្នាំ និងលើសពីនេះ (២,៤%)។

### តារាង ៨.៣ ភាពមានការងារធ្វើមិនគ្រប់គ្រាន់ទាក់ទងនឹងពេលវេលា តាមក្រុមអាយុ និងភេទ

| ក្រុមអាយុ | ទាំងពីរភេទ | ប្រុស (ចំនួន) | ស្រី | ទាំងពីរភេ | ប្រុស (%) [a] | ស្រី |
|---|---|---|---|---|---|---|
| ១៥–២៤ | ២៨.១១៣ | ១៧.៤២៣ | ១០.៦៨៩ | ១៦,១ | ១៦,១ | ១៦,៣ |
| ២៥–៣៤ | ៤៣.៨៩៥ | ២៧.៤៧៦ | ១៦.៤១៩ | ២៥,២ | ២៥,៣ | ២៥,១ |
| ៣៥–៤៤ | ៤៨.៩៦៦ | ២៨.៨៩៦ | ២០.០៧០ | ២៨,១ | ២៦,៦ | ៣០,៦ |
| ៤៥–៥៤ | ៣៣.៧៩១ | ២១.៦០៨ | ១២.១៨៤ | ១៩,៤ | ១៩,៩ | ១៨,៦ |
| ៥៥–៦៤ | ១៤.៩៥២ | ១០.៥៣៩ | ៤.៤១៣ | ៨,៦ | ៩,៧ | ៦,៧ |
| ៦៥+ | ៤.៣៧៥ | ២.៦០៦ | ១.៧៦៩ | ២,៥ | ២,៤ | ២,៧ |
| សរុប | ១០៨.៥៤៧ | ៦៥.៥៤៤ | ១៧៤.០៩២ | ១០០ | ១០០ | ១០០ |

អត្រាការមានការងារធ្វើមិនគ្រប់ម៉ោងពាក់ព័ន្ធនឹងពេលវេលា ត្រូវបានកំណត់ថា ជាភាគរយនៃអ្នកមានការងារធ្វើដែលជាធម្មតាធ្វើការតិចជាង ៤០ ម៉ោងក្នុងមួយសប្តាហ៍ ហើយមានបំណង និងមានលទ្ធភាពធ្វើការបន្ថែមម៉ោងលើសពីចំនួនម៉ោងធ្វើការធម្មតារបស់ពួកគេ។ យោងតាមលទ្ធផលអង្កេត (សូមមើលតារាង ៨.៤) អត្រាការមានការងារធ្វើមិនគ្រប់ម៉ោងពាក់ព័ន្ធនឹងពេលវេលាសរុប មានកម្រិតទាបបំផុតក្នុងឆ្នាំ ២០២៥ ដោយមានត្រឹមតែ ១,៩%។

### តារាង ៨.៤ អត្រាការមានការងារធ្វើមិនគ្រប់ម៉ោងតាមក្រុមអាយុ និងភេទ

| ក្រុមអាយុ | កម្ពុជា | | | ទីប្រជុំជន | | | ជនបទ | | |
|---|---|---|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| ១៥–២៤ | ១,៧ | ២,០ | ១,៤ | ១,២ | ១,៥ | ១,០ | ២,០ | ២,៣ | ១,៧ |
| ២៥–៣៤ | ២,០ | ២,៤ | ១,៥ | ១,៤ | ១,៨ | ១,០ | ២,៤ | ២,៩ | ១,៩ |
| ៣៥–៤៤ | ២,០ | ២,៣ | ១,៧ | ១,៦ | ១,៩ | ១,២ | ២,៣ | ២,៥ | ២,២ |
| ៤៥–៥៤ | ២,៣ | ២,៩ | ១,៧ | ២,៥ | ២,៩ | ២,១ | ២,២ | ២,៩ | ១,៥ |
| ៥៥–៦៤ | ១,៦ | ២,១ | ១,០ | ២,០ | ២,៤ | ១,៤ | ១,៤ | ២,០ | ០,៨ |
| ៦៥+ | ១,០ | ១,១ | ០,៨ | ០,៤ | - | ០,៨ | ១,៣ | ១,៨ | ០,៨ |
| សរុប | ១,៩ | ២,៣ | ១,៥ | ១,៦ | ១,៩ | ១,៣ | ២,១ | ២,៥ | ១,៧ |

# ជំពូក ៩
# ការងារយុវជន

## ៩.១ សេចក្តីផ្តើម

ជំពូកនេះពិពណ៌នាអំពីលក្ខណៈរបស់ប្រជាជនយុវជន ដោយគ្របដណ្តប់លើប្រធានបទសំខាន់ៗ រួមមានយុវជនចូលរួមក្នុងកម្លាំងពលកម្ម ការមានការងារធ្វើ និងភាពគ្មានការងារធ្វើរបស់យុវជន ព្រមទាំងយុវជនដែលមិនស្ថិតក្នុងការងារធ្វើ ការអប់រំ ឬការបណ្តុះបណ្តាល (NEET)។

ផ្អែកតាមនិយមន័យអន្តរជាតិ អង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥ បានកំណត់ថា «យុវជន» សំដៅលើបុគ្គលដែលមានអាយុពី ១៥ – ២៤ ឆ្នាំ។ សម្រាប់របាយការណ៍នេះ ប្រជាជនយុវជនត្រូវបានបែងចែកបន្ថែមជា ២ ក្រុមអាយុ ដែលមានចន្លោះ ៥ ឆ្នាំ គឺ ក្រុមអាយុ ១៥–១៩ ឆ្នាំ (យុវវ័យ) និងក្រុមអាយុ ២០–២៤ ឆ្នាំ (យុវជនវ័យក្មេង)។

## ៩.២ យុវជនចូលរួមក្នុងកម្លាំងពលកម្ម

ចំនួនប្រជាជនយុវជននៅក្នុងកម្លាំងពលកម្ម បង្ហាញពីវិសាលភាពដែលយុវជនមានការងារធ្វើ មានលទ្ធភាពធ្វើការ និងកំពុងស្វែងរកការងារធ្វើយ៉ាងសកម្មនៅក្នុងសេដ្ឋកិច្ច។

ដូចបានបង្ហាញក្នុងតារាង ៩.១ នៅឆ្នាំ ២០២៥ មានយុវជនជាង ១.៨ លាននាក់ ស្ថិតនៅក្នុងកម្លាំងពលកម្ម ក្នុងនោះមានប្រុសចំនួន ៩៥០.៩៩៥ នាក់ និងស្រីចំនួន ៨៣៤.១០១ នាក់ ដែលស្មើនឹង ៦១.១%នៃប្រជាជនយុវជនសរុប។ អត្រាចូលរួមក្នុងកម្លាំងពលកម្មរបស់យុវជន មានកម្រិតខ្ពស់ជាងនៅតំបន់ជនបទ (៦២.២%) បើធៀបនឹងតំបន់ទីប្រជុំជន (៥៩.៥%)។

យុវជននៅតំបន់ជនបទ ជាពិសេសក្រុមអាយុ ១៥–១៩ ឆ្នាំ មាននិន្នាការចាកចេញពីការអប់រំមុនអាយុ ដើម្បីចូលរួមក្នុងទីផ្សារការងារ ដែលភាគច្រើនបណ្តាលមកពីការមានឱកាសទទួលបានការអប់រំ និងការបណ្តុះបណ្តាលបន្តនៅមានកម្រិត។ ទោះជាយ៉ាងណា ស្ថានភាពនេះអាចកម្រិតឱកាសការងារ និងការអភិវឌ្ឍអាជីពរបស់ពួកគេនាពេលអនាគត។

**តារាង ៩.១ យុវជននៅក្នុងកម្លាំងពលកម្ម តាមតំបន់ និងភេទ**

| ក្រុមអាយុ | កម្ពុជា | | | ទីប្រជុំជន | | | ជនបទ | | |
|---|---|---|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| កម្លាំងពលកម្ម | | | | | | | | | |
| កម្លាំងពលកម្មយុវជន (១៥–២៤ឆ្នាំ) | ១.៧៨៥.០៩៦ | ៩៥០.៩៩៥ | ៨៣៤.១០១ | ៦៨៩.៧៥៦ | ៣៥៥.៥៤៦ | ៣៣៤.២១០ | ១.០៩៥.៣៤០ | ៥៩៥.៤៤៩ | ៤៩៩.៨៩១ |
| ១៥–១៩ឆ្នាំ | ៧៣៥.៤៥៣ | ៣៨៨.៧១០ | ៣៤៦.៧៤២ | ២៦៦.៣៦៩ | ១៣៣.៩៩៧ | ១៣២.៣៧២ | ៤៦៩.០៨៤ | ២៥៤.៧១៣ | ២១៤.៣៧០ |
| ២០–២៤ឆ្នាំ | ១.០៤៩.៦៤៣ | ៥៦២.២៨៥ | ៤៨៧.៣៥៨ | ៤២៣.៣៨៧ | ២២១.៥៤៩ | ២០១.៨៣៨ | ៦២៦.២៥៦ | ៣៤០.៧៣៦ | ២៨៥.៥២០ |
| កម្លាំងពលកម្មសរុប (១៥ឆ្នាំឡើង) | ៩.៤០៧.៧១៧ | ៤.៨៩៤.១៩៧ | ៤.៥១៣.៥១៩ | ៣.៩១០.៨២០ | ១.៩៩២.៤៥៥ | ១.៩១៨.៣៦៦ | ៥.៤៩៦.៨៩៦ | ២.៩០១.៧៤៣ | ២.៥៩៥.១៥៤ |
| អត្រាចូលរួមក្នុងកម្លាំងពលកម្ម (%) | | | | | | | | | |
| កម្លាំងពលកម្មយុវជន (១៥–២៤ឆ្នាំ) | ៦១,១ | ៦៤,២ | ៥៧,៩ | ៥៩,៥ | ៦១,១ | ៥៧,៩ | ៦២,២ | ៦៦,៣ | ៥៧,៩ |
| ១៥–១៩ឆ្នាំ | ៤៦,៦ | ៤៨,៩ | ៤៤,២ | ៤២,៧ | ៤២,៨ | ៤២,៥ | ៤៩,១ | ៥២,៨ | ៤៥,៤ |
| ២០–២៤ឆ្នាំ | ៧៨,២ | ៨២,០ | ៧៤,២ | ៧៩,២ | ៨២,២ | ៧៦,១ | ៧៧,៦ | ៨១,៩ | ៧៣,០ |
| **កម្លាំងពលកម្មសរុប (១៥ឆ្នាំឡើង)** | ៧១,៦ | ៧៧,៧ | ៦៥,៩ | ៧៣,៦ | ៧៨,៥ | ៦៩,១ | ៧០,២ | ៧៧,១ | ៦៣,៨ |

## ៩.៣ យុវជនមានការងារធ្វើ និងគ្មានការងារ

អត្រាយុវជនមានការងារធ្វើ សំដៅលើចំនួនយុវជនដែលមានការងារធ្វើ និងមានអាយុពី ១៥ –២៤ ឆ្នាំ។ រីឯអត្រាយុវជនគ្មានការងារធ្វើ គឺជាចំនួនយុវជនគ្មានការងារធ្វើដែលមានអាយុពី ១៥–២៤ឆ្នាំ បង្ហាញជាភាគរយនៃកម្លាំងពលកម្មយុវជនសរុប។

តារាង ៩.២ បង្ហាញពីចំនួន និងការបែងចែកជាភាគរយនៃយុវជនដែលមានការងារធ្វើ និងគ្មានការងារធ្វើ តាមតំបន់ទីប្រជុំជន តំបន់ជនបទ និងភេទ។ នៅឆ្នាំ ២០២៥ មានយុវជនដែលមានការងារធ្វើសរុបចំនួន ១.៦០៩.២២៦ នាក់ ក្នុងនោះ ៤៨,៧% ជាប្រុស និង ៥១,៣% ជាស្រី។ លំនាំដូចគ្នានេះ ដែលមានស្រីមានការងារធ្វើច្រើនជាងប្រុសមានការងារធ្វើ ក៏ត្រូវបានសង្កេតឃើញនៅតំបន់ទីប្រជុំជនផងដែរ ខណៈដែលនៅតំបន់ជនបទ មានប្រុសមានការងារធ្វើច្រើនជាងស្រីមានការងារធ្វើ។

ចំពោះយុវជនគ្មានការងារធ្វើ មានយុវជនជាប្រុសគ្មានការងារធ្វើច្រើនជាងស្រី ទាំងនៅតំបន់ទីប្រជុំជន និងតំបន់ជនបទ។ សមាមាត្រយុវជនដែលមានការងារធ្វើ ធៀបនឹងចំនួនអ្នកមានការងារធ្វើសរុប មាន ១៧,៨% ខណៈដែលសមាមាត្រយុវជនគ្មានការងារធ្វើ ធៀបនឹងចំនួនអ្នកគ្មានការងារធ្វើសរុប មាន ៥១,៤%។

តារាង ៩.២ បង្ហាញថា អត្រាយុវជនគ្មានការងារធ្វើ ត្រូវបានប៉ាន់ស្មានថាមាន ៩,៩% នៅឆ្នាំ ២០២៥។ អត្រាគ្មានការងារធ្វើមានកម្រិតខ្ពស់ជាងបន្តិចក្នុងចំណោមស្រី (១០,៨%) បើធៀបនឹងយុវជនប្រុស (៩,១%)។ ទន្ទឹមនឹងនេះអត្រាគ្មានការងារធ្វើរបស់យុវជនមានកម្រិតខ្ពស់ជាងគួរឱ្យកត់សម្គាល់នៅតំបន់ទីប្រជុំជន គឺមាន (១៥,៦%) បើធៀបនឹងតំបន់ជនបទ (៦,២%)។ ទាំងនៅតំបន់ទីប្រជុំជន និងតំបន់ជនបទ អត្រាគ្មានការងារធ្វើមានកម្រិតខ្ពស់ជាងក្នុងចំណោមយុវជនស្រី បើធៀបនឹងយុវជនប្រុស។

### តារាង ៩.២ យុវជនមានការងារធ្វើ និងគ្មានការងារ តាមតំបន់ និងភេទ

| ការងារ | កម្ពុជា | | | ទីប្រជុំជន | | | ជនបទ | | |
|---|---|---|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| ចំនួនកម្លាំងពលកម្ម [a] | | | | | | | | | |
| យុវជនមានការងារធ្វើ [b] | ១.៦០៩.២២៦ | ៨៦៤.៨០៨ | ៧៤៤.៤១៨ | ៥៨២.៣១៨ | ២៩៨.២៩៦ | ២៨៤.០២២ | ១.០២៦.៩០៨ | ៥៦៦.៥១២ | ៤៦០.៣៩៦ |
| យុវជនគ្មានការងារធ្វើ | ១៧៥.៨៧០ | ៨៦.១៨៧ | ៨៩.៦៨៣ | ១០៧.៤៣៨ | ៥៧.២៥០ | ៥០.១៨៨ | ៦៨.៤៣២ | ២៨.៩៣៧ | ៣៩.៤៩៥ |
| សរុប | ១.៧៨៥.០៩៦ | ៩៥០.៩៩៥ | ៨៣៤.១០១ | ៦៨៩.៧៥៦ | ៣៥៥.៥៤៦ | ៣៣៤.២១០ | ១.០៩៥.៣៤០ | ៥៩៥.៤៤៩ | ៤៩៩.៨៩១ |
| ភាគរយនៃចំនួនសរុបអាយុ ១៥ ឡើង | | | | | | | | | |
| យុវជនមានការងារធ្វើ[c] | ១៧,៨ | ១៨,២ | ១៧,២ | ១៥,៧ | ១៥,៦ | ១៥,៧ | ១៩,២ | ១៩,៩ | ១៨,៤ |
| យុវជនគ្មានការងារធ្វើ[d] | ៥១,៤ | ៥៨,៨ | ៤៥,៩ | ៥៦,៥ | ៦៦,៥ | ៤៨,២ | ៤៥,០ | ៤៧,៩ | ៤៣,២ |
| កម្លាំងពលកម្មយុវជនសរុប | ១៩,០ | ១៩,៤ | ១៨,៥ | ១៧,៦ | ១៧,៨ | ១៧,៤ | ១៩,៩ | ២០,៥ | ១៩,៣ |
| អត្រាកម្លាំងពលកម្មយុវជន(%) | | | | | | | | | |
| អត្រាយុវជនគ្មានការងារធ្វើ | ៩,៩ | ៩,១ | ១០,៨ | ១៥,៦ | ១៦,១ | ១៥,០ | ៦,២ | ៤,៩ | ៧,៩ |
| **សរុប** | **១០០** | **១០០** | **១០០** | **១០០** | **១០០** | **១០០** | **១០០** | **១០០** | **១០០** |

a "កម្លាំងពលកម្ម" សំដៅលើអ្នកដែលបច្ចុប្បន្នមានការងារធ្វើ ឬគ្មានការងារធ្វើ ប៉ុន្តែកំពុងស្វែងរកការងារធ្វើ។

b "យុវជន" សំដៅលើអ្នកមានអាយុ ១៥ ទៅ ២៤ ឆ្នាំ។

c. ជួរដេកនេះបង្ហាញជាភាគរយ ចំណែករបស់ប្រុស ស្រី និងសរុបអ្នកមានការងារធ្វើ ក្នុងក្រុមអាយុ ១៥-២៤ ឆ្នាំ នៃប្រជាជនមានការងារធ្វើសរុប (អាយុ ១៥ ឆ្នាំឡើង)។

d.ជួរដេកនេះបង្ហាញជាភាគរយ ចំណែករបស់ប្រុស ស្រី និងសរុបអ្នកគ្មានការងារធ្វើ ក្នុងក្រុមអាយុ ១៥-២៤ ឆ្នាំ នៃប្រជាអ្នកគ្មានការងារធ្វើសរុប (អាយុ ១៥ ឆ្នាំឡើង)។

e ជួរដេកនេះបង្ហាញជាភាគរយ ចំណែករបស់ប្រុស ស្រី និងសរុបកម្លាំងពលកម្មយុវជន (ពោលគឺទាំងអ្នកមានការងារធ្វើ និងអ្នកគ្មានការងារធ្វើ ក្នុងក្រុមអាយុ ១៥-២៤ឆ្នាំ) នៃកម្លាំងពលកម្មសរុប (អាយុ ១៥ ឆ្នាំឡើង)។

តារាង ៩.៣ បង្ហាញពីការបែងចែកយុវជនមានការងារធ្វើតាមមុខរបរ និងភេទ។ សមាមាត្រធំបំផុតនៃយុវជនមានការងារធ្វើ ស្ថិតនៅក្នុងក្រុមប្រតិបត្តិកររោងចក្រ និងម៉ាស៊ីននិងអ្នកដំឡើង (២៦,៩%) បន្ទាប់មកគឺបុគ្គលិកផ្នែកផ្តល់សេវា និងអ្នកលក់ (២៣,០%)។ មុខរបរអ្នកជំនាញកសិកម្ម ជលផល និងរុក្ខាប្រមាញ់ដែលមានជំនាញ និងមុខរបរងាយៗនីមួយៗ មានសមាមាត្រ ១៤,៦% នៃយុវជនដែលមានការងារធ្វើ។

ទាំងយុវជនប្រុស និងស្រី ភាគច្រើនបម្រើការងារការីម៉ាស៊ីន និងរោងចក្រ និងអ្នកដំឡើង ដែលមានសមាមាត្រ ២៣,៩% និង ៣០,៤% រៀងគ្នា។ លើសពីនេះ សមាមាត្រយុវជនស្រីដែលបម្រើការងារជាអ្នកផ្តល់សេវា និងអ្នកលក់ ព្រមទាំងអ្នកធ្វើសិប្បកម្ម និងមុខរបរពាក់ព័ន្ធ មានខ្ពស់ជាងយុវជនប្រុស។

## តារាង ៩.៣ យុវជនមានការងារធ្វើ តាមមុខរបរ និងភេទ

| មុខរបរ a | ទាំងពីរភេទ | ប្រុស (ចំនួន) | ស្រី | ទាំងពីរភេទ | ប្រុស (%) | ស្រី |
|---|---|---|---|---|---|---|
| អ្នកគ្រប់គ្រង | ៥.៤០៩ | ៩៧១ | ៤.៤៣៨ | ០,៣ | ០,១ | ០,៦ |
| អ្នកមានវិជ្ជាជីវៈ | ៧៣.៧៩៩ | ២១.២១៥ | ៥២.៥៨៤ | ៤,៦ | ២,៥ | ៧,១ |
| អ្នកបច្ចេកទេស និវិជ្ជាជិវៈរង | ៦២.៣២៧ | ៣៣.៩០៨ | ២៨.៤១៨ | ៣,៩ | ៣,៩ | ៣,៨ |
| ជំនួយការស្មៀន | ៧៤.៨២៦ | ៣០.៦២១ | ៤៤.២០៥ | ៤,៦ | ៣,៥ | ៥,៩ |
| អ្នកផ្តល់សេវាកម្ម និងលក់ | ៣៧០.០៤០ | ១៤៩.៣១៨ | ២២០.៧២២ | ២៣,០ | ១៧,៣ | ២៩,៧ |
| អ្នកជំនាញកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១៦៨.៧៣៨ | ១០៣.៤៧៣ | ៦៥.២៦៤ | ១០,៥ | ១២,០ | ៨,៨ |
| អ្នកធ្វើសិប្បកម្ម និងអាជីវកម្មពាក់ព័ន្ធ | ១៧២.៥១៩ | ១៤៧.៩៩៤ | ២៤.៥២៥ | ១០,៧ | ១៧,១ | ៣,៣ |
| ការីម៉ាស៊ីន និងរោងចក្រ និងអ្នកដំឡើង | ៤៣៣.៤១៤ | ២០៦.៩២០ | ២២៦.៤៩៤ | ២៦,៩ | ២៣,៩ | ៣០,៤ |
| អ្នកធ្វើមុខរបរបឋម | ២៣៥.៦៧៩ | ១៥៨.២៦៨ | ៧៧.៤១១ | ១៤,៦ | ១៨,៣ | ១០,៤ |
| កងកម្លាំងប្រដាប់អាវុធ | ១២.៤៧៥ | ១២.១១៨ | ៣៥៦ | ០,៨ | ១,៤ | ០,០ |
| .សរុប | **១.៦០៩.២២៦** | **៨៦៤.៨០៨** | **៧៤៤.៤១៨** | ១០០ | ១០០ | ១០០ |

តារាង ៩.៤ បង្ហាញថា សមាមាត្រខ្ពស់បំផុតនៃយុវជនមានការងារធ្វើ ស្ថិតនៅក្នុងវិស័យសេវាកម្ម (៤៣,៨%) បន្ទាប់មកគឺវិស័យឧស្សាហកម្ម (៣៩,៣%)។ ប្រុសភាគច្រើន (៤០,១%) បម្រើការងារនៅក្នុងវិស័យឧស្សាហកម្ម ខណៈដែលស្រីភាគច្រើន (៤៨,៣%) បម្រើការងារនៅក្នុងវិស័យសេវាកម្ម។

## តារាង ៩.៤ យុវជនមានការងារធ្វើ តាមសេដ្ឋកិច្ច និងភេទ

| សកម្មភាពសេដ្ឋកិច្ចa | ទាំងពីរភេទ | ប្រុស (ចំនួន) | ស្រី | ទាំងពីរភេទ | ប្រុស (%) | ស្រី |
|---|---|---|---|---|---|---|
| **កសិកម្ម** | ២៧២.៣៤៩ | ១៧៣.២៧២ | ៩៩.០៧៨ | ១៦,៩ | ២០,០ | ១៣,៣ |
| ផលិតកម្ម ដំណាំ និងចិញ្ចឹមសត្វ សកម្មភាពបរបាញ់ និងសេវាកម្មពាក់ព័ន្ធ | ២៤៨.៦៨០ | ១៥៦.៣១២ | ៩២.៣៦៨ | ១៥,៥ | ១៨,១ | ១២,៤ |
| រុក្ខាប្រមាញ់ និងការកាប់ព្រៃឈើ | ៤.៤៧០ | ៣.១៩៦ | ១.២៧៤ | ០,៣ | ០,៤ | ០,២ |
| នេសាទ និងវារីវប្បកម្ម | ១៩.១៩៩ | ១៣.៧៦៤ | ៥.៤៣៥ | ១,២ | ១,៦ | ០,៧ |
| **ឧស្សាហកម្ម** | **៦៣២.២៤៣** | **៣៤៦.៥៣៦** | **២៨៥.៧០៧** | **៣៩,៣** | **៤០,១** | **៣៨,៤** |
| រុករករ៉ែ និងថ្ម | ២.២៩៨ | ២.២៩៨ | - | ០,១ | ០,៣ | - |
| ផលិតផ្នែកកាត់ដេរសំលៀកបំពាក់ | ៤៧៦.១៥៦ | ២០៩.៥៦៣ | ២៦៦.៥៩៣ | ២៩,៦ | ២៤,២ | ៣៥,៨ |
| ផ្គត់ផ្គង់អគ្គីសនី ឧស្ម័ន | ៧.៤៤៨ | ៦.៤០៩ | ១.០៤០ | ០,៥ | ០,៧ | ០,១ |
| ផ្គត់ផ្គង់ទឹក គ្រប់គ្រងសំរាម លូទឹក និងម៉ាស៊ីនត្រជាក់ | ៤.៩០៩ | ៣.៧០២ | ១.២០៧ | ០,៣ | ០,៤ | ០,២ |
| សំណង់ | ១៤១.៤៣២ | ១២៤.៥៦៥ | ១៦.៨៦៧ | ៨,៨ | ១៤,៤ | ២,៣ |

| | | | | | | |
|---|---|---|---|---|---|---|
| **សេវាកម្ម** | ៧០៩.៦៣៤ | ៣៤៥.០០០ | ៣៥៩.៦៣៤ | ៤៣,៨ | ៣៩,៩ | ៤៨,៣ |
| លក់ដុំ និងលក់រាយ ជួសជុលយានយន្ត | ២៣៤.៤៨៧ | ៩៩.៨៩០ | ១៣៤.៥៩៨ | ១៤,៦ | ១១,៦ | ១៨,១ |
| ដឹកជញ្ជូន និងស្តុកទំនិញ | ៧៨.៣៨៦ | ៧២.១៦៥ | ៦.២២១ | ៤,៩ | ៨,៣ | ០,៨ |
| សកម្មភាពសេវាកម្មស្នាក់នៅ និងអាហារ | ១០៩.២៩០ | ៤០.៣៥៦ | ៦៨.៩៣៤ | ៦,៨ | ៤,៧ | ៩,៣ |
| ព័ត៌មាន និងទំនាក់ទំនង | ១១.៥៨២ | ៧.៨៦១ | ៣.៧២១ | ០,៧ | ០,៩ | ០,៥ |
| សកម្មភាពហិរញ្ញវត្ថុ និងធានារ៉ាប់រង | ២៥.១៣៥ | ១៥.៤៣៦ | ៩.៦៩៩ | ១,៦ | ១,៨ | ១,៣ |
| សកម្មភាពអចលនទ្រព្យ | ២.១៨៨ | ១.៤១៨ | ៧៧០ | ០,១ | ០,២ | ០,១ |
| សកម្មភាពវិជ្ជាជីវៈ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា | ២០.០៦២ | ៦.១២៥ | ១៣.៩៣៧ | ១,២ | ០,៧ | ១,៩ |
| សកម្មភាពរដ្ឋបាល និងសេវកម្មគាំទ្រ | ៥៨.៧៧៦ | ៣៨.៤៩១ | ២០.២៨៦ | ៣,៧ | ៤,៥ | ២,៧ |
| រដ្ឋបាលសាធារណៈ និងការពារ សន្តិសុខសង្គមជាកាតព្វកិច្ច | ២៧.៨៨៨ | ២១.៧១៨ | ៦.១៧០ | ១,៧ | ២,៥ | ០,៨ |
| អប់រំ | ៣៦.៩៣៩ | ៥.៣៥១ | ៣១.៥៨៩ | ២,៣ | ០,៦ | ៤,២ |
| សកម្មភាពសុខភាពមនុស្ស និងកិច្ចការសង្គម | ៨.៥៣២ | ១.៣៧០ | ៧.១៦២ | ០,៥ | ០,២ | ១,០ |
| សិល្បៈ កម្សាន្ត និងសប្បាយ | ៤២.៨០៣ | ១៦.៦៨៧ | ២៦.១១៦ | ២,៧ | ១,៩ | ៣,៥ |
| សកម្មភាពសេវាកម្មដទៃទៀត | ៣៥.៨៣៦ | ១៤.៨៣៧ | ២០.៩៩៩ | ២,២ | ១,៧ | ២,៨ |
| សកម្មភាពគ្រួសារជានិយោជក និងសកម្មភាពផលិតទំនិញ និង សេវាកម្មត្រូវគ្នារបស់គ្រួសារសម្រាប់ប្រើប្រាស់ខ្លួនឯង | ១២.៣០៦ | ៣.២៩៧ | ៩.០០៩ | ០,៨ | ០,៤ | ១,២ |
| សកម្មភាពអង្គការ និងអង្គភាពក្រៅប្រទេស | ៤២៣ | - | ៤២៣ | ០,០ | - | ០,១ |
| **សរុប** | **១.៦០៩.២២៦** | **៨៦៤.៨០៨** | **៧៤៤.៤១៨** | **១០០** | **១០០** | **១០០** |

តារាង ៩.៥ យុវជនដែលមានការងារធ្វើ តាមកម្រិតអប់រំ និងភេទ ។ សម្រាប់ទាំងយុវជនប្រុស និងយុវជនស្រី ភាគច្រើននៃយុវជនដែលមានការងារធ្វើ មានកម្រិតអប់រំបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ ដែលរួមគ្នាមានសមាមាត្រលើសពី ៦៤,0% នៃយុវជនដែលមានការងារធ្វើសរុប។

កម្រិតមធ្យមសិក្សាបឋមភូមិ គឺជាកម្រិតអប់រំដែលមានសមាមាត្រខ្ពស់បំផុតសម្រាប់ទាំងយុវជនប្រុស ស្រី និងយុវជនសរុប ដោយមានប្រមាណ ៣៤,0% នៃយុវជនដែលមានការងារធ្វើ។

នៅកម្រិតអប់រំខ្ពស់ មានភាពខុសគ្នាតាមភេទគួរឱ្យកត់សម្គាល់។ សមាមាត្រប្រុសដែលមានការងារធ្វើ និងបានបញ្ចប់ការសិក្សាកម្រិតមធ្យមសិក្សាទុតិយភូមិ មានខ្ពស់ជាងស្រី (២៨,៧% ធៀបនឹង ២២,៨%)។ ដូចគ្នានេះដែរ សមាមាត្រប្រុសដែលបានបញ្ចប់ការសិក្សាថ្នាក់ឧត្តមសិក្សា ក៏មានខ្ពស់ជាងស្រី (១១,២% ធៀបនឹង ៦,៩%)។ ដោយឡែក សម្រាប់ការអប់រំបច្ចេកទេស/វិជ្ជាជីវៈ សមាមាត្រស្រីមានខ្ពស់ជាងបន្តិច (០,៦% ធៀបនឹង ០,៥% សម្រាប់ប្រុស)។

## តារាង ៩.៥ យុវជនមានការងារធ្វើ តាមកម្រិតអប់រំ និងភេទ

| កម្រឹតសិក្សា | មិនដែលចូលរៀន | បឋមសិក្សា | អនុវិទ្យាល័យ | វិទ្យាល័យ | បច្ចេកទេស/វិជ្ជាជីវៈ | ឧត្តមសិក្សា | សរុប |
|---|---|---|---|---|---|---|---|
| | | | | **ចំនួន** | | | |
| ស្រី | ១១.៩៧៤ | ២៩៧.៦២៦ | ២៩២.៧៦២ | ១៩៧.៥១០ | ៤.៨៨៧ | ៦០.០៤៩ | ៨៦៤.៨០៨ |
| ប្រុស | ៤.៤៦៨ | ១៨៤.២៣៧ | ២៥៤.៧០០ | ២១៣.៧៩០ | ៣.៨២២ | ៨៣.៤០១ | ៧៤៤.៤១៨ |
| **ទាំងពីរភេទ** | **១៦.៤៤២** | **៤៨១.៨៦៣** | **៥៤៧.៤៦២** | **៤១១.៣០១** | **៨.៧០៩** | **១៤៣.៤៥០** | **១.៦០៩.២២៦** |
| | | | | (%) | | | |
| ស្រី | ១,៤ | ៣៤,៤ | ៣៣,៩ | ២២,៨ | ០,៦ | ៦,៩ | ១០០ |
| ប្រុស | ០,៦ | ២៤,៧ | ៣៤,២ | ២៨,៧ | ០,៥ | ១១,២ | ១០០ |
| **ទាំងពីរភេទ** | **១,០** | **២៩,៩** | **៣៤,០** | **២៥,៦** | **០,៥** | **៨,៩** | **១០០** |

តារាង ៩.៦ បង្ហាញពីការបែងចែកយុវជនគ្មានការងារធ្វើ តាមកម្រិតអប់រំ និងភេទ នៅប្រទេសកម្ពុជា ឆ្នាំ ២០២៥។ លទ្ធផលអង្កេតបង្ហាញថា អ្នកគ្មានការងារធ្វើក្នុងចំណោមយុវជន ផ្តោតជាចម្បងលើអ្នកដែលមានកម្រិតអប់រំខ្ពស់ ជាពិសេសអ្នកដែលបានបញ្ចប់ការសិក្សាកម្រិតមធ្យមសិក្សាទុតិយភូមិ និងឧត្តមសិក្សា។

ក្នុងចំណោមយុវជនគ្មានការងារធ្វើសរុប ៤៤,៩% បានបញ្ចប់ការសិក្សាកម្រិតមធ្យមសិក្សាទុតិយភូមិ ដែលជាកម្រិតអប់រំមានសមាមាត្រខ្ពស់បំផុត។ សមាមាត្រនេះមានកម្រិតខ្ពស់ជាងក្នុងចំណោមប្រុស (៤៨,៩%) បើធៀបនឹងស្រី (៤០,៧%) ដែលបង្ហាញថា ស្ទើរតែពាក់កណ្តាលនៃប្រុសគ្មានការងារធ្វើ បានបញ្ចប់ការសិក្សាកម្រិតមធ្យមសិក្សាទុតិយភូមិ។

អ្នកបានបញ្ចប់ការសិក្សាកម្រិតឧត្តមសិក្សា មានសមាមាត្រ ២០,៩ % នៃយុវជនគ្មានការងារធ្វើ។ សមាមាត្រនេះមានកម្រិតខ្ពស់ជាងបន្តិចក្នុងចំណោមយុវជនស្រី (២១,៥%) បើធៀបនឹងយុវជនប្រុស (២០,៣%) ដែលបង្ហាញថា យុវជនគ្មានការងារធ្វើមួយចំណែកគួរឱ្យកត់សម្គាល់ បានបញ្ចប់ការសិក្សាកម្រិតឧត្តមសិក្សា។

យុវជនដែលបានបញ្ចប់ការសិក្សាកម្រិតមធ្យមសិក្សាបឋមភូមិ មានសមាមាត្រ ១៧,៨% នៃយុវជនគ្មានការងារធ្វើសរុប។ សមាមាត្រនេះមានកម្រិតខ្ពស់គួរឱ្យកត់សម្គាល់ក្នុងចំណោមស្រី (២១,៣%) បើធៀបនឹងប្រុស (១៤,៤%) ដែលបង្ហាញថា ស្រីគ្មានការងារធ្វើ ទំនងជាបានបញ្ចប់ការសិក្សាកម្រិតមធ្យមសិក្សាបឋមភូមិច្រើនជាងប្រុស។

យុវជនដែលបានបញ្ចប់ការសិក្សាកម្រិតបឋមសិក្សា មានសមាមាត្រ ១៥,៦% នៃយុវជនគ្មានការងារធ្វើសរុប ដោយមានភាពខុសគ្នាតិចតួចរវាងស្រី (១៥,៨%) និងប្រុស (១៥,៥%)។

**តារាង ៩.៦ យុវជនគ្មានការងារធ្វើ តាមកម្រិតអប់រំ និងភេទ**

| កម្រិតសិក្សា | មិនដែលចូលរៀន | បឋមសិក្សា | អនុវិទ្យាល័យ | វិទ្យាល័យ | បច្ចេកទេស/វិជ្ជាជីវៈ | ឧត្តមសិក្សា | សរុប |
|---|---|---|---|---|---|---|---|
| | | | | ចំនួន | | | |
| ស្រី | - | ១៣.៥៧៨ | ១៨.៣៥១ | ៣៥.០៤៩ | ៧០៩ | ១៨.៥០០ | ៨៦.១៨៧ |
| ប្រុស | ២៨៣ | ១៣.៩២៧ | ១២.៩៥២ | ៤៣.៨៩២ | ៤១៨ | ១៨.២១១ | ៨៩.៦៨៣ |
| **ទាំងពីរភេទ** | ២៨៣ | ២៧.៥០៥ | ៣១.៣០៣ | ៧៨.៩៤១ | ១.១២៧ | ៣៦.៧១២ | ១៧៥.៨៧០ |
| | | | | (%) | | | |
| ស្រី | - | ១៥,៨ | ២១,៣ | ៤០,៧ | ០,៨ | ២១,៥ | ១០០ |
| ប្រុស | ០,៣ | ១៥,៥ | ១៤,៤ | ៤៨,៩ | ០,៥ | ២០,៣ | ១០០ |
| **ទាំងពីរភេទ** | **០,២** | **១៥,៦** | **១៧,៨** | **៤៤,៩** | **០,៦** | **២០,៩** | **១០០** |

## ៩.៤ យុវជនមិនធ្វើការងារ មិនសិក្សា ឬបណ្តុះបណ្តាល

ផ្នែកនេះបង្ហាញព័ត៌មានស្តីពីយុវជនមិនធ្វើការងារ មិនសិក្សា ឬការបណ្តុះបណ្តាល។ សូចនាករ យុវជនមិនការងារធ្វើ មិនសិក្សា ឬការបណ្តុះបណ្តាល គឺជាសូចនាករដែលត្រូវបានប្រើប្រាស់យ៉ាង ទូលំទូលាយ សម្រាប់រៀបចំគោលនយោបាយក្នុងការកំណត់ឱកាសបណ្តុះបណ្តាលសមស្របសម្រាប់យុវជន។ លើសពីនេះ សូចនាករនេះក៏ត្រូវបានប្រើប្រាស់ដើម្បីគាំទ្រយុវជនឱ្យទទួលបានការងារធ្វើប្រកប ដោយចីរភាពតាមរយៈការពង្រីកឱកាស

ការងារសម្រាប់យុវជន ការពង្រីកកម្មវិធីហាត់ការងារ កំណែទម្រង់ការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងការពង្រឹងសេវាប្រឹក្សាយោបល់អំពីអាជីព។

បន្ថែមពីនេះ រាជរដ្ឋាភិបាលក៏ប្រើប្រាស់សូចនាករនេះ សម្រាប់ការរៀបចំ និងអនុវត្តការផ្តល់ថវិកាជាយុទ្ធសាស្រ្តក្រោមកម្មវិធីផ្សេងៗដែលមានគោលបំណងលើកកម្ពស់លទ្ធផលនៃការបណ្តុះបណ្តាល សម្រាប់យុវជនដែលស្ថិតក្នុងស្ថានភាពងាយរងគ្រោះ និងយុវជនដែលមានការលំបាកក្នុងការរៀនសូត្រ ឬមានពិការភាព។ ប្រសិនបើគ្មានព័ត៌មានអំពីយុវជនមិនធ្វើការងារ មិនសិក្សា ឬការបណ្តុះបណ្តាលទេនោះការរៀបចំ និងអនុវត្តវិធានការដើម្បីទាក់ទាញឱ្យយុវជនក្រុមនេះចូលរួមក្នុងការងារ ការអប់រំ ឬការបណ្តុះបណ្តាល នឹងមានការលំបាកយ៉ាងខ្លាំង។

តារាង ៩.៧ បង្ហាញពីចំនួន និងការបែងចែកជាភាគរយនៃយុវជនអាយុ ១៥–២៤ ឆ្នាំ ដែលមិនធ្វើការងារ មិនសិក្សា ឬការបណ្តុះបណ្តាល តាមតំបន់ និងភេទ។ នៅឆ្នាំ ២០២៥ មានយុវជនមិនធ្វើការងារមិនសិក្សា ឬការបណ្តុះបណ្តាល សរុបចំនួន ៣៨១.៩៩៧ នាក់ ដែលស្មើនឹង ១៣,១% នៃយុវជនសរុបទាំងអស់។

សមាមាត្រយុវជនមិនធ្វើការងារ មិនសិក្សា ឬការបណ្តុះបណ្តាលមានខ្ពស់ជាងក្នុងចំណោមយុវជនស្រី (១៤,៥%) បើធៀបនឹងយុវជនប្រុស (១១,៧%)។ លើសពីនេះ សមាមាត្រយុវជនគ្មានការងារធ្វើ ការអប់រំ ឬការបណ្តុះបណ្តាល មានខ្ពស់ជាងនៅតំបន់ជនបទ (១៤,២%) បើធៀបនឹងតំបន់ទីប្រជុំជន (១១,៣%)។

**តារាង ៩.៧ យុវជនមិនធ្វើការងារ មិនសិក្សា ឬបណ្តុះបណ្តា តាមក្រុមអាយុ តំបន់ និងភេទ**

| ក្រុមអាយុ | កម្ពុជា | | | ទីប្រជុំជន | | | ជនបទ | | |
|---|---|---|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| | | | | ចំនួន | | | | | |
| ១៥–១៩ឆ្នាំ | ១៨៣.៤១១ | ៩៣.៦៦២ | ៨៩.៧៤៩ | ៦៣.៤៤៤ | ៣៥.៣៣៥ | ២៨.១០៩ | ១១៩.៩៦៨ | ៥៨.៣២៨ | ៦១.៦៤០ |
| ២០–២៤ឆ្នាំ | ១៩៨.៥៨៦ | ៨០.០៦៤ | ១១៨.៥២២ | ៦៧.៥០៥ | ៣១.៩៤៩ | ៣៥.៥៥៦ | ១៣១.០៨១ | ៤៨.១១៥ | ៨២.៩៦៥ |
| **សរុប** | **៣៨១.៩៩៧** | **១៧៣.៧២៧** | **២០៨.២៧១** | **១៣០.៩៤៩** | **៦៧.២៨៤** | **៦៣.៦៦៥** | **២៥១.០៤៨** | **១០៦.៤៤៣** | **១៤៤.៦០៥** |
| **ចំណែកនៃយុវជន** | | | | (%) | | | | | |
| ១៥–១៩ឆ្នាំ | ១១,៦ | ១១,៨ | ១១,៤ | ១០,២ | ១១,៣ | ៩,០ | ១២,៦ | ១២,១ | ១៣,០ |
| ២០–២៤ឆ្នាំ | ១៤,៨ | ១១.៧ | ១៨,០ | ១២,៦ | ១១,៩ | ១៣,៤ | ១៦,២ | ១១,៦ | ២១,២ |
| សរុប (១៥-២៤ឆ្នាំ) | ១៣,១ | ១១.៧ | ១៤,៥ | ១១,៣ | ១១,៦ | ១១,០ | ១៤,២ | ១១,៨ | ១៦,៧ |

# ជំពូក ១០

# ភាពគ្មានការងារធ្វើ

## ១០. ១ សេចក្ដីផ្ដើម

ជំពូកនេះបង្ហាញអំពីលក្ខណៈរបស់អ្នកគ្មានការងារធ្វើ ដោយពិពណ៌នាអំពីអ្នកគ្មានការងារធ្វើតាមក្រុមអាយុ និងភេទ រយៈពេលនៃការគ្មានការងារធ្វើ និងវិធីសាស្ត្រស្វែងរកការងារ ព្រមទាំងបង្ហាញអត្រាគ្មានការងារធ្វើ និងអត្រានៃការប្រើប្រាស់មិនគ្រប់គ្រាន់នូវកម្លាំងពលកម្ម។

អ្នកគ្មានការងារធ្វើ សំដៅលើបុគ្គលទាំងអស់ ដែលក្នុងអំឡុងពេលយោង មិនមានការងារធ្វើ ប៉ុន្តែកំពុងស្វែងរកការងារយ៉ាងសកម្ម និងមានលទ្ធភាពអាចចូលបំពេញការងារបាន។

## ១០.២ ភាពគ្មានការងារធ្វើ

ក្នុងឆ្នាំ២០២៥ កម្ពុជា មានអ្នកគ្មានការងារធ្វើដែលមានអាយុ ១៥ ឆ្នាំឡើង សរុបចំនួន ៣៤២.០៦៧ នាក់ (តារាង ១០.១)។ ក្នុងចំណោមនោះ មាន ១៧៥.៨៧០ នាក់ (៥១,៤%) មានអាយុពី ១៥–២៤ ឆ្នាំ និង ១៦៦.១៩៧ នាក់ (៤៨,៤%) មានអាយុពី ២៥–៦៤ ឆ្នាំ ខណៈដែលអ្នកមានអាយុ ៦៥ ឆ្នាំឡើង មានត្រឹមតែ ៤៩៩ នាក់ (០,១%) ប៉ុណ្ណោះ។

ក្នុងក្រុមអាយុក្មេងជាងគេ (១៥–២៤ ឆ្នាំ) ចំនួនប្រុសគ្មានការងារធ្វើមានច្រើនជាងស្រី ខណៈដែលផ្ទុយទៅវិញ នៅក្នុងក្រុមអាយុចាស់ជាង (៣៥–៦៤ ឆ្នាំ) ចំនួនស្រីគ្មានការងារធ្វើមានច្រើនជាងប្រុស។

**តារាង ១០.១ អ្នកគ្មានការងារធ្វើ តាមក្រុមអាយុ និងភេទ**

| ក្រុមអាយុ | ទាំងពីរភេទ | ប្រុស (ចំនួន) | ស្រី | ទាំងពីរភេទ | ប្រុស (%) | ស្រី |
|---|---|---|---|---|---|---|
| ១៥–២៤ | ១៧៥.៨៧០ | ៨៦.១៨៧ | ៨៩.៦៨៣ | ៥១,៤ | ៥៨,៨ | ៤៥,៩ |
| ២៥–៣៤ | ៥៦.៧៧៣ | ២១.៨៩២ | ៣៤.៨៨១ | ១៦,៦ | ១៤,៩ | ១៧,៨ |
| ៣៥–៤៤ | ៥៤.៧២៥ | ២០.៦០១ | ៣៤.១២៤ | ១៦,០ | ១៤,១ | ១៧,៤ |
| ៤៥–៥៤ | ៤០.៧៥៤ | ១២.៧៦៩ | ២៧.៩៨៥ | ១១,៩ | ៨,៧ | ១៤,៣ |
| ៥៥–៦៤ | ១៣.៤៤៦ | ៥.០៥៤ | ៨.៣៩៣ | ៣,៩ | ៣,៤ | ៤,៣ |
| ៦៥+ | ៤៩៩ | ០ | ៤៩៩.៣៦១៩៨ | ០,១ | - | ០,៣ |
| **សរុប** | **៣៤២.០៦៧** | **១៤៦.៥០៤** | **១៩៥.៥៦៤** | **១០០** | **១០០** | **១០០** |

តារាង ១០.២ បង្ហាញពីការបែងចែក អ្នកគ្មានការងារធ្វើតាមកម្រិតការអប់រំ។ ក្នុងចំណោមអ្នកគ្មានការងារធ្វើនៅឆ្នាំ២០២៥ ប្រមាណជិតមួយភាគបី(៣១,២%)បានបញ្ចប់ការអប់រំមធ្យមសិក្សាទុតិយភូមិ ខណៈជាងមួយភាគបួន(២៩,២%) បានបញ្ចប់ការអប់រំបឋមសិក្សា និងប្រមាណមួយភាគប្រាំ (២០,២%) បានបញ្ចប់ការអប់រំមធ្យមសិក្សាបឋមភូមិ។ ចំណែកឯអ្នកដែលបានបញ្ចប់ការសិក្សាថ្នាក់ឧត្តមសិក្សា មានតិចជាងមួយភាគដប់ (១៤,៦%)។ ក្នុងចំណោមអ្នកគ្មានការងារធ្វើដែលមានការអប់រំត្រឹមបឋមសិក្សា ស្រីមានចំនួនច្រើនជាងប្រុស។ ផ្ទុយទៅវិញ សមាមាត្រប្រុសគ្មានការងារធ្វើដែលបានបញ្ចប់ការអប់រំមធ្យមសិក្សាទុតិយភូមិ ឬទទួលបានការអប់រំថ្នាក់ឧត្តម

សិក្សា មានខ្ពស់ជាងស្រីគ្មានការងារធ្វើ។ បើពិនិត្យតាមទីកន្លែងរស់នៅ អ្នកគ្មានការងារធ្វើនៅតំបន់ទីប្រជុំជនភាគច្រើនបានបញ្ចប់ការអប់រំមធ្យមសិក្សាទុតិយភូមិ (៣៦,៧%)។ ចំណែកនៅតំបន់ជនបទ សមាមាត្រខ្ពស់បំផុតនៃអ្នកគ្មានការងារធ្វើបានបញ្ចប់ការអប់រំបឋមសិក្សា (៣៨,៤%) បន្ទាប់មកគឺអ្នកដែលបានបញ្ចប់ការអប់រំមធ្យមសិក្សាទុតិយភូមិ (២៤,៣%)។

**តារាង ១០.២ ប្រជាជនគ្មានការងារធ្វើ តាមកម្រិតសិក្សា តំបន់ និងភេទ**

(%)

| កម្រឹតសិក្សា | កម្ពុជា | | | ទីប្រជុំជន | | | ជនបទ | | |
|---|---|---|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| មិនធ្លាប់បានចូលរៀន | ៤,៥ | ២,៦ | ៦,០ | ២,១ | ០,៩ | ៣,០ | ៧,៦ | ៤,៩ | ៩,៤ |
| បឋមសិក្សា | ២៩,២ | ២៣,៦ | ៣៣,៣ | ២១,៨ | ១៨,១ | ២៤,៨ | ៣៨,៤ | ៣១,៣ | ៤៣,០ |
| អនុវិទ្យាល័យ | ២០,២ | ២៥,៤ | ១៦,៣ | ១៩,១ | ១៨,៧ | ១៩,៤ | ២១,៦ | ៣៥,១ | ១២,៨ |
| វិទ្យាល័យ | ៣១,២ | ៣១,៦ | ៣០,៩ | ៣៦,៧ | ៤០,១ | ៣៣,៩ | ២៤,៣ | ១៩,៤ | ២៧,៥ |
| អប់រំបច្ចេកទេស និងវិជ្ជាជីវៈ | ០,៣ | ០,៥ | ០,២ | ០,៤ | ០,៨ | - | ០,៣ | - | ០,៥ |
| ឧត្តមសិក្សា | ១៤,៦ | ១៦,៤ | ១៣,២ | ១៩,៩ | ២១,៣ | ១៨,៨ | ៧,៨ | ៩,៣ | ៦,៨ |
| សរុប(%) | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ |
| **សរុប (ចំនួន)** | **៣៤២.០៦៧** | **១៤៦.៥០៤** | **១៩៥.៥៦៤** | **១៩០.១៦២** | **៨៦.០៧០** | **១០៤.០៩៣** | **១៥១.៩០៥** | **៦០.៤៣៤** | **៩១.៤៧១** |

## ១០.៣ រយៈពេលគ្មានការងារធ្វើ

រយៈពេលនៃភាពគ្មានការងារធ្វើ គឺជារយៈពេលដែលបុគ្គលស្ថិតក្នុងស្ថានភាពគ្មានការងារធ្វើ ដោយគ្មានការងារធ្វើ និងកំពុងស្វែងរកការងារដែលមានប្រាក់ឈ្នួលឬកំពុងព្យាយាមចាប់ផ្តើមអាជីវកម្មផ្ទាល់ខ្លួន។

តារាង ១០.៣ បង្ហាញថា ភាគច្រើនលើសលប់នៃអ្នកគ្មានការងារធ្វើ (៩៤,១%) បានជួបប្រទះភាពគ្មានការងារធ្វើរយៈពេលខ្លី (តិចជាង ១២ ខែ) ក្នុងឆ្នាំ ២០២៥ ខណៈដែលមានត្រឹមតែ ៥,៩% ប៉ុណ្ណោះ ដែលបានស្វែងរកការងាររយៈពេល ១ ឆ្នាំ ឬយូរជាងនេះ។

ក្នុងចំណោមអ្នកគ្មានការងារធ្វើរយៈពេលខ្លី ភាគច្រើនបានស្វែងរកការងារធ្វើក្នុងរយៈពេលតិចជាង ៣ ខែ ដោយក្នុងនោះ ១៣,% អ្នកគ្មានការងារធ្វើរយៈពេលតិចជាង ១ ខែ និង ៥៨,១% អ្នកគ្មានការងារធ្វើរយៈពេលពី ១ ខែ ដល់តិចជាង ៣ ខែ។ បន្ថែមពីនេះ ១៤,០% បានស្វែងរកការងាររយៈពេលពី ៣ ខែ ដល់តិចជាង ៦ ខែ ខណៈដែល ៨,៩% អ្នកគ្មានការងារធ្វើរយៈពេលពី ៦ ខែ ដល់តិចជាង ១ ឆ្នាំ។

ស្រីដែលកំពុងស្វែងរកការងារធ្វើ មាននិន្នាការជួបប្រទះភាពគ្មានការងារធ្វើរយៈពេលខ្លីខ្ពស់ជាងប្រុស។ ផ្ទុយទៅវិញ អត្រានៃភាពគ្មានការងារធ្វើរយៈពេលវែង មានកម្រិតខ្ពស់ជាងក្នុងចំណោមប្រុស បើធៀបនឹងស្រី។

**តារាង ១០.៣ រយៈពេលគ្មានការងារធ្វើ តាមភេទ**

| រយៈពេល | | ទាំងពីរភេទ | ប្រុស (ចំនួន) | ស្រី | ទាំងពីរភេទ | ប្រុស (%) | ស្រី |
|---|---|---|---|---|---|---|---|
| គ្មានការងារធ្វើរយៈពេលខ្លី, | តិចជាង១ខែ | ៤៤.៩៩១ | ១៨.៣៧៩ | ២៦.៦១១ | ១៣,២ | ១២,៥ | ១៣,៦ |
| | ១ខែ ទៅតិចជាង ៣ខែ | ១៩៨.៧០១ | ៨៧.១៩០ | ១១១.៥១០ | ៥៨,១ | ៥៩,៥ | ៥៧,០ |
| | ៣ខែ ទៅតិចជាង ៦ខែ | ៤៧.៧៦៣ | ១៩.២២៦ | ២៨.៥៣៦ | ១៤,០ | ១៣,១ | ១៤,៦ |
| | ៦ខែ ទៅតិចជាង ១២ខែ | ៣០.៣៨៥ | ១១.២០៧ | ១៩.១៧៨ | ៨,៩ | ៧,៦ | ៩,៨ |
| | **សរុបរងរយៈពេលខ្លី** | **៣២១.៨៤០** | **១៣៦.០០២** | **១៨៥.៨៣៥** | **៩៤,១** | **៩២,៨** | **៩៥,០** |
| គ្មានការងារធ្វើរយៈពេលវែង | ១២ខែ ទៅតិចជាង ២ឆ្នាំ | ១៤.៥៥៣ | ៧.៧០៤ | ៦.៨៤៩ | ៤,៣ | ៥,៣ | ៣,៥ |
| | ២ឆ្នាំឡើងទៅ | ៥.៦៧៦ | ២.៧៩៧ | ២.៨៧៩ | ១,៧ | ១,៩ | ១,៥ |
| | **សរុបរងរយៈពេលវែង** | **២០.២២៩** | **១០.៥០១** | **៩.៧២៨** | **៥,៩** | **៧,២** | **៥,០** |
| មានឆន្ទៈក្នុងការធ្វើការ | | **២.៧០២** | **៨៩៨** | **១.៨០៣** | ០,៨ | ០,៦ | ០,៩ |
| ចាប់ផ្តើមការងារនៅអនាគត់ | | **៥.៥៧២** | **៣.០៧៤** | **២.៤៩៧** | **១,៦** | **២,១** | **១,៣** |
| **សរុបអ្នកគ្មានការងារធ្វើ** | | **៣៤២.០៦៧** | **១៤៦.៥០៤** | **១៩៥.៥៦៤** | **១០០** | **១០០** | **១០០** |

## ១០.៤ វិធីសាស្ត្រស្វែងរកការងារ

រូបភាព ១០.១ បង្ហាញពីមធ្យោបាយនៃអ្នកគ្មានការងារធ្វើបានប្រើប្រាស់ ដើម្បីស្វែងរកការងារធ្វើដែលមានប្រាក់ឈ្នួល ឬចាប់ផ្តើមអាជីវកម្ម ក្នុងអំឡុងពេល ៤ សប្តាហ៍មុនថ្ងៃសម្ភាសន៍។ ការស្វែងរកជំនួយពីសាច់ញាតិ មិត្តភក្តិ និងអ្នកជទៃ គឺជាមធ្យោបាយស្វែងរកការងារដែលត្រូវបានប្រើប្រាស់ច្រើនជាងគេ ដោយមានប្រមាណពីរភាគប្រាំ (៤០,២%) នៃអ្នកគ្មានការងារធ្វើ។ ប្រមាណមួយភាគប្រាំ (២០,៩%) បានដាក់ពាក្យស្នើសុំការងារធ្វើដោយផ្ទាល់ទៅនិយោជក។ មធ្យោបាយផ្សេងទៀតដែលត្រូវបានប្រើប្រាស់ជាទូទៅ រួមមាន ការទៅសាកសួរនៅរោងចក្រ ឬកន្លែងធ្វើការ (១១,៤%) និងការសិក្សា ឬអានការផ្សព្វផ្សាយជ្រើសរើសបុគ្គលិក (៧,៨%)។

មធ្យោបាយផ្សេងទៀតដែលត្រូវបានប្រើប្រាស់ក្នុងសមាមាត្រទាបជាង រួមមាន មធ្យោបាយផ្សេងៗទៀតដែលមិនបានបញ្ជាក់(៦,៧%) ការផ្សព្វផ្សាយ ឬឆ្លើយតបនឹងការផ្សព្វផ្សាយជ្រើសរើសបុគ្គលិក (៤,៤%) ការបង្ហោះ ឬធ្វើបច្ចុប្បន្នភាពប្រវត្តិរូបសង្ខេបនៅលើបណ្តាញវិជ្ជាជីវៈ (៣,២%) ការចូលរួមប្រឡងឬសម្ភាសការងារ (២,៧%) និងការចុះឈ្មោះជាមួយទីភ្នាក់ងារជ្រើសរើសបុគ្គលិកឯកជន(២,៥%)។

លទ្ធផលទាំងនេះបង្ហាញថា ការពឹងផ្អែកលើបណ្តាញទំនាក់ទំនងក្រៅផ្លូវការ ដូចជាសាច់ញាតិ មិត្តភក្តិ និងអ្នកស្គាល់គ្នា ព្រមទាំងការទាក់ទងដោយផ្ទាល់ជាមួយនិយោជក នៅតែជាមធ្យោបាយសំខាន់បំផុតសម្រាប់ការស្វែងរកការងាររបស់បុគ្គលគ្មានការងារ។

**រូបភាព ១០.១ វិធីសាស្ត្រស្វែងរកការងារ**

*(%)*




## ១០.៥ អត្រាគ្មានការងារធ្វើ

អត្រាគ្មានការងារធ្វើ ផ្តោតលើចំនួនប្រជាជនគ្មានការងារ ជាភាគរយនៃកម្លាំងពលកម្មសរុប ដែលតាមនិយមន័យរួមមានទាំងអ្នកមានការងារធ្វើ និងអ្នកគ្មានការងារ ដែលកំពុងស្វែងរកការងារ និងមានលទ្ធភាពចាប់ផ្តើមធ្វើការបាន។ អត្រាគ្មានការងារធ្វើ គឺជាសូចនាករសំខាន់មួយនៃទីផ្សារការងារ ដែលត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ ដើម្បីបង្ហាញពីស្ថានភាពដំណើរការនៃទីផ្សារការងារ និងសមត្ថភាពរបស់សេដ្ឋកិច្ចក្នុងការបង្កើតការងារគ្រប់គ្រាន់សម្រាប់កម្លាំងពលកម្ម។

សូចនាករនេះ ត្រូវបានប្រើប្រាស់ដោយអ្នករៀបចំគោលនយោបាយ ដៃគូអភិវឌ្ឍន៍ អ្នកស្រាវជ្រាវ អ្នកសិក្សាស្រាវជ្រាវ និងសាធារណជន ដើម្បីវាយតម្លៃស្ថានភាពទីផ្សារការងារ។ លើសពីនេះ អត្រាគ្មានការងារធ្វើអាចគាំទ្រដល់ការស្រាវជ្រាវ និងការវិភាគទីផ្សារការងារ ព្រមទាំងការរៀបចំ និងការវាយតម្លៃគោលនយោបាយទីផ្សារការងារ។

អត្រាគ្មានការងារធ្វើ ក៏ជាសូចនាករដែលអាចឆ្លុះបញ្ចាំងពីភាពមិនស៊ីសង្វាក់គ្នារវាងការផ្គត់ផ្គង់កម្លាំងពលកម្ម និងតម្រូវការកម្លាំងពលកម្មផងដែរ ដោយវាអាចឆ្លុះបញ្ចាំងបានមួយផ្នែកពីវដ្តអាជីវកម្ម និងស្ថានភាពសេដ្ឋកិច្ច និងសង្គមរបស់ប្រជាជន។ អត្រាគ្មានការងារធ្វើ ទាប អាចបង្ហាញថា ប្រទេសមួយមានដំណើរការសេដ្ឋកិច្ចល្អ។ ទោះជាយ៉ាងណា អត្រាគ្មានការងារធ្វើ ដែលទាបពេក ក៏អាចឆ្លុះបញ្ចាំងពីការខ្វះជម្រើសក្រៅពីការងារផងដែរ ដូចជាកង្វះឱកាសអប់រំ ប្រព័ន្ធគាំពារសង្គម និងបណ្តាញសុវត្ថិភាពសង្គមផ្សេងៗ ដែលធ្វើឱ្យប្រជាជនចាំបាច់ត្រូវធ្វើការ ដើម្បីធានាការរស់នៅ។

តារាង ១០.៤ បង្ហាញថា អត្រាគ្មានការងារធ្វើសរុបនៅកម្ពុជាក្នុងឆ្នាំ ២០២៥ មានចំនួន៣.៦% ដោយអត្រានេះមានកម្រិតស្មើគ្នាសម្រាប់ទាំងប្រុស និងស្រី។ យោងតាមតារាង ១០.៤ អត្រាគ្មានការងារធ្វើមានកម្រិតខ្ពស់ជាងក្នុងចំណោមបុគ្គលដែលមានកម្រិតអប់រំបើប្រៀបធៀបនឹងអ្នកដែលមិនធ្លាប់បានចូលរៀនអត្រាគ្មានការងារធ្វើមានកម្រិតខ្ពស់បំផុតក្នុងចំណោមអ្នកដែលបានបញ្ចប់ការអប់រំមធ្យមសិក្សាទុតិយភូមិ(៦,១%) បន្ទាប់មកអ្នកដែលបានបញ្ចប់ការអប់រំមធ្យមសិក្សាបឋមភូមិ (២,៩%) និងអ្នកដែលបានបញ្ចប់ការអប់រំថ្នាក់ឧត្តមសិក្សា (៦,៦%)។ អ្នក

ដែលបានបញ្ចប់ត្រឹមបឋមសិក្សាមានអត្រាគ្មានការងារធ្វើ ២,៥% ខណៈដែលអ្នកមិនធ្លាប់បានចូលរៀនមានអត្រាគ្មានការងារធ្វើ ៣,៤%។

ជាទូទៅ អត្រាគ្មានការងារធ្វើរបស់ស្រីមានកម្រិតខ្ពស់ជាងប្រុសនៅគ្រប់កម្រិតអប់រំ លើកលែងតែកម្រិតមធ្យមសិក្សាទុតិយភូមិប៉ុណ្ណោះ។ លទ្ធផលនេះអាចបញ្ជាក់ថា ស្រីប្រហែលជាមិនមានជម្រើសផ្សេងក្រៅពីទទួលយកការងារគ្រប់ប្រភេទ ដើម្បីធានាជីវភាពរស់នៅ។

**តារាង ១០.៤ អត្រាគ្មានការងារធ្វើ តាមកម្រិតអប់រំ តំបន់ និងភេទ**

(%)

| កម្រិតអប់រំ | កម្ពុជា | | | ទីប្រជុំជន | | | ជនបទ | | |
|---|---|---|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| មិនបានចូលរៀន | ៣,៤ | ២,១ | ៤,៣ | ៣,២ | ១,៩ | ៣,៩ | ៣,៥ | ២,២ | ៤,៥ |
| បឋមសិក្សា | ២,៥ | ១,៧ | ៣,៣ | ៣,១ | ២,៥ | ៣,៦ | ២,២ | ១,៤ | ៣,១ |
| មធ្យមសិក្សាបឋមភូមិ | ២,៩ | ២,៩ | ២,៩ | ៣,៧ | ៣,២ | ៤,១ | ២,៤ | ២,៦ | ២,០ |
| មធ្យមសិក្សាទុតិយភូមិ | ៦,០ | ៤,៨ | ៧,៦ | ៧,៨ | ៦,៨ | ៩,៣ | ៤,២ | ២,៥ | ៦,០ |
| អប់រំបច្ចេកទេស និងវិជ្ជាជីវៈ | ២,២ | ២,៤ | ២,០ | ៣,១ | ៦,០ | - | ១,៥ | - | ៤,០ |
| ឧត្តមសិក្សា | ៦,៦ | ៥,៧ | ៧,៦ | ៧,០ | ៦,១ | ៨,១ | ៥,៤ | ៤,៦ | ៦,៥ |
| សរុប | ៣,៦ | ៣,០ | ៤,៣ | ៤,៩ | ៤,៣ | ៥,៤ | ២,៨ | ២,១ | ៣,៥ |

តារាង ១០.៥ បង្ហាញពីអត្រាគ្មានការងារធ្វើតាមក្រុមអាយុ តំបន់ និងភេទ។ តារាងនេះបង្ហាញថា អត្រាគ្មានការងារធ្វើសរុបនៅកម្ពុជាក្នុងឆ្នាំ ២០២៥ មានចំនួន ៣,៦% ប៉ុន្តែជាទូទៅ អត្រានេះបានថយចុះទៅតាមការកើនឡើងនៃអាយុ។ ដូច្នេះ អត្រាគ្មានការងារធ្វើមានកម្រិតខ្ពស់បំផុតក្នុងចំណោមយុវជនអាយុ ១៥–២៤ ឆ្នាំ (៩,៩%) និងមានកម្រិតទាបបំផុតក្នុងចំណោមបុគ្គលដែលមានអាយុ ៦៥ ឆ្នាំឡើងទៅ (០,១%)។

អត្រាគ្មានការងារធ្វើខ្ពស់បំផុតត្រូវបានកត់សម្គាល់ឃើញក្នុងចំណោមយុវជនប្រុស(អាយុ១៥–២៤ឆ្នាំ) ដែលរស់នៅក្នុងតំបន់ទីប្រជុំជន។

**តារាង ១០.៥ អត្រាគ្មានការងារធ្វើ តាមក្រុមអាយុ តំបន់ និងភេទ**

(%)

| ក្រុមអាយុ | កម្ពុជា | | | ទីប្រជុំជន | | | ជនបទ | | |
|---|---|---|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| ១៥–២៤ | ៩,៩ | ៩,១ | ១០,៨ | ១៥,៦ | ១៦,១ | ១៥,០ | ៦,២ | ៤,៩ | ៧,៩ |
| ២៥–៣៤ | ២,៥ | ១,៩ | ៣,២ | ៣,១ | ២,៦ | ៣,៥ | ២,១ | ១,៤ | ២,៩ |
| ៣៥–៤៤ | ២,២ | ១,៦ | ២,៩ | ២,៦ | ១,៦ | ៣,៧ | ១,៩ | ១,៦ | ២,២ |
| ៤៥–៥៤ | ២,៧ | ១,៧ | ៣,៨ | ២,៣ | ១,៣ | ៣,៣ | ៣,០ | ២,០ | ៤,២ |
| ៥៥–៦៤ | ១,៤ | ១,០ | ១,៩ | ២,៩ | ១,៩ | ៤,០ | ០,៥ | ០,៥ | ០,៦ |
| ៦៥+ | ០,១ | - | ០,២ | - | - | - | ០,២ | - | ០,៤ |
| **សរុប** | **៣,៦** | **៣,០** | **៤,៣** | **៤,៩** | **៤,៣** | **៥,៤** | **២,៨** | **២,១** | **៣,៥** |

ទោះជាយ៉ាងណា អត្រាគ្មានការងារធ្វើទាបនៅក្នុងប្រទេសមួយ មិនមែនមានន័យថា ទីផ្សារការងារមានប្រសិទ្ធភាពនោះទេ។ ក្រៅពីអាចឆ្លុះបញ្ចាំងពីការខ្វះជម្រើសផ្សេងក្រៅពីការងារដូចដែលបានរៀបរាប់ខាងលើ អត្រាគ្មានការងារធ្វើទាបក៏អាចលាក់បាំងនូវស្ថានភាពដែលកម្មករនិយោជិត និងកម្មករធ្វើការដោយខ្លួនឯងមួយចំនួនធំ ត្រូវធ្វើការក្នុងរយៈពេលយូរជាងធម្មតា ប៉ុន្តែទទួលបានប្រាក់ចំណូលទាប ឬក៏អាចឆ្លុះបញ្ចាំងថា ភាគច្រើនលើសលប់នៃអ្នកមានការងារធ្វើស្ថិតក្នុងការងារក្រៅប្រព័ន្ធ ដែលផ្តល់ការការពារតិចតួចចំពោះហានិភ័យនៃការបាត់បង់ប្រាក់ចំណូល ឬការបាត់បង់ការងារធ្វើ។

## ១០.៦ ការប្រើមិនគ្រប់គ្រាន់នូវកម្លាំងពលកម្ម

នៅក្នុងឆ្នាំ ២០១៣ សន្និសីទអន្តរជាតិនៃអ្នកស្ថិតិការងារលើកទី ១៩ (19th International Conference of Labour Statisticians – 19th ICLS) បានអនុម័តសេចក្តីសម្រេចស្តីពីស្ថិតិការងារ ការងារធ្វើ និងការប្រើប្រាស់មិនគ្រប់គ្រាន់នូវកម្លាំងពលកម្ម។ សេចក្តីសម្រេចនេះបានទទួលស្គាល់ថា អត្រាគ្មានការងារធ្វើមានដែនកំណត់ក្នុងការឆ្លុះបញ្ចាំងពីការប្រើប្រាស់មិនគ្រប់គ្រាន់នូវកម្លាំងពលកម្ម។

យោងតាមសេចក្តីសម្រេចនេះ ការប្រើប្រាស់មិនគ្រប់គ្រាន់នូវកម្លាំងពលកម្ម សំដៅលើភាពមិនស៊ីសង្វាក់គ្នាទាំងអស់រវាងការផ្គត់ផ្គង់កម្លាំងពលកម្ម និងតម្រូវការកម្លាំងពលកម្ម ដែលបណ្តាលឱ្យប្រជាជននៅតែមានតម្រូវការការងារធ្វើដែលមិនទាន់ត្រូវបានបំពេញ។

ដោយទទួលស្គាល់ថា អត្រាគ្មានការងារធ្វើមានដែនកំណត់ក្នុងការវាស់វែងការប្រើប្រាស់មិនគ្រប់គ្រាន់នូវកម្លាំងពលកម្ម សន្និសីទអន្តរជាតិនៃអ្នកស្ថិតិការងារលើកទី ១៩ (19th ICLS) បានណែនាំនិយមន័យស្ថិតិសម្រាប់ ការប្រើប្រាស់មិនគ្រប់គ្រាន់នូវកម្លាំងពលកម្ម ដោយផ្អែកលើសូចនាករចំនួន ៤ ដែលត្រូវបានគណនាដោយប្រើសមាសធាតុសំខាន់ចំនួន ៣ ដូចខាងក្រោម៖

(i) ការងារធ្វើមិនគ្រប់ម៉ោងដោយសាររយៈពេលការងារ សំដៅលើស្ថានភាពដែលអ្នកមានការងារធ្វើមានម៉ោងធ្វើការមិនគ្រប់គ្រាន់ បើប្រៀបធៀបនឹងស្ថានភាពការងារផ្សេងដែលពួកគេមានបំណង និងមានលទ្ធភាពចូលរួមធ្វើការ។

(ii) ភាពគ្មានការងារធ្វើ ឆ្លុះបញ្ចាំងពីបុគ្គលដែលមិនមានការងារធ្វើ កំពុងស្វែងរកការងារយ៉ាងសកម្ម និងមានលទ្ធភាពចាប់ផ្តើមធ្វើការបាន។

ស្នូលនៃការប្រើប្រាស់មិនគ្រប់គ្រាន់នូវកម្លាំងពលកម្ម គឺ ភាពគ្មានការងារធ្វើ។ បុគ្គលគ្មានការងារធ្វើ គឺជាអ្នកដែលមានតម្រូវការការងារធ្វើដែលមិនទាន់ត្រូវបានបំពេញយ៉ាងច្បាស់លាស់បំផុត។ ទោះបីជា អត្រាគ្មានការងារធ្វើមានដែនកំណត់ក៏ដោយ សូចនាករនេះនៅតែត្រូវបានប្រើប្រាស់ជាញឹកញាប់ជារង្វាស់តែមួយគត់សម្រាប់វាស់វែងការប្រើប្រាស់មិនគ្រប់គ្រាន់នូវកម្លាំងពលកម្ម។

ទោះជាយ៉ាងណា អត្រាគ្មានការងារធ្វើអាចឆ្លុះបញ្ចាំងបានត្រឹមតែមួយផ្នែកប៉ុណ្ណោះអំពីការប្រើប្រាស់មិនគ្រប់គ្រាន់នូវកម្លាំងពលកម្ម។ ជាក់ស្តែង ក្នុងបរិបទជាច្រើន អាចនៅមានការផ្គត់ផ្គង់កម្លាំងពលកម្មដែលមិនទាន់ត្រូវបានប្រើប្រាស់ពេញលេញ ទាំងក្នុងចំណោមអ្នកដែលមានការងារធ្វើ (ដែលមានបំណងចង់ធ្វើការច្រើន

ម៉ោងជាងម៉ោងដែលកំពុងធ្វើ) និងក្នុងចំណោមអ្នកដែលស្ថិតនៅក្រៅកម្លាំងពលកម្ម (ដែលបានបញ្ឈប់ការស្វែងរកការងារ ឬមិនទាន់មានលទ្ធភាពចាប់ផ្តើមធ្វើការភ្លាមៗ ប៉ុន្តែនៅតែមានបំណងចង់ធ្វើការនាពេលខាងមុខ)។

លើសពីនេះ ការប្រើប្រាស់មិនគ្រប់គ្រាន់នូវកម្លាំងពលកម្មក៏អាចកើតមានក្នុងន័យគុណភាពផងដែរ ដូចជាភាពមិនស៊ីសង្វាក់គ្នារវាងជំនាញ និងការងារ (skills mismatch) ដែលបុគ្គលិកមានគុណវុឌ្ឍិ ឬជំនាញខ្ពស់ជាងតម្រូវការនៃការងារដែលខ្លួនកំពុងបំពេញ។

(iii) កម្លាំងពលកម្មសក្តានុពល (Potential labour force) សំដៅលើបុគ្គលដែលមិនមានការងារធ្វើ ប៉ុន្តែបង្ហាញពីចំណាប់អារម្មណ៍ចង់ធ្វើការ ទោះជាយ៉ាងណា ដោយសារលក្ខខណ្ឌដែលមានស្រាប់ ពួកគេមិនអាចស្វែងរកការងារយ៉ាងសកម្ម និង/ឬ មិនមានលទ្ធភាពចាប់ផ្តើមធ្វើការបាន។

រូបភាព១០.២ បង្ហាញពីសមាសភាពនៃប្រជាជនក្នុងវ័យធ្វើការតាមស្ថានភាពកម្លាំងពលកម្ម ដោយផ្ទៃពណ៌ប្រផេះបង្ហាញពីផ្នែកដែលមានការប្រើប្រាស់មិនគ្រប់គ្រាន់នូវកម្លាំងពលកម្មនៅក្នុងក្របខណ្ឌនេះ។

**រូបភាព ១០.២ សមាសធាតុនៃការប្រើមិនគ្រប់គ្រាន់នូវកម្លាំងពលកម្ម**




សូចនាករសំខាន់ទាំង ៤ ស្តីពីការប្រើប្រាស់មិនគ្រប់គ្រាន់នូវកម្លាំងពលកម្ម ដែលត្រូវបានណែនាំក្នុងសេចក្តីសម្រេចនេះ ត្រូវបានគណនាដូចខាងក្រោម៖

$$\text{LU1 - អត្រាគ្មានការងារធ្វើ} = \frac{\text{គ្មានការងារធ្វើ}}{\text{កម្លាំងពលកម្ម}} \times ១០០$$

LU2 - អត្រារួមមានការងារធ្វើមិនគ្រប់គ្រាន់ទាក់ទងនឹងពេលវេលា និងគ្មានការងារធ្វើ

$$= \frac{\text{មានការងារធ្វើមិនគ្រប់គ្រាន់ទាក់ទងនឹងពេលវេលា + គ្មានការងារធ្វើ}}{\text{កម្លាំងពលកម្ម}} \times ១០០$$

LU3 - អត្រារួមគ្មានការងារធ្វើ និងកម្លាំងពលកម្មសក្តានុពល

$$= \frac{\text{គ្មានការងារធ្វើ+ កម្លាំងពលកម្មសក្តានុពល}}{\text{កម្លាំងពលកម្ម+កម្លាំងពលកម្មសក្តានុពល}} \times ១០០$$

LU4 – រង្វាស់សមាសធាតុនៃការប្រើមិនគ្រប់គ្រាន់នូវកម្លាំងពលកម្ម

$$= \frac{\text{មានការងារធ្វើមិនគ្រប់គ្រាន់ទាក់ទងនឹងពេលវេលា + គ្មានការងារធ្វើ+ កម្លាំងពលកម្មសក្តានុពល}}{\text{កម្លាំងពលកម្ម+កម្លាំងពលកម្មសក្តានុពល}} \times ១០០$$

តារាង ១០.៦ បង្ហាញពីអត្រាការប្រើប្រាស់មិនគ្រប់គ្រាន់នូវកម្លាំងពលកម្ម។ ក្នុងឆ្នាំ ២០២៥ មានបុគ្គលចំនួន ៣៤២.០៦៧ នាក់ ដែលកំពុងស្វែងរកការងារយ៉ាងសកម្ម និងមានលទ្ធភាពចាប់ផ្តើមធ្វើការ ដែលស្មើនឹងអត្រាគ្មានការងារធ្វើ ៣,៦%។ ទោះជាយ៉ាងណា ក៏នៅមានក្រុមមនុស្សមួយចំនួនដែលមានបំណងចង់ធ្វើការ ប៉ុន្តែលក្ខខណ្ឌដែលមានស្រាប់បានកំណត់សមត្ថភាពរបស់ពួកគេក្នុងការស្វែងរកការងារយ៉ាងសកម្ម ឬក្នុងការចាប់ផ្តើមធ្វើការ។ ក្រុមនេះរួមមាន បុគ្គលចំនួន ២០.៣៨៥ នាក់ ដែលមិនមានការងារធ្វើ កំពុងស្វែងរកការងារយ៉ាងសកម្ម ប៉ុន្តែមិនមានលទ្ធភាពចាប់ផ្តើមធ្វើការ (អ្នកស្វែងរកការងារដែលមិនមានលទ្ធភាពចាប់ផ្តើមធ្វើការ) និងបុគ្គលចំនួន ១៣៤.៩១៤ នាក់ ដែលមិនបានស្វែងរកការងារនាពេលបច្ចុប្បន្ន ប៉ុន្តែមានបំណងចង់ធ្វើការ និងមានលទ្ធភាពចាប់ផ្តើមធ្វើការ (អ្នកស្វែងរកការងារសក្តានុពលដែលមានលទ្ធភាពចាប់ផ្តើមធ្វើការ)។

ទិន្នន័យនេះបង្ហាញថា មានមនុស្សសរុបចំនួន ១៥៥.២៩៩ នាក់ ដែលទោះបីជាត្រូវបានចាត់ទុកថាស្ថិតនៅក្រៅកម្លាំងពលកម្មក៏ដោយ ក៏នៅតែបង្កើតសម្ពាធលើទីផ្សារការងារ ដែលក្រុមនេះត្រូវបានហៅថា «កម្លាំងពលកម្មសក្តានុពល» ។ នៅពេលបូកកម្លាំងពលកម្មសក្តានុពលនេះចូលទៅក្នុងកម្លាំងពលកម្ម នោះនឹងបង្កើតបានជា «កម្លាំងពលកម្មពង្រីក» (Extended labour force)។

បន្ថែមពីលើអត្រាគ្មានការងារធ្វើ កម្លាំងពលកម្មសក្តានុពលក៏ជាសូចនាករមួយដែលឆ្លុះបញ្ចាំងពីការប្រើប្រាស់មិនគ្រប់គ្រាន់នូវកម្លាំងពលកម្មផងដែរ។ នៅពេលបូកចំនួនបុគ្គលគ្មានការងារធ្វើជាមួយកម្លាំងពលកម្មសក្តានុពល ហើយគណនាជាភាគរយនៃកម្លាំងពលកម្មពង្រីក នឹងទទួលបានសូចនាករ LU3 ដែលក្នុងករណីនេះមានអត្រា ៥,២%។ សូចនាករនេះបង្ហាញពីផ្នែកនៃការផ្គត់ផ្គង់កម្លាំងពលកម្មដែលមិនទាន់ត្រូវបានប្រើប្រាស់។

ក្នុងចំណោមអ្នកមានការងារធ្វើ មានបុគ្គលចំនួន ១៧៤.០៩២ នាក់ បានរាយការណ៍ថា ពួកគេចង់ធ្វើការបន្ថែមម៉ោង ដែលបង្ហាញថាកម្លាំងពលកម្មរបស់ពួកគេមិនទាន់ត្រូវបានប្រើប្រាស់ពេញលេញ។ ដូច្នេះ សូចនាករសមាសនៃការប្រើប្រាស់មិនគ្រប់គ្រាន់នូវកម្លាំងពលកម្ម (LU4) ត្រូវបានគណនាពីផលបូកនៃអ្នកមានការងារធ្វើមិនគ្រប់ម៉ោងដោយសាររយៈពេលការងារ បុគ្គលគ្មានការងារធ្វើ និងកម្លាំងពលកម្មសក្តានុពល ជាភាគរយនៃកម្លាំងពលកម្មពង្រីក។ លទ្ធផលបង្ហាញថា ៧,០% នៃបុគ្គលដែលមានការផ្សារភ្ជាប់ជាមួយទីផ្សារការងារ ត្រូវបានចាត់ទុកថា កម្លាំងពលកម្មរបស់ពួកគេមិនទាន់ត្រូវបានប្រើប្រាស់ពេញលេញ។

**តារាង ១០.៦ សូចនាករទីផ្សារការងារ**

| សូចនាករកម្លាំងពលកម្ម | | | ទាំងពីរភេទ | ប្រុស | ស្រី |
|---|---|---|---|---|---|
| កម្លាំងពលកម្ម (ចំនួន) | W (a+b+c+d+e+f) | ប្រជាជនក្នុងអាយុធ្វើការ | ១៣.១៤៣.៧០១ | ៦.២៩៩.១២១ | ៦.៨៤៤.៥៨០ |
| | X (L+P) | កម្លាំងពលកម្មពង្រីក | ៩.៥៦៣.០១៦ | ៤.៩៥២.៧០៨ | ៤.៦១០.៣០៨ |
| | L (E+c) | កម្លាំងពលកម្ម | ៩.៤០៧.៧១៧ | ៤.៨៩៤.១៩៧ | ៤.៥១៣.៥១៩ |
| មានការងារធ្វើ (ចំនួន) | E (a+b) | មានការងារធ្វើ | ៩.០៦៥.៦៤៩ | ៤.៧៤៧.៦៩៤ | ៤.៣១៧.៩៥៦ |
| | a | មានការងារធ្វើពេញលេញ | ៨.៨៩១.៥៥៧ | ៤.២៥២.៤១១ | ៣.៧៣៣.២១៩ |
| | b | មានការងារធ្វើមិនគ្រប់គ្រាន់ទាក់ទងនឹងពេលវេលា | ១៧៤.០៩២ | ១០៨.៥៤៧ | ៦៥.៥៤៤ |
| គ្មានការងារធ្វើ (ចំនួន) | c | គ្មានការងារធ្វើ | ៣៤២.០៦៧ | ១៤៦.៥០៤ | ១៩៥.៥៦៤ |
| នៅក្រៅកម្លាំងពលកម្ម (ចំនួន) | P (d+e) | កម្លាំងពលកម្មសក្តានុពល | ១៥៥.២៩៩ | ៥៨.៥១១ | ៩៦.៧៨៩ |
| | d | អ្នកស្វែងរកការងារមិនអាចធ្វើបាន | ២០.៣៨៥ | ៩.៩៤០ | ១០.៤៤៥ |
| | e | អ្នកស្វែងរកការងារសក្តានុពល | ១៣៤.៩១៤ | ៤៨.៥៧១ | ៨៦.៣៤៤ |
| | f | នៅក្រៅកម្លាំងពលកម្មបន្ថែម | ៣.៧៣៥.៩៨៤ | ១.៤០៤.៩២៤ | ២.៣៣១.០៦០ |
| សូចនាករនៃការប្រើមិនគ្រប់គ្រាន់នូវកម្លាំងពលកម្ម (%) | c/L*100 | LU1 (អត្រាគ្មានការងារធ្វើ) | ៣,៦ | ៣,០ | ៤,៣ |
| | (b+c)/L*100 | LU2 | ៥,៥ | ៥,២ | ៥,៨ |
| | (c+P)/X*100 | LU3 | ៥,២ | ៤,១ | ៦,៣ |
| | (b+c+P)/X*100 | LU4 | ៧,០ | ៦,៣ | ៧,៨ |

ដូចដែលបានបង្ហាញក្នុងតារាង ១០.៦ មានបុគ្គលប្រមាណ ៣.៧ លាននាក់ ឬស្មើនឹង ២៨,៤% នៃប្រជាជនក្នុងវ័យធ្វើការ ដែលស្ថិតនៅក្រៅកម្លាំងពលកម្មពង្រីក។ បុគ្គលដែលស្ថិតនៅក្រៅកម្លាំងពលកម្មពង្រីក រួមមានប្រជាជនក្នុងវ័យធ្វើការដែលមិនបានស្វែងរកការងារ ហើយក៏មិនមានលទ្ធភាព ឬមិនមានបំណងចង់ធ្វើការផងដែរ។

តារាង ១០.៧ បង្ហាញពីការបែងចែកប្រជាជនក្នុងវ័យធ្វើការដែលស្ថិតនៅក្រៅកម្លាំងពលកម្មពង្រីក តាមសកម្មភាពចម្បងដែលពួកគេបានអនុវត្តក្នុងអំឡុងពេលយោងនៃការអង្កេត។ សកម្មភាពដែលមានសមាមាត្រខ្ពស់ជាងគេ គឺការសិក្សា ឬការបណ្តុះបណ្តាល ដែលមានចំនួន ៣០,៩% ហើយសកម្មភាពទាំងនេះមិនត្រូវបានចាត់ទុកជាការងារធ្វើឡើយ។ ជិតពាក់កណ្តាល (៤៣,០%) នៃប្រុសដែលស្ថិតនៅក្រៅកម្លាំងពលកម្មពង្រីក បានរាយការណ៍ថា កំពុងសិក្សា ឬទទួលការបណ្តុះបណ្តាល។

ប្រមាណ ១៩,០% នៃបុគ្គលដែលស្ថិតនៅក្រៅកម្លាំងពលកម្មពង្រីក បានរាយការណ៍ថា ពួកគេមិនអាចធ្វើការបាន ដោយសារជំងឺរ៉ាំរ៉ៃ របួស ឬពិការភាព។ ចំណែកឯ ១៦,៦% បានចំណាយពេលក្នុងការមើលថែកុមារ ឬថែទាំសមាជិកគ្រួសារវ័យចំណាស់។ លើសពីនេះ ៣,៩% បានរាយការណ៍ថា ពួកគេបានចូលនិវត្តន៍ ឬជាអ្នកទទួលប្រាក់សោធននិវត្តន៍។

## តារាង ១០.៧ ការបែងចែកប្រជាជនក្នុងអាយុធ្វើការដែលស្ថិតនៅក្រៅកម្លាំងពលកម្មបន្ថែម តាមសកម្មភាពចម្បងបច្ចុប្បន្ន

| សកម្មភាពចម្បងបច្ចុប្បន្ន | ទាំងពីរភេទ | ប្រុស (ចំនួន) | ស្រី | ទាំងពីរភេទ | ប្រុស (%) | ស្រី |
|---|---|---|---|---|---|---|
| កំពុងសិក្សា ឬទទួលការបណ្តុះបណ្តាល | ៧៨៥.៨៨៣ | ៣៧៧.១៩៧ | ៤០៨.៦៨៦ | ៣០,៩ | ៤៣,០ | ២៤,៥ |
| បំពេញការងារផ្ទះ ឬទទួលខុសត្រូវក្នុងគ្រួសារ | ២២៨.០៦៥ | ៣១.៣៥២ | ១៩៦.៧១២ | ៩,០ | ៣,៦ | ១១,៨ |
| ធ្វើកសិកម្ម ឬនេសាទ ដើម្បីផលិតស្បៀងអាហារសម្រាប់គ្រួសារ | ៩.២២៧ | ៥.១៤៣ | ៤.០៨៤ | ០,៤ | ០,៦ | ០,២ |
| ចូលនិវត្តន៍ ឬទទួលប្រាក់សោធននិវត្តន៍ | ៩៨.៨២៤ | ៧៥.៣០៦ | ២៣.៥១៨ | ៣,៩ | ៨,៦ | ១,៤ |
| មានជំងឺ របួស ឬពិការភាពរយៈពេលវែង | ៤៨៣.៧៦០ | ១៧៧.២៨៣ | ៣០៦.៤៧៧ | ១៩,០ | ២០,២ | ១៨,៤ |
| ធ្វើការងារស្ម័គ្រចិត្ត ការងារសហគមន៍ ឬការងារសប្បុរសធម៌ | ៣.៣៩៨ | ២.១០៦ | ១.២៩២ | ០,១ | ០,២ | ០,១ |
| ចូលរួមសកម្មភាពវប្បធម៌ ឬសកម្មភាពកម្សាន្ត | ៨.៧៦០ | ៣.៧៨១ | ៤.៩៧៩ | ០,៣ | ០,៤ | ០,៣ |
| ថែទាំកុមារ ឬថែទាំសមាជិកវ័យចាស់ក្នុងគ្រួសារ | ៤២៣.៤១៧ | ៤១.៩៩៧ | ៣៨១.៤២១ | ១៦,៦ | ៤,៨ | ២២,៩ |
| ការបណ្តុះបណ្តាល និងកម្មសិក្សា | ៦.៧៩៨ | ៥.១៧០ | ១.៦២៨ | ០,៣ | ០,៦ | ០,១ |
| ផ្សេងទៀត | ៤៩៧.៣០២ | ១៥៨.៤៦២ | ៣៣៨.៨៤០ | ១៩,៥ | ១៨,១ | ២០,៣ |
| **សរុប** | **២.៥៤៥.៤៣៥** | **៨៧៧.៧៩៧** | **១.៦៦៧.៦៣៨** | **១០០** | **១០០** | **១០០** |

# ជំពូក ១១
# ចំណាយជ្រើសរើសរបស់ពលករចំណាកស្រុកនិវត្តន៍

## ១១.១ សេចក្តីផ្តើម

ជំពូកនេះបង្ហាញព័ត៌មានអំពីចំណាយលើការជ្រើសរើស ដែលបានកើតឡើងចំពោះពលករចំណាកស្រុកដែលវិលត្រលប់មកវិញ អាយុ ១៥ ឆ្នាំឡើងទៅ និងជាសមាជិកនៃគ្រួសារ។ ទិន្នន័យនេះគ្របដណ្តប់លើប្រទេសចុងក្រោយដែលបានទៅធ្វើការនៅបរទេស មធ្យោបាយដែលបានប្រើប្រាស់ក្នុងការស្វែងរកការងារនៅបរទេស ការចំណាយដែលបានបង់ដើម្បីទទួលបានការងារដំបូងនៅបរទេស ប្រាក់ចំណូលពីការងារដំបូងនោះ និងចំនួនខែនៃប្រាក់ឈ្នួលដែលត្រូវការដើម្បីសងត្រលប់ចំណាយលើការជ្រើសរើស។

ដោយទទួលស្គាល់ផលប៉ះពាល់នៃការចំណាកស្រុកសម្រាប់ការងារទៅលើទាំងប្រទេសដើម និងប្រទេសគោលដៅ បញ្ហាពាក់ព័ន្ធនឹងចំណាកស្រុកត្រូវបានបញ្ចូលទៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ ក្នុងគោលដៅទី១០ ដែលមានគោលបំណងកាត់បន្ថយវិសមភាពទាំងក្នុងទាំងក្នុងប្រទេស និងក្នុងចំណោមបណ្តាលប្រទេសនានា នៅក្នុងចំណុចដៅ ១០.៧ បានប្រគល់សិទ្ធិឲ្យរដ្ឋាភិបាល សម្រួលដល់សណ្តាប់ធ្នាប់ សុវត្ថិភាព ការធ្វើចំណាកស្រុកប្រជាជនឲ្យមាន សុវត្ថិភាព ស្របច្បាប់ និងមានការទទួលខុសត្រូវតាមរយៈការអនុវត្តគោលនយោបាយចំណាកស្រុកដែលបានរៀបចំផែនការ និងគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព។

សូចនាករ ១០.៧.១ វាស់វែងចំណាយលើការជ្រើសរើសដែលពលករជាអ្នកទទួលប្រាក់ឈ្នួលត្រូវរ៉ាប់រងដោយគណនាជាសមាមាត្រនៃប្រាក់ចំណូលប្រចាំឆ្នាំដែលពួកគេទទួលបាននៅក្នុងប្រទេសគោលដៅ។

យោងតាម អង្គការអន្តរជាតិខាងការងារ «ការជ្រើសរើស» សំដៅលើដំណើរការនៃការផ្សព្វផ្សាយឱកាសការងារ ការផ្សព្វផ្សាយព័ត៌មាន ការជ្រើសរើសបេក្ខជន ការដឹកជញ្ជូន និងការដាក់ឱ្យចូលបម្រើការងារ ហើយក្នុងករណីដែលពាក់ព័ន្ធ រួមទាំងការសម្របសម្រួលការវិលត្រលប់របស់ពលករទៅកាន់ប្រទេសដើមផងដែរ។ សកម្មភាពទាំងនេះអនុវត្តចំពោះទាំងអ្នកស្វែងរកការងារ និងបុគ្គលដែលកំពុងមានការងារធ្វើ។

យោងតាមនិយមន័យរបស់ អង្គការអន្តរជាតិខាងការងារស្តីពី ការជ្រើសរើសពលករ ប្រជាជនគោលដៅសម្រាប់ការវាស់វែងចំណាយលើការជ្រើសរើស រួមមាន ពលករចំណាកស្រុក និង ពលករចំណាកស្រុកដែលវិលត្រលប់មកវិញ ដែលកំពុងធ្វើការ ឬធ្លាប់បានធ្វើការនៅក្នុងប្រទេសដែលពួកគេមិនមែនជាពលរដ្ឋ។

ដើម្បីកាត់បន្ថយភាពលម្អៀងដែលបណ្តាលមកពីការចងចាំ ការវាស់វែងនេះគួរតែកំណត់ចំពោះបុគ្គលដែលបានធ្វើចំណាកស្រុកដើម្បីការងារក្នុងអំឡុងពេលថ្មីៗនេះ ជាទូទៅមិនលើសពី ៣ ឆ្នាំ មុនកាលបរិច្ឆេទនៃការវាស់វែង។

សម្រាប់ អង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥ ប្រជាជនគោលដៅសម្រាប់ការវាស់វែងចំណាយលើការជ្រើសរើស រួមមាន ពលករចំណាកស្រុកដែលវិលត្រលប់មកវិញ។ ពលករទាំងនេះ ត្រូវបានកំណត់និយមន័យថា ជាបុគ្គលដែលមានអាយុ ១៥ ឆ្នាំឡើងទៅ ដែលធ្លាប់បានផ្លាស់ទីទៅរស់នៅ និងធ្វើការនៅបរទេស ដើម្បីទទួលបានប្រាក់ឈ្នួល ឬប្រាក់ចំណេញ ហើយក្រោយមកបានវិលត្រលប់មកកម្ពុជាវិញ។

ការជ្រើសរើសសំណាកសម្រាប់ អង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥ មិនត្រូវបានកែសម្រួលដើម្បីបង្កើនការចាប់យកព័ត៌មានអំពីពលករចំណាកស្រុកដែលវិលត្រលប់មកវិញ។ ដូច្នេះ លទ្ធផលនៃការអង្កេតនេះទំនងជាប៉ាន់ប្រមាណទាបជាងចំនួនជាក់ស្តែងនៃពលករចំណាកស្រុកដែលវិលត្រលប់មកវិញ។ លើសពីនេះ ការអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥ បានប្រមូលព័ត៌មានតែពីពលករចំណាកស្រុកដែលបានវិលត្រលប់មករស់នៅក្នុងគ្រួសារលំនៅឋានរបស់ខ្លួននៅពេលធ្វើការអង្កេតប៉ុណ្ណោះ។ ដោយសារទំហំសំណាកនៃពលករចំណាកស្រុកដែលវិលត្រលប់មកវិញមានចំនួនតិច (សរុប ៦៣០ ករណី) ការសន្និដ្ឋានមួយចំនួននៅក្នុងជំពូកនេះ ជាពិសេសការសន្និដ្ឋានដែលផ្អែកលើសូចនាករដែលបានបែងចែកតាមលក្ខណៈផ្សេងៗ គួរតែត្រូវបានបកស្រាយ និងប្រើប្រាស់ដោយមានការប្រុងប្រយ័ត្ន។

## ១១.២ ស្ថានភាពចំណាកស្រុក

តារាង ១១.១ បង្ហាញពីការបែងចែកប្រជាជនតាមប្រទេសកំណើត និងភេទ។ ប្រជាជនភាគច្រើនលើសលប់ (៩៩,៨%) កើតនៅប្រទេសកម្ពុជា ដោយមានភាពខុសគ្នាតិចតួចរវាងប្រុស (៩៩,៧៧%) និងស្រី (៩៩,៨៣%)។ ប្រជាជនដែលកើតនៅបរទេសមានសមាមាត្រតិចតួចប៉ុណ្ណោះនៃប្រជាជនសរុប។

ក្នុងចំណោមអ្នកដែលកើតនៅបរទេស អ្នកដែលកើតនៅប្រទេសវៀតណាមមានសមាមាត្រខ្ពស់ជាងគេ (០,១៦%) បន្ទាប់មកប្រទេសថៃ (០,០២%) និងប្រទេសបែលហ្ស៊ិក (០,០១%)។ ចំណែកអ្នកដែលកើតនៅប្រទេសបារាំង និងសាធារណរដ្ឋកូរ៉េ មានសមាមាត្រតិចជាង ០,០១% ដូចគ្នា ខណៈដែលអ្នកកើតនៅប្រទេសចិនមានសមាមាត្រតិចតួចបំផុត។ ជារួម ការបែងចែកប្រជាជនតាមប្រទេសកំណើតមានលក្ខណៈប្រហាក់ប្រហែលគ្នារវាងប្រុស និងស្រី។

**តារាង ១១.១ ការបែងចែកប្រជាជនតាមប្រទេសកំណើត និងភេទ**

| Country born | ទាំងពីរភេទ | ប្រុស (ចំនួន) | ស្រី | ទាំងពីរភេទ | ប្រុស (%) | ស្រី |
|---|---|---|---|---|---|---|
| កម្ពុជា | ១៧.៥៧៣.៦១១ | ៨.៥៥៣.១៣៦ | ៩.០២០.៤៧៥ | ៩៩,៨០ | ៩៩,៧៧ | ៩៩,៨៣ |
| បារាំង | ៦១៤ | ៦១៤ | - | ០,០០ | ០,០១ | - |
| បែលហ្ស៊ិក | ១.៨០៣ | ១.៨០៣ | - | ០,០១ | ០,០២ | - |
| ថៃ | ៣.២៣០ | ២.៣៧១ | ៨៥៨ | ០,០២ | ០,០៣ | ០,០១ |
| វៀតណាម | ២៨.៦២៣ | ១៤.៧៤២ | ១៣.៨៨១ | ០,១៦ | ០,១៧ | ០,១៥ |
| ចិន | ១៧៥ | ១៧៥ | - | ០,០០ | ០,០០ | - |
| កូរ៉េខាងត្បូង | ៤៦០ | - | ៤៦០ | ០,០០ | - | ០,០១ |
| សរុប | ១៧.៦០៨.៥១៦ | ៨.៥៧២.៨៤១ | ៩.០៣៥.៦៧៥ | ១០០ | ១០០ | ១០០ |

តារាង ១១.២ បង្ហាញពីការបែងចែកពលករចំណាកស្រុកដែលវិលត្រលប់មកវិញ អាយុ ១៥ ឆ្នាំឡើងទៅ តាមរយៈពេលស្នាក់នៅបរទេស និងភេទ។ ពលករចំណាកស្រុកដែលវិលត្រលប់មកវិញភាគច្រើន បានស្នាក់នៅបរទេសក្នុងរយៈពេលយូរ ដោយជិតបីភាគបួន (៧៤,៨%) បានស្នាក់នៅបរទេសរយៈពេល ១០ ឆ្នាំ ឬលើសពីនេះ។ សមាមាត្រនេះមានកម្រិតខ្ពស់ជាងក្នុងចំណោមស្រី (៧៧,៧%) បើប្រៀបធៀបនឹងប្រុស (៧២,៥%)។

ប្រមាណ ១២,៣% នៃពលករចំណាកស្រុកដែលវិលត្រលប់មកវិញ បានស្នាក់នៅបរទេសរយៈពេលពី ៥ឆ្នាំ ដល់តិចជាង ១០ ឆ្នាំ ខណៈដែល ១១,៧% បានស្នាក់នៅបរទេសរយៈពេលពី ១ ឆ្នាំ ដល់តិចជាង ៥ ឆ្នាំ។ ប្រុសមានសមាមាត្រខ្ពស់ជាងស្រីក្នុងការស្នាក់នៅបរទេសរយៈពេលពី ១ ឆ្នាំ ដល់តិចជាង ៥ ឆ្នាំ (១៥,៣% ធៀបនឹង ៧,០%) ខណៈដែលស្រីមានសមាមាត្រខ្ពស់ជាងប្រុសក្នុងការស្នាក់នៅបរទេសរយៈពេលពី ៥ ឆ្នាំ ដល់តិចជាង ១០ ឆ្នាំ (១៤,០% ធៀបនឹង ១១,០%)។

មានតែសមាមាត្រតិចតួចប៉ុណ្ណោះ (១,៣%) នៃពលករចំណាកស្រុកដែលវិលត្រលប់មកវិញ ដែលបានស្នាក់នៅបរទេសរយៈពេលតិចជាង ១២ ខែ ដោយមានភាពខុសគ្នាតិចតួចរវាងប្រុស (១,២%) និងស្រី (១,៤%)។ ជារួម ពលករចំណាកស្រុកដែលវិលត្រលប់មកវិញជាស្រី មាននិន្នាការស្នាក់នៅបរទេសក្នុងរយៈពេលយូរជាងពលករជាប្រុស។

### តារាង ១១.២ ការបែងចែកប្រជាជនតាមរយៈពេលរស់ក្នុងប្រទេសកម្ពុជា

| មូលហេតុចម្បង | ទាំងពីរភេទ | ប្រុស (ចំនួន) | ស្រី | ទាំងពីរភេទ | ប្រុស (%) | ស្រី |
|---|---|---|---|---|---|---|
| តិចជាង១២ខែ | ៤៣៨ | ២៣០ | ២០៩ | ១,៣ | ១,២ | ១,៤ |
| ១ឆ្នាំ ទៅតិចជាង ៥ឆ្នាំ | ៤.០៨៥ | ៣.០២៣ | ១.០៦១ | ១១,៧ | ១៥,៣ | ៧,០ |
| ៥ឆ្នាំ ទៅតិចជាង ១០ឆ្នាំ | ៤.២៨៣ | ២.១៦១ | ២.១២២ | ១២,៣ | ១១,០ | ១៤,០ |
| ១០ឆ្នាំឡើងទៅ | ២៦.១០០ | ១៤.២៩២ | ១១.៨០៨ | ៧៤,៨ | ៧២,៥ | ៧៧,៧ |
| **សរុប** | **៣៤.៩០៥** | **១៩.៧០៥** | **១៥.២០០** | **១០០** | **១០០** | **១០០** |

តារាង ១១.៣ បង្ហាញពីការបែងចែកពលករចំណាកស្រុកដែលវិលត្រលប់មកវិញ អាយុ ១៥ ឆ្នាំឡើងទៅ តាមមូលហេតុចម្បងនៃការវិលត្រឡប់មកកម្ពុជា និងភេទ។ ពលករចំណាកស្រុកដែលវិលត្រលប់មកវិញភាគច្រើនលើសលប់ (៩០,២%) បានរាយការណ៍ថា ពួកគេវិលត្រលប់មកវិញដោយសារគ្រួសារបានផ្លាស់ទីលំនៅ ឬដើម្បីមករស់នៅជាមួយសមាជិកគ្រួសារ។ មូលហេតុនេះត្រូវបានរាយការណ៍ច្រើនជាងក្នុងចំណោមស្រី (៩៤,៦%) បើប្រៀបធៀបនឹងប្រុស (៨៦,៨%)។

ការរៀបអាពាហ៍ពិពាហ៍ គឺជាមូលហេតុចម្បងនៃការវិលត្រលប់មកកម្ពុជា សម្រាប់ពលករចំណាកស្រុកដែលវិលត្រលប់មកវិញចំនួន ៩,៨%។ ប្រុសមានសមាមាត្រខ្ពស់ជាងស្រីក្នុងការរាយការណ៍ថា ការរៀបអាពាហ៍ពិពាហ៍ជាមូលហេតុនៃការវិលត្រលប់មកវិញ (១៣,២% ធៀបនឹង ៥,៤%)។

### តារាង ១១.៣ ការបែងចែកប្រជាជន តាមមូលហេតុចម្បងនៃការវិលត្រលប់មកកម្ពុជា

| មូលហេតុចម្បង | ទាំងពីរភេទ | ប្រុស (ចំនួន) | ស្រី | ទាំងពីរភេទ | ប្រុស (%) | ស្រី |
|---|---|---|---|---|---|---|
| រៀបការ | ៣.៤១០ | ២.៥៩២ | ៨១៨ | ៩,៨ | ១៣,២ | ៥,៤ |
| គ្រួសារផ្លាស់ទីលំនៅ ឬទៅរស់នៅជាមួយគ្រួសារ | ៣១.៤៩៥ | ១៧.១១៣ | ១៤.៣៨២ | ៩០,២ | ៨៦,៨ | ៩៤,៦ |
| **សរុប** | **៣៤.៩០៥** | **១៩.៧០៥** | **១៥.២០០** | **១០០** | **១០០** | **១០០** |

តារាង ១១.៤ បង្ហាញពីការបែងចែកពលករចំណាកស្រុកដែលវិលត្រលប់មកវិញ អាយុ ១៥ ឆ្នាំឡើងទៅ តាមសញ្ជាតិ និងភេទ។ ពលករចំណាកស្រុកដែលវិលត្រលប់មកវិញភាគច្រើនលើសលប់ (៩០,៩%) មានសញ្ជាតិវៀតណាម។ សមាមាត្រនេះមានកម្រិតខ្ពស់ជាងគួរឱ្យកត់សម្គាល់ក្នុងចំណោមស្រី (៩៨,០%) បើប្រៀបធៀបនឹងប្រុស (៨៥,៣%)។

សញ្ជាតិបែលហ្សិក គឺជាសញ្ជាតិដែលមានសមាមាត្រខ្ពស់លំដាប់ទីពីរ ដោយមានចំនួន ៤,៦% នៃពលករចំណាកស្រុកដែលវិលត្រលប់មកវិញទាំងអស់។ ប្រុសមានសមាមាត្រខ្ពស់ជាងស្រីក្នុងការមានសញ្ជាតិបែលហ្សិក (៨,% ធៀបនឹង ០,០% ក្នុងចំណោមស្រី)។

សមាមាត្រតិចតួចផ្សេងទៀត រួមមាន អ្នកមានសញ្ជាតិថៃ (១,៩%) សញ្ជាតិបារាំង (១,៦%) សញ្ជាតិឥណ្ឌូនេស៊ី (០,៦%) និងសញ្ជាតិចិន (០,៤%)។ ប្រុសមានសមាមាត្រខ្ពស់ជាងស្រីក្នុងចំណោមអ្នកដែលមានសញ្ជាតិបារាំង បែលហ្សិក ឥណ្ឌូនេស៊ី និងចិន ខណៈដែលស្រីមានសមាមាត្រខ្ពស់ជាងបន្តិចក្នុងការមានសញ្ជាតិថៃ (២,០% ធៀបនឹង ១,៨%)។

**តារាង ១១.៤ ការបែងចែកប្រជាជន តាមសញ្ជាតិ និងភេទ**

| សញ្ជាតិ | ទាំងពីរភេទ | ប្រុស (ចំនួន) | ស្រី | ទាំងពីរភេទ | ប្រុស (%) | ស្រី |
|---|---|---|---|---|---|---|
| បារាំង | ៦១៤ | ៦១៤ | - | ១,៦ | ២,៨ | - |
| បែលហ្សិក | ១.៨០៣ | ១.៨០៣ | - | ៤,៦ | ៨,២ | - |
| ថៃ | ៧៥១ | ៣៩៣ | ៣៥៧ | ១,៩ | ១,៨ | ២,០ |
| វៀតណាម | ៣៥.៩២៤ | ១៨.៧២៣ | ១៧.២០១ | ៩០,៩ | ៨៥,៣ | ៩៨,០ |
| ឥណ្ឌូនេស៊ី | ២៤០ | ២៤០ | - | ០,៦ | ១,១ | - |
| ចិន | ១៧៥ | ១៧៥ | - | ០,៤ | ០,៨ | - |
| សរុប | ៣៩.៥០៧ | ២១.៩៤៩ | ១៧.៥៥៨ | ១០០ | ១០០ | ១០០ |

## ១១.៣ បទពិសោធន៍ការងារនៅបរទេសរបស់ប្រជាជនដែលកើតនៅកម្ពុជា

តារាង ១១.៥ បង្ហាញពីការបែងចែកពលករចំណាកស្រុកដែលវិលត្រលប់មកវិញនៅកម្ពុជា តាមក្រុមអាយុ ភេទ និងតំបន់នៃលំនៅឋាន។ ជារួម ពលករចំណាកស្រុកដែលវិលត្រលប់មកវិញ ភាគច្រើនស្ថិតក្នុងក្រុមអាយុធ្វើការសំខាន់ គឺអាយុពី ២៥ - ៤៤ ឆ្នាំ ដែលរួមគ្នាមានសមាមាត្រ ៦៦,៨% នៃពលករចំណាកស្រុកដែលវិលត្រលប់មកវិញទាំងអស់។

សមាមាត្រខ្ពស់ជាងគេត្រូវបានកត់សម្គាល់ក្នុងចំណោមអ្នកដែលមានអាយុពី ៣៥-៤៤ ឆ្នាំ (៣៤,៧%) បន្ទាប់មកគឺក្រុមអាយុពី ២៥-៣៤ ឆ្នាំ (៣២,១%)។ យុវជនអាយុពី ១៥-២៤ ឆ្នាំ មានសមាមាត្រ ១៤,០% ខណៈដែលមានតែ ៤,៨% ប៉ុណ្ណោះ ដែលមានអាយុ ៥៥ ឆ្នាំឡើងទៅ។

ពលករចំណាកស្រុកដែលវិលត្រលប់មកវិញជាប្រុស មានចំនួនច្រើនជាងស្រី ដោយមានចំនួន ២១៥.៦៥៩ នាក់ (៥៩,៥%) បើធៀបនឹងស្រីដែលមានចំនួន ១៤៦.៦៤៤ នាក់ (៤០,៥%)។ ពលករចំណាកស្រុកដែលវិលត្រលប់មកវិញជាស្រី មាននិន្នាការវ័យក្មេងជាងប្រុសបន្តិច ដោយមានសមាមាត្រខ្ពស់ជាងក្នុងក្រុមអាយុ ២៥–៣៤ ឆ្នាំ (៣៣,៨% ធៀបនឹង ៣១,០% ក្នុងចំណោមប្រុស)។ ផ្ទុយទៅវិញ ប្រុសមានសមាមាត្រ

ខ្ពស់ជាងបន្តិចនៅក្នុងក្រុមអាយុចាស់ ជាពិសេសក្រុមដែលមានអាយុ ៥៥ ឆ្នាំឡើងទៅ។ ពលករចំណាកស្រុកដែលវិលត្រលប់មកវិញភាគច្រើនរស់នៅតំបន់ជនបទ ដោយមានចំនួន ២៧៨.៩៤៦ នាក់ (៧៧,០%) ខណៈដែលមានតែ ៨៣.៣៥៨ នាក់ (២៣,០%) ប៉ុណ្ណោះរស់នៅតំបន់ទីប្រជុំជន។ ទាំងនៅតំបន់ទីប្រជុំជន និងតំបន់ជនបទ ពលករចំណាកស្រុកដែលវិលត្រលប់មកវិញភាគច្រើនស្ថិតក្នុងក្រុមអាយុ ២៥–៤៤ ឆ្នាំ ដែលមានសមាមាត្រ ៦២,៨% និង ៦៨.១% រៀងគ្នា។ តំបន់ជនបទមានសមាមាត្រខ្ពស់ជាងបន្តិចនៃពលករចំណាកស្រុកដែលវិលត្រលប់មកវិញក្នុងក្រុមអាយុ ២៥–៣៤ ឆ្នាំ (៣៣.២%) និង ៣៥–៤៤ ឆ្នាំ (៣៤,៩%) ខណៈដែលតំបន់ទីប្រជុំជនមានសមាមាត្រខ្ពស់ជាងក្នុងក្រុមអាយុចាស់។ ក្នុងចំណោមអ្នករស់នៅតំបន់ទីប្រជុំជន មាន ៨,៩% ដែលមានអាយុ ៥៥ ឆ្នាំឡើងទៅ បើធៀបនឹង ៣,៦% ក្នុងចំណោមអ្នករស់នៅតំបន់ជនបទ។

**តារាង ១១.៥ ការបែងចែកប្រជាជនដែលបានផ្លាស់ទៅរស់នៅ ឬធ្វើការនៅបរទេសដើម្បីទទួលបានប្រាក់ឈ្នួល តាមក្រុមអាយុ និងភេទ**

(%)

| ក្រុមអាយុ | កម្ពុជា | | | ទីប្រជុំជន | | | ជនបទ | | |
|---|---|---|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| <១៥ | ១,៤ | ១,៥ | ១,២ | ០,៧ | ១,២ | - | ១,៦ | ១,៦ | ១,៦ |
| ១៥–២៤ | ១៤,០ | ១៤,២ | ១៣,៨ | ១៣,៥ | ១៤,៤ | ១២,៣ | ១៤,២ | ១៤,១ | ១៤,៣ |
| ២៥–៣៤ | ៣២,១ | ៣១,០ | ៣៣,៨ | ២៨,៦ | ២៧,៧ | ២៩,៩ | ៣៣,២ | ៣១,៩ | ៣៥,០ |
| ៣៥–៤៤ | ៣៤,៧ | ៣៤,៨ | ៣៤,៥ | ៣៤,២ | ៣៥,០ | ៣៣,០ | ៣៤,៩ | ៣៤,៨ | ៣៥,០ |
| ៤៥–៥៤ | ១៣,០ | ១៣,១ | ១២,៨ | ១៤,១ | ១១,៥ | ១៧,៧ | ១២,៦ | ១៣,៥ | ១១,២ |
| ៥៥–៦៤ | ៣,៦ | ៤,០ | ៣,០ | ៥,៨ | ៥,៨ | ៥,៨ | ២,៩ | ៣,៤ | ២,១ |
| ៦៥+ | ១,២ | ១,៥ | ០,៩ | ៣,១ | ៤,៤ | ១,៣ | ០,៧ | ០,៦ | ០.៧ |
| សរុប (%) | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ |
| សរុប (ចំនួន) | ៣៦២.៣០៤ | ២១៥.៦៥៩ | ១៤៦.៦៤៤ | ៨៣.៣៥៨ | ៤៨.៦៨៦ | ៣៤.៦៧២ | ២៧៨.៩៤៦ | ១៦៦.៩៧៣ | ១១១.៩៧៣ |

## ១១.៤ ពលករចំណាកស្រុកនិវត្តន៍

ការអង្កេតបានប៉ាន់ប្រមាណថា មានបុគ្គលអាយុ ១៥ ឆ្នាំឡើងទៅចំនួន ២៦៨.៥៧៧ នាក់ ដែលបានទៅធ្វើការនៅបរទេស ហើយបានវិលត្រលប់មកកម្ពុជាវិញក្នុងអំឡុងពេល ៣ ឆ្នាំ មុនពេលធ្វើការអង្កេត (តារាង ១១.៦)។ ក្នុងចំណោមនោះ មានប្រុសចំនួន ១៥៨.៥៣៨ នាក់ (៥៩,០%) និងស្រីចំនួន ១១០.០៣៩ នាក់ (៤១,០%)។ ពលករចំណាកស្រុកដែលវិលត្រលប់មកវិញភាគច្រើន រស់នៅតំបន់ជនបទ។

ពលករចំណាកស្រុកដែលវិលត្រលប់មកវិញ ភាគច្រើនស្ថិតក្នុងក្រុមអាយុក្មេង និងក្រុមអាយុស្ថិតក្នុងវ័យធ្វើការសំខាន់។ ក្រុមអាយុពី ២៥–៣៤ ឆ្នាំ មានសមាមាត្រខ្ពស់ជាងគេ បន្ទាប់មកគឺក្រុមអាយុពី ៣៥–៤៤ ឆ្នាំ (តារាង ១១.៦)។ ជារួម ជាងពីរភាគបីនៃពលករចំណាកស្រុកដែលវិលត្រលប់មកវិញមានអាយុចន្លោះពី ២៥–៤៤ឆ្នាំ ដែលបង្ហាញថាការធ្វើទេសន្តរប្រវេសន៍និងការវិលត្រលប់មកវិញ ភាគច្រើនកើតមានក្នុងចំណោមមនុស្សពេញវ័យដែលស្ថិតក្នុងវ័យសកម្មភាពសេដ្ឋកិច្ចខ្ពស់បំផុត។

### តារាង ១១.៦ ការបែងចែកប្រជាជនក្នុងអាយុធ្វើការដែលបានទៅរស់នៅ និងធ្វើការនៅបរទេសដើម្បីទទួលបានប្រាក់ឈ្នួល តាមក្រុមអាយុ និងភេទ

(%)

| ក្រុមអាយុ | កម្ពុជា | | | ទីប្រជុំជន | | | ជនបទ | | |
|---|---|---|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| ១៥–២៤ | ១៦,៧ | ១៦,៣ | ១៧,៣ | ១៨,៩ | ២០,០ | ១៧,២ | ១៦,២ | ១៥,៤ | ១៧,៣ |
| ២៥–៣៤ | ៣៣,១ | ៣៣,០ | ៣៣,២ | ២៦,១ | ៣០,០ | ២០,៣ | ៣៤,៨ | ៣៣,៨ | ៣៦,២ |
| ៣៥–៤៤ | ៣៤,៣ | ៣៥,០ | ៣៣,៣ | ៣៣,៥ | ៣២,១ | ៣៥,៦ | ៣៤,៥ | ៣៥,៧ | ៣២,៧ |
| ៤៥–៥៤ | ១២,៤ | ១១,៩ | ១៣,១ | ១៤,៧ | ១២,៣ | ១៨,៤ | ១១,៩ | ១១,៨ | ១១,៩ |
| ៥៥–៦៤ | ៣,១ | ៣,៣ | ២,៧ | ៥,២ | ៤,៥ | ៦,២ | ២,៦ | ៣,១ | ១,៩ |
| ៦៥+ | ០,៤ | ០,៤ | ០,៤ | ១,៦ | ១,១ | ២,៣ | ០,១ | ០,២ | - |
| សរុប (%) | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ |
| សរុប(ចំនួន) | ២៦៨.៥៧៧ | ១៥៨.៥៣៨ | ១១០.០៣៩ | ៥១.៨៦១ | ៣១.១៩០ | ២០.៦៧១ | ២១៦.៧១៦ | ១២៧.៣៤៨ | ៨៩.៣៦៨ |

យោងតាមតារាង ១១.៧ ពលកររចំណាកស្រុកដែលវិលត្រលប់មកវិញភាគច្រើនលើសលប់ បានធ្វើការចុងក្រោយនៅប្រទេសថៃ ដែលមានសមាមាត្រ ៩០,១% នៃពលកររចំណាកស្រុកដែលវិលត្រលប់មកវិញទាំងអស់។ ប្រទេសថៃក៏ជាប្រទេសគោលដៅចម្បងសម្រាប់ទាំងប្រុស (៨៧,៩%) និងស្រី (៩៣,២%) ផងដែរ ដែលឆ្លុះបញ្ចាំងពីតួនាទីដ៏សំខាន់របស់ប្រទេសនេះជាប្រទេសគោលដៅសម្រាប់ពលកររទេសន្តរប្រវេសន៍កម្ពុជា។

ពលកររចំណាកស្រុកដែលវិលត្រលប់មកវិញមួយសមាមាត្រតិចជាង បានធ្វើការនៅប្រទេសផ្សេងៗ។ ក្នុងចំណោមប្រទេសទាំងនោះ សមាមាត្រខ្ពស់ជាងគេគឺ សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ (២,៨%) សាធារណរដ្ឋកូរ៉េ (២,៧%) និងប្រទេសម៉ាឡេស៊ី (១,៧%)។ ដោយឡែក សមាមាត្រតិចជាងនេះ បានធ្វើការនៅប្រទេសចិន (០,៧%) ប្រទេសជប៉ុន (០,៦%) ប្រទេសបារាំង (០,៥%) ប្រទេសវៀតណាម (០,៤%) សហរដ្ឋអាមេរិក (០,៣%) ប្រទេសលីបង់ (០,២%) និងប្រទេសឥណ្ឌូនេស៊ី (០,១%)។

ភាពខុសគ្នាតាមភេទត្រូវបានសង្កេតឃើញយ៉ាងច្បាស់ចំពោះប្រទេសគោលដៅនៃការធ្វើការនៅបរទេស។ ពលកររចំណាកស្រុកដែលវិលត្រលប់មកវិញជាស្រី មានសមាមាត្រធ្វើការនៅប្រទេសថៃខ្ពស់ជាងប្រុស (៩៣,២% ធៀបនឹង ៨៧,៩%)។ ផ្ទុយទៅវិញ ប្រុសមានសមាមាត្រខ្ពស់ជាងស្រីក្នុងការធ្វើការនៅសាធារណរដ្ឋកូរ៉េ (៣,៤% ធៀបនឹង ១,៥%) និងប្រទេសម៉ាឡេស៊ី (២,៦% ធៀបនឹង ០,៣%)។

ការបែងចែកនេះបង្ហាញថា ទេសន្តរប្រវេសន៍ការងាររបស់ពលកររកម្ពុជា នៅតែផ្តោតជាចម្បងទៅលើប្រទេសថៃ ខណៈដែលការធ្វើទេសន្តរប្រវេសន៍ទៅកាន់ប្រទេសគោលដៅផ្សេងៗនៅមានកម្រិតទាប ហើយកើតមានច្រើនជាងក្នុងចំណោមពលករជាប្រុស។

## តារាង ១១.៧ ការបែងចែកប្រជាជនក្នុងអាយុយធ្វើការដែលបានទៅធ្វើការនៅបរទេស តាមប្រទេសចុងក្រោយដើម្បីធ្វើការ និងភេទ

| Last Foreign Country | ទាំងពីរភេទ | ប្រុស (ចំនួន) | ស្រី | ទាំងពីរភេទ | ប្រុស (%) | ស្រី |
|---|---|---|---|---|---|---|
| បារាំង | ១.២៩៧ | ៨២៩ | ៤៦៨ | ០,៥ | ០,៥ | ០,៤ |
| សហរដ្ឋអាមេរិក | ៨០៩ | ៨០៩ | - | ០,៣ | ០,៥ | - |
| ឡេបាណន់ | ៤០៧ | ៤០៧ | - | ០,២ | ០,៣ | - |
| ថៃ | ២៤១.៨៨៨ | ១៣៩.២៨៣ | ១០២.៦០៤ | ៩០,១ | ៨៧,៩ | ៩៣,២ |
| វៀតណាម | ១.១៩០ | ១.១៩០ | - | ០,៤ | ០,៨ | - |
| ឥណ្ឌូនេស៊ី | ៣៧២ | - | ៣៧២ | ០,១ | - | ០,៣ |
| ម៉ាឡេស៊ី | ៤.៤៦២ | ៤.១១៦ | ៣៤៦ | ១,៧ | ២,៦ | ០,៣ |
| ចិន | ២.០០៨ | ១.១៣៤ | ៨៧៤ | ០,៧ | ០,៧ | ០,៨ |
| កូរ៉េខាងជើង | ៧.៥២៦ | ៤.៥១៥ | ៣.០១១ | ២,៨ | ២,៨ | ២,៧ |
| កូរ៉េខាងត្បូង | ៧.១៣១ | ៥.៤៥៧ | ១.៦៧៤ | ២,៧ | ៣,៤ | ១,៥ |
| ជប៉ុន | ១.៤៨៨ | ៧៩៩ | ៦៨៩ | ០,៦ | ០,៥ | ០,៦ |
| **សរុប** | **២៦៨.៥៧៧** | **១៥៨.៥៣៨** | **១១០.០៣៩** | **១០០** | **១០០** | **១០០** |

តារាង ១១.៨ បង្ហាញពីការបែងចែកពលករចំណាកស្រុកដែលវិលត្រលប់មកវិញ អាយុ ១៥ ឆ្នាំឡើងទៅ តាមមូលហេតុចម្បងនៃការធ្វើទេសន្តរប្រវេសន៍ទៅបរទេស ដោយបែងចែកតាមភេទ។ លទ្ធផលបង្ហាញថា មូលហេតុដែលពាក់ព័ន្ធនឹងការងារ គឺជាកត្តាចម្បងដែលជំរុញឱ្យមានចំណាកស្រុក។ ពលករចំណាកស្រុកដែលវិលត្រលប់មកវិញជាងប្រាំពីរនាក់ក្នុងចំណោមដប់នាក់ (៧០,៨%) បានរាយការណ៍ថា ពួកគេបានទៅបរទេសដើម្បីស្វែងរកការងារធ្វើ ដែលជាមូលហេតុដែលត្រូវបានរាយការណ៍ច្រើនជាងគេ។ សមាមាត្រនេះមានលក្ខណៈប្រហាក់ប្រហែលគ្នារវាងប្រុស (៧០,៤%) និងស្រី (៧១,៥%)។

ប្រមាណមួយភាគប្រាំ (២០,៥%) នៃពលករចំណាកស្រុកដែលវិលត្រលប់មកវិញ បានទៅបរទេសដើម្បីចូលបម្រើការងារដែលបានរៀបចំទុកជាមុន។ ប្រុសមានសមាមាត្រខ្ពស់ជាងស្រីបន្តិចក្នុងការទទួលបានការងារមុនពេលចាកចេញទៅបរទេស ដោយមាន ២១,៣% បានរាយការណ៍ថា នេះជាមូលហេតុនៃការធ្វើទេសន្តរប្រវេសន៍បើធៀបនឹង ១៩,៣% ក្នុងចំណោមស្រី។

មូលហេតុដែលពាក់ព័ន្ធនឹងគ្រួសារ ឬការរៀបអាពាហ៍ពិពាហ៍ មានសមាមាត្រ ៣,៥% នៃពលករចំណាកស្រុកដែលវិលត្រលប់មកវិញ ដោយស្រីមានសមាមាត្រខ្ពស់ជាងប្រុសគួរឱ្យកត់សម្គាល់ក្នុងការរាយការណ៍មូលហេតុនេះ (៥,៦% ធៀបនឹង ២,០%)។

បន្ថែមពីនេះ ១,៩% បានរាយការណ៍ថា ពួកគេបានទៅបរទេសដោយសារមូលហេតុផ្សេងទៀតដែលមិនពាក់ព័ន្ធនឹងការងារ ខណៈដែល ១,៤% បានទៅបរទេសដើម្បីសិក្សា ឬទទួលការបណ្តុះបណ្តាល។ សមាមាត្រនេះមានកម្រិតខ្ពស់ជាងក្នុងចំណោមប្រុស (១,៨%) បើប្រៀបធៀបនឹងស្រី (០,៨%)។

**តារាង ១១.៨ ការបែងចែកប្រជាជនក្នុងអាយុយធ្វើការតាមមូលហេតុចម្បងនៃការវិលត្រលប់មកវិញ និងភេទ**

| មូលហេតុចម្បង | ទាំងពីរភេទ | ស្ត្រី (ចំនួន) | បុរស | ទាំងពីរភេទ | ស្ត្រី (%) | បុរស |
|---|---|---|---|---|---|---|
| ចាប់ផ្តើមការងារដែលបានរៀបចំទុកជាមុន | ៥៥.០២៧ | ៣៣.៨៣៣ | ២១.១៩៤ | ២០.៥ | ២១.៣ | ១៩.៣ |
| ផ្ទេរកន្លែងការងារ | ១.៧៧៩ | ១.៣៧៧ | ៤០២ | ០.៧ | ០.៩ | ០.៤ |
| ស្វែងរកការងារធ្វើ | ១៩០.២១២ | ១១១.៥៨១ | ៧៨.៦៣០ | ៧០.៨ | ៧០.៤ | ៧១.៥ |
| ដើម្បីសិក្សា ឬទទួលការបណ្តុះបណ្តាលផ្ទាល់ខ្លួន | ៣.៦៩៧ | ២.៨៤៣ | ៨៥៤ | ១.៤ | ១.៨ | ០.៨ |
| ដោយសារគ្រួសារ ឬអាពាហ៍ពិពាហ៍ | ៩.៣១១ | ៣.១៦០ | ៦.១៥១ | ៣.៥ | ២.០ | ៥.៦ |
| ជម្លោះ ឬអសន្តិសុខ | ២.៩៤៥ | ២.១៩៣ | ៧៥១ | ១.១ | ១.៤ | ០.៧ |
| ការធ្វើទុក្ខបុកម្នេញ | ៣៨៣ | ៣៨៣ | - | ០.១ | ០.២ | - |
| មូលហេតុផ្សេងទៀតដែលមិនពាក់ព័ន្ធនឹងការងារ | ៥.២២៣ | ៣.១៦៧ | ២.០៥៦ | ១.៩ | ២.០ | ១.៩ |
| សរុប | ២៦៨.៥៧៧ | ១៥៨.៥៣៨ | ១១០.០៣៩ | ១០០ | ១០០ | ១០០ |

តារាង ១១.៩ បង្ហាញពីការបែងចែកពលករចំណាកស្រុកដែលវិលត្រលប់មកវិញ តាមមូលហេតុចម្បងនៃការវិលត្រលប់មកប្រទេសកំណើត ដោយបែងចែកតាមភេទ (ប្រុស និងស្រី)។

មូលហេតុដែលត្រូវបានរាយការណ៍ច្រើនជាងគេសម្រាប់ការវិលត្រឡប់មកវិញ គឺអសន្តិសុខ និងការរើសអើង ដែលមានសមាមាត្រ ៣៦,០% នៃពលករចំណាកស្រុកដែលវិលត្រលប់មកវិញទាំងអស់។ មូលហេតុនេះត្រូវបានរាយការណ៍ច្រើនជាងក្នុងចំណោមប្រុស (៣៩,៣%) បើប្រៀបធៀបនឹងស្រី (៣២,៣%)។ មូលហេតុដែលមានសមាមាត្រខ្ពស់លំដាប់ទីពីរ គឺការបញ្ចប់ការសិក្សា ឬការបណ្តុះបណ្តាល (១៦,៣%) បន្ទាប់មកគឺការបញ្ជូនត្រឡប់ (១២,៤%)។

មូលហេតុដែលពាក់ព័ន្ធនឹងគ្រួសារ រួមទាំងការរៀបអាពាហ៍ពិពាហ៍ និងកូន មានសមាមាត្រ ៩,៥% នៃការវិលត្រលប់មកវិញ ខណៈដែល ៩,៩% បានវិលត្រលប់មកវិញដោយសារមូលហេតុផ្សេងទៀតដែលមិនបានបញ្ជាក់។ ដោយឡែក សមាមាត្រតិចជាងនេះ បានវិលត្រលប់មកវិញដោយសារការឈប់សម្រាក ឬវិស្សមកាល (៥,១%) បំណងចង់រស់នៅក្នុងប្រទេសកំណើត (៤,០%) ទិដ្ឋាការ ឬលិខិតអនុញ្ញាតស្នាក់នៅផុតសុពលភាព (៣,៨%) និងការបញ្ចប់ការងារ ឬការចូលនិវត្តន៍ (២,៧%)។

**តារាង ១១.៩ ការបែងចែកប្រជាជន តាមមូលហេតុចម្បងនៃពលករចំណាកស្រុកនិវត្តន៍ និងភេទ**

| មូលហេតុចម្បង | ទាំងពីរភេទ | ស្ត្រី (ចំនួន) | បុរស | ទាំងពីរភេទ | ស្ត្រី (%) | បុរស |
|---|---|---|---|---|---|---|
| ការងារបានបញ្ចប់ ឬចូលនិវត្តន៍ | ៤៤២ | ៤៤២ | - | ២,៧ | ៥,២ | - |
| បានបញ្ចប់ការសិក្សា ឬការបណ្តុះបណ្តាលផ្ទាល់ខ្លួន | ២.៦៦៦ | ១.៦២៣ | ១.០៤៤ | ១៦,៣ | ១៨,៩ | ១៣ |
| វិស្សមកាល ឬសម្រាក | ៨៤០ | - | ៨៤០ | ៥,១ | - | ១០,៨ |
| ដោយសារគ្រួសារ អាពាហ៍ពិពាហ៍ ឬកូន | ១.៥៤៨ | ៦៧៣ | ៨៧៤ | ៩,៥ | ៧,៨ | ១១ |
| ទិដ្ឋាការ ឬលិខិតអនុញ្ញាតបានផុតសុពលភាព | ៦១៨ | - | ៦១៨ | ៣,៨ | - | ៨,០ |
| ត្រូវបានបណ្តេញចេញពីប្រទេស | ២.០១៩ | ១.២៦៧ | ៧៥១ | ១២,៤ | ១៥ | ៩,៧ |
| អសន្តិសុខ ឬការរើសអើង | ៥.៨៨៣ | ៣.៣៧៦ | ២.៥០៧ | ៣៦,០ | ៣៩,៣ | ៣២,៣ |
| មានបំណងរស់នៅក្នុងប្រទេសកំណើត | ៧១១ | ៧១១ | - | ៤,០ | ៨,៣ | - |
| ផ្សេងទៀត | ១.៦០៩ | ៤៨៨ | ១.១២១ | ៩,៩ | ៥,៧ | ១៤,៥ |
| **សរុប** | **១៦.៣៣៥** | **៨.៥៧៩** | **៧.៧៥៦** | **១០០** | **១០០** | **១០០** |

## ១១,៥ បទពិសោធន៍ការងារក្រៅប្រទេស

បទពិសោធន៍ការងារនៅក្រៅប្រទេស សំដៅលើចំណេះដឹង ជំនាញ និងសមត្ថភាពដែលបុគ្គលទទួលបានពីការធ្វើការនៅប្រទេសក្រៅ។ បទពិសោធន៍នេះផ្តល់ឱកាសឱ្យបុគ្គលអភិវឌ្ឍជំនាញវិជ្ជាជីវៈ ពង្រឹងសមត្ថភាពភាសា និងការប្រាស្រ័យទាក់ទង ព្រមទាំងទទួលបានបទពិសោធន៍ពីវប្បធម៌ និងបរិយាកាសការងារដែលមានភាពខុសប្លែកគ្នា។

ការធ្វើការនៅក្រៅប្រទេសអាចជួយលើកកម្ពស់ឱកាសការងារ បង្កើនសមត្ថភាពក្នុងការសម្របខ្លួនទៅនឹងបរិយាកាសថ្មី និងរួមចំណែកដល់ការអភិវឌ្ឍសមត្ថភាពផ្ទាល់ខ្លួន។ លើសពីនេះ បទពិសោធន៍ការងារនៅក្រៅប្រទេសជាញឹកញាប់អាចជួយឱ្យបុគ្គលទទួលបានជំនាញបច្ចេកទេសថ្មីៗ ពង្រីកបណ្តាញវិជ្ជាជីវៈ និងនាំយកចំណេះដឹង និងបទពិសោធន៍ដ៏មានតម្លៃត្រលប់មកប្រើប្រាស់សម្រាប់ការអភិវឌ្ឍប្រទេសកំណើតរបស់ខ្លួន។

តារាង ១១.១០ បង្ហាញពីការបែងចែកប្រជាជនតាមរយៈពេលដែលត្រូវការដើម្បីចាប់ផ្តើមការងារ បន្ទាប់ពីបានទៅដល់ប្រទេសគោលដៅ ដោយបែងចែកតាមភេទ។

លទ្ធផលនៃការអង្កេតបង្ហាញថា ពលករចំណាកស្រុកភាគច្រើនអាចចាប់ផ្តើមការងារបានក្នុងរយៈពេលមួយសប្តាហ៍បន្ទាប់ពីទៅដល់ប្រទេសគោលដៅ ដែលមានចំនួន ៧៤,៥% នៃពលករចំណាកស្រុកទាំងអស់។ សមាមាត្រនេះមានកម្រិតខ្ពស់ទាំងក្នុងចំណោមប្រុស (៨២,៨%) និងស្រី (៧៨,៥%) ដែលឆ្លុះបញ្ចាំងថា ពលករចំណាកស្រុកភាគច្រើនអាចទទួលបានការងារធ្វើយ៉ាងឆាប់រហ័ស បន្ទាប់ពីបានទៅដល់ប្រទេសគោលដៅ។

បន្ថែមពីនេះ ពលករចំណាកស្រុកចំនួន ១២,២% បានចាប់ផ្តើមការងារក្នុងរយៈពេលពីមួយសប្តាហ៍ទៅតិចជាងមួយខែ ខណៈដែល ៥,៤% ត្រូវការរយៈពេលពីមួយខែទៅតិចជាងបីខែ ដើម្បីទទួលបានការងារធ្វើ។ មានតែសមាមាត្រតិចតួចប៉ុណ្ណោះ ដែលត្រូវការរយៈពេលពីបីខែទៅតិចជាងប្រាំមួយខែដើម្បីចាប់ផ្តើមការងារ ដោយក្នុងនោះមានប្រុស ១,២% និងស្រី ០,៦%។

គួរឱ្យកត់សម្គាល់ថា ពលករចំណាកស្រុកចំនួន ៧,៩% បានរាយការណ៍ថា មិនអាចរកការងារធ្វើបានឡើយ ដោយសមាមាត្រនេះមានខ្ពស់ជាងក្នុងចំណោមស្រី (៥,២%) បើប្រៀបធៀបនឹងប្រុស (២,៣%)។

**តារាង ១១.១០ ការបែងចែកប្រជាជនតាមរយៈពេលចាប់ផ្តើមការងារនៅក្រៅប្រទេស**

| មូលហេតុចម្បង | ទាំងពីរភេទ | ស្ត្រី (ចំនួន) | បុរស | ទាំងពីរភេទ | ស្ត្រី (%) | បុរស |
|---|---|---|---|---|---|---|
| មិនបានរកឃើញការងារធ្វើ | ២.៧៩៥ | ៧៩០ | ៣.៥៨៦ | ៧,៩ | ២,៣ | ៥,២ |
| តិចជាង ១ សប្តាហ៍ក្រោយមក | ២៦.៣០៩ | ២៨.៣០៤ | ៥៤.៦១២ | ៧៤,៥ | ៨២,៨ | ៧៨,៥ |
| ចាប់ពី ១ សប្តាហ៍ ដល់តិចជាង ១ ខែ | ៤.៣២៨ | ៣.៨៣៤ | ៨.១៦២ | ១២,២ | ១១,២ | ១១,៧ |
| ចាប់ពី ១ ខែ ដល់តិចជាង ៣ ខែ | ១.៨៩៨ | ៨៤៨ | ២.៧៤៦ | ៥,៤ | ២,៥ | ៣,៩ |
| ចាប់ពី ៣ ខែ ដល់តិចជាង ៦ ខែ | - | ៤២២ | ៤២២ | - | ១,២ | ០,៦ |
| **សរុប** | **៣៥.៣២៩** | **៣៤.១៩៨** | **៦៩.៥២៨** | **១០០** | **១០០** | **១០០** |

តារាង ១១.១១ បង្ហាញពីការបែងចែកការងារដំបូងរបស់ពលករចំណាកស្រុកនៅក្រៅប្រទេសតាមមុខរបរ និងភេទ។ លទ្ធផលនៃការអង្កេតបង្ហាញថា ពលករចំណាកស្រុកភាគច្រើនបានបម្រើការងារក្នុងមុខរបរបឋម និងមុខរបរសិប្បកម្ម និងពាណិជ្ជកម្មពាក់ព័ន្ធ ជាការងារដំបូងរបស់ពួកគេនៅក្រៅប្រទេស។

មុខរបរបឋមមានសមាមាត្រខ្ពស់ជាងគេ ដោយមានចំនួន ៤៣,០% នៃពលករចំណាកស្រុកទាំងអស់។ មុខរបរនេះមានសមាមាត្រខ្ពស់ទាំងក្នុងចំណោមប្រុស (៥៥,៩%) និងស្រី (៤៩,៥%)។ ចំណែកមុខរបរសិប្បកម្ម និងពាណិជ្ជកម្មពាក់ព័ន្ធ មានសមាមាត្រខ្ពស់លំដាប់ទីពីរ ដែលស្មើនឹង ៣៣,១% នៃពលករចំណាកស្រុកទាំងអស់ ក្នុងនោះមានប្រុស ២៩,៦% និងស្រី ៣១,៣%។

**តារាង ១១.១១ ប្រភេទការងារដំបូងនៅក្រៅប្រទេស តាមមុខរបរ និងភេទ**

| មុខរបរ | ទាំងពីរភេទ | ស្ត្រី (ចំនួន) | បុរស | ទាំងពីរភេទ | ស្ត្រី (%) | បុរស |
|---|---|---|---|---|---|---|
| អ្នកគ្រប់គ្រង | Na | na | na | na | na | na |
| អ្នកមានវិជ្ជាជីវៈ | ៩៣៤ | ៣៦៦ | ៥៦៨ | ១,១ | ១,៧ | ១,៤ |
| អ្នកបច្ចេកទេស និង និងវិជ្ជាជីវៈរង | ១.៧៨៩ | ១.៣១៦ | ៤៧៣ | ៤,០ | ១,៤ | ២,៧ |
| ស្មៀន | na | na | na | na | na | na |
| បុគ្គលិកបម្រើសេវាកម្ម និង អ្នកលក់ដូរតាមហាង ឬផ្សារ | ៤.៦៣៩ | ២.៩៧១ | ១.៦៦៨ | ៩,១ | ៥,០ | ៧,០ |
| អ្នកជំនាញកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | na | na | na | na | na | na |
| អ្នកធ្វើសិប្បកម្ម និងអាជីវកម្មពាក់ព័ន្ធ | ២០.៦៧២ | ១០.៧៨១ | ៩.៨៩១ | ៣៣,១ | ២៩,៦ | ៣១,៣ |
| ការីម៉ាស៊ីន និងរោងចក្រ និងអ្នកផ្គុំតម្លើង | ៥.២៦៥ | ៣.១១៧ | ២.១៤៨ | ៩,៦ | ៦,៤ | ៨,០ |
| អ្នកធ្វើមុខរបរងាយ | ៣២.៦៤២ | ១៣.៩៨៣ | ១៨.៦៥៩ | ៤៣,០ | ៥៥,៩ | ៤៩,៥ |
| កងកម្លាំងប្រដាប់អាវុធ | na | na | na | na | na | na |
| សរុប | ៦៥.៩៤២ | ៣២.៥៣៤ | ៣៣.៤០៨ | ១០០ | ១០០ | ១០០ |

តារាង ១១.១២ បង្ហាញពីការបែងចែកការងារដំបូងរបស់ពលករចំណាកស្រុកនៅក្រៅប្រទេស តាមវិស័យសេដ្ឋកិច្ច និងភេទ។

ទិន្នន័យបង្ហាញថា ពលករចំណាកស្រុកភាគច្រើនបានបម្រើការងារក្នុងវិស័យសំណង់ បន្ទាប់មកគឺវិស័យកសិកម្ម និងវិស័យកម្មន្តសាល។

វិស័យសំណង់មានសមាមាត្រខ្ពស់ជាងគេនៃការងារដំបូងនៅក្រៅប្រទេស ដោយមានចំនួន ៥១,៧% នៃពលករចំណាកស្រុកទាំងអស់។ សមាមាត្រនេះមានភាពប្រហាក់ប្រហែលគ្នារវាងប្រុស (៥២,១%) និងស្រី (៥១,៣%) ដែលបង្ហាញថា វិស័យសំណង់គឺជាវិស័យសេដ្ឋកិច្ចសំខាន់បំផុតសម្រាប់ការងាររបស់ពលករចំណាកស្រុកទាំងប្រុស និងស្រី។

វិស័យកសិកម្មជាវិស័យដែលមានសមាមាត្រខ្ពស់លំដាប់ទីពីរ ដោយមានចំនួន ១៧,៥% នៃការងារដំបូងរបស់ពលករចំណាកស្រុកនៅក្រៅប្រទេស។ ពលករចំណាកស្រុកជាស្រី (២២,៩%) មានសមាមាត្រធ្វើការក្នុងវិស័យនេះខ្ពស់ជាងពលករចំណាកស្រុកជាប្រុស (១២,០%)។

វិស័យកម្មន្តសាលមានសមាមាត្រខ្ពស់លំដាប់ទីបី ដោយតំណាងឱ្យ ១៤,៧% នៃពលករចំណាកស្រុកទាំងអស់។ សមាមាត្រនៃពលករចំណាកស្រុកជាប្រុសដែលធ្វើការក្នុងវិស័យនេះ (២០,៥%) មានកម្រិតខ្ពស់ជាងគួរឱ្យកត់សម្គាល់ បើប្រៀបធៀបនឹងពលករចំណាកស្រុកជាស្រី (៨,៩%)។

### តារាង ១១.១២ ប្រភេទការងារដំបូងនៅក្រៅប្រទេស តាមវិស័យសេដ្ឋកិច្ច និងភេទ

| សកម្មភាពសេដ្ឋកិច្ច | ទាំងពីរភេទ | ស្ត្រី (ចំនួន) | បុរស | ទាំងពីរភេទ | ស្ត្រី (%) | បុរស |
|---|---|---|---|---|---|---|
| កសិកម្ម | ១១.៥៦៨ | ៣.៩១៩ | ៧.៦៤៩ | ១៧,៥ | ១២,០ | ២២,៩ |
| ការធ្វើអាជីវកម្មរ៉ែ និងការដ្ឋានថ្ម | ៤៨៧ | - | ៤៨៧ | ០,៧ | ០,០ | ១,៥ |
| ឧស្សាហកម្មកែច្នៃ | ៩.៦៦៧ | ៦.៦៨៥ | ២.៩៨១ | ១៤,៧ | ២០,៥ | ៨,៩ |
| សំណង់ | ៣៤.០៧០ | ១៦.៩៣៨ | ១៧.១៣២ | ៥១,៧ | ៥២,១ | ៥១,៣ |
| លក់ដុំ និងរាយ; ការជួសជុលយានយន្ត និងទោចក្រយានយន្ត | ៣.៣៧៧ | ១.៦១៤ | ១.៧៦៣ | ៥,១ | ៥,០ | ៥,៣ |
| សកម្មភាពស្នាក់នៅ និងសេវាកម្មម្ហូបអាហារ | ១.២៩២ | ១.២៩២ | - | ២,០ | ៤,០ | ០,០ |
| សកម្មភាពរដ្ឋបាល និងសេវាកម្មគាំទ្រ | ៤.៦៤៧ | ២.០៨៥ | ២.៥៦២ | ៧,០ | ៦,៤ | ៧,៧ |
| សកម្មភាពសេវាកម្មផ្សេងៗទៀត | ៨៣៤ | - | ៨៣៤ | ១,៣ | ០,០ | ២,៥ |
| សរុប | **៦៥.៩៤២** | **៣២.៥៣៤** | **៣៣.៤០៨** | **១០០** | **១០០** | **១០០** |

តារាង ១១.១៣ បង្ហាញពីប្រភពព័ត៌មានដែលពលករចំណាកស្រុកប្រើប្រាស់ដើម្បីទទួលបានព័ត៌មានអំពីការងារនៅក្រៅប្រទេស ដោយបែងចែកតាមភេទ។ លទ្ធផលនៃការអង្កេតបង្ហាញថា សមាជិកគ្រួសារ និងសាច់ញាតិ គឺជាប្រភពព័ត៌មានសំខាន់បំផុតសម្រាប់ការស្វែងរកព័ត៌មានអំពីការងារនៅក្រៅប្រទេស បន្ទាប់មកគឺមិត្តភក្តិ និងអ្នកស្គាល់គ្នា។

ពលករចំណាកស្រុកចំនួន ២៥,៧% ទទួលបានព័ត៌មានអំពីការងារពីសមាជិកគ្រួសារ ឬសាច់ញាតិដែលរស់នៅក្នុងប្រទេសកំណើត ដោយសមាមាត្រនេះមានខ្ពស់ជាងក្នុងចំណោមប្រុស (៣១,៤%) បើប្រៀបធៀបនឹងស្រី (២០,២%)។ ប្រភពព័ត៌មានដែលមានសារៈសំខាន់លំដាប់ទីពីរ គឺសមាជិកគ្រួសារ ឬសាច់ញាតិដែលរស់នៅក្រៅប្រទេស (២១,៤%) ដែលមានសារៈសំខាន់ជាងសម្រាប់ស្រី (២៧,១%) បើប្រៀបធៀបនឹងប្រុស (១៥,៤%)។

ចំណែកព័ត៌មានដែលទទួលបានពីមិត្តភក្តិ ឬអ្នកស្គាល់គ្នាដែលរស់នៅក្នុងប្រទេសកំណើត មានចំនួន ១៨,២% ខណៈព័ត៌មានពីមិត្តភក្តិ ឬអ្នកស្គាល់គ្នាដែលរស់នៅក្រៅប្រទេស មានចំនួន ៩,៨%។ រីឯព័ត៌មានដែលទទួលបានដោយផ្ទាល់ពីនិយោជក មានចំនួន ១២,៩% នៃពលករចំណាកស្រុកទាំងអស់។

### តារាង ១១.១៣ ប្រភពព័ត៌មានអំពីការងារដំបូងនៅក្រៅប្រទេសសម្រាប់ពលករចំណាកស្រុកនិវត្តន៍តាមភេទ

| វិធីសាស្ត្រស្វែងរកការងារ | ទាំងពីរភេទ | ស្ត្រី (ចំនួន) | បុរស | ទាំងពីរភេទ | ស្ត្រី (%) | បុរស |
|---|---|---|---|---|---|---|
| ពីនិយោជក/ថៅកែ | ៨.៤៧៦ | ៣.៧៥១ | ៤.៧២៥ | ១២,៩ | ១១,៧ | ១៤,១ |
| មិត្តភ័ក្តិ ឬអ្នកស្គាល់គ្នាដែលរស់នៅក្នុងប្រទេសដើម | ១១.៩៤១ | ៤.៩៣៥ | ៧.០០៧ | ១៨,២ | ១៥,៣ | ២១,០ |
| មិត្តភ័ក្តិ ឬអ្នកស្គាល់គ្នាដែលរស់នៅក្នុងប្រទេសបរទេស | ៦.៤៣៤ | ៣.៣៨៩ | ៣.០៤៦ | ៩,៨ | ១០,៥ | ៩,១ |
| សមាជិកគ្រួសារ ឬសាច់ញាតិដែលរស់នៅក្នុងប្រទេសដើម | ១៦.៨៤៨ | ១០.១០៥ | ៦.៧៤៣ | ២៥,៧ | ៣១,៤ | ២០,២ |
| សមាជិកគ្រួសារ ឬសាច់ញាតិដែលរស់នៅក្នុងប្រទេសបរទេស | ១៤.០៣១ | ៤.៩៦៨ | ៩.០៦៣ | ២១,៤ | ១៥,៤ | ២៧,១ |
| ទីភ្នាក់ងារជ្រើសរើសបុគ្គលិករបស់រដ្ឋាភិបាល | ៧៩៣ | ៥១៤ | ២៧៩ | ១,២ | ១,៦ | ០,៨ |
| ភ្នាក់ងារជ្រើសរើសបុគ្គលិកឯកជន | ១.៩៥០ | ១.៥៦០ | ៣៩០ | ៣,០ | ៤,៨ | ១,២ |
| អ្នកជ្រើសរើសបុគ្គលិកឯកជន, ឈ្មួញកណ្តាល | ២.៤៨១ | ១.២៣៦ | ១.២៤៥ | ៣,៨ | ៣,៨ | ៣,៧ |
| ផ្សេងទៀត | - | - | - | ៤,០ | ៥,៣ | ២,៧ |
| សរុប | **២.៦១៤** | **១.៧០៣** | **៩១១** | **១០០** | **១០០** | **១០០** |

តារាង ១១.១៤ បង្ហាញពីមធ្យោបាយដែលពលករចំណាកស្រុកបានប្រើប្រាស់ក្នុងការធ្វើដំណើរចូលទៅកាន់ប្រទេសគោលដៅចុងក្រោយនៅក្រៅប្រទេស ដោយបែងចែកតាមភេទ។ លទ្ធផលនៃការអង្កេតបង្ហាញថា សមាជិកគ្រួសារ និងសាច់ញាតិ គឺជាមធ្យោបាយសំខាន់បំផុតដែលជួយឱ្យពលករចំណាកស្រុកទទួលបានឱកាសការងារនៅក្រៅប្រទេស បន្ទាប់មកគឺមិត្តភក្តិ និងអ្នកស្គាល់គ្នា និងការជ្រើសរើសដោយផ្ទាល់ពីនិយោជកបរទេស។

ពលករចំណាកស្រុកចំនួន ៤៤,៩% បានធ្វើដំណើរចូលទៅកាន់ប្រទេសគោលដៅតាមរយៈជំនួយពីសមាជិកគ្រួសារ ឬសាច់ញាតិ។ គំរូនេះមានភាពប្រហាក់ប្រហែលគ្នាទាំងក្នុងចំណោមប្រុស (៤៥,២%) និងស្រី (៤៤,៧%) ដែលបង្ហាញពីតួនាទីដ៏សំខាន់របស់បណ្តាញគ្រួសារ ក្នុងការជួយសម្រួលដល់ការធ្វើចំណាកស្រុក។

មធ្យោបាយដែលមានសមាមាត្រខ្ពស់លំដាប់ទីពីរ គឺតាមរយៈមិត្តភក្តិ ឬអ្នកស្គាល់គ្នា ដែលមានចំនួន ១៧,៨% នៃពលករចំណាកស្រុកទាំងអស់។ មធ្យោបាយនេះមានការពេញនិយមជាងក្នុងចំណោមស្រី (២២,៧%) បើប្រៀបធៀបនឹងប្រុស (១២,៦%)។ បន្ថែមពីនេះ ពលករចំណាកស្រុកចំនួន ១៥,២% បានធ្វើដំណើរចូលទៅកាន់ប្រទេសគោលដៅតាមរយៈការជ្រើសរើសដោយផ្ទាល់ពីនិយោជកបរទេស ដោយមានសមាមាត្រប្រហាក់ប្រហែលគ្នារវាងប្រុស (១៥,០%) និងស្រី (១៥,៤%)។

**តារាង ១១.១៤ វិធីជ្រើសរើសពលករចំណាកស្រុកនិវត្តន៍បានប្រើប្រាស់ ដើម្បីទទួលបានការងារដំបូងនៅក្រៅប្រទេស តាមភេទ**

| វិធីសាស្ត្រស្វែងរកការងារ | ទាំងពីរភេទ | ស្ត្រី (ចំនួន) | បុរស | ទាំងពីរភេទ | ស្ត្រី (%) | បុរស |
|---|---|---|---|---|---|---|
| បានចុះឈ្មោះជាមួយ ភ្នាក់ងាររដ្ឋាភិបាលពីប្រទេសដើម | ២.០៩៦ | ១៣៧៨ | ៧១៨ | ៣,២ | ៤,៣ | ២,១ |
| បានចុះឈ្មោះជាមួយភ្នាក់ងារជ្រើសរើសឯកជនពីប្រទេសដើម | ២.៨២៣ | ១.៦០៩ | ១.២១៤ | ៤,៣ | ៥,០ | ៣,៦ |
| បានចុះឈ្មោះជាមួយភ្នាក់ងារជ្រើសរើសឯកជនពីបរទេស | ៨២៤ | ៨២៤ | - | ១,៣ | ២,៦ | - |
| ពីនិយោជកបរទេសដោយផ្ទាល់ | ៩.៩៦៣ | ៤.៨៣០ | ៥.១៣៣ | ១៥,២ | ១៥,០ | ១៥,៤ |
| អ្នកជ្រើសរើសបុគ្គលឯកជន, ឈ្មួញកណ្តាល | ៦.៩០២ | ៣.៥៤៣ | ៣.៣៥៨ | ១០,៥ | ១១,០ | ១០,១ |
| សមាជិកគ្រួសារ, សាច់ញាតិ | ២៩.៤៦៦ | ១៤.៥៤៧ | ១៤.៩១៩ | ៤៤,៩ | ៤៥,២ | ៤៤,៧ |
| មិត្តភ័ក្តិ ឬអ្នកស្គាល់គ្នា | ១១.៦៦១ | ៤.០៦៨ | ៧.៥៩៣ | ១៧,៨ | ១២,៦ | ២២,៧ |
| ផ្សេងទៀត | ១.៨៣៣ | ១.៣៦២ | ៤៧២ | ២,៨ | ៤,២ | ១,៤ |
| **សរុប** | **៦៥.៥៦៩** | **៣២.១៦១** | **៣៣.៤០៨** | **១០០** | **១០០** | **១០០** |

ពលករចំណាកស្រុកត្រលប់មកវិញ ត្រូវបានសួរអំពីមធ្យោបាយដែលពួកគេបានប្រើប្រាស់ក្នុងការចូលទៅកាន់ប្រទេសចុងក្រោយដែលពួកគេបានធ្វើការ។ លទ្ធផលបង្ហាញថា ពលករចំណាកស្រុកភាគច្រើនបានចូលតាមច្រកអន្តោប្រវេសន៍ស្របច្បាប់ ដោយប្រើទិដ្ឋាការការងារ ដែលមានចំនួន ៦០,៨%។ជាងមួយភាគបួននៃពលករចំណាកស្រុក (៣០,៦%) បានចូលទៅកាន់ប្រទេសគោលដៅដោយមិនឆ្លងកាត់បណ្តាញស្របច្បាប់ ឬមិនប្រើច្រកចូលផ្លូវការឡើយ។ ចំណែកសមាមាត្រតិចជាងនេះ (៤,៥%) បានចូលតាមច្រកអន្តោប្រវេសន៍ស្របច្បាប់ ប៉ុន្តែមិនបានប្រើទិដ្ឋាការការងារទេ ដោយប្រើទិដ្ឋាការទេសចរណ៍ជំនួសវិញ (តារាង ១១.១៥)។

**តារាង១១.១៥ វិធីប្រើដោយពលករចំណាកស្រុកនិវត្តន៍ចូលទៅប្រទេសក្រៅចុងក្រោយដើម្បីធ្វើការតាមភេទ**

| វិធីប្រើចូលទៅប្រទេសក្រៅចុងក្រោយ | ទាំងពីរភេទ | ស្ត្រី (ចំនួន) | បុរស | ទាំងពីរភេទ | ស្ត្រី (%) | បុរស |
|---|---|---|---|---|---|---|
| តាមរយៈច្បាប់អន្តោប្រវេសន៍មានទិដ្ឋាការការងារ | ៣៩.៨៥៧ | ១៨.៥៣៣ | ២១.៣២៤ | ៦០,៨ | ៥៧,៦ | ៦៣,៨ |
| តាមរយៈច្បាប់អន្តោប្រវេសន៍គ្មានទិដ្ឋាការការងារ(ឧ: ធ្វើដំណើរ ឬអ្នកទេសចរ) | ២.៩៣៥ | ១.៧៩៣ | ១.១៤២ | ៤,៥ | ៥,៦ | ៣,៤ |
| មិនតាមច្រកផ្លូវការ ឬតាមច្បាប់ទម្លាប់ | ២០.០៧៨ | ១០.៩៨៩ | ៩.០៩០ | ៣០,៦ | ៣៤,២ | ២៧,២ |
| គ្មានចម្លើយ | ២.៦៩៩ | ៨៤៦ | ១.៨៥៣ | ៤,១ | ២,៦ | ៥,៥ |
| សរុប | ៦៥.៥៦៩ | ៣២.១៦១ | ៣៣,៤០៨ | ១០០ | ១០០ | ១០០ |

## ១១.៦ ចំណាយជ្រើសរើស

ផ្នែកនេះបង្ហាញពីលទ្ធផលនៃការអង្កេតពាក់ព័ន្ធនឹង ថ្លៃដើមនៃការជ្រើសរើសពលករ ដែលសំដៅលើចំណាយដែលពលករចំណាកស្រុកបានបង់ ដើម្បីទទួលបានការងារនៅក្រៅប្រទេស។ ថ្លៃដើមទាំងនេះអាចរួមមាន៖

(i) ចំណាយលើឯកសារ ដូចជា លិខិតឆ្លងដែន ទិដ្ឋាការ ការពិនិត្យសុខភាព និងលទ្ធផលតេស្ត ការបណ្តុះបណ្តាលមុនពេលចេញដំណើរ ការវាយតម្លៃជំនាញ បុព្វលាភធានារ៉ាប់រង ថ្លៃអនុម័តកិច្ចសន្យា និងថ្លៃសម្រាប់ការអនុញ្ញាតធ្វើដំណើរ ឬការត្រួតពិនិត្យសន្តិសុខ។ (ii) ថ្លៃសេវារបស់ភ្នាក់ងារជ្រើសរើសពលករ ឬអ្នកសម្របសម្រួលការងារ (ប្រសិនបើមាន)។ (iii) ចំណាយលើការធ្វើដំណើរ ដូចជា ថ្លៃស្នាក់នៅ និងចំណាយពាក់ព័ន្ធផ្សេងៗ។ (iv) ការចំណាយផ្សេងទៀត ទាំងផ្លូវការ និងក្រៅផ្លូវការ រួមទាំងការបង់ប្រាក់ឱ្យមិត្តភក្តិ ឬសាច់ញាតិដែលបានជួយស្វែងរកការងារ ព្រមទាំងការបង់ប្រាក់ក្រៅផ្លូវការ ឬថ្លៃសេវាផ្សេងៗ និងការប្រាក់លើប្រាក់កម្ចីដែលបានខ្ចីសម្រាប់ការធ្វើចំណាកស្រុក។

តារាង ១១.១៦ បង្ហាញពីការបែងចែកចំនួនពលករចំណាកស្រុកត្រឡប់មកវិញ តាមចំណាយសរុបដែលបានបង់ ដើម្បីទទួលបានការងារដំបូងនៅក្នុងប្រទេសចុងក្រោយដែលពួកគេបានធ្វើការ រួមទាំងការកាត់ប្រាក់ពីប្រាក់ឈ្នួលទាំងអស់ដែលពាក់ព័ន្ធនឹងការជ្រើសរើសពលករ។

ដូចដែលបានបង្ហាញក្នុងតារាង ពលករចំណាកស្រុកត្រឡប់មកវិញប្រមាណ ៨,៥% បានចំណាយតិចជាង ៤០០.០០០ រៀល (១០០ ដុល្លារអាមេរិក) ខណៈដែល ៥២,៦% បានចំណាយចន្លោះពី ៤០០.០០០ រៀល ដល់ប្រមាណ ១.៦០០.០០០ រៀល (៤០០ ដុល្លារអាមេរិក)។ ជាមធ្យម ថ្លៃដើមនៃការជ្រើសរើសពលករមានចំនួន ៣.៤៩២.៣០៩ រៀល (៨៧៣ ដុល្លារអាមេរិក)។

**តារាង ១១.១៦ ចំណាយទទួលបានការងារដំបូងនៅបរទេសរបស់ពលករចំណាកស្រុកនិវត្តន៍ តាមភេទ**

| ការចំណាយ | ទាំងពីរភេទ | ស្ត្រី (ចំនួន) | បុរស | ទាំងពីរភេទ | ស្ត្រី (%) | បុរស |
|---|---|---|---|---|---|---|
| តិចជាង៤០០.០០០ | ៥.៤៣៥ | ២.៤៩២ | ២.៩៤២ | ៨,៥ | ៨,១ | ៨,៨ |
| ៤០០.០០០ ដល់តិចជាង១.៦០០.០០០ | ៣៣.៧៩២ | ១៦.៥០៣ | ១៧.២៨៨ | ៥២,៦ | ៥៣,៥ | ៥១,៧ |
| ១.៦០០.០០០ ដល់តិចជាង ២.៤០០.០០០ | ៨.៨២១ | ៤.៩០៥ | ៣.៩១៦ | ១៣,៧ | ១៥,៩ | ១១,៧ |
| ២.៤០០.០០០ ដល់តិចជាង ៣.២០០.០០០ | ៣.៥៥៦ | ៨០១ | ២.៧៥៥ | ៥,៥ | ២,៦ | ៨,២ |
| ៣.២០០.០០០ ដល់តិចជាង ៤.០០០.០០០ | ៣.១៣៥ | ១.១៥៧ | ១.៩៧៨ | ៤,៩ | ៣,៧ | ៥,៩ |
| ៤.០០០.០០០ ឡើងទៅ | ៩.៥៣៤ | ៥.០០៥ | ៤.៥២៩ | ១៤,៨ | ១៦,២ | ១៣,៦ |
| សរុប | ៦៤.២៧១ | ៣០.៨៦៣ | ៣៣.៤០៨ | ១០០ | ១០០ | ១០០ |
| មធ្យមនៃការចំណាយ (រៀល) | ៣.៤៩២.៣០៩ | ៣.៦១៧.៧៥៣ | ៣.៣៧១.៥៤៩ | | | |

## ១១.៧ ចំណូល

ពលករចំណាកស្រុកត្រលប់មកវិញ ត្រូវបានស្នើឱ្យរាយការណ៍អំពីប្រាក់ចំណូលសរុបដែលទទួលបានក្នុងខែដំបូង ពីការងារដំបូងរបស់ពួកគេនៅក្នុងប្រទេសចុងក្រោយដែលបានធ្វើការនៅក្រៅប្រទេស។ ប្រាក់ចំណូលនេះរួមមាន ប្រាក់ឈ្នួល ប្រាក់បំណាច់ជាវត្ថុដែលគិតជាតម្លៃប្រចាំខែ ប្រាក់រង្វាន់ និងតម្លៃប្រចាំខែនៃការកាត់ប្រាក់ឈ្នួលដែលបានបង់សម្រាប់ការទទួលបានការងារដំបូង ប្រសិនបើមាន។

តារាង ១១.១៧ បង្ហាញពីប្រាក់ចំណូលប្រចាំខែសរុបរបស់ពលករចំណាកស្រុកត្រលប់មកវិញ ពីការងារដំបូងរបស់ពួកគេនៅក្នុងប្រទេសចុងក្រោយដែលបានរស់នៅ និងធ្វើការនៅក្រៅប្រទេស។ ជារួម ប្រាក់ចំណូលប្រចាំខែជាមធ្យមរបស់ពលករចំណាកស្រុកត្រលប់មកវិញ មានចំនួន ៤,៣ លានរៀល (១,០៧០ ដុល្លារអាមេរិក)។

ពលករចំណាកស្រុកត្រលប់មកវិញប្រមាណ ៧ នាក់ក្នុងចំណោម ១០ នាក់ (៦៤,៩%) ទទួលបានប្រាក់ចំណូលប្រចាំខែចន្លោះពី ៤០០,០០០ រៀល (១០០ ដុល្លារអាមេរិក) ដល់ប្រមាណ ១,៦ លានរៀល (៤០០ ដុល្លារអាមេរិក)។ ដោយឡែក អ្នកដែលមានប្រាក់ចំណូលខ្ពស់បំផុត គឺទទួលបានយ៉ាងហោចណាស់ ៤,០ លានរៀល (១,០០០ ដុល្លារអាមេរិក) ក្នុងមួយខែ មានត្រឹមតែ ១៤,៤% នៃពលករចំណាកស្រុកត្រលប់មកវិញសរុបប៉ុណ្ណោះ។

**តារាង ១១.១៧ ចំណូលប្រចាំខែរបស់ពលករចំណាកស្រុកនិវត្តន៍ពីការងារដំបូងនៅបរទេស តាមភេទ**

| ចំណូលប្រចាំខែ | ទាំងពីរភេទ | ស្ត្រី (ចំនួន) | បុរស | ទាំងពីរភេទ | ស្ត្រី (%) | បុរស |
|---|---|---|---|---|---|---|
| តិចជាង៤០០.០០០ | ៤.០០០ | ២.២៨១ | ១.៧១៩ | ៦,១ | ៧,១ | ៥,១ |
| ៤០០.០០០ ដល់តិចជាង១.៦០០.០០០ | ៤២.៥៥៣ | ១៧.៧០១ | ២៤.៨៥២ | ៦៤,៩ | ៥៥,០ | ៧៤,៤ |
| ១.៦០០.០០០ ដល់តិចជាង ២.៤០០.០០០ | ៣.៩៦០ | ២.៧៤៦ | ១.២១៤ | ៦,០ | ៨,៥ | ៣,៦ |
| ២.៤០០.០០០ ដល់តិចជាង ៣.២០០.០០០ | ៤.៦៥៨ | ២.៩៣៦ | ១.៧២៣ | ៧,១ | ៩,១ | ៥,២ |
| ៣.២០០.០០០ ដល់តិចជាង ៤.០០០.០០០ | ៩៥៣ | ៤៥០ | ៥០៣ | ១,៥ | ១,៤ | ១,៥ |
| ៤.០០០.០០០ ឡើងទៅ | ៩.៤៤៥ | ៦.០៤៨ | ៣.៣៩៦ | ១៤,៤ | ១៨,៨ | ១០,២ |
| សរុប | ៦៥.៥៦៩ | ៣២.១៦១ | ៣៣.៤០៨ | ១០០ | ១០០ | ១០០ |
| មធ្យមនៃការចំណាយ (រៀល) | ៤.២៧៩.៦៤៩ | ៦.៨២២.៥១២ | ១.៨៣១.៧២១ | | | |

## ១១.៨ សូចនាករចំណាយជ្រើសរើស

សូចនាករថ្លៃដើមនៃការជ្រើសរើសពលករ គឺជាសូចនាករស្ថិតិសំខាន់ដែលត្រូវផលិតសម្រាប់សូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDG) លេខ ១០,៧,១។ សូចនាករនេះត្រូវបានគណនាសម្រាប់ពលករចំណាកស្រុក ដោយយកសមាមាត្ររវាងថ្លៃដើមនៃការជ្រើសរើសពលករ និងប្រាក់ចំណូលប្រចាំខែ។ ដូច្នេះ ថ្លៃដើមនៃការជ្រើសរើសដែលពលករចំណាកស្រុកត្រឡប់មកវិញនៅកម្ពុជាបានចំណាយ អាចត្រូវបានបង្ហាញជាសមាមាត្រធៀបនឹងប្រាក់ចំណូលប្រចាំខែដែលពួកគេទទួលបាននៅក្រៅប្រទេស។

សម្រាប់ការអង្កេតនេះ សូចនាករ RCI របស់ពលករចំណាកស្រុកត្រលប់មកវិញ ត្រូវបានគណនាដោយយកថ្លៃដើមនៃការជ្រើសរើសពលករជាមធ្យម ចែកនឹងប្រាក់ចំណូលជាមធ្យមក្នុងខែដំបូងនៃការងារ។ វិធីសាស្ត្រគណនានេះ ផ្អែកលើកថាខណ្ឌទី ១១ និងទី ៥២ នៃសេចក្តីព្រាងគោលការណ៍ណែនាំរបស់អង្គការអន្តរជាតិខាងការងារ (ILO) ស្តីពីការប្រមូលស្ថិតិសម្រាប់សូចនាករ SDG ១០.៧.១។

តារាង ១១.១៨ បង្ហាញពី សូចនាករថ្លៃដើមនៃការជ្រើសរើសពលករ តាមភេទ តំបន់ ក្រុមអាយុ វិស័យសេដ្ឋកិច្ច និងប្រទេសចុងក្រោយដែលពលករចំណាកស្រុកបានធ្វើការនៅក្រៅប្រទេស។ លទ្ធផលបង្ហាញថា សមាមាត្ររវាងថ្លៃដើមនៃការជ្រើសរើសពលករជាមធ្យម និងប្រាក់ចំណូលប្រចាំខែជាមធ្យម ស្មើនឹងប្រមាណ ០,៨ ខែ នៃប្រាក់ចំណូល។ តាមភេទ សមាមាត្រនេះមានចំនួន ០,៦ ខែ សម្រាប់ប្រុស និង ១,៨ ខែ សម្រាប់ស្រី។ តាមក្រុមអាយុ សមាមាត្ររវាងថ្លៃដើមនៃការជ្រើសរើសពលករ និងប្រាក់ចំណូលប្រចាំខែ សម្រាប់ពលករចំណាកស្រុកត្រលប់មកវិញដែលមានអាយុ ១៥–២៤ ឆ្នាំ មានចំនួន ០,៦ ខណៈសម្រាប់អ្នកដែលមានអាយុ ២៥ ឆ្នាំ និងលើសពីនេះ មានចំនួន ០,៨។ តាមវិស័យសេដ្ឋកិច្ច សមាមាត្រនេះមានកម្រិតខ្ពស់បំផុតក្នុងចំណោមពលករចំណាកស្រុកដែលបានធ្វើការនៅក្នុង វិស័យសេវាកម្ម (១,៩) បន្ទាប់មកគឺ វិស័យកសិកម្ម (០,៤) និង វិស័យឧស្សាហកម្ម (០,៣)។ ចំពោះប្រទេសចុងក្រោយដែលបានធ្វើការនៅក្រៅប្រទេស សមាមាត្រនេះមានកម្រិតខ្ពស់ជាងសម្រាប់ពលករចំណាកស្រុកដែលត្រលប់មកពី ប្រទេសថៃ (១,៥) បើប្រៀបធៀបនឹងអ្នកដែលត្រលប់មកពីប្រទេសផ្សេងៗ។

### តារាង ១១.១៨ សូចនាករចំណាយជ្រើសរើស តាមភេទ តំបន់ ក្រុមអាយុ វិស័យសេដ្ឋកិច្ច និងប្រទេសចុងក្រោយរបស់ការងារ

(ខែនៃបៀវត្សរ៍)

| សូចនាករចំណាយជ្រើសរើស | ទាំងពីរភេទ | ប្រុស | ស្រី |
|---|---|---|---|
| **តាមតំបន់** | | | |
| ទីប្រជុំជន | ០,៥ | ០,៤ | ២,២ |
| ជនបទ | ១,០ | ០,៧ | ១,៨ |
| **ក្រុមអាយុ** | | | |
| ១៥–២៤ | ០,៦ | ០,៣ | ០,៩ |
| ២៥+ | ០,៨ | ០,៦ | ២,១ |
| **តាមវិស័យសេដ្ឋកិច្ច** | | | |
| កសិកម្ម | ០,៤ | ០,២ | ១,៧ |
| ឧស្សាហកម្ម | ០,៣ | ០,២ | ១,៨ |

| | | | |
|---|---|---|---|
| សេវកម្ម | ១,៩ | ៣,៣ | ០,៨ |
| **ប្រទេសចុងក្រោយបានធ្វើការនៅបរទេស** | | | |
| ថៃ | ១,៥ | ១,២ | ១,៨ |
| ប្រទេសផ្សេងទៀត | ០,៣ | ០,៣ | ២,៥ |
| **សរុប** | **០,៨** | **០,៦** | **១,៨** |

## ១១.៩ ចំនួនខែត្រូវសងចំណាយជ្រើសរើស

តារាង ១១.១៩ បង្ហាញពីចំនួនខែដែលពលករចំណាកស្រុកត្រលប់មកវិញត្រូវការដើម្បីសងថ្លៃដើមដែលបានចំណាយសម្រាប់ការទទួលបានការងារនៅក្រៅប្រទេស ដោយផ្អែកលើការរាយការណ៍របស់ពួកគេផ្ទាល់។ ពលករមួយចំនួនបានខ្ចីប្រាក់ពីអ្នកផ្តល់ប្រាក់កម្ចី ឬពីភ្នាក់ងារជ្រើសរើសពលករ ដើម្បីបង់ថ្លៃដើមនៃការជ្រើសរើស ហើយបន្ទាប់មកបានសងប្រាក់កម្ចីទាំងនោះវិញពីប្រាក់ចំណូលដែលពួកគេទទួលបានក្រោយពេលចាប់ផ្តើមធ្វើការ។ ដូចដែលបានបង្ហាញក្នុងតារាង ១១.១៩ ចំនួនខែជាមធ្យមដែលពលករចំណាកស្រុកត្រលប់មកវិញបានរាយការណ៍ថា ត្រូវការដើម្បីសងថ្លៃដើមនៃការជ្រើសរើសពលករ គឺ ២,៤ ខែ។ នៅពេលធ្វើការអង្កេត ពលករចំណាកស្រុកត្រលប់មកវិញប្រមាណ ៣១,៤% បានសងថ្លៃដើមនៃការជ្រើសរើសពលកររួចរាល់ទាំងស្រុង។ ប្រមាណ ៦៤,៣% ត្រូវធ្វើការចន្លោះពី ១ ខែ ដល់តិចជាង ១២ ខែ ដើម្បីសងប្រាក់កម្ចីរបស់ពួកគេ។ មានតែពលករចំណាកស្រុកត្រលប់មកវិញមួយចំនួនតូចប៉ុណ្ណោះ ដែលត្រូវធ្វើការរយៈពេលមួយឆ្នាំ ឬច្រើនជាងនេះ ដើម្បីសងប្រាក់កម្ចី។ ភាពខុសគ្នារវាងការគណនាជាក់ស្តែងនៃសូចនាករថ្លៃដើមនៃការជ្រើសរើសពលករ ដែលមានតម្លៃ ០,៨ ខែ និងការវាយតម្លៃដោយខ្លួនឯងរបស់ពលករ ដែលមានតម្លៃ ២,៤ ខែ មានកម្រិតខុសគ្នាគួរឱ្យកត់សម្គាល់។ ទោះជាយ៉ាងណា ដោយសារចំនួនករណីនៅក្នុងសំណាកមានចំនួនតិច ដូច្នេះការបកស្រាយភាពខុសគ្នានេះ គួរតែធ្វើឡើងដោយមានការប្រុងប្រយ័ត្ន។

**តារាង ១១.១៩ ចំនួនខែរបស់ពលករចំណាកស្រុកនិវត្តន៍ត្រូវទូទាត់សងចំណាយជ្រើសរើស តាមភេទ**

| ចំនួនខែ | ទាំងពីរភេទ | បុរស (ចំនួន) | ស្រី | ទាំងពីរភេទ | បុរស (%) | ស្រី |
|---|---|---|---|---|---|---|
| បានចំណាយ | ២០.៦១៨ | ១២.៦៨៦ | ៧.៩៣២ | ៣១,៤ | ៣៩,៤ | ២៣,៧ |
| ១ខែ ដល់តិចជាង ៣ខែ | ៣១.៣៨២ | ១៣.៤៣៣ | ១៧.៩៤៩ | ៤៧,៩ | ៤១,៨ | ៥៣,៧ |
| ៣ខែ ដល់តិចជាង ៦ ខែ | ៦.៨១៤ | ២.៦៥៦ | ៤.១៥៨ | ១០,៤ | ៨,៣ | ១២,៤ |
| ៦ខែ ដល់តិចជាង ១២ខែ | ៣.៩០៥ | ២.៥២៧ | ១.៣៧៨ | ៦,០ | ៧,៩ | ៤,១ |
| ១២ខែ ដល់តិចជាង ២៤ខែ | ២.៤១៤ | ៤២៣ | ១.៩៩១ | ៣,៧ | ១,៣ | ៦,០ |
| ២៤ខែឡើងទៅ | ៤៣៦ | ៤៣៦ | ០ | ០,៧ | ១,៤ | - |
| **សរុប** | **៦៥.៥៦៩** | **៣២.១៦១** | **៣៣.៤០៨** | **១០០,០** | **១០០,០** | **១០០,០** |
| មធ្យមនៃខែដែលត្រូវសងចំណាយ | ២,៤ | ២,៥ | ២,៣ | | | |

# ជំពូក ១២
# សូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងការងារសមរម្យជ្រើសរើស

ការតាមដានវឌ្ឍនភាពឆ្ពោះទៅសម្រេចបាន គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងគោលដៅរងរបស់វា តម្រូវឱ្យមានសំណុំសូចនាករដែលមានសុពលភាព និងភាពជឿជាក់គ្រប់គ្រាន់។ សូចនាករទាំងនេះមានតួនាទីយ៉ាងសំខាន់ក្នុងការវាស់វែងលទ្ធផលនៃការអភិវឌ្ឍ ការកំណត់បញ្ហាដែលត្រូវយកចិត្តទុកដាក់ និងការផ្តល់ភស្តុតាងសម្រាប់គាំទ្រដល់ការរៀបចំគោលនយោបាយ និងការសម្រេចចិត្ត។ នៅថ្នាក់ជាតិ ប្រទេសនីមួយៗអាចវាយតម្លៃវឌ្ឍនភាពនៃការអនុវត្ត របៀបវារៈឆ្នាំ ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព របស់អង្គការសហប្រជាជាតិ តាមរយៈការជ្រើសរើស និងកំណត់អាទិភាពសូចនាករដែលឆ្លុះបញ្ចាំងបានល្អបំផុតពីអាទិភាពជាតិ បរិបទជាតិ និងសមត្ថភាពប្រព័ន្ធស្ថិតិរបស់ប្រទេស។ វិធីសាស្ត្រនេះធានាថា ការតាមដានវឌ្ឍនភាពនៃ SDGs មានភាពសមស្របទៅនឹងបរិបទជាតិ ខណៈដែលនៅតែរក្សាបាននូវភាពស្របតាមក្របខ័ណ្ឌអភិវឌ្ឍន៍សកល។

រាជរដ្ឋាភិបាលកម្ពុជាបានបង្ហាញពីការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការអនុវត្ត របៀបវារៈឆ្នាំ ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព របស់អង្គការសហប្រជាជាតិ និងការសម្រេចបាននូវ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ។ ដើម្បីគាំទ្រដល់ការប្តេជ្ញាចិត្តនេះ ក្រសួងផែនការត្រូវបានកំណត់ជាស្ថាប័ននាំមុខ ដែលទទួលខុសត្រូវក្នុងការសម្របសម្រួល និងតាមដានការអនុវត្តក្របខ័ណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅថ្នាក់ជាតិ។ ក្របខ័ណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជាឆ្នាំ ២០១៦-២០៣០ បានដាក់បញ្ចូលគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពសកលទាំង ១៧ គោលដៅ ព្រមទាំងបានបន្ថែមគោលដៅជាតិមួយទៀត ស្តីពីការបោសសម្អាតមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម។ ការបន្ថែមគោលដៅនេះឆ្លុះបញ្ចាំងពីបរិបទអភិវឌ្ឍន៍ពិសេសរបស់កម្ពុជា និងបញ្ជាក់ពីអាទិភាពជាបន្តបន្ទាប់របស់រាជរដ្ឋាភិបាលក្នុងការធានាឱ្យប្រទេសកម្ពុជាគ្មានមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម ដើម្បីបង្កើតបរិយាកាសដែលមានសុវត្ថិភាព និងគាំទ្រដល់ការអភិវឌ្ឍប្រកបដោយចីរភាព។

## ១២.១ សេចក្តីផ្តើម

ជំពូកនេះបង្ហាញអំពីសូចនាករមួយចំនួនដែលពាក់ព័ន្ធនឹង គោលដៅទី១ គោលដៅទី៥ និងគោលដៅទី៨ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ ជំពូកនេះក៏រួមបញ្ចូលផងដែរនូវសូចនាករស្តីពី ការងារសមរម្យ ដែលអាចគណនាបានពីទិន្នន័យនៃការអង្កេត។

គោលដៅទី១ មានគោលបំណងបញ្ចប់ភាពក្រីក្រ ហើយសូចនាករមួយក្នុងចំណោមសូចនាករសំខាន់ៗ សម្រាប់គោលដៅនេះ គឺការគាំពារសង្គម។ គោលដៅទី៥ ផ្តោតលើការលើកកម្ពស់សមភាពយេនឌ័រ ខណៈដែល គោលដៅទី៨ ផ្តោតលើការជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន និងចីរភាព ការមានការងារពេញលេញ និងមានផលិតភាព ព្រមទាំងការងារសមរម្យសម្រាប់មនុស្សគ្រប់រូប។ សូចនាករទាំងនេះត្រូវបានបង្ហាញនៅក្នុង តារាង ១២.១។

## ១២.២ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងការងារសមរម្យ

តារាង ១២.១ បង្ហាញអំពីសូចនាករមួយចំនួនដែលត្រូវបានជ្រើសរើសពី គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពព្រមទាំងសូចនាករស្តីពី ការងារសមរម្យ ដែលអាចគណនាបានពីទិន្នន័យនៃ ការអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥។

គោលដៅទី១ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព មានគោលបំណងបញ្ចប់ភាពក្រីក្រគ្រប់ទម្រង់ ហើយសូចនាករមួយក្នុងចំណោមសូចនាករសំខាន់ៗ គឺ ការគាំពារសង្គម។ សមាមាត្រនិយោជិតដែលនិយោជកបានបង់វិភាគទានទៅក្នុងរបបសន្តិសុខសង្គម គឺជាសូចនាករមួយសម្រាប់វាស់វែងការគាំពារសង្គម។ សូចនាករនេះអាចត្រូវបានបំពេញបន្ថែមដោយសមាមាត្រនិយោជិតដែលមានសិទ្ធិទទួលបានការឈប់សម្រាកព្យាបាលដោយមានប្រាក់ឈ្នួល។ដូចដែលបានបង្ហាញក្នុងតារាង ១២.១ និយោជិតចំនួន ៤៣,៥% មាននិយោជកបង់វិភាគទានចូលរួមក្នុងរបបសន្តិសុខសង្គម ខណៈដែល ៤០,៣% មានសិទ្ធិទទួលបានការឈប់សម្រាកព្យាបាលដោយមានប្រាក់ឈ្នួល។

គោលដៅទី៥ មានគោលបំណងសម្រេចឱ្យបាននូវសមភាពយេនឌ័រ និងពង្រឹងភាពអង់អាចដល់ស្រី និងកុមារីទាំងអស់។ សូចនាករមួយចំនួនសម្រាប់វាស់វែងគោលដៅនេះ រួមមាន សមាមាត្រស្រីដែលកាន់តំណែងជាអ្នកគ្រប់គ្រង និងប្រាក់ចំណូលជាមធ្យមតាមភេទ។ ក្នុងឆ្នាំ២០២៥ ស្រីកាន់កាប់តំណែងជាអ្នកគ្រប់គ្រងមានចំនួន ២២,៣% នៃតំណែងអ្នកគ្រប់គ្រងទាំងអស់ (តារាង ១២.១)។

សូចនាករសម្រាប់ គោលដៅទី៨ មានភាពស្របគ្នាបំផុតជាមួយនឹងសូចនាករស្តីពី ការងារសមរម្យ របស់អង្គការអន្តរជាតិខាងការងារ ។ តារាង ១២.១ បង្ហាញពីសូចនាករមួយចំនួនស្តីពីការងារសមរម្យ តាមភេទ និងតំបន់។ ជាឧទាហរណ៍ ក្នុងឆ្នាំ២០២៥ អ្នកមានការងារធ្វើប្រមាណ ៧៥,១% ស្ថិតក្នុងការងារក្រៅប្រព័ន្ធ។ នេះមានន័យថា ពួកគេមិនទទួលបានអត្ថប្រយោជន៍ការងារ ដូចជា ប្រាក់សោធននិវត្តន៍ ការឈប់សម្រាកដោយមានប្រាក់ឈ្នួល និងការឈប់សម្រាកព្យាបាលដោយមានប្រាក់ឈ្នួលឡើយ។ អត្រាគ្មានការងារធ្វើរបស់យុវជន (៩,៩%) មានកម្រិតខ្ពស់ជាងអត្រាគ្មានការងារធ្វើថ្នាក់ជាតិ (៣,៦%) ខណៈដែល ១៣,១% នៃយុវជនមិនធ្វើការងារ មិនសិក្សា ឬបណ្តុះបណ្តាល ។

សូចនាករមួយទៀតដែលពាក់ព័ន្ធនឹងការងារសមរម្យ គឺសមាមាត្រនិយោជិតដែលមានប្រាក់ចំណូលប្រចាំខែទាបជាង ពីរភាគបី នៃប្រាក់ចំណូលប្រចាំខែជាមេដ្យានរបស់ប្រទេស ដែលត្រូវបានចាត់ទុកថាជាការងារដែលមានប្រាក់ឈ្នួលទាប។ តារាង ១២.១ បង្ហាញថា និយោជិត ៨,៦% នៅកម្ពុជាស្ថិតក្នុងការងារដែលមានប្រាក់ឈ្នួលទាប ក្នុងនោះមានប្រុស ៨,៩% និងស្រី ៨,៤%។ សមាមាត្រនិយោជិតដែលមានការងារបែបនេះមានខ្ពស់ជាងនៅតំបន់ជនបទ (៩,៤%) បើប្រៀបធៀបនឹងតំបន់ទីប្រជុំជន (៧,៦%)។

ជាចុងក្រោយ តារាងនេះបង្ហាញថា និយោជិតជាងមួយភាគបី (៣១,៣%) បានធ្វើការលើសម៉ោងការងារធម្មតា (លើសពី ៤៨ ម៉ោង ក្នុងមួយសប្តាហ៍)។ សមាមាត្រនិយោជិតដែលធ្វើការលើសម៉ោងការងារធម្មតាខ្ពស់ជាងគេ ត្រូវបានកត់សម្គាល់ឃើញនៅតំបន់ទីប្រជុំជន (៣៥,៤%)។

# តារាង ១២.១ សូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងការងារសមរម្យជ្រើសរើសនៅកម្ពុជា ឆ្នាំ ២០២៥

(%)

| សមាមាត្រនិយោជិតដែលនិយោជករបស់ពួកគេបង់ភាគទានទៅក្នុងរបបសន្តិសុខសង្គម[a] | |
|---|---|
| ប្រុស | ៣៥,៦ |
| ស្រី | ៥៣,៨ |
| សរុប | ៤៣,៥ |

| ចំណែកមុខងារអ្នកគ្រប់គ្រង [a] | |
|---|---|
| ប្រុស | ៧៧,៧ |
| ស្រី | ២២,៣ |
| សរុប | ១០០ |

| សមាមាត្រនៃនិយោជិតទទួលប្រាក់ឈ្នួលពេលឈប់សម្រាក [b] | |
|---|---|
| ប្រុស | ៣៦,៥ |
| ស្រី | ៥០,៦ |
| ទីប្រជុំជន | ៥២,១ |
| ជនបទ | ៣៤,៩ |
| សរុប | ៤២,៦ |

| សមាមាត្រនៃនិយោជិតទទួលប្រាក់ឈ្នួលពេលឈប់សម្រាកឈឺ [b] | |
|---|---|
| ប្រុស | ៣៥,៦ |
| ស្រី | ៤៦,៤ |
| ទីប្រជុំជន | ៤៩,០ |
| ជនបទ | ៣៣,២ |
| សរុប | ៤០,៣ |

| អ្នកធ្វើការងារក្រៅប្រព័ន្ធ ជាសមាមាត្រនៃអ្នកធ្វើការទាំងអស់ [b] | |
|---|---|
| ប្រុស | ៧៧,៧ |
| ស្រី | ៧២,១ |
| ទីប្រជុំជន | ៦៦,៨ |
| ជនបទ | ៨០,៨ |
| សរុប | ៧៥,១ |

| យុវជនមិនធ្វើការងារ មិនសិក្សា ឬបណ្តុះបណ្តាល(អាយុ១៥-២៤ឆ្នាំ) [a] | |
|---|---|
| ប្រុស | ១១,៧ |
| ស្រី | ១៨,០ |
| ទីប្រជុំជន | ១២,៦ |
| ជនបទ | ១៦,២ |
| សរុប | ១៤,៨ |

| អ្នកមានការងារធ្វើធៀបនឹងប្រជាជន (អាយុ១៥ឆ្នាំឡើង) b | |
|---|---|
| ប្រុស | ៧៥,៤ |
| ស្រី | ៦៣,១ |
| ទីប្រជុំជន | ៧០,០ |
| ជនបទ | ៦៨,៣ |
| សរុប | ៦៩,០ |

| | |
|---|---|
| ប្រុស | ៩,១ |
| ស្រី | ១០,៨ |
| ទីប្រជុំជន | ១៥,៦ |
| ជនបទ | ៦,២ |
| សរុប | ៩,៩ |

| អត្រាគ្មានការងារធ្វើ [a] | |
|---|---|
| ប្រុស | ៣,០ |
| ស្រី | ៤,៣ |
| ទីប្រជុំជន | ៤,៩ |
| ជនបទ | ២,៨ |
| សរុប | ៣,៦ |

| សមាមាត្រនៃអ្នកធ្វើការដោយទុនផ្ទាល់ខ្លួន និងអ្នកធ្វើការអោយគ្រួសារមិនយកប្រាក់ឈ្នួល ក្នុងអ្នកធ្វើការទាំងអស់ [b] | |
|---|---|
| ប្រុស | ៤០,៦ |
| ស្រី | ៤៩,៦ |
| ទីប្រជុំជន | ៣៩,៣ |
| ជនបទ | ៤៨,៨ |
| សរុប | ៤៤,៩ |

| អ្នកធ្វើការលើសម៉ោង(អ្នកធ្វើការម៉ោងធម្មតាច្រើនជាង៤៨ម៉ោងក្នុងមួយសប្តាហ៍) ជាសមាមាត្រនៃអ្នកធ្វើការទាំងអស់ | |
|---|---|
| ប្រុស | ៣២,៤ |
| ស្រី | ៣០,២ |

| អ្នកមានការងារធ្វើតាមស្ថានភាពការងារ b | |
